ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការអនុវត្តគណនេយ្យភាពសង្គមសម្រាប់
# ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
# ឆ្នាំ ២០១៦-២០១៨

ខែ មីនា ឆ្នាំ២០១៦

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវក្របខ័ណ្ឌយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីធានាដល់ ដំណើរការអភិបាលកិច្ច និងការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយបានរៀបចំ បង្កើតជាច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលជាមូលដ្ឋានគតិយុត្ត សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ មូលដ្ឋានគតិយុត្តទាំងពីរនេះ បានជួយជំរុញឱ្យមានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាគ្រប់លំដាប់នៅថ្នាក់ក្រោមជាតិ ដែលបច្ចុប្បន្នបាននឹងកំពុងដើរតួនាទីជាតួអង្គអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅមូលដ្ឋាន។ ប្រការនេះ បានតម្រូវឱ្យក្រុមប្រឹក្សាថ្នាក់ក្រោមជាតិនីមួយៗត្រូវមានគណនេយ្យភាពជាចម្បង និងដោយផ្ទាល់ចំពោះប្រជាពលរដ្ឋរបស់ខ្លួន ដោយធានានូវតម្លាភាព និងលើកស្ទួយការចូលរួមរបស់ប្រជាពលរដ្ឋ។ ជាពិសេស ក្រុមប្រឹក្សាចាំបាច់ត្រូវធានាថារាល់មតិយោបល់ និងតម្រូវការនានារបស់ស្ត្រី បុរស យុវជន កុមារ ជនពិការ ជនជាតិដើម និងក្រុមជនងាយរងគ្រោះ ត្រូវបានយកទៅពិចារណា នៅក្នុងការកំណត់អាទិភាពអភិវឌ្ឍន៍នានា និងនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត ចំពោះការវិភាជន៍ ការប្រើប្រាស់ និងការគ្រប់គ្រងធនធានរបស់ខ្លួន ព្រមទាំងការផ្តល់សេវាសាធារណៈ សេវារដ្ឋបាល កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម នៅក្នុងសហគមន៍មូលដ្ឋានរបស់ខ្លួន។

នៅខែកក្កដា ឆ្នាំ២០១៣ គ.ជ.អ.ប បានអនុម័តផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលបានគូសបញ្ជាក់អំពីចក្ខុវិស័យ គោលបំណង លទ្ធផលរំពឹងទុក និងគោលការណ៍គន្លឹះនានាសម្រាប់គណនេយ្យភាពសង្គម ព្រមទាំងយុទ្ធសាស្ត្រគន្លឹះចំនួនប្រាំ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋធ្វើការងាររួមគ្នាក្នុងការអភិវឌ្ឍនៅមូលដ្ឋាន។

បន្ទាប់ពីបានអនុម័តឯកសារផែនការយុទ្ធសាស្ត្ររួចមក គ.ជ.អ.ប បានបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនៅថ្នាក់ជាតិ ដើម្បីរៀបចំជាឯកសារផែនការអនុវត្ត គណនេយ្យភាពសង្គមនេះឡើងសម្រាប់អនុវត្តរយៈពេល៣ឆ្នាំ ពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០១៨។ លើសពីនេះទៀតឯកសារនេះ បានយកទៅពិគ្រោះយោបល់នៅក្នុងសិក្ខាសាលាថ្នាក់ជាតិនៅថ្ងៃទី១៣-១៤ ខែសីហា ឆ្នាំ២០១៤ ជាមួយភាគីពាក់ព័ន្ធ ដែលជាតំណាងក្រុមប្រឹក្សាមកពីថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ គណៈអភិបាលថ្នាក់ខេត្ត និងស្រុក ព្រមទាំងតំណាងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ហើយធាតុចូលទាំងអស់ដែលបានពីការពិគ្រោះយោបល់ បានដាក់បញ្ចូលទៅតាមផ្នែកនីមួយៗនៃឯកសារផែនការនេះ។ ផែនការអនុវត្តនេះបានពិនិត្យ និងអនុម័តដាក់ឲ្យប្រើប្រាស់ដោយគណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម នៅក្នុងកិច្ចប្រជុំលើកទី២ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៦ ។

ឯកសារនេះ មានរៀបរាប់លម្អិតអំពីសមាសភាគសម្រាប់អនុវត្តចំនួន៤ ដូចជា ១). ភាពងាយទទួលបានព័ត៌មាននានានិងព័ត៌មានថវិកា ២). ការតាមដានត្រួតពិនិត្យដោយប្រជាពលរដ្ឋ ៣). ការសម្របសម្រួល និងការពង្រឹងសមត្ថភាព និង ៤). ការប្រមូលមេរៀនបទពិសោធន៍ និងការតាមដានត្រួតពិនិត្យ។ ឯកសារនេះ ក៏មានបរិយាយផងដែរអំពីការរៀបចំស្ថាប័នអនុវត្តដែលបានព្រមព្រៀងគ្នា ចំនួនតំបន់គោលដៅអនុវត្តតាមបណ្តាឆ្នាំ ស្ថានភាពទូទៅនៃថវិកា និងការផ្តល់ហិរញ្ញប្បទាន ហានិភ័យមួយចំនួនដែលត្រូវយកចិត្តទុកដាក់ដោះស្រាយ

ដើម្បីធានាឱ្យការអនុវត្តទទួលបានជោគជ័យ និងលទ្ធផលមួយចំនួនដែលរំពឹងថានឹងសម្រេចបានបន្ទាប់ពីបានអនុវត្តផែនការនេះ។

ជោគជ័យនៃការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម គឺអាស្រ័យទៅលើការរៀបចំបង្កើតភាពជាដៃគូរវាងក្រសួង ស្ថាប័នថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពផ្តល់សេវា ជាមួយនិងអង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋ។ ក្នុងនោះ លេខាធិការដ្ឋានគ.ជ.អ.ប ត្រូវសម្របសម្រួលរៀបចំឱ្យមានគោលនយោបាយ និងលិខិតបទដ្ឋានចាំបាច់នានា ដើម្បីអនុវត្តផែនការ នេះ និងត្រូវដើរតួនាទីសម្របសម្រួលជាទូទៅ ដើម្បីធានាឱ្យមានការចូលរួមពីក្រសួងសំខាន់ៗ ដូចជា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងតំណាងអង្គការសង្គមស៊ីវិល និងត្រូវលើកកម្ពស់តួនាទីរបស់ក្រុមប្រឹក្សាក្នុងការពិនិត្យមើលពីលើ និងតួនាទីជាតំណាងពាក់ព័ន្ធនឹងការផ្តល់សេវានានា តាមបែបវិមជ្ឈការ និងវិសហមជ្ឈការ រួមទាំងការធ្វើសេចក្តីរាយការណ៍ពីលទ្ធផលសម្រេចបានផងដែរ។ ដោយឡែកចំពោះអង្គការសង្គមស៊ីវិលវិញ ចាំបាច់ត្រូវរៀបចំជារចនាសម្ព័ន្ធមួយ ដែលមានសមត្ថភាព និងថវិកាគាំទ្រគ្រប់គ្រាន់ដើម្បីធានា ដល់ការអនុវត្តគណនេយ្យភាពសង្គម ដែលមានតួនាទីចម្បងក្នុងការទំនាក់ទំនងជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងផ្សេងៗទៀតទៅតាមការចាំបាច់ និងត្រូវចែករំលែកព័ត៌មានគ្នាទៅវិញទៅមកអំពីសមិទ្ធផលសម្រេចបាន នៃការអនុវត្តគណនេយ្យភាពសង្គមនៅមូលដ្ឋាន។

ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលចំពោះការចូលរួមយ៉ាងសកម្មជាមួយលេខាធិការដ្ឋានគ.ជ.អ.ប ក្នុងការរៀបចំផែនការអនុវត្តគណនេយ្យភាពសង្គម រួមទាំងការគាំទ្រថវិកា និងការសម្របសម្រួលដល់ដំណើរការអនុវត្តការងារគណនេយ្យភាពសង្គមនេះ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ មិនា ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប**

**សម្តេចក្រឡាហោម ស ខេង**

# មាតិកា


**អារម្ភកថា** ....... i

**មាតិកា** ....... iii

**បញ្ជីតារាង** ....... v

**ជំពូកទី ១ ÷ទិដ្ឋភាពទូទៅនៃគណនេយ្យភាពសង្គម** ....... 1

**១. សេចក្តីផ្តើម** ....... 1

**២.អំពីសមាសភាគរបស់គណនេយ្យភាពសង្គម** ....... 1

**៣. វដ្តនៃការអនុវត្តសកម្មភាព** ....... 3

**៤ .វិសាលភាព..** ....... 4

**ជំពូកទី ២÷សមាសភាគ និងលទ្ធផលរំពឹងទុក** ....... 6

**១.សេចក្តីផ្តើម** ....... 6

**២. សមាសភាគទី១÷ ការទទួលបានព័ត៌មាននានា និងព័ត៌មានថវិកា** ....... 7

២.១.ព័ត៌មានអំពីការអនុវត្តការងារ ....... 12

២.២.ការបើកចំហព័ត៌មានថវិកា ....... 13

២.៣.ការរៀបចំប្រព័ន្ធ លិខិតបទដ្ឋាន និងការអនុវត្តតាមគោលការណ៍ណែនាំ ....... 14

២.៤. ការលើកកម្ពស់ការយល់ដឹង និងការពង្រឹងសមត្ថភាព ....... 16

**៣.សមាសភាគទី២÷ ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ** ....... 19

៣.១.ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ ....... 21

៣.២. កិច្ចប្រជុំរួមគ្នា និងផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម ....... 23

៣.៣.ការរៀបចំលិខិតបទដ្ឋាននានាដើម្បីគាំទ្រការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ និងការត្រួតពិនិត្យ របស់ក្រុមប្រឹក្សាឃុំ ....... 26

៣.៤. ការលើកកម្ពស់ការយល់ដឹង និងការពង្រឹងសមត្ថភាព ....... 27

**៤.សមាសភាគទី៣ ÷ ការសម្របសម្រួល និងការពង្រឹងសមត្ថភាព** ....... 30

៤.១.ការសម្របសម្រួល ....... 33

៤.២. ការបណ្តុះបណ្តាល ការហ្វឹកហ្វឺន និងការពង្រឹងសមត្ថភាព ....... 35

**៥.សមាសភាគទី៤÷ ការប្រមូលមេរៀនបទពិសោធន៍ និងការត្រួតពិនិត្យតាមដាន** ....... 38

៥.១.ការប្រមូលមេរៀនបទពិសោធន៍ និងការផ្តល់ព័ត៌មានត្រឡប់ ....... 39

៥.២.ការត្រួតពិនិត្យតាមដាន និងលទ្ធផលសម្រេច ....... 42

**ជំពូកទី ៣÷ការរៀបចំស្ថាប័ន ការចាត់ចែងអនុវត្ត និងការផ្តល់ហិរញ្ញប្បទាន** .....45

**១. សេចក្តីផ្តើម**.....45

**២. ការរៀបចំស្ថាប័ន** .....45

២.១.ទិដ្ឋភាពទូទៅ ..... 45

២.២.ការទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋ (ផ្នែកផ្គត់ផ្គង់) ..... 47

២.៣.ការទទួលខុសត្រូវរបស់អង្គការដៃគូអនុវត្ត..... 50

**៣.ការចាត់ចែងអនុវត្ត**.....54

៣.១. ការចាប់ផ្តើមអនុវត្ត..... 54

៣.២. ក្របខ័ណ្ឌពេលវេលាសម្រាប់ការអនុវត្ត ..... 55

**៤. ការផ្តល់ហិរញ្ញប្បទាន**.....55

៤.១. ការចំណាយថវិកា..... 55

៤.២. ការផ្តល់ហិរញ្ញប្បទាន ..... 56

**ឧបសម្ព័ន្ធទី១ ÷ ការគ្រប់គ្រងហានិភ័យ** .....61

**ឧបសម្ព័ន្ធទី២÷ សមិទ្ធផលរំពឹងទុកទទួលបានពីការអនុវត្ត**.....63

**ឧបសម្ព័ន្ធទី៣ ÷ការបែងចែកការទទួលខុសត្រូវទៅតាមលទ្ធផលរំពឹងទុកនិងសកម្មភាព** .....72

**ឧបសម្ព័ន្ធទី៤ ÷វាក្យស័ព្ទសំខាន់ៗ និងនិយមន័យ**.....75

**ឧបសម្ព័ន្ធទី ៥÷ បញ្ជីអក្សរកាត់**.....79

# បញ្ជីតារាង

តារាងទី ១៖ ការរៀបចំយុទ្ធសាស្ត្រទៅជាសមាសភាគសម្រាប់អនុវត្ត ........................................................ 1
តារាងទី ២៖ សង្ខេបអំពីសមាសភាគស្តីពីការទទួលបានព័ត៌មាននានានិងព័ត៌មានថវិកា ............................ 18
តារាងទី ៣៖ សង្ខេបអំពីសមាសភាគស្តីពីការត្រួតពិនិត្យដោយប្រជាពលរដ្ឋ ............................................ 29
តារាងទី ៤៖ សង្ខេបអំពីសមាសភាគស្តីពីការសម្របសម្រួលនិងការពង្រឹងសមត្ថភាព ................................ 37
តារាងទី ៥៖ សង្ខេបអំពីសមាសភាគនៃការត្រួតពិនិត្យតាមដាន និងការពង្រឹងសមត្ថភាព .......................... 43
តារាងទី ៦៖ ការប៉ាន់ស្មានថវិកាតាមសមាសភាគ (សម្រាប់រយៈពេលចាប់ពីឆ្នាំ២០១៦ដល់២០១៨) ........... 56
តារាងទី ៧៖ ការចំណាយគ្រោងចាប់ពីឆ្នាំ២០១៦-២០១៨ សម្រាប់ផ្នែកតម្រូវការនិងផ្នែកផ្គត់ផ្គង់................ 56
តារាងទី ៨៖ លទ្ធផលសំខាន់ៗ និងការវាស់វែង ...................................................................................... 65

# ជំពូកទី ១
# ទិដ្ឋភាពទូទៅនៃគណនេយ្យភាពសង្គម

## ១. សេចក្តីផ្តើម

ផែនការអនុវត្តគណនេយ្យភាពសង្គម (ផ.អ.គ.ស) បង្ហាញអំពីវិសាលភាព ខ្លឹមសារ និងអភិក្រម សម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គម(ផ.យ.គ.ស)សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដែលបានអនុម័តជាឯកសារគោលនយោបាយដោយ គ.ជ.អ.ប នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣។ ឯកសារផែនការអនុវត្តគណនេយ្យភាពសង្គមនេះបានពិភាក្សា និងឯកភាពជាមួយតំណាងអង្គការសង្គមស៊ីវិល ជាមូលដ្ឋានរួមមួយសម្រាប់យកទៅអនុវត្ត។

ជាទិដ្ឋភាពរួម **ផ.អ.គ.ស**មានបង្ហាញអំពីសកម្មភាព និងការរៀបចំនានាដែលនឹងយកទៅអនុវត្តដោយ ក្រសួង ស្ថាប័ន អង្គភាពនានា (ហៅថា**ផ្នែកផ្គត់ផ្គង់**) និងដោយប្រជាពលរដ្ឋតាមរយៈ អង្គការសង្គមស៊ីវិល(ហៅថា**ផ្នែកតម្រូវការ**)។ ឯកសារនេះ បានរៀបរាប់អំពីវិសាលភាព និងខ្លឹមសារសមាសភាគ ការរៀបចំស្ថាប័ន ថវិកា និងការផ្តល់ហិរញ្ញប្បទាន លទ្ធផលរំពឹងទុក និងហានិភ័យដែលអាចកើតឡើង។

គណនេយ្យភាពសង្គម គឺជាដំណើរការនៃការផ្សារភ្ជាប់ទំនាក់ទំនងដ៏ល្អប្រសើររវាងប្រជាពលរដ្ឋជាមួយនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយវាក៏ជាមធ្យោបាយមួយដែលបន្សីគ្នារវាងគោលការណ៍ទាំងឡាយនៃអភិបាលកិច្ចដែលក្នុងនោះរាល់ការធ្វើសេចក្តីសម្រេចចិត្ត និងការអនុវត្តសកម្មភាពជាសាធារណៈនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវប្រកាន់យកតាមកិច្ចដំណើរការនេះ។ កិច្ចសហការរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ (អ្នកផ្តល់សេវា) និងប្រជាពលរដ្ឋ (អ្នកប្រើប្រាស់សេវា) គឺសំដៅគាំទ្រដល់អ្នកផ្តល់សេវាសាធារណៈឱ្យបំពេញការងាររបស់ខ្លួនបានប្រសើរជាងមុន។ បទពិសោធន៍កន្លងមកបានបង្ហាញថា ឧបករណ៍គណនេយ្យភាពសង្គមនានា (ដូចជាប័ណ្ណដាក់ពិន្ទុដោយសហគមន៍) ជួយជំរុញឱ្យមានការគោរពគ្នា និងការចូលរួមរវាងប្រជាពលរដ្ឋ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

## ២.អំពីសមាសភាគរបស់គណនេយ្យភាពសង្គម

ផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គមបានដាក់ចេញនូវយុទ្ធសាស្ត្រចំនួន៥ ដើម្បីសម្រេចបាននូវគោលបំណងរួម គឺពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ និងពង្រឹងគណនេយ្យភាពសង្គមនៅប្រទេសកម្ពុជា។

យុទ្ធសាស្ត្រទាំងប្រាំនៃផ.យ.គ.ស ត្រូវបានរៀបចំទៅជាសមាសភាគចំនួន៤ នៅក្នុងផ.អ.គ.សដើម្បីជំរុញការអនុវត្តប្រកបដោយប្រសិទ្ធភាព ដូចមានបង្ហាញក្នុងតារាងខាងក្រោម៖

តារាងទី១៖ ការរៀបចំយុទ្ធសាស្ត្រទៅជាសមាសភាគសម្រាប់អនុវត្ត

| ផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គម | សមាសភាគនៃផែនការអនុវត្តរយៈពេល៣ឆ្នាំ |
|---|---|
| ១.ព័ត៌មាន<br>ការលើកកម្ពស់តម្លាភាព ភាពងាយទទួលបាន និងការ | សមាសភាគទី១<br>ភាពងាយទទួលបានព័ត៌មាននានានិងព័ត៌មានថវិកា |

| ផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គម | សមាសភាគនៃផែនការអនុវត្តរយៈពេល៣ឆ្នាំ |
|---|---|
| ប្រើប្រាស់នូវព័ត៌មានស្តីពីស្តង់ដារ ថវិកា និងការបំពេញការងារ | |
| **២. ការត្រួតពិនិត្យតាមដាន**<br>ការសម្របសម្រួលឱ្យមានការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ និងការវាយការណ៍ពីការបំពេញការងារ និងការផ្តល់សេវាមូលដ្ឋាន | **សមាសភាគទី២**<br>ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ |
| **៣.ការងារថវិកា៖** ការលើកកម្ពស់ ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីថវិកា | បញ្ចូលទៅក្នុងសមាសភាគទី១<br>ភាពងាយទទួលបានព័ត៌មាននានានិងព័ត៌មានថវិកា |
| **៤. ការសម្របសម្រួលការចូលរួម**<br>ការគាំទ្រដល់តួអង្គរដ្ឋ និងមិនមែនរដ្ឋនានា និងការកសាងសមត្ថភាពដល់តួអង្គទាំងនោះ ដើម្បីសម្របសម្រួលការចូលរួមរបស់ប្រជាពលរដ្ឋ និងកិច្ចដំណើរការនានានៃគណនេយ្យភាពសង្គម | **សមាសភាគទី៣**<br>ការសម្របសម្រួល និងការពង្រឹងសមត្ថភាព |
| **៥ . ការសិក្សារៀនសូត្រស្វែងយល់**<br>ការប្រមូលមេរៀនបទពិសោធន៍ដែលបានមកពីអន្តរាគមន៍នានានៅមូលដ្ឋាន ដើម្បីប្រែក្លាយបទពិសោធន៍ទាំងនេះដាក់បញ្ចូលទៅក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងពង្រឹងការបំពេញការងារអង្គការសង្គមស៊ីវិលនានា | **សមាសភាគទី៤**<br>ការប្រមូលមេរៀនបទពិសោធន៍និងការត្រួតពិនិត្យតាមដាន |

ផែនការអនុវត្តគណនេយ្យភាពសង្គមចែកចេញជាបួនសមាសភាគរួមមាន៖ ១).ភាពងាយទទួលបានព័ត៌មាននានានិងព័ត៌មានថវិកា ២).ការសម្របសម្រួលឱ្យមានការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ ៣).ការសម្របសម្រួលនិងការពង្រឹងសមត្ថភាព និង ៤).ការប្រមូលមេរៀនបទពិសោធន៍និងការត្រួតពិនិត្យតាមដាន។ សមាសភាគទាំង៤មានទំនាក់ទំនងនិងបំពេញគ្នាទៅវិញទៅមក ហើយសមាសភាគនីមួយៗមានការចូលរួមអនុវត្តដោយតួអង្គទាំងពីរ (រដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រុមប្រជាពលរដ្ឋ)។ សមាសភាគទាំង៤ មានពន្យល់លម្អិតដូចខាងក្រោម៖

១) **ភាពងាយទទួលបានព័ត៌មាននានា និងព័ត៌មានថវិកា៖** មានគោលបំណងពង្រឹងភាពងាយទទួលបានព័ត៌មានសាធារណៈរបស់ប្រជាពលរដ្ឋ (រួមមានព័ត៌មានសាមញ្ញៗពាក់ព័ន្ធនឹងថវិកា) និងការបង្កើនសមត្ថភាពរបស់ប្រជាពលរដ្ឋឱ្យបានយល់ដឹង និងប្រើប្រាស់ព័ត៌មានទាំងនោះ។ សមាសភាគនេះគឺសំដៅពង្រឹងសមត្ថភាពរបស់តួអង្គទាំងពីរពាក់ព័ន្ធនឹងព័ត៌មានសាធារណៈ។

២) **ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ៖** មានគោលបំណងឱ្យប្រជាពលរដ្ឋអាចធ្វើការត្រួតពិនិត្យវាយតម្លៃដោយឯករាជ្យលើការផ្តល់សេវាសាធារណៈ ការបំពេញការងាររបស់រដ្ឋបាល និងវិភាគលើព័ត៌មានដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ លទ្ធផលនៃការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋនឹងត្រូវចែករំលែកជាមួយអង្គភាពពាក់ព័ន្ធនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយនិងប្រើ

ប្រាស់សម្រាប់រៀបចំផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គមតាមរយៈកិច្ចប្រជុំរួម ដើម្បីរៀបចំផែនការសកម្មភាពរួមនេះ នឹងធានាឱ្យមានសកម្មភាពតាមដាន ត្រួតពិនិត្យ របស់ភាគីពាក់ព័ន្ធទាំងអស់ ព្រមទាំងបញ្ចូលសកម្មភាពទាំងនោះទៅក្នុងដំណើរការកសាងផែនការ និងការធ្វើសេចក្តីសម្រេចនានានៅថ្នាក់ឃុំ។

៣) **ការសម្របសម្រួល និងការពង្រឹងសមត្ថភាព៖** មានគោលបំណងផ្តល់ការបណ្តុះបណ្តាល ផ្តល់ការប្រឹក្សាយោបល់ និងផ្តល់ការហ្វឹកហ្វឺននានា ដល់អ្នកសម្របសម្រួលនៅតាមសហគមន៍ អង្គការសង្គមស៊ីវិល បុគ្គលិក សមាជិកក្រុមប្រឹក្សាឃុំ ស្រុក និងដល់អ្នកផ្តល់សេវាសាធារណៈនៅមូលដ្ឋាន។ ការសម្របសម្រួល និងការពង្រឹងសមត្ថភាពសំដៅគាំទ្រដល់សកម្មភាពសំខាន់ៗចំនួនពីរគឺការពង្រឹងសមត្ថភាព និងការធានានិរន្តរភាពរបស់សកម្មភាពនានា។

៤) **ការប្រមូលមេរៀនបទពិសោធន៍ និងការត្រួតពិនិត្យតាមដាន៖** មានគោលបំណងបង្កើតឱ្យមានយន្តការ និងទម្លាប់រៀនបណ្តើរអនុវត្តបណ្តើរ។ លទ្ធផលនៃការត្រួតពិនិត្យតាមដានដែលរកឃើញនៅសហគមន៍នឹងក្លាយជាធាតុចូល សម្រាប់ការអភិវឌ្ឍសមត្ថភាព និងការកែលម្អការអនុវត្តការងារជាក់ស្តែង។

## ៣. វដ្តនៃការអនុវត្តសកម្មភាព

សកម្មភាពគណនេយ្យភាពសង្គមនឹងត្រូវអនុវត្តតាមរយៈវដ្តនៃការអនុវត្តសកម្មភាពរួមមាន៖ ការចែករំលែកព័ត៌មាន និងការពង្រឹងការយល់ដឹងពីថវិកា ការអនុវត្តគណនេយ្យភាពសង្គម (ដូចជាការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ) ការសម្របសម្រួល ការពង្រឹងសមត្ថភាព ការសិក្សារៀនសូត្រ និងការត្រួតពិនិត្យ។ល។

ការកំណត់ពេលវេលាសម្រាប់សកម្មភាពនានានៅក្នុងសមាសភាគនីមួយៗមានសារៈសំខាន់ណាស់ ដើម្បីឱ្យសកម្មភាពទាំងនោះដើរស្របគ្នាជាមួយពេលវេលានៃដំណើរការដែលមានស្រាប់។ ដើម្បីទទួលបានអត្ថប្រយោជន៍ជាអតិបរមា សកម្មភាពទាំងឡាយត្រូវបញ្ចូលនូវការពង្រឹងសមត្ថភាពការផ្តល់យោបល់ត្រឡប់ និងផ្តល់ជាទុនចូលរួមទៅក្នុងប្រព័ន្ធអភិបាលកិច្ចនានានៅមូលដ្ឋាន។

**រូបភាពទី១ វដ្តនៃការអនុវត្តគណនេយ្យភាពសង្គម**




## ៤. វិសាលភាព

ក្នុងរយៈពេលបីឆ្នាំ(២០១៦-២០១៨) សកម្មភាពគណនេយ្យភាពសង្គមដែលពិពណ៌នាក្នុងផែនការនេះនឹងត្រូវអនុវត្តលើវិស័យទាំងបីដោយផ្តោតលើ សេវាមណ្ឌលសុខភាព សាលាបឋមសិក្សា និងសេវារដ្ឋបាលឃុំ នៅក្នុង ១២០ស្រុក។ វិសាលភាពនៃការអនុវត្តមានដូចខាងក្រោម៖

- **នៅដំណាក់កាលដំបូងនៃការអនុវត្តកិច្ចការនេះនឹងផ្តោតនៅតាមតំបន់ជនបទ**[1] រីឯតំបន់ទីប្រជុំជន (ស្រុក សង្កាត់ ខណ្ឌ និងក្រុង) នឹងត្រូវអនុវត្តនៅដំណាក់កាលទី២នៃផែនការអនុវត្តគណនេយ្យភាពសង្គមដោយបញ្ចូលនូវសេវាផ្សេងៗទៀត និងអនុវត្តនៅថ្នាក់រដ្ឋបាលផ្សេងៗទៀតនៃរដ្ឋបាលថ្នាក់ក្រោមជាតិ[2]។

---

[1] តម្រូវការនៃគណនេយ្យភាពសង្គមនៅតំបន់ជនបទ និងទីប្រជុំជនអាចមានលក្ខណៈខុសគ្នា។

[2] ប្រភព: តារាងចំនុចដៅពាក់ព័ន្ធនឹងគណនេយ្យភាពតាមបែបប្រជាធិបតេយ្យនៃឯកសារផអ៣ ដំណាក់កាលទី២ ទំព័រ៣៤។

- **គ្រប់ឃុំទាំងអស់ដែលស្ថិតក្នុងស្រុកគោលដៅនឹងត្រូវអនុវត្តសកម្មភាពគណនេយ្យភាពសង្គមដែល** មានសកម្មភាពជាច្រើននឹងត្រូវអនុវត្តនៅតាមភូមិ សាលារៀន និងមណ្ឌលសុខភាព ប៉ុន្តែត្រូវចាត់ទុកថាជាក្របខ័ណ្ឌថ្នាក់ស្រុក។
- **ថ្នាក់ខេត្ត**ត្រូវមានតួនាទីសំខាន់ក្នុង**ការគាំទ្រ សម្របសម្រួល** និង**ទំនាក់ទំនង**ជាមួយស្ថាប័ន និងអង្គភាពសំខាន់ៗ បើទោះបីជាសកម្មភាពផ.អ.គ.ស ផ្តោតតែនៅថ្នាក់មូលដ្ឋានឃុំ និងស្រុកក៏ដោយ។
- ស្រុកដែលកំពុងអនុវត្តកម្មវិធី ឬគម្រោងអ្វីមួយដែលស្រដៀងគ្នាអាចសម្រេចចិត្តចូលរួមអនុវត្តការងារគណនេយ្យភាពសង្គម នៅអំឡុងឆ្នាំ២០១៦-២០១៨ ឬរង់ចាំអនុវត្តនៅដំណាក់កាលទី២ **ដើម្បីជៀសវាងការយល់ច្រឡំដល់អ្នកពាក់ព័ន្ធនៅមូលដ្ឋាន។**
- អង្គការមិនមែនរដ្ឋាភិបាលមិនអាចអនុវត្តតាមវិធីសាស្ត្រពីរផ្សេងគ្នា ទៅតាមប្រភពផ្តល់ហិរញ្ញប្បទានផ្សេងគ្នាបានឡើយ។
- ថ្វីត្បិតតែការគិតគូរផ្តោតលើឃុំ ប៉ុន្តែក្រុង ស្រុក សង្កាត់ក៏ជាអាទិភាពសម្រាប់ធ្វើការសិក្សាបង្កើតឧបករណ៍បន្ថែមក្នុងទម្រង់ កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4Cs)។

ការជ្រើសរើសស្រុកគោលដៅ ត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យសមស្របមួយចំនួនដូចជា៖

១).ផ្តល់អាទិភាពដល់ស្រុកដែលបានអនុវត្តក្នុងដំណាក់កាលសាកល្បង (២០១៤និង២០១៥) ព្រោះស្រុកទាំងនោះធ្លាប់បានទទួលការបណ្តុះបណ្តាល និងអនុវត្តសាកល្បង។

២).ផ្តល់អាទិភាពជូនស្រុកដែលនឹងទទួលការអនុវត្តការផ្ទេរមុខងារពីក្រសួងអប់រំ សុខាភិបាល និងក្រសួងពាក់ព័ន្ធ។

៣).ស្រុក ដែលមានការិយាល័យច្រកចេញចូលតែមួយ

៤).ស្រុកដែលមានអង្គការសង្គមស៊ីវិលកំពុងអនុវត្ត ហើយដែលអង្គការទាំងនោះត្រូវមាន៖

- ផែនការអនុវត្តជាក់លាក់ (យ៉ាងតិច៣ឆ្នាំ)
- ការប្តេជ្ញាចិត្ត និងប្រព័ន្ធហិរញ្ញវត្ថុរឹងមាំ (និរន្តរភាពហិរញ្ញវត្ថុ)
- រចនាសម្ព័ន្ធរឹងមាំ ទាំងថ្នាក់ជាតិ ថ្នាក់ខេត្ត ឬមានអង្គការដៃគូអនុវត្តនៅមូលដ្ឋានច្បាស់លាស់
- សមត្ថភាពបច្ចេកទេស និងអនុវត្តតាមគោលការណ៍ និងឧបករណ៍ដូចបានកំណត់ជាក់លាក់ក្នុងសេចក្តីណែនាំស្តីពីប្រតិបត្តិការ *(ឧ.អនុវត្តលើបីវិស័យ ដោយផ្តោតលើ មណ្ឌលសុខភាព សាលារៀន និងរដ្ឋបាលឃុំ ហើយប្រើ"ប័ណ្ណដាក់ពិន្ទុសហគមន៍"ជាឧបករណ៍សម្រាប់តាមដាននិងត្រួតពិនិត្យ)។*

# ជំពូកទី ២
# សមាសភាគ និងលទ្ធផលរំពឹងទុក

## ១.សេចក្តីផ្តើម

គណនេយ្យភាពសង្គមក្នុងកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ មានគោលបំណងផ្តល់នូវសិទ្ធិអំណាចដល់ប្រជាពលរដ្ឋ សហគមន៍មូលដ្ឋាន ជាពិសេសក្រុមដែលតំណាងឲ្យផលប្រយោជន៍របស់ស្ត្រី យុវវ័យ និងក្រុមជនងាយរងគ្រោះនានា ក្នុងការចូលរួមពង្រឹង ការចាត់ចែងធនធាន ការប្រើប្រាស់ថវិកា និងការផ្តល់សេវាសាធារណៈនៅមូលដ្ឋាន តាមរយៈការលើកកម្ពស់នូវភាពងាយទទួលបានព័ត៌មាន និងការចូលរួមពិនិត្យតាមដានលើការងារថវិកា និងការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ផែនការអនុវត្តគណនេយ្យភាពសង្គម ត្រូវបានរំពឹងទុកនូវលទ្ធផលមួយចំនួនគឺ **ទី១៖** ផ្តើមចេញពីលទ្ធផលនៃទំនាក់ទំនងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយប្រជាពលរដ្ឋ ឬតំណាងនានារបស់ប្រជាពលរដ្ឋនឹងធ្វើឲ្យមានការផ្លាស់ប្តូរ ឬឆ្លើយតបរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះចំពោះប្រជាពលរដ្ឋ។ **ទី២៖** សមត្ថភាពរបស់ប្រជាពលរដ្ឋ(ស្ត្រី និងបុរស) និងតំណាងនានារបស់ប្រជាពលរដ្ឋត្រូវបានលើកកម្ពស់កាន់តែប្រសើរឡើងដើម្បីបន្តចូលរួមផ្តល់យោបល់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ។ ជាមួយគ្នានោះដែរ ការងារគណនេយ្យភាពសង្គមនឹងចូលរួមចំណែកផ្តល់ប្រយោជន៍នានា រួមមាន៖

- ការផ្តល់សេវា និងការបែងចែកធនធានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងកាន់តែមានលក្ខណៈតម្លាភាព ប្រសិទ្ធភាព គណនេយ្យភាព និងសមធម៌។
- សហគមន៍មូលដ្ឋាន និងប្រជាពលរដ្ឋទាំងឡាយ ជាពិសេសស្ត្រី និងយុវវ័យ ដែលជាតួអង្គសំខាន់ក្នុងការចូលរួមចំណែកឲ្យមានការផ្លាស់ប្តូរ នឹងត្រូវបានលើកកម្ពស់សិទ្ធអំណាចរបស់ខ្លួនតាមរយៈការបង្កលក្ខណៈឲ្យពួកគេមានការយល់ដឹងកាន់តែច្រើនឡើងអំពីសិទ្ធិ និងការទទួលខុសត្រូវរបស់ខ្លួន ក្នុងការប្រាស្រ័យទាក់ទងជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។
- មូលធនសង្គម ព្រមទាំងភាពជឿជាក់ក្នុងចំណោមសមាជិកនានារបស់សហគមន៍ និងរវាងប្រជាពលរដ្ឋជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកើនឡើង និងជាមូលដ្ឋានដ៏សំខាន់ក្នុងការជំរុញទាំងការអភិវឌ្ឍសង្គម និងកំណើនសេដ្ឋកិច្ចមូលដ្ឋាន។

ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុករួមខាងលើ និងឆ្លើយតបនឹងយុទ្ធសាស្រ្តទាំង៥ នៃផែនការយុទ្ធសាស្រ្តគណនេយ្យភាពសង្គមដែលបានអនុម័តក្នុងខែកក្កដា ឆ្នាំ២០១៣ កន្លងមកនេះ ផែនការអនុវត្តគណនេយ្យភាពសង្គមបានបែងចែកជាបួនសមាសភាគសំខាន់ៗ ដូចបានចែងក្នុងជំពូកទី១ ចំនុចទី ២ ″ អំពីសមាសភាគរបស់

គណនេយ្យភាពសង្គម " ដែលត្រូវប្រកាន់យកដោយតួអង្គពាក់ព័ន្ធទាំងអស់ដើម្បីសហការគ្នាអនុវត្តផែនការនេះប្រកបដោយជោគជ័យ។

## ២. សមាសភាគទី១÷ ភាពងាយទទួលបានព័ត៌មាននានា និងព័ត៌មានថវិកា

**សមាសភាគនេះមានគោលបំណងលើកកម្ពស់តម្លាភាព ភាពងាយទទួលបានព័ត៌មាន និងព័ត៌មានថវិកា** ដែលជាសមាសធាតុដ៏សំខាន់នៃដំណើរការកំណែទម្រង់តាមបែបប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និង គណនេយ្យភាពសង្គម។ ប្រសិនបើពុំមានព័ត៌មានអំពីស្តង់ដារនៃសេវា ប្រជាពលរដ្ឋមិនអាចដឹងបានថាតើមានសេវាអ្វីខ្លះដែលត្រូវផ្តល់ ឬសេវាអ្វីខ្លះដែលត្រូវស្នើសុំ ដែលទាក់ទងនឹងសុខភាព ការអប់រំ និងសេវា នានាពីរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការចែករំលែកព័ត៌មានគ្នាទៅវិញទៅមកនឹងនាំឱ្យមានការយល់គ្នា ទំនាក់ទំនងគ្នា និងធ្វើសកម្មភាពរួមគ្នាកាន់តែល្អប្រសើរ។ ផ្អែកតាមបទពិសោធន៍ជាក់ស្តែងកន្លងមកការពិភាក្សារវាងតួអង្គទាំងពីរអាចឈានទៅដល់ការកែលម្អការផ្តល់សេវាកាន់តែល្អប្រសើរឡើង។ ប្រសិនបើប្រជាពលរដ្ឋមិនបានទទួលព័ត៌មានច្បាស់លាស់ មិនមានលក្ខណៈជាប្រព័ន្ធ និងមិនទាន់ពេលវេលានោះ ប្រជាពលរដ្ឋក៏ពុំអាចចូលរួមក្នុងដំណើរការគណនេយ្យភាពសង្គមបានប្រកបដោយប្រសិទ្ធភាព។ ម៉្យាងទៀតប្រសិនបើប្រជាពលរដ្ឋមិនទទួលបានព័ត៌មាន និងពុំដឹងថា អាចមានឥទ្ធិពលទៅលើការធ្វើសេចក្តីសម្រេចចិត្តនោះ ប្រជាពលរដ្ឋក៏ពុំចង់ដឹងអំពីព័ត៌មានអ្វីឡើយ។

**ពាក់ព័ន្ធនឹងសារៈសំខាន់នៃព័ត៌មានអំពីថវិកា និងការចំណាយ៖** តាមការស្រាវជ្រាវបង្ហាញថា នៅប្រទេសកម្ពុជា ទាំងតម្លាភាពផ្នែកហិរញ្ញវត្ថុសាធារណៈរួមទាំងការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីបញ្ហាហិរញ្ញវត្ថុសាធារណៈនៅមានកម្រិតនៅឡើយ។ ការអង្កេតស្តីពី"ការបើកចំហផ្នែកថវិកា" [3] បានបង្ហាញថា ប្រទេសកម្ពុជាស្ថិតនៅចំណាត់ថ្នាក់ទាបជាងគេក្នុងចំណោមបណ្តាប្រទេសដែលបានអង្កេត។ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប) បានជំរុញឱ្យមានការបើកចំហព័ត៌មាន ថវិកានិងមូលនិធិឃុំសង្កាត់ និងលើកស្ទួយតម្លាភាពក្នុងការប្រើប្រាស់ថវិកាទាំងនោះ ប៉ុន្តែការអង្កេតនាពេលថ្មីៗ បានរកឃើញថាមានប្រជាពលរដ្ឋចំនួនតិចតួចប៉ុណ្ណោះដែលចង់ដឹងព័ត៌មានពាក់ព័ន្ធនឹងថវិកា ហើយតម្លាភាពនៃការប្រើប្រាស់ថវិកា នៅមានកម្រិតនៅឡើយ។

**យោងតាមយុទ្ធសាស្ត្រទី១ និងយុទ្ធសាស្ត្រទី៣នៃផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គម ការអនុវត្តសមាសភាគទី១នេះនឹងជួយពង្រឹងតម្លាភាព ភាពងាយទទួលបានព័ត៌មាន តម្រូវការព័ត៌មាននានា និងព័ត៌មានថវិកាសម្រាប់សាធារណជន។** សមាសភាគទី១នេះ រួមមាន៖ ការរៀបចំព័ត៌មាន ការធ្វើឱ្យព័ត៌មានងាយស្រួលយល់ និងការផ្សព្វផ្សាយព័ត៌មាន ព្រមទាំងពង្រឹងការយល់ដឹងអំពីព័ត៌មានថវិកា។ ការអនុវត្តសមាសភាគនេះ គឺសំដៅ៖ ១) ពង្រឹងការផ្តល់ និងការផ្សព្វផ្សាយព័ត៌មានជាសាធារណៈនៅថ្នាក់មូលដ្ឋាន (រួមទាំងព័ត៌មានពាក់ព័ន្ធនឹងថវិកា) ២)ធ្វើឱ្យកាន់តែមានភាពងាយស្រួលក្នុងការទទួលបានព័ត៌មាន និង៣)ពង្រឹងសមត្ថភាពរបស់

[3]ការអង្កេតស្តីពីព័ត៌មានថវិកា ឆ្នាំ២០១០ ដោយ International Budget Partnership (IBP) http://www.internationalbudget.org/wp-content/uploads/2011/04/OBI2010-Cambodia.pdf

ប្រជាពលរដ្ឋក្នុងការស្វែងយល់អំពីព័ត៌មានដែលបានផ្តល់ឱ្យ។ ការផ្តល់ព័ត៌មានឱ្យកាន់តែប្រសើរ ការបង្កើនការយល់ដឹងអំពីព័ត៌មាននឹងជួយសម្រួលដល់ការពិភាក្សារកដំណោះស្រាយកែលម្អការផ្តល់សេវានៅមូលដ្ឋាន។

**តើត្រូវផ្តល់ព័ត៌មានអំពីអ្វីខ្លះ?** ដើម្បីឱ្យការចូលរួមមានប្រសិទ្ធភាព ប្រជាពលរដ្ឋត្រូវការព័ត៌មានអំពីគោលនយោបាយ និងដំណើរការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ អំពីស្តង់ដារសេវា និងអភិបាលកិច្ច អំពីថវិកានិងការចំណាយប្រចាំឆ្នាំ និងអំពីតំបន់គោលដៅសម្រាប់ផ្តល់សេវា និងការបំពេញការងារដែលសម្រេចបានជាក់ស្តែង។ ព័ត៌មានទាំងនេះ គួរផ្តោតលើតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ (ដូចជា សុខភាព ការសិក្សាអប់រំ អនាម័យ និងទឹកស្អាត ការគ្រប់គ្រងធនធានធម្មជាតិ និងសេវានានារបស់ឃុំ)។ ព័ត៌មានទាំងនេះ ចែកចេញជា២ប្រភេទ៖ ព័ត៌មានដែលត្រូវកែសម្រួលជារៀងរាល់ឆ្នាំ (ដូចជាព័ត៌មាននៃការបំពេញការងារ) និងព័ត៌មានដែលត្រូវកែសម្រួលតែនៅពេលណាមានការផ្លាស់ប្តូរណាមួយ (ដូចជាគោលនយោបាយ)។

- **ព័ត៌មានស្តីពីគោលនយោបាយ និងនីតិវិធី៖** ការរៀបចំព័ត៌មានអំពីគោលនយោបាយ ច្បាប់ ផែនការ និងនីតិវិធីសំខាន់ៗរបស់រាជរដ្ឋាភិបាលមានលក្ខណៈសាមញ្ញ ងាយយល់ អាចជួយឱ្យប្រជាពលរដ្ឋយល់ដឹងអំពីបរិបទនៃកិច្ចអភិវឌ្ឍ ដើម្បីឱ្យប្រជាពលរដ្ឋបានយល់អំពីដំណើរការ អំពីការរៀបចំសេចក្តីសម្រេចចិត្ត។ ក្រៅពីនោះ នៅមានព័ត៌មានគោលនយោបាយផ្សេងៗទៀត ដែលមាននៅក្នុងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ វិធានផ្ទៃក្នុង ក្រមសីលធម៌...។ល។ ក៏ត្រូវធ្វើឱ្យមានលក្ខណៈសាមញ្ញ ងាយយល់ សម្រាប់ប្រជាពលរដ្ឋផងដែរ។ នីតិវិធីនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការផ្តល់សេវានានារួមមានការគ្រប់គ្រងចាត់ចែងថវិកា នីតិវិធីទំនាក់ទំនងជាមួយអង្គភាពផ្តល់សេវានានា ដូចជាត្រូវទាក់ទងជាមួយអ្នកណា ត្រូវទៅទទួលព័ត៌មាននៅកន្លែងណា និងត្រូវធ្វើបណ្តឹងតវ៉ាដោយរបៀបណា។តារាងតម្លៃសេវាដែលត្រូវបង់ ប្រភេទសេវាដែលមិនត្រូវបង់ថ្លៃ ពេលម៉ោងបំពេញការងារ និងក្រមសីលធម៌របស់បុគ្គលិកជាដើម ក៏ជាប្រភេទព័ត៌មានស្តីពីគោលនយោបាយដែរ។ នៅថ្នាក់ឃុំ ព័ត៌មានអំពីដំណើរការប្រើប្រាស់មូលនិធិឃុំ សង្កាត់ (ដូចជា ការដេញថ្លៃ និងការអនុវត្តគម្រោង) គឺជាព័ត៌មានអំពីនីតិវិធី។ ព័ត៌មានបែបនេះធ្លាប់បានផ្តល់រួចមកហើយដោយគ.ជ.អ.ប ក្រសួងមហាផ្ទៃ និងក្រសួងផ្សេងៗទៀត[4] នៅតាមតំបន់មួយចំនួន។

- **ព័ត៌មានស្តីពីស្តង់ដារ និងសិទ្ធិទទួលបានសេវា៖** ព័ត៌មានទាំងនេះ នឹងជួយឱ្យប្រជាពលរដ្ឋបានដឹងពីសិទ្ធិតាមផ្លូវច្បាប់របស់ខ្លួន។ សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានសេវាសំខាន់ៗនៅមូលដ្ឋានដែលបានកំណត់នៅក្នុងគោលនយោបាយ និងច្បាប់នានា និងដែលបានផ្សព្វផ្សាយដោយក្រសួង មានដូចជា៖ គោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលតម្រូវឱ្យសាលារៀនបង្ហាញពីស្តង់ដារ ផលធៀបសិស្ស-គ្រូ (មិនលើសពី៤២នាក់/ថ្នាក់/គ្រូម្នាក់)។ គោលនយោបាយក្រសួងសុខាភិបាលស្តីពីសំណុំសកម្មភាពអប្បបរមាសម្រាប់ការអភិវឌ្ឍមណ្ឌលសុខភាព ការថែទាំសុខភាពបឋមតម្រូវឱ្យមានគិលានុបដ្ឋាក គិលានុបដ្ឋាយិកា ឆ្មប ដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ ឬត្រូវមានឱសថគ្រប់គ្រាន់។ ក្រសួងមហាផ្ទៃចេញសេចក្តីណែនាំស្តីពីនីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋាន ការណែនាំអំពីការគ្រប់គ្រង និងប្រើប្រាស់មូលនិធិឃុំ សង្កាត់ និងមូលនិធិក្រុង ស្រុក។

---

[4]ឧទាហរណ៍ ក្រមសីលធម៌របស់បុគ្គលិក និងព័ត៌មានស្តីពីការផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយ ប្រព័ន្ធដោះស្រាយបណ្តឹងតវ៉ានៃក្រុមការងារគណនេយ្យភាព។

- **ព័ត៌មានពាក់ព័ន្ធថវិកា និងការចំណាយ៖** ប្រជាពលរដ្ឋ គួរដឹងអំពីចំនួន និងប្រភពនៃថវិកា។ បច្ចុប្បន្ននេះ ព័ត៌មានថវិកា ដូចជាថវិកាសម្រាប់រដ្ឋបាលឃុំ សម្រាប់សាលារៀន មួយចំនួនបានបិទផ្សាយរួចហើយនៅតាមជញ្ជាំងការិយាល័យសម្រាប់សាធារណជនអាចមើលបាន។ ដោយឡែកមណ្ឌលសុខភាពភាគច្រើនមិនបានដឹងពីចំនួនថវិកាសរុបរហូតដល់ដំណាច់ឆ្នាំ (តែអាចយោងចំនួនថវិកាសម្រាប់ឆ្នាំមុនៗមកធ្វើជាមូលដ្ឋានក្នុងការបិទផ្សាយបានដែរ)។ ព័ត៌មានទាំងនេះត្រូវមានការចងក្រងបូកសរុប និងបង្ហាញតាមទម្រង់មួយសម្រាប់ប្រជាពលរដ្ឋស្វែងយល់។ ព័ត៌មានថវិកានេះ ត្រូវស៊ីគ្នាជាមួយព័ត៌មាននៃការប្រើប្រាស់ថវិកានៅដំណាច់ឆ្នាំនីមួយៗ។

- **ការបើកចំហរព័ត៌មាននានា និងព័ត៌មានថវិការបស់ថ្នាក់ស្រុក ក្រុង (ពិសេសស្រុក ក្រុងដែលទទួលបានការផ្ទេរមុខងារ)៖** លេខាធិកាធិការដ្ឋានគ.ជ.អ.ប នឹងជួលទីប្រឹក្សារយៈពេលខ្លីដើម្បីធ្វើការសិក្សាលើលទ្ធភាព ព្រមទាំងការរៀបចំបង្កើតនូវឧបករណ៍ និងឯកសារជំនួយបច្ចេកទេសនានា ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម ពិសេសការបើកចំហរព័ត៌មាននានារួមទាំងថវិកានៅថ្នាក់ស្រុក ក្រុង នាឆ្នាំទី២ ឬទី៣នៃផែនការអនុវត្តនេះ។

- **ព័ត៌មានស្តីពីចំណុចដៅអនុវត្ត៖** ចំណុចដៅនានា (ដូចជា គោលដៅអភិវឌ្ឍសហសវត្សកម្ពុជា ឬចំណុចដៅនៃកម្មវិធីនានា) ដែលបានកំណត់ឡើងដើម្បីផ្ទៀងផ្ទាត់ និងកែលម្អការបំពេញការងារ។ ការតាមដានលទ្ធផលនៃការបំពេញការងារធៀបនឹងចំណុចដៅកំណត់ នឹងជួយឱ្យដឹងថាតើនៅមូលដ្ឋានបានបំពេញការងារយ៉ាងដូចម្តេច។ព័ត៌មានទាំងនេះមានបង្ហាញជាសាធារណៈមួយចំនួនរួចហើយ ប៉ុន្តែមិនបានផ្សព្វផ្សាយឱ្យបានទូលំទូលាយនៅតាមមូលដ្ឋាននៅឡើយ។ ឧទាហរណ៍៖
  - នៅតាមសាលាបឋមសិក្សា៖ ចំណុចដៅនៃលទ្ធផលសំខាន់ៗរួមមាន អត្រាចុះឈ្មោះចូលរៀនថ្នាក់ទី១(៩៦%) ការចុះឈ្មោះនៅកម្រិតការអប់រំកុមារតូចនៅអាយុ៥ឆ្នាំ (៥០%)ផលធៀប សិស្ស-គ្រូ (សិស្ស៤២នាក់) អត្រានៃការឡើងថ្នាក់ពីថ្នាក់ទី១ដល់ទី៦ (៧៥%)។
  - នៅមណ្ឌលសុខភាព៖ គោលដៅសម្រាប់ឆ្នាំ២០១៧ រួមមានការផ្តល់វ៉ាក់សាំងការពារ (សម្រាប់ក្មេងទទួលវ៉ាក់សាំងបង្ការDPT ចំនួន៣ដង) មានស្ត្រី៧០% បានមកពិនិត្យសុខភាពមុនពេលសម្រាល (មកពិនិត្យបាន៤ដង) ការផ្តល់សេវាសុខភាពបាន៩៥% និងកាត់បន្ថយអត្រាស្លាប់ឲ្យបាន៧០%ចំពោះកុមារក្រោមអាយុ៥ឆ្នាំ។
  - នៅរដ្ឋបាលឃុំ៖ មានស្តង់ដារសេវា អត្រានុកូលដ្ឋានដូចជា ការចុះសំបុត្រ កំណើត សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្រមរណភាព។
- **ព័ត៌មានស្តីពីការបំពេញការងារ និងលទ្ធផលដែលសម្រេចបាន៖** ប្រជាពលរដ្ឋ ត្រូវការព័ត៌មានស្តីពីការបំពេញការងារ និងលទ្ធផលរបស់ភ្នាក់ងារផ្តល់សេវា ដូចជាសាលាបឋមសិក្សា មណ្ឌលសុខភាព និងរដ្ឋបាលឃុំ។ "កម្រងព័ត៌មានឃុំ" ដែលមាននៅក្នុងទិន្នន័យមូលដ្ឋានឃុំធ្លាប់បានយកមកចងក្រងរួចហើយដែរ។ សកម្មភាពជ.អ.គ.សនឹងជំរុញការចងក្រង និងការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធសូចនាករបំពេញការងារសំខាន់ៗមួយចំនួនជាមុន។ ព័ត៌មានពាក់ព័ន្ធការបំពេញការងារ និងលទ្ធផលមានដូចជា៖

  ១. អត្រាចុះឈ្មោះចូលរៀននៅមុនអាយុកំណត់សម្រាប់កុមារ

  ២. អត្រាចុះឈ្មោះចូលរៀនថ្នាក់បឋមសិក្សា

  ៣. អត្រាសិស្សានុសិស្សរៀនដល់ថ្នាក់ទី៦

៤. ចំនួនសិស្សក្នុងគ្រូ១នាក់
៥. ចំនួនផ្តល់វ៉ាក់សាំងបង្ការ (កុមារទទួលវ៉ាក់សាំងបង្ការDPTបាន៣ដង)
៦. អត្រាមកពិនិត្យសុខភាពមុនពេលសម្រាល (មកពិនិត្យ បាន4ដង)
៧. អត្រាផ្តល់សេវាសុខភាព
៨. ចំនួនកុមារស្លាប់ក្រោមអាយុ៥ឆ្នាំ
៩. ភាគរយការចុះសំបុត្រកំណើត ធៀបនឹងសេវាស្តង់ដារ
១០. ភាគរយការចុះសំបុត្រអាពាហ៍ពិពាហ៍ ធៀបនឹងសេវាស្តង់ដារ
១១. ភាគរយការចុះសំបុត្រមរណភាព ធៀបនឹងសេវាស្តង់ដារ
១២. សូចនាករនៃការអនុវត្តរបស់ឃុំ (សម្រាប់គម្រោងមូលនិធិឃុំ សង្កាត់)
១៣. សូចនាករផ្នែកសេដ្ឋកិច្ចសង្គម។

ឧបករណ៍ចំបងសម្រាប់ការផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋ ហៅថា **កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ។** ផ្ទាំងព័ត៌មានសំខាន់ៗ ស្តីពីការងារផ្តល់សេវា និងកិច្ចអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាចំណុចចាប់ផ្តើមពិភាក្សា និងចែករំលែកនៅក្នុងការងារគណនេយ្យភាពសង្គម ។ ហេតុនេះ ថ្នាក់ស្រុក ត្រូវដើរតួនាទីសំខាន់ក្នុងការប្រមូលចងក្រងព័ត៌មានទាំងនោះ បន្ទាប់មកបែងចែកទៅថ្នាក់ឃុំ អ្នកផ្តល់សេវានានានៅមូលដ្ឋាន និងអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ សម្រាប់ធ្វើការផ្សព្វផ្សាយ ដល់ប្រជាពលរដ្ឋ។ កញ្ចប់ព័ត៌មាននេះ ត្រូវរៀបចំឡើងយ៉ាងណា ឱ្យបានឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកពាក់ព័ន្ធនានា រួមមានស្ត្រី យុវវ័យ កុមារ ជនពិការ ជនជាតិដើម និងប្រជាពលរដ្ឋក្រីក្រ។ ព័ត៌មានដែលដាក់បញ្ចូលក្នុងផ្ទាំងព័ត៌មាន គឺមានព័ត៌មានស្តីពី ស្តង់ដារការងារដែលកំណត់ដោយគោលនយោបាយជាតិ សូចនាករបំពេញការងាររបស់អ្នកផ្តល់សេវាធៀបទៅនឹងស្តង់ដារការងារនោះ និងមានព័ត៌មានអំពីថវិកា ដូចជា ចំណូល និងចំណាយ ព្រមទាំងប្រភពថវិកា។

គួរមានការលើកទឹកចិត្តចំពោះអ្នកពាក់ព័ន្ធសំខាន់ៗនៅមូលដ្ឋានក្នុងការប្រមូលព័ត៌មាន ដើម្បីជួយបំពេញបន្ថែមនូវព័ត៌មាននានាពាក់ព័ន្ធនឹងអង្គភាពផ្តល់សេវា (មណ្ឌលសុខភាព សាលាបឋមសិក្សា និងរដ្ឋបាលឃុំ) ទៅក្នុងកញ្ចប់ព័ត៌មានទាំងនោះ ដូចជា ធនធានធម្មជាតិក្នុងមូលដ្ឋាន ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជាដើម ឬបន្ថែមព័ត៌មានអ្វីដែលគិតថាចាំបាច់សម្រាប់សហគមន៍ និងព័ត៌មានបន្ថែមស្តីពីសុខភាព ឬការសិក្សាអប់រំ (ដូចជាថ្នាក់អប់រំក្រៅប្រព័ន្ធ) ឬសូចនាករទាក់ទងនឹងហានិភ័យណាមួយនៅមូលដ្ឋាននោះ។ ព័ត៌មានបន្ថែមទាំងនោះ អាចបានមកពីការអនុវត្តប័ណ្ណដាក់ពិន្ទុដោយសហគមន៍ (ដូចការពន្យល់ នៅក្នុងសមាសភាគទី២ នៃផ.អ.គ.ស) ដែលប័ណ្ណដាក់ពិន្ទុ នេះនឹងបង្ហាញអំពីកម្រិតនៃការពេញចិត្តរបស់ប្រជាពលរដ្ឋទៅលើការបំពេញការងារ ការផ្តល់សេវា និងដំណើរការពាក់ព័ន្ធនានា។

ក្នុងករណីខ្លះ អង្គការដៃគូអនុវត្តក៏អាចផ្តល់ព័ត៌មានលម្អិតអំពីវិស័យផ្សេងៗហើយស្នើសុំធ្វើការកែសម្រួលព័ត៌មានទាំងនោះឱ្យកាន់តែងាយស្រួលសម្រាប់ប្រជាពលរដ្ឋ។ ទម្រង់សម្រាប់ការផ្តល់ព័ត៌មានបន្ថែម ត្រូវដូចគ្នានឹងទម្រង់ព័ត៌មាន ខាងលើដែរ ឬក៏អាចជាទម្រង់ជាក់លាក់ណាមួយទៅតាមគោលបំណងនីមួយៗ ប៉ុន្តែ ត្រូវធ្វើយ៉ាងណាឱ្យព័ត៌មាននោះងាយទទួលបាន។

តាមរយៈកញ្ចប់ព័ត៌មានដែលបានបិទផ្សាយប្រជាពលរដ្ឋនឹងទទួលបានព័ត៌មាន និងអាចធ្វើការប្រៀបធៀបលទ្ធផលអនុវត្តការងាររបស់ភាគីពាក់ព័ន្ធនានា។ នៅក្នុងដំណាក់កាលដំបូងនៃ**ផែនការអនុវត្តគណនេយ្យភាពសង្គម** ប្រជាពលរដ្ឋ អាចធ្វើការប្រៀបធៀបរវាង៖

- លទ្ធផលនៃការអនុវត្តជាក់ស្តែង ជាមួយនឹងលទ្ធផលគ្រោងទៅតាមគោលដៅ ស្តង់ដារការងារ តម្រូវការផែនការ និងធ្វើការប្រៀបធៀបរវាងថវិកាគ្រោង និងចំណាយជាមួយលទ្ធផលអនុវត្តជាក់ស្តែង។
- ការផ្លាស់ប្តូរនានា និងនិន្នាការប្រែប្រួល ទៅតាមពេលវេលា
- លទ្ធផលការងាររបស់អង្គភាពមួយ ជាមួយអង្គភាពផ្សេងទៀត ដែលប្រហាក់ប្រហែលគ្នា។
- លទ្ធផលការងាររបស់មណ្ឌលសុខភាព សាលារៀន និងរដ្ឋបាលឃុំ ។

"**កញ្ចប់ព័ត៌មាន**" គឺជាយន្តការទំនាក់ទំនងរវាងអ្នកផ្តល់សេវានៅមូលដ្ឋានជាមួយប្រជាពលរដ្ឋ។ ព័ត៌មាននេះជួយប្រជាពលរដ្ឋឱ្យយល់ដឹងអំពីដំណើរការនានា អំពីសិទ្ធិប្រជាពលរដ្ឋ ស្តង់ដានៃការបំពេញការងាររបស់អ្នកផ្តល់សេវា និងផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម ព្រមទាំងព័ត៌មានថវិកា។ កញ្ចប់ព័ត៌មាននឹងបង្ហាញព័ត៌មានងាយស្រួលសម្រាប់ប្រជាពលរដ្ឋស្វែងយល់ ចូលរួមចំណែកកែលម្អការបំពេញការងារ និងការផ្តល់សេវា។

**ទម្រង់ ខ្លឹមសារព័ត៌មាន មានភាពសាមញ្ញ និងងាយយល់គឺជាកត្តាសំខាន់**សម្រាប់អ្នករៀបចំកញ្ចប់ព័ត៌មាន ហេតុនេះអ្នករៀបចំកញ្ចប់ព័ត៌មានត្រូវពិភាក្សា ព្រមព្រៀងអំពីទម្រង់សាមញ្ញ មានក្រាហ្វិចងាយស្រួលយល់ និងងាយប្រើប្រាស់។ កញ្ចប់ព័ត៌មានគំរូ បានធ្វើការសាកល្បងជាមួយឃុំ និងអង្គការដៃគូអនុវត្ត មុនសម្រេចឱ្យប្រើប្រាស់។ ព័ត៌មាននេះ ត្រូវចងក្រង និងបង្ហាញជាទម្រង់ផ្ទាំងរូបភាពផ្សព្វផ្សាយធំៗ ជាខិត្តប័ណ្ណ ឬតាមមធ្យោបាយទំនាក់ទំនងផ្សេងៗ។ ការសាកល្បងកញ្ចប់ព័ត៌មាន បានធ្វើជាមួយក្រុមប្រជាពលរដ្ឋដូចជាស្ត្រី យុវវ័យ កុមារ ជនពិការ ជនជាតិដើម និងប្រជាពលរដ្ឋក្រីក្រ[5]ដើម្បីដឹងប្រាកដថាព័ត៌មាននោះ មានខ្លឹមសារ និងមានភាពងាយស្រួលយល់ដល់ប្រជាពលរដ្ឋ។

ការរៀបចំកញ្ចប់ព័ត៌មាន និងការផ្តល់ព័ត៌មាន ត្រូវផ្អែកលើគោលការណ៍បើកចំហ។ គ.ជ.អ.ប នឹងរៀបចំគោលការណ៍ណែនាំដែលតម្រូវឱ្យមានការផ្តល់ព័ត៌មានប្រចាំឆ្នាំមានភាពត្រឹមត្រូវពិតប្រាកដ និងមានបិទផ្សាយជាសាធារណៈ ដែលប្រជាពលរដ្ឋ អាចទទួលបានគ្រប់ៗគ្នា។ គ.ជ.អ.ប នឹងពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ព្រមទាំងតម្រូវឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ អនុវត្តតាមគោលការណ៍បើកចំហព័ត៌មាន ដែលជាតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ហើយត្រូវមានការត្រួតពិនិត្យតាមដាន និងធ្វើអធិការកិច្ច ដើម្បីដឹងថាគោលការណ៍ណែនាំទាំងនោះត្រូវបានយកទៅអនុវត្តបានត្រឹមត្រូវ។

**អង្គភាពផ្តល់សេវា ប្រជាពលរដ្ឋ អង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ នឹងបានយល់ដឹង និងប្រើប្រាស់កញ្ចប់ព័ត៌មានបានល្អប្រសើរ តាមរយៈសកម្មភាពនៃការបង្កើនការយល់ដឹង និងពង្រឹងសមត្ថភាព អំពីព័ត៌មាននិងថវិកា។** កិច្ចការសំខាន់មួយគឺធ្វើយ៉ាងណាឱ្យព័ត៌មាននេះបានទៅដល់តំបន់គោលដៅ មានន័យថាត្រូវផ្តល់ព័ត៌មានទៅឱ្យដល់ប្រជាពលរដ្ឋ មិនមែនរង់ចាំប្រជាពលរដ្ឋមកកាន់ការិយាល័យរដ្ឋបាលដើម្បីសុំព័ត៌មានទាំង

---

[5] ទោះបីព័ត៌មានមានចំនួនកើនឡើងសម្រាប់សាធារណៈជន និងតាមបណ្តាញអ៊ិនធឺណែត ភាគច្រើននៃព័ត៌មានទាំងនេះរៀបចំសម្រាប់ប្រើប្រាស់ដោយអ្នកជំនាញបច្ចេកទេស និងអ្នកជំនាញតាមវិស័យនានានៅថ្នាក់ជាតិ។ ចំពោះប្រជាពលរដ្ឋវិញ ត្រូវផ្តល់នូវភាពងាយស្រួលក្នុងការទទួលព័ត៌មានទៅដល់ប្រជាពលរដ្ឋ។

នោះទេ។ មិនត្រឹមតែប៉ុណ្ណោះត្រូវរៀបចំការប្រជុំពិភាក្សាអំពីកញ្ចប់ព័ត៌មាន និងត្រូវរៀបចំយុទ្ធនាការបង្កើនការយល់ដឹងនៅតាមសហគមន៍ ការអភិវឌ្ឍសមត្ថភាពរបស់អង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ និងការបណ្តុះបណ្តាលអ្នកសម្របសម្រួលគណនេយ្យភាពនៅតាមសហគមន៍នៅគ្រប់ឃុំ ដើម្បីជំរុញឱ្យមានការចាប់អារម្មណ៍ និងការចង់ដឹងព័ត៌មាននានា ហើយសំខាន់គឺការបង្កើនចំណេះដឹងអំពីថវិកា និងការយល់ដឹងអំពីការគ្រប់គ្រងចាត់ចែងហិរញ្ញវត្ថុ និងការរៀបចំថវិកា ដូច្នេះចាំបាច់ត្រូវមានការបណ្តុះបណ្តាល ការហ្វឹកហ្វឺនយ៉ាងណាដើម្បីឱ្យប្រជាពលរដ្ឋមានភាពងាយស្រួលក្នុងការទទួលបានព័ត៌មានសាធារណៈទាំងនេះ ដោយយកចិត្តទុកដាក់ជាពិសេសលើក្រុមគោលដៅជាស្ត្រី យុវវ័យ កុមារ ជនពិការ ជនជាតិដើម និងប្រជាពលរដ្ឋក្រីក្រ ដែលជាក្រុមអាចនាំឱ្យមានការផ្លាស់ប្តូរជាចម្បងនៅក្នុងកម្រិតសហគមន៍។

**ទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិត្រូវមានការទទួលខុសត្រូវក្នុងការធ្វើឱ្យមានការផ្លាស់ប្តូរ** ដែលក្នុងនោះរដ្ឋបាលថ្នាក់ក្រោមជាតិ[6] ត្រូវមានតួនាទី៖ ប្រមូលទិន្នន័យ រៀបចំកញ្ចប់ព័ត៌មាន និងបិទផ្សាយព័ត៌មានសំខាន់ៗនៅតាមទីកន្លែងដែលងាយស្រួលមើល។ ចំណែកអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ ត្រូវជួយដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្សព្វផ្សាយកញ្ចប់ព័ត៌មាន (នៅថ្នាក់ឃុំ និងភូមិ) ធ្វើបច្ចុប្បន្នភាពទិន្នន័យផ្ទាំងព័ត៌មាននៅមូលដ្ឋាន ពង្រឹងការយល់ដឹងរបស់ប្រជាពលរដ្ឋព្រមទាំងជំរុញឱ្យមានការទាមទារ និងចង់បាននូវព័ត៌មាននានា។

### ២.១.ព័ត៌មានអំពីការបំពេញងារ

**គោលបំណងសំខាន់ក្នុងផ្នែកនេះ គឺការប្រមូលព័ត៌មានស្តីពីគោលនយោបាយស្តង់ដារ ការបំពេញការងារថវិកា ហើយរៀបចំព័ត៌មានពាក់ព័ន្ធបញ្ចូលទៅក្នុងកញ្ចប់ព័ត៌មាន។** ព័ត៌មានដែលត្រូវប្រមូលរួមមាន៖ ការផ្តល់សេវារបស់រដ្ឋបាលឃុំពីសាលាឃុំ សេវាសុខភាពពីមណ្ឌលសុខភាព និងសេវាអប់រំពីសាលាបឋមសិក្សា ដើម្បីធ្វើការរៀបចំជាទម្រង់ទិន្នន័យមួយដែលត្រូវបញ្ចូលនៅថ្នាក់ស្រុក។ នៅដំណាក់កាលដំបូងនេះលេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួងពាក់ព័ន្ធ រួមជាមួយទីប្រឹក្សាបច្ចេកទេសមួយក្រុមនឹងពិនិត្យមើលព័ត៌មានដែលមានស្រាប់ ពិចារណាអំពីការចាំបាច់ក្នុងការបន្ថែមព័ត៌មានមួយចំនួន ព្រមទាំងរៀបចំការណែនាំខ្លីៗដែលពន្យល់អំពីដំណើរការប្រមូលព័ត៌មាន[7] ឧទាហរណ៍ដូចជា៖ នរណាជាអ្នកទទួលខុសត្រូវក្នុងការស្រង់ទិន្នន័យ? តើមន្ត្រីបង្គោលនៅថ្នាក់ស្រុកត្រូវស្រង់ទិន្នន័យដើម្បីផលិតជាកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋប្រចាំឆ្នាំដែរឬទេ? តើចាំបាច់ត្រូវបង្កើតឱ្យមានគណៈកម្មការរួមមួយនៅថ្នាក់ស្រុកដែរឬទេ? សម្រាប់ធ្វើការត្រួតពិនិត្យទៅលើការប្រមូលទិន្នន័យ ផលិតព័ត៌មាន និងការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ។

លទ្ធផលរំពឹងទុកផ្នែកនេះ ត្រូវអនុវត្តសកម្មភាពចំនួនពីរ ដូចខាងក្រោម៖

#### សកម្មភាព ២.១.១ ការប្រមូលទិន្នន័យ ពិនិត្យផ្ទៀងផ្ទាត់ និងការចងក្រងព័ត៌មានសម្រាប់ប្រជាពលរដ្ឋ

សកម្មភាពនេះផ្តោតលើការប្រមូលទិន្នន័យ ពិនិត្យ ផ្ទៀងផ្ទាត់ព័ត៌មានពាក់ព័ន្ធទៅនឹងអ្នកផ្តល់សេវាឱ្យបានត្រឹមត្រូវ ជាមួយនឹងព័ត៌មានដទៃទៀតដែលចាំបាច់សម្រាប់ការបិទផ្សាយ។ ព័ត៌មានសំខាន់ៗចាំបាច់ដែល

---

[6] ពាក្យ "រាជរដ្ឋាភិបាល" ដែលបានប្រើប្រាស់ក្នុងឯកសារនេះ គឺសំដៅលើសាលារៀន មណ្ឌលសុខភាព ឃុំ សង្កាត់ និង ក្រុង ស្រុក ខណ្ឌ ហើយនាពេលអនាគតអាចមានអង្គភាពផ្តល់សេវាដទៃទៀត នៅពេលណាដែលមានការផ្ទេរមុខងារជាក់លាក់ទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

[7] សូមមើលលម្អិតនៅក្នុងសៀវភៅណែនាំស្តីពីកិច្ចប្រតិបត្តិការគណនេយ្យភាពសង្គមសម្រាប់ផ្នែកផ្គត់ផ្គង់

ត្រូវមាននៅក្នុងកញ្ចប់ព័ត៌មានត្រូវបែងចែកទៅតាមប្រភេទនៃព័ត៌មាននីមួយៗ។ ទោះបីមានការលំបាកក្នុងការចងក្រងព័ត៌មានខ្លះក៏ដោយក៏ព័ត៌មានសំខាន់ៗទាំងនោះ ភាគច្រើនជាព័ត៌មានដែលមានស្រាប់។ ការរៀបចំការណែនាំនេះ[8] គឺសំដៅធ្វើយ៉ាងណាឱ្យទម្រង់នៃការផ្តល់ព័ត៌មានទាំងឡាយមានលក្ខណៈរលូន និងល្អប្រសើរជាងមុន។ ជាមួយគ្នាដែរ ត្រូវមានការលើកទឹកចិត្តដល់ថ្នាក់ស្រុក ថ្នាក់ឃុំ និងអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិឱ្យធ្វើការផ្សព្វផ្សាយ និងចងក្រងព័ត៌មានបន្ថែមដែលអាចយកទៅប្រើប្រាស់ជាតម្រូវការ និងជាប្រយោជន៍ដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

### សកម្មភាព ២.១.២ ការបោះពុម្ព (Post-On) និងផ្សព្វផ្សាយ

ក្រុមប្រឹក្សាឃុំ និងអង្គភាពផ្តល់សេវានានា ត្រូវរៀបចំបិទផ្សាយព័ត៌មានទៅតាមទម្រង់កំណត់ណាមួយដោយសហការជាមួយអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ។

អ្នកពាក់ព័ន្ធនានានៅថ្នាក់ឃុំ និងថ្នាក់ស្រុក ត្រូវទទួលខុសត្រូវ ក្នុងការបង្កើតមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានាដូចជា ក្តារព័ត៌មាន របាយការណ៍ និងខិត្តប័ណ្ណ ដើម្បីផ្សព្វផ្សាយអំពីកញ្ចប់ព័ត៌មានទាំងនោះ។ អង្គការសង្គមស៊ីវិលត្រូវជួយរៀបចំកិច្ចពិភាក្សានៅថ្នាក់មូលដ្ឋាន ដើម្បីពិនិត្យផ្ទៀតផ្ទាត់ឡើងវិញ និងបញ្ជាក់ពីភាពសុក្រឹត្យរបស់ព័ត៌មានដែលបានផ្សព្វផ្សាយ។ អង្គការសង្គមស៊ីវិលត្រូវជួយបង្កើតឯកសារមេរៀននានា និងជួយលើកកម្ពស់ការយល់ដឹង ព្រមទាំងចុះតាមតំបន់គោលដៅ ដើម្បីផ្សព្វផ្សាយព័ត៌មាន។

## ២.២.ការបើកចំហព័ត៌មានថវិកា

លទ្ធផលរំពឹងទុកដែលទាក់ទងនឹងការបើកចំហព័ត៌មានថវិកា អាចសម្រេចបានតាមរយៈការអនុវត្តសកម្មភាពសំខាន់ៗចំនួនពីរ៖

### សកម្មភាព ២.២.១ ប្រមូល ពិនិត្យឡើងវិញ និងចងក្រងព័ត៌មានអំពីថវិកា

ការបើកចំហព័ត៌មានថវិកា និងការរៀបចំកញ្ចប់ព័ត៌មាន គឺជាកិច្ចការដ៏ចម្បងមួយនៃផែនការយុទ្ធសាស្រ្តស្តីពីការងារគណនេយ្យភាពសង្គម។ ការប្រមូលព័ត៌មានទាក់ទងនឹងថវិកាមានលក្ខណៈខុសគ្នាពីអង្គភាពមួយទៅអង្គភាពមួយទៀត។ ជាទូទៅនៅសាលាឃុំ និងសាលារៀនមានការយល់ដឹងច្រើនអំពីថវិកា និងចំណាត់ថ្នាក់ថវិកា ដូច្នេះគេអាចធ្វើផែនការប៉ាន់ស្មាន និងគ្រប់គ្រងការចំណាយបាន។ ព័ត៌មានថវិកាដែលត្រូវបង្ហាញត្រូវមានតួលេខថវិកាបដិភាគរបស់សហគមន៍ ជំនួយថវិកាផ្សេងៗដែលសាលារៀនបានទទួល និងថវិកាគ្រោងនឹងទទួល (ដូចជាជំនួយហិរញ្ញប្បទានរបស់ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់ប្រទេសស៊ុយអែត(Sida) និងដៃគូអភិវឌ្ឍន៍នានា)។ ចំណែកឯព័ត៌មានថវិការបស់មណ្ឌលសុខភាពនៅមានលក្ខណៈស្មុគស្មាញ និងពិបាកធ្វើបច្ចុប្បន្នភាព ហេតុនេះ គួរស្រង់ទិន្នន័យថវិកាពីឆ្នាំមុនមកបិទផ្សាយ។

[8] មានទិន្នន័យជាច្រើនដែលមានស្រាប់ តែទិន្នន័យទាំងនោះភាគច្រើន គឺសម្រាប់តែធ្វើការរាយការណ៍ទៅថ្នាក់ជាតិតែប៉ុណ្ណោះ និងមិនងាយស្រួលក្នុងការស្វែងរកយកមកប្រើប្រាស់នៅកម្រិតមូលដ្ឋានឡើយ ហើយក៏មានព័ត៌មានជាច្រើនទៀតដែលមិនមានអត្ថប្រយោជន៍សម្រាប់ក្រុមប្រឹក្សា និងប្រជាពលរដ្ឋទូទៅនោះទេ។ ជាទូទៅ មិនមានការរៀបចំឬប្រមូលផ្តុំ ទិន្នន័យនៅថ្នាក់មូលដ្ឋានទេ ។ ការប្រមូលទិន្នន័យហាក់ផ្តោតតែនៅថ្នាក់ខេត្តប៉ុណ្ណោះ មានន័យថាការធ្វើវិមជ្ឈការក្នុងផ្នែកគ្រប់គ្រងនិងប្រមូលទិន្នន័យ មិនទាន់បានអនុវត្តឲ្យបានពេញលេញនៅថ្នាក់ស្រុក។ ទម្រង់ដែលមានស្រាប់ទាំងនោះ មិនអាចឱ្យអ្នកប្រើប្រាស់យកទៅធ្វើការប្រៀបធៀបឬធ្វើការពន្យល់បង្ហាញឱ្យងាយយល់បានឡើយ។

### សកម្មភាព ២.២.២ ការបង្ហាញ និងបិទផ្សាយព័ត៌មានថវិកាដែលមានលក្ខណៈសាមញ្ញ

ព័ត៌មានថវិកាដែលមានលក្ខណៈសាមញ្ញនឹងត្រូវរៀបចំដាក់បញ្ចូលនៅក្នុងកញ្ចប់ព័ត៌មាន និងបិទផ្សាយនៅតាមសាលាឃុំ សាលាបឋមសិក្សា មណ្ឌលសុខភាព ឬសាលាស្រុក ទៅតាមការណែនាំ។ សាលាឃុំ សាលាបឋមសិក្សា និងមណ្ឌលសុខភាព ត្រូវអនុញ្ញាតឱ្យសហគមន៍មើលព័ត៌មានថវិការបស់ខ្លួន។ ការអនុវត្តសកម្មភាព ២.២.២គឺតម្រូវឱ្យ បង្កើតទម្រង់បែបបទនៃការផ្តល់ព័ត៌មានជាលក្ខណៈសាកល្បងមួយជួយគាំទ្រឱ្យមានការបង្ហាញ និងបិទផ្សាយព័ត៌មានអំពីថវិកាដែលមានលក្ខណៈជាប្រព័ន្ធ ជាពិសេសព័ត៌មានថវិការបស់សាលាឃុំ មណ្ឌលសុខភាព និងសាលារៀន។

## ២.៣.ការរៀបចំប្រព័ន្ធ លិខិតបទដ្ឋាន និងការអនុវត្តតាមគោលការណ៍ណែនាំ

ការអនុវត្តក្នុងផ្នែកនេះ គឺដើម្បីបង្កើតឱ្យមានជាប្រព័ន្ធ សេចក្តីណែនាំ លិខិតបទដ្ឋាននានា និងការអនុវត្តតាមគោលការណ៍ណែនាំ ដើម្បី ជំរុញឱ្យភាគីពាក់ព័ន្ធខិតខំបង្កភាពងាយស្រួលដល់ការទទួលបានព័ត៌មាននានា និងព័ត៌មានថវិកាព្រមទាំងរៀបចំឱ្យមានជានីតិវិធីតាមដានត្រួតពិនិត្យ។ ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកនេះ ត្រូវអនុវត្តសកម្មភាពចំនួន៤ ដូចខាងក្រោម៖

### សកម្មភាព ២.៣.១: ការរៀបចំបង្កើត និងដាក់ឱ្យអនុវត្តនូវវិធីសាស្ត្រគ្រប់គ្រងទិន្នន័យនៅថ្នាក់ស្រុក

ព័ត៌មានផ្សេងៗដែលប្រមូលបាន នឹងត្រូវរៀបចំចងក្រង និងរក្សាទុកនៅថ្នាក់ស្រុក ដែលអនុញ្ញាតឱ្យមានការប្រៀបធៀបព័ត៌មាន និងភាពងាយទទួលបានព័ត៌មាន។ រដ្ឋបាលស្រុកនឹងប្រមូលទិន្នន័យ រៀបចំផ្ទាំងព័ត៌មាន (Post-On) ហើយផ្តល់ព័ត៌មានទាំងនោះទៅឱ្យក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ ដើម្បីធ្វើការវិភាគ និងប្រើប្រាស់ព័ត៌មានទាំងនោះ។ បច្ចុប្បន្ន ការគ្រប់គ្រង ការចាត់ចែង និងការប្រមូលទិន្នន័យ បញ្ចូលក្នុងប្រព័ន្ធមួយចំនួន ដូចជាទិន្នន័យព័ត៌មានគម្រោង(PID) និងទិន្នន័យមូលដ្ឋានឃុំ (CDB) ធ្វើឡើងនៅថ្នាក់ខេត្តមិនមែននៅថ្នាក់ស្រុកឡើយ។ សកម្មភាព នេះនឹងគាំទ្រដល់ការបញ្ចូលទិន្នន័យ ផ្តល់សិទ្ធិគ្រប់គ្រង និងការថែរក្សាទុកទិន្នន័យនៅថ្នាក់ស្រុក ដែលអាចជួយជំរុញឱ្យការទទួលព័ត៌មាននៅថ្នាក់ឃុំ និងថ្នាក់ស្រុកកាន់តែឆាប់រហ័សជាងមុន។ ជំហានដំបូងនេះចាំបាច់តម្រូវឲ្យមានការត្រួតពិនិត្យផ្នែកបច្ចេកទេសទៅលើដំណើរការនៃការប្រមូលទិន្នន័យ ហើយត្រូវធ្វើការកែប្រែសេចក្តីណែនាំដែលពាក់ព័ន្ធមួយចំនួនផងដែរ។ ការកែសម្រួលការគ្រប់គ្រងទិន្នន័យ គឺជាកិច្ចការដ៏សំខាន់មួយ ដែលជួយក្នុងការពង្រឹងភាពជាម្ចាស់ និងជំរុញដល់ការប្រើប្រាស់ទិន្នន័យ។ សកម្មភាពដែលត្រូវអនុវត្តផ្សេងទៀតរួមមាន ការរៀបចំយុទ្ធសាស្ត្ររក្សាទុកព័ត៌មាន និងការពិចារណាបង្កើតឱ្យមានជាគេហទំព័រ ឬប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងនៅថ្នាក់ស្រុក[9]។

### សកម្មភាព ២.៣.២: ការរៀបចំបង្កើត និងដាក់ឱ្យអនុវត្តលិខិតបទដ្ឋាន និងសេចក្តីណែនាំនានាសម្រាប់ការបើកចំហព័ត៌មានថវិកា និងព័ត៌មាននានានៅមូលដ្ឋាន

[9] សកម្មភាពនេះអាចអនុវត្តបានភាគច្រើនតែនៅក្នុងទីប្រជុំជន ជាពិសេសការអនុវត្តដោយការិយាល័យប្រជាពលរដ្ឋទាំង៣៥ និងការិយាល័យព័ត៌មានសម្រាប់ប្រជាពលរដ្ឋ(CICs)ដែលទើបបង្កើតថ្មីទាំង៦ ដែលបានសាកល្បងនៅក្នុងការិយាល័យច្រកចេញចូលតែមួយ។ ការរៀបរាប់ផ្នែកនេះ សមស្របសម្រាប់ការិយាល័យព័ត៌មានសម្រាប់ប្រជាពលរដ្ឋ(CICs)។

លិខិតបទដ្ឋាន និងសេចក្តីណែនាំនានា ដែលត្រូវបង្កើតឡើង ត្រូវបានចែងអំពីទំហំការងារ និងខ្លឹមសារនៃព័ត៌មាននានា ព័ត៌មានថវិកា និងការបើកទូលាយព័ត៌មាននោះជាសាធារណៈ ព្រមទាំងមធ្យោបាយក្នុងការធ្វើឱ្យការទទួលព័ត៌មានមានលក្ខណៈកាន់តែប្រសើរឡើង។ សកម្មភាព ២.៣.២ នឹងជួយជំរុញឱ្យគ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិ មណ្ឌលសុខភាព និងសាលារៀនមានកាតព្វកិច្ច និងមានមធ្យោបាយក្នុងការផ្តល់ព័ត៌មានទៅឱ្យប្រជាពលរដ្ឋ។ មន្ត្រីអនុវត្តនឹងទទួលបាននូវការបណ្តុះបណ្តាល ការអនុវត្តឱ្យមានការបើកចំហព័ត៌មាន (ឧទាហរណ៍តួនាទីក្នុងការធ្វើឱ្យមានភាពងាយស្រួលក្នុងការទទួលបានព័ត៌មានក៏ដូចជាវិធីសាស្ត្រក្នុងការផ្តល់សេវាទៅប្រជាពលរដ្ឋផងដែរ)។

**សកម្មភាព ២.៣.៣ ការបង្កើត និងដាក់ឱ្យអនុវត្ត នូវប្រព័ន្ធត្រួតពិនិត្យ និងការអនុវត្តតាមគោលការណ៍ណែនាំ សម្រាប់ការបើកចំហព័ត៌មានថវិកានៅមូលដ្ឋាន**

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវការប្រកាសស្តីពីការផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋ ហេតុនេះក្រសួងមហាផ្ទៃនឹងរៀបចំប្រកាសនោះ ដោយកំណត់អំពីល័ក្ខខ័ណ្ឌការលើកទឹកចិត្ត និងទណ្ឌកម្មចាំបាច់នានា ដើម្បីជំរុញឱ្យមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តតាម[10]។ ចំពោះដំណើរការនៃការត្រួតពិនិត្យវិញ[11] ចាំបាច់ត្រូវបង្កើត និងធ្វើឱ្យក្លាយជាប្រព័ន្ធមានលក្ខណៈជាផ្លូវការ (បន្ថែមទៅលើយន្តការត្រួតពិនិត្យ និងការផ្តល់យោបល់របស់អង្គការសង្គមស៊ីវិល)។ ឧទាហរណ៍ត្រូវចាប់ផ្តើមពីការប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់ និងសៀវភៅណែនាំ ហើយដល់ឆ្នាំ២០១៦ទើបរៀបចំដំណើរការនោះឱ្យទៅជាដំណើរការធ្វើអធិការកិច្ចទៅលើការអនុវត្តតាមគោលការណ៍ណែនាំ ដែលមានលក្ខណៈកាន់តែឯករាជ្យជាផ្លូវការនិងលក្ខណៈជាប្រព័ន្ធ(រៀបចំឡើងនៅពេលអនុវត្តផអ៣ទី២)។ ការធ្វើអធិការកិច្ចត្រូវវាយតម្លៃទៅលើ ១).តើព័ត៌មានដែលបានផ្តល់ស្របតាមគោលការណ៍ណែនាំដែរឬទេ? ២).តើព័ត៌មានដែលបានផ្តល់មានភាពត្រឹមត្រូវដែរឬទេ[12]។ សកម្មភាពទាំងនោះមានរួមបញ្ចូលទាំងការរៀបចំបង្កើត និងការអនុវត្តនីតិវិធីសម្រាប់ត្រួតពិនិត្យរដ្ឋបាល និងអង្គការសង្គមស៊ីវិលដើម្បីធានាថាព័ត៌មាននិងរបាយការណ៍នានាដែលបានផ្តល់ដោយសាលាឃុំ មណ្ឌលសុខភាព សាលារៀន មានភាពត្រឹមត្រូវ មានភស្តុតាងជាក់ស្តែងដែលជាផ្នែកមួយនៃការពង្រឹងគោលការណ៍ណែនាំក្នុងការផ្តល់នូវព័ត៌មាន និងទម្រង់បែបបទក្នុងការធ្វើរបាយការណ៍។ សកម្មភាពត្រួតពិនិត្យគឺដើម្បីឱ្យដឹងថាតើរដ្ឋបាលថ្នាក់ក្រោមជាតិបានប្រមូលចងក្រងទិន្នន័យបានត្រឹមត្រូវដែរឬទេ? កិច្ចការនេះចាំបាច់ត្រូវធ្វើការពិភាក្សាបន្ថែមទៀត ថាតើត្រូវចាប់ផ្តើមឡើងដូចម្តេច? ព្រមទាំងពិភាក្សាអំពីរបៀបនៃធ្វើការតាមដានត្រួតពិនិត្យនៅពេលដែលប្រព័ន្ធត្រួតពិនិត្យមិនទាន់បានបង្កើតឡើងនៅឡើយ។

**សកម្មភាព ២.៣.៤ រៀបចំបង្កើត និងដាក់ឱ្យអនុវត្តនូវដំណើរការត្រួតពិនិត្យរបស់អង្គការសង្គមស៊ីវិល ចំពោះការបើកចំហព័ត៌មានស្តីពីថវិកានៅមូលដ្ឋាន**

ការបង្កើតឱ្យមានយន្តការត្រួតពិនិត្យតាមដាន ដើម្បីឱ្យដឹងថាតើគោលការណ៍ណែនាំស្តីពីការបើកចំហព័ត៌មានថវិកាត្រូវបានអនុវត្តនៅមូលដ្ឋានដែរឬទេ។ យន្តការនេះត្រូវមានការចូលរួមពីបណ្តាអង្គការដៃគូអនុវត្តដែលនឹងជួយផ្តល់ព័ត៌មានត្រឡប់ជាទៀងទាត់ អំពីវឌ្ឍនភាពដែលសម្រេចបាន។ សកម្មភាព២.៣.៤គឺជារៀបចំ

---

[10] ទោះបីជាវាស្ថិតនៅក្រោមការទទួលខុសត្រូវចម្បងរបស់ក្រសួងមហាផ្ទៃក៏ដោយ ក៏ក្រសួងអាចផ្ទេរការទទួលខុសត្រូវ (ជាការផ្ទេរមុខងារទៅឲ្យថ្នាក់ខេត្ត) ឬអាចធ្វើអធិការកិច្ចរួមគ្នាជាមួយអ្នកចូលរួមផ្នែកឯកជន ឬអង្គការសង្គមស៊ីវិល។

[11] ដំណើរការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋនឹងមានរៀបរាប់លំអិតបន្ថែមនៅក្នុងសមាសភាគទី២។

[12]ប្រការសំខាន់ គឺត្រូវបញ្ចូលអង្គការសង្គមស៊ីវិលនៅក្នុងការអនុវត្តតាមការត្រួតពិនិត្យ(និងឱ្យបានស្របទៅតាមគោលការណ៍នៃគណនេយ្យភាពសង្គម)។

បង្កើតឱ្យមានប្រព័ន្ធត្រួតពិនិត្យ និងការធ្វើសេចក្តីរាយការណ៍ពីបណ្តាអង្គការដៃគូអនុវត្ត ចំពោះការអនុវត្តតាមគោលការណ៍នានាពាក់ព័ន្ធការផ្សព្វផ្សាយព័ត៌មានសាធារណៈ និងព័ត៌មានថវិកានៅមូលដ្ឋានសាលាឃុំ មណ្ឌលសុខភាព និងសាលារៀន (អង្គការដៃគូអនុវត្ត អាចបញ្ចូលទៅក្នុងសកម្មភាពរបស់ខ្លួនទាក់ទងនឹងការងារផ្តល់គោលការណ៍ណែនាំ និងការកសាងសមត្ថភាពផងដែរ)។ គ.ជ.អ.ប នឹងរៀបចំ ផ្សព្វផ្សាយអំពីគោលការណ៍ណែនាំដើម្បីជំរុញឱ្យមានការឆ្លើយតបចំពោះការត្រួតពិនិត្យរបស់អង្គការដៃគូអនុវត្ត។

## ២.៤. ការលើកកម្ពស់ការយល់ដឹង និងការពង្រឹងសមត្ថភាព

លទ្ធផលរំពឹងទុកផ្នែកនេះ មានបំណងលើកទឹកចិត្តឲ្យប្រជាពលរដ្ឋចង់ដឹងព័ត៌មានផ្សេងៗ ព្រមទាំងព័ត៌មានថវិកា ដើម្បីឱ្យតួអង្គទាំងអស់យល់ដឹងអំពីព័ត៌មានដែលទទួលបាន អំពីសិទ្ធិរបស់ប្រជាពលរដ្ឋ ក៏ដូចជាទីកន្លែង របៀបក្នុងការស្វែងរក និងប្រើប្រាស់ព័ត៌មានទាំងនោះព្រមទាំងកសាងសមត្ថភាពរបស់ប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋានឱ្យចេះប្រើប្រាស់ព័ត៌មាននានា និងព័ត៌មានថវិកាប្រកបដោយប្រសិទ្ធភាព។ ការរៀបចំយុទ្ធនាការលើកកម្ពស់ការយល់ដឹងនៅមូលដ្ឋាន ដែលត្រូវធ្វើស្របគ្នាជាមួយនឹងការផ្សព្វផ្សាយផ្ទាំងពត៌មាន ទាំងនៅថ្នាក់ស្រុក ថ្នាក់ឃុំ និងភូមិ ក៏ដូចជាការលើកកម្ពស់ការយល់ដឹងការបង្កើតជំនាញផ្សេងៗ ការផ្សព្វផ្សាយវិភាគព័ត៌មាននានា និងព័ត៌មានថវិកា។ សកម្មភាពទាំងនេះត្រូវផ្តោតជាពិសេសទៅលើស្ត្រី យុវវ័យ កុមារ ជនពិការ ជនជាតិដើម និងជនក្រីក្រ ហើយត្រូវធ្វើយ៉ាងណាឱ្យព័ត៌មានទាំងអស់ បានទៅដល់ក្រុមគោលដៅទាំងនោះ។ ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកផ្នែកនេះ ចាំបាច់ ត្រូវអនុវត្តសកម្មភាពចំនួនបី ដូចខាងក្រោម៖

### សកម្មភាព ២.៤.១ បណ្តុះបណ្តាលសមត្ថភាពអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍អំពីគណនេយ្យភាពសង្គម ព័ត៌មាននានា និងព័ត៌មានថវិកា

អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍គឺជាតួអង្គដ៏សំខាន់ក្នុងការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងអំពីព័ត៌មាននានា និងព័ត៌មានថវិកា។ ការអនុវត្តសកម្មភាព២.៤.១ ពាក់ព័ន្ធដល់ការពន្យល់អំពីព័ត៌មានជាមូលដ្ឋានស្តីពីយុទ្ធសាស្ត្រគណនេយ្យភាពសង្គម និងគោលការណ៍នានាព្រមទាំងការបណ្តុះបណ្តាល និងផ្តល់យោបល់ដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ឱ្យយល់អំពីសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានព័ត៌មានអំពីសារៈសំខាន់នៃព័ត៌មានទាំងនោះ។ អ្នកសម្របសម្រួលត្រូវរៀនអំពីរបៀបវិភាគព័ត៌មានដែលមានក្នុងកញ្ចប់ព័ត៌មាន របៀបផ្សព្វផ្សាយព័ត៌មានទៅប្រជាពលរដ្ឋ និងជួយពន្យល់ប្រជាពលរដ្ឋឱ្យបានយល់ដឹងពីការប្រើប្រាស់ព័ត៌មានទាំងនោះ។ អាស្រ័យដូចបានរៀបរាប់ខាងលើ ទើបការរៀបចំកញ្ចប់ព័ត៌មាន មានបញ្ចូលទាំងព័ត៌មានថវិកាសាធារណៈ និងការចំណាយថវិកានេះ។ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ នឹងទទួលបានការបណ្តុះបណ្តាលអំពីថវិកាសាធារណៈ ហើយធ្វើការអប់រំបន្តដល់ប្រជាពលរដ្ឋ សំដៅជួយពួកគាត់អាចទទួលបាន និងប្រើប្រាស់ព័ត៌មានថវិកាមកធ្វើជាមូលដ្ឋានសម្រាប់ពិភាក្សាជាមួយមន្ត្រីមូលដ្ឋានទាក់ទងនឹងបញ្ហាថវិកាសាធារណៈ។ សកម្មភាពទាំងនេះត្រូវផ្តោតការយកចិត្តទុកដាក់ដោយឡែកចំពោះស្ត្រី យុវវ័យ កុមារ ជនជាតិដើម ជនពិការ និងសមាជិកផ្សេងៗទៀតរបស់សហគមន៍ដែលមិនសូវទទួលបានឱកាសចូលរួមក្នុងការពិភាក្សាពីបញ្ហាថវិកា និងត្រូវពន្យល់ដល់ពួកគេអំពីសារៈសំខាន់នៃការយល់ដឹងពីព័ត៌មាន និងថវិកានេះ។

**សកម្មភាព ២.៤.២ ការបណ្តុះបណ្តាលសមាជិកក្រុមប្រឹក្សា មន្រ្តីមូលដ្ឋាន និងអ្នកផ្តល់សេវានៅមូលដ្ឋាន អំពីព័ត៌មាននានា និងព័ត៌មានថវិកា**

ក្រសួង ស្ថាប័ន អង្គភាពនៅមូលដ្ឋានមានតួនាទីយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយ និងជួយឱ្យប្រជាពលរដ្ឋមានការយល់ដឹងពីកញ្ចប់ព័ត៌មាន និងសារៈសំខាន់នៃតម្លាភាពហិរញ្ញវត្ថុសាធារណៈ។ នៅក្នុងសកម្មភាពនេះ សមាជិកក្រុមប្រឹក្សា មន្រ្តីនានា និងអ្នកផ្តល់សេវានៅមូលដ្ឋាននឹងទទួលបានការបណ្តុះបណ្តាល និងការគាំទ្រដើម្បីយល់ដឹងអំពីព័ត៌មាននៃចំណូល និងចំណាយថវិកា និងអំពីរបៀបគាំទ្រឱ្យប្រជាពលរដ្ឋទូទៅមានការយល់ដឹងពីព័ត៌មាននានា និងព័ត៌មានថវិកា។

**សកម្មភាព ២.៤.៣ ការលើកកម្ពស់ ការយល់ដឹងរបស់អង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ សហគមន៍នានា និងប្រជាពលរដ្ឋទាក់ទងនឹងព័ត៌មាននានា និងព័ត៌មានថវិកា**

កញ្ចប់ព័ត៌មាន និងព័ត៌មានថវិកានឹងត្រូវចែកជូនទៅស្ថាប័ន អង្គភាពពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការដៃគូអនុវត្ត ។ កញ្ចប់ព័ត៌មាននេះត្រូវរៀបចំតាមទម្រង់ថ្មីដែលងាយស្រួលមើល ទទួលបានព័ត៌មានឆាប់រហ័ស និងងាយស្រួលយល់ ហើយអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងសមាជិកក្រុមប្រឹក្សានឹងប្រើប្រាស់សម្រាប់ជួយដល់ប្រជាពលរដ្ឋ ឱ្យយល់ពីសារប្រយោជន៍នៃព័ត៌មានទាក់ទងនឹងសិទ្ធិ ស្តង់ដានៃការបំពេញការងារ និងថវិកា។ ការពង្រឹងសមត្ថភាពយល់ដឹងជាមូលដ្ឋានអំពីថវិកា គឺជាសកម្មភាពចម្បងនៃផ្នែកនេះ។ ក្រុមប្រឹក្សាឃុំ និងអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ ត្រូវធ្វើការជាមួយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ត្រូវរៀបចំយុទ្ធនាការ លើកកម្ពស់ការយល់ដឹង ការប្រជុំនៅតាមសហគមន៍ ការចេញជាសេចក្តីប្រកាសព័ត៌មាន ការផ្តល់កិច្ចសម្ភាសន៍ដល់អ្នកសារព័ត៌មាន ការរៀបចំឱ្យមានការជួបជុំស្តាប់វិទ្យុ និងការមើលទូរទស្សន៍ជាដើម ដើម្បីលើកទឹកចិត្តដល់ប្រជាពលរដ្ឋឱ្យចេះធ្វើការឆ្លុះបញ្ចាំង និងពិភាក្សារួមគ្នាអំពីព័ត៌មាននានា ដែលមាននៅក្នុងកញ្ចប់ព័ត៌មាន និងព័ត៌មានថវិកា។

**ដូច្នេះដើម្បីសម្រេចលទ្ធផលនៃសមាសភាគនេះ គឺទាមទារឲ្យផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការបំពេញតួនាទីដូចខាងក្រោម៖**

- **ផ្នែកផ្គត់ផ្គង់៖** រហូតដល់ឆ្នាំ២០១៨ ឃុំទាំងអស់នៅក្នុងស្រុកទាំង១២០ ត្រូវបើកចំហព័ត៌មាន រួមមានព័ត៌មានស្តីពី សិទ្ធិ ស្តង់ដា ការបំពេញការងារ និងព័ត៌មានថវិការបស់គ្រប់សាលាបឋមសិក្សា មណ្ឌលសុខភាព និងសាលាឃុំ។ ការតាមដានត្រួតពិនិត្យនឹងត្រូវអនុវត្តជាប្រចាំ ដើម្បីធានាសុក្រឹត្យភាពរបស់ទិន្នន័យ និងភាពទៀងទាត់ក្នុងការអនុវត្តការងារ។ ការប្រមូលទិន្នន័យត្រូវធ្វើការកែសម្រួលឱ្យកាន់តែប្រសើរឡើងនៅថ្នាក់ស្រុក។
- **ផ្នែកតម្រូវការ៖** ការលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋនឹងត្រូវធ្វើឡើងជាលក្ខណៈប្រព័ន្ធ និងមានការពង្រឹងសមត្ថភាពស្របតាមតម្រូវការចាំបាច់។ ការយល់ដឹងអំពីថវិកានឹងក្លាយជាទុនសម្រាប់ឱ្យប្រជាពលរដ្ឋចូលរួមចំណែកពង្រឹងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាអ្នកផ្តល់សេវានៅមូលដ្ឋាន។ ប្រជាពលរដ្ឋ និងអង្គការដៃគូអនុវត្ត នឹងប្រើប្រាស់ព័ត៌មានទាំងនេះសម្រាប់ការងារតាមដានត្រួតពិនិត្យ ដូចបានរៀបរាប់នៅក្នុងសមាសភាគទី២។

**តារាងទី២៖ សង្ខេបអំពីសមាសភាគស្ដីពីការទទួលបានព័ត៌មាននានា និងព័ត៌មានថវិកា**

| ផ្នែក | ការពិពណ៌នា |
|---|---|
| គោលបំណង | • លើកកម្ពស់តម្លាភាព ការទទួលបាន និងការទាមទារព័ត៌មានសាធារណៈស្ដីពីគោលនយោបាយ ស្តង់ដារ ការងារថវិកា ការចំណាយ និងការបំពេញការងារ<br>• លើកកម្ពស់សមត្ថភាពយល់ដឹងរបស់ភាគីពាក់ព័ន្ធអំពីថវិកា និងពង្រឹងឱ្យមានការសាកសួរអំពីការងារថវិកា ។ |
| សមិទ្ធផល និង សូចនាករ | **បង្កបរិយាកាសប្រកបដោយនិរន្តរភាពក្នុងការបើកចំហព័ត៌មានមូលដ្ឋាននិងថវិកា**<br>• ប្រព័ន្ធតាមដានត្រួតពិនិត្យ និងក្របខ័ណ្ឌបទបញ្ញត្តិពេញលេញសម្រាប់ការយល់ដឹងពីអ្នកពាក់ព័ន្ធក្នុងមូលដ្ឋាន(បទបញ្ញត្តិ និងការអនុវត្ត)<br>**បើកចំហថវិកាមូលដ្ឋាន**<br>• រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្ដល់សេវាមូលដ្ឋានត្រូវបិទផ្សាយថវិកាតាមទម្រង់ និងនៅទីតាំងដែលបានព្រមព្រៀងគ្នា<br>• សហគមន៍ ឬប្រជាពលរដ្ឋទទួលបានព័ត៌មានថវិកាក្នុងដំណើការត្រួតពិនិត្យតាមដាន<br>**ការបើកចំហ និងទទួលព័ត៌មាន**<br>• ព័ត៌មានជាក់លាក់ផ្សេងៗ (គោលនយោបាយ សិទ្ធិ ការបំពេញការងារ) ដែលមាន នឹងត្រូវបានប្រើប្រាស់សម្រាប់ដំណើរការត្រួតពិនិត្យតាមដាន<br>• ប្រជាពលរដ្ឋ យល់ដឹងអំពីខ្លឹមសារព័ត៌មាន ការប្រើប្រាស់ព័ត៌មាន និងអាចរកបាននូវព័ត៌មានទាំងនោះបាន។<br>**ព័ត៌មានអំពីការប្រើប្រាស់ថវិកា និងព័ត៌មាននានា ជួយធ្វើឱ្យប្រសើរឡើងនូវការបំពេញការងារ**<br>• រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលបន្ទុកធ្វើការបំពេញការងារកាន់ប្រសើរឡើង និងពង្រឹងការយល់ដឹងនានា ដែលនេះគឺជាការតាំងចិត្តរបស់រាជរដ្ឋាភិបាល។ |
| លទ្ធផលរំពឹងទុក | **២.១.ព័ត៌មានអំពីការអនុវត្តការងារ**<br>**សកម្មភាព ២.១.១** ការប្រមូលទិន្នន័យ និងពិនិត្យផ្ទៀងផ្ទាត់ ដើម្បីចងក្រងជាកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ<br>**សកម្មភាព ២.១.២** ការបោះពុម្ព និងផ្សព្វផ្សាយ កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ<br>**២.២. ការបើកចំហព័ត៌មានថវិកា**<br>**សកម្មភាព ២.២.១** ប្រមូល ពិនិត្យឡើងវិញ និងចងក្រងព័ត៌មានអំពីថវិកា<br>**សកម្មភាព ២.២.២** ការបង្ហាញ និងការបិទផ្សាយព័ត៌មានថវិកាដែលមានលក្ខណៈសាមញ្ញ<br>**២.៣.ការរៀបចំប្រព័ន្ធ លិខិតបទដ្ឋាន និងការអនុវត្តតាមគោលការណ៍ណែនាំ**<br>**សកម្មភាព ២.៣.១** ការរៀបចំបង្កើត និងដាក់ឱ្យអនុវត្ត វិធីសាស្ត្រគ្រប់គ្រងទិន្នន័យនៅថ្នាក់ស្រុក<br>**សកម្មភាព ២.៣.២** ការរៀបចំបង្កើត និងដាក់ឱ្យអនុវត្ត លិខិតបទដ្ឋាន និងសេចក្ដីណែនាំនានាសម្រាប់ការបើកចំហព័ត៌មានថវិកា និងព័ត៌មាននានានៅមូលដ្ឋាន<br>**សកម្មភាព ២.៣.៣** ការបង្កើត និងដាក់ឱ្យអនុវត្ត នូវប្រព័ន្ធត្រួតពិនិត្យ និងការអនុវត្តតាម |

| | |
|---|---|
| | គោលការណ៍ណែនាំសម្រាប់ការបើកចំហព័ត៌មានថវិកានៅមូលដ្ឋាន<br>**សកម្មភាព ២.៣.៤** រៀបចំបង្កើត និងដាក់ឱ្យអនុវត្តនូវដំណើរការត្រួតពិនិត្យរបស់អង្គការសង្គមស៊ីវិល ចំពោះការបើកចំហព័ត៌មានស្តីពីថវិកានៅមូលដ្ឋាន<br>**២.៤. ការលើកកម្ពស់ការយល់ដឹង និងការពង្រឹងសមត្ថភាព**<br>**សកម្មភាព ២.៤.១** បណ្តុះបណ្តាលសមត្ថភាពអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ អំពីគណនេយ្យភាពសង្គម ព័ត៌មាននានា និងព័ត៌មានថវិកា<br>**សកម្មភាព ២.៤.២** ការបណ្តុះបណ្តាល សមាជិកក្រុមប្រឹក្សា មន្ត្រីមូលដ្ឋាន និងអ្នកផ្តល់សេវានៅមូលដ្ឋាន អំពី ព័ត៌មាននានា និងព័ត៌មានថវិកា<br>**សកម្មភាព ២.៤.៣** ការលើកកម្ពស់ ការយល់ដឹងរបស់អង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ សហគមន៍នានា និងប្រជាពលរដ្ឋទាក់ទងនឹងព័ត៌មាននានា និងព័ត៌មានថវិកា |

## ៣.សមាសភាគទី២÷ ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ

**សមាសភាគនេះមានគោលបំណង** ពង្រឹងតួនាទីរបស់ប្រជាពលរដ្ឋ អ្នកប្រើប្រាស់សេវា និងសមាជិកក្រុមប្រឹក្សាឃុំក្នុងការត្រួតពិនិត្យតាមដាន និងទាមទារគណនេយ្យភាពពីអ្នកផ្តល់សេវានៅថ្នាក់មូលដ្ឋាន ដោយមានការណែនាំឱ្យមានការសម្របសម្រួល ការត្រួតពិនិត្យតាមដាន និងការធ្វើរបាយការណ៍ដោយប្រជាពលរដ្ឋ និងសហគមន៍ ស្តីពីការផ្តល់សវារបស់រដ្ឋបាលឃុំ មណ្ឌលសុខភាព និងសាលាបឋមសិក្សា។

កន្លងមក ការចូលរួមរបស់ប្រជាពលរដ្ឋបានធ្វើឡើងតែតាមរយៈដំណើរការកសាងផែនការអភិវឌ្ឍ ឬកម្មវិធីវិនិយោគឃុំប៉ុណ្ណោះ។ ដោយសារតែដំណើរការនៃការកសាងផែនការ គឺជាផ្នែកមួយដ៏សំខាន់នៃកិច្ចការងាររបស់ឃុំ ដូចនេះផ.**អ.គ.ស** នឹងជួយបំពេញបន្ថែមនូវសកម្មភាពសំខាន់ៗមួយចំនួន ទៅក្នុងដំណើរការនេះដែលជួយលើកកម្ពស់សិទ្ធិអំណាចរបស់ប្រជាពលរដ្ឋ។ យន្តការដែលបានអនុវត្តកន្លងមកមានលក្ខណៈផ្លូវការ ដែលធ្វើឱ្យប្រជាពលរដ្ឋមានការចូលរួមតិចតួច និងមិនសូវសកម្ម។ ប៉ុន្តែផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គមបានផ្តោតលើសកម្មភាពតាមដានត្រួតពិនិត្យនៅសហគមន៍ ដែលក្នុងនោះប្រជាពលរដ្ឋអាចចូលរួមដោយសេរី និងដើរតួនាទីយ៉ាងសកម្មនិងលើកកម្ពស់សិទ្ធិអំណាចរបស់សមាជិកក្រុមប្រឹក្សា និងប្រជាពលរដ្ឋក្នុងការឆ្លុះបញ្ចាំង ពីការបំពេញការងារធៀបទៅនឹងស្តង់ដារ និងផ្តោតលើសកម្មភាពផ្សេងៗដែលអាចអនុវត្តដោយសហគមន៍ ក្រុមប្រឹក្សា អ្នកផ្តល់សេវា និងអង្គភាពជំនាញ ដើម្បីឱ្យការបំពេញការងារកាន់តែមានលក្ខណៈល្អប្រសើរ។ ការត្រួតពិនិត្យតាមដានលើការបំពេញការងារនឹងជួយលើកកម្ពស់សិទ្ធិអំណាចរបស់ប្រជាពលរដ្ឋតាមរយៈការទទួលបានព័ត៌មាន ដែលអាចឱ្យពួកគេចូលរួមចំណែកនៅក្នុងដំណើរការដែលមានស្រាប់ក្នុងការកសាងផែនការ។ ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋលើការបំពេញការងាររបស់អ្នកផ្តល់សេវា គឺជាកត្តាមួយដ៏សំខាន់ក្នុង ការលើកកម្ពស់សិទ្ធិអំណាចប្រជាពលរដ្ឋ។ ផ.អ.គ.សនឹងផ្តល់ដល់ប្រជាពលរដ្ឋនូវព័ត៌មានដែលមានលក្ខណៈអន្តរវិស័យបានច្បាស់លាស់ និងចូលរួមក្នុងដំណើរការត្រួតពិនិត្យវាយតម្លៃស៊ីជម្រៅទៅលើសេវាណាមួយដែលពួកគេគិតថាជាសេវាជាអាទិភាព។

**ដូច្នេះដើម្បីសម្រេចលទ្ធផលនៃសមាសភាគនេះ ទាមទារឲ្យផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការបំពេញតួនាទីដូចខាងក្រោម៖**

**ផ្នែកតម្រូវការ៖ សមាសភាគទី២នេះ បង្ហាញនូវដំណើរការសម្របសម្រួលឱ្យមានការចូលរួមក្នុងការត្រួតពិនិត្យតាមដានលើមុខងារ និងសេវាមួយចំនួន។** ដោយមានការគាំទ្រពីអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍នៅមូលដ្ឋានដែលបានទទួលការបណ្តុះបណ្តាល និងគាំទ្រពីអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ ដើម្បីទទួលបានព័ត៌មានអំពីស្តង់ដារ និងសូចនាករនៃការបំពេញការងារដូចមានបញ្ជាក់ក្នុងសមាសភាគទី១ ដែលក្នុងនោះ ប្រជាពលរដ្ឋនឹងធ្វើការវាយតម្លៃទៅលើការបំពេញការងាររបស់អ្នកផ្តល់សេវានៅមូលដ្ឋាន (មណ្ឌលសុខភាព សាលាបឋមសិក្សា និងសាលាឃុំ) និងចាត់អាទិភាពនៃបញ្ហាដែលជាកង្វល់ខ្លាំងបំផុត ។ ឧបករណ៍សម្រាប់ធ្វើការវាយតម្លៃដោយប្រជាពលរដ្ឋនេះ ហៅថា "**ប័ណ្ណដាក់ពិន្ទុ**"។ លទ្ធផលទទួលបានពីការវាយតម្លៃនេះនឹងត្រូវធ្វើការចែករំលែក និងពិភាក្សាគ្នាជាមួយសមាជិកក្រុមប្រឹក្សាឃុំ អ្នកផ្តល់សេវា និងមន្ត្រីនានាពីថ្នាក់ស្រុក តាមរយៈកិច្ចប្រជុំដែលមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ដែលហៅថា"**កិច្ចប្រជុំរួម**" ។ នៅក្នុងកិច្ចប្រជុំរួមគ្នានេះអ្នកចូលរួមទាំងអស់ត្រូវខិតខំរិះរកដំណោះស្រាយចំពោះបញ្ហាចោទនានា និងរៀបចំជាផែនការសកម្មភាពព្រមព្រៀងគ្នាមួយ ហៅថា"**ផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម**"។ ផែនការសកម្មភាពនេះនឹងត្រូវកំណត់ឡើងនូវសកម្មភាពមួយចំនួនដែលត្រូវ អនុវត្តដោយភាគីចំនួន៤គឺ៖

១. សហគមន៍

២. អ្នកផ្តល់សេវា

៣. ក្រុមប្រឹក្សាឃុំ

៤. រដ្ឋបាលស្រុក ការិយាល័យស្រុកប្រតិបត្តិ និងការិយាល័យអប់រំ យុវជន និងកីឡាស្រុក។

ដើម្បីលើកកម្ពស់គណនេយ្យភាព លទ្ធផលនៃការវាយតម្លៃ និងផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម ដែលបានគ្រោងឡើង ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនៅថ្នាក់ស្រុកនិងថ្នាក់ឃុំ ព្រមទាំងលើកយកទៅបង្ហាញនៅក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក។

**ផ្នែកផ្គត់ផ្គង់៖ សមាសភាគនេះ បានកំណត់នូវសកម្មភាពរបស់រដ្ឋាភិបាលក្នុងការបង្កើតឱ្យមានជានីតិវិធីដើម្បីគាំទ្រដល់សកម្មភាពត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋតាមសហគមន៍ (មតិព័ត៌មានត្រឡប់ និងការតាមដាននានា)**។ រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គភាពផ្តល់សេវា (រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងភ្នាក់ងារផ្តល់សេវាពាក់ព័ន្ធ) នឹងចូលរួមក្នុងកិច្ចប្រជុំរួមដើម្បីស្តាប់លទ្ធផលនៃការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ ដើម្បីរៀបចំ និងចាត់វិធានការឆ្លើយតបនានា។ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធានាឱ្យកិច្ចប្រជុំរួមនេះ ប្រព្រឹត្តទៅក្នុងបរិយាកាសល្អ និងមានអ្នកសម្របសម្រួលដែលមានអព្យាក្រឹត្យភាពផងដែរ។ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវពង្រឹងទំនាក់ទំនងការងារ និងការប្រាស្រ័យទាក់ទងរវាងប្រជាពលរដ្ឋ តាមរយៈដំណើរការសម្របសម្រួលនានា ការចែករំលែកព័ត៌មាន ការយោគយល់ ការគោរពមុខងារតួនាទី និងការគោរពសិទ្ធិគ្នាទៅវិញទៅមក។ ដើម្បីសម្រេចបានលទ្ធផលនេះបានលុះត្រាតែ៖

១) មានការធានាថាគ្រប់ភាគីទាំងអស់ដែលចូលរួមកិច្ចប្រជុំរួមគ្នា យល់ដឹងពីបទដ្ឋានស្តង់ដារ និងលទ្ធផលនៃការបំពេញការងារ

២) សមាជិកក្រុមប្រឹក្សាចុះទៅជួបជាមួយប្រជាពលរដ្ឋ ជាជាងឱ្យប្រជាពលរដ្ឋមកចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សា
៣) មានការសម្របសម្រួលប្រកបដោយវិជ្ជាជីវៈ
៤) មានការយកចិត្តទុកដាក់ ចំពោះសមភាពយេនឌ័រ និងស្ថានភាពសេដ្ឋកិច្ចសង្គម
៥) លើកកម្ពស់ការចូលរួម និងការផ្លាស់ប្តូរមតិយោបល់៖ រាល់សកម្មភាពនៃការត្រួតពិនិត្យ និងការរៀបចំកិច្ចប្រជុំរួមគ្នានានា ត្រូវសម្របសម្រួលដោយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ដែលទទួលបានការបណ្តុះបណ្តាល និងមានការគាំទ្រពីអង្គការដៃគូអនុវត្ត (សូមមើលសមាសភាគទី៣)។

**លទ្ធផលនៃកិច្ចប្រជុំរួមគ្នាជាមូលដ្ឋាននៃការរៀបចំផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម (ផ.ស.រ.គ)** នឹងរៀបរាប់អំពីអ្វីដែលប្រជាពលរដ្ឋ អ្នកផ្តល់សេវានៅមូលដ្ឋាន រដ្ឋបាលឃុំ និងការិយាល័យស្រុកត្រូវធ្វើដើម្បីដោះស្រាយបញ្ហាខ្វះខាតដែលបានរកឃើញតាមរយៈ សកម្មភាពតាមដានត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ (ប័ណ្ណដាក់ពិន្ទុ)។ **ផ.ស.រ.គ** នឹងត្រូវរៀបចំតាមរយៈ**កិច្ចប្រជុំរួមគ្នា** និងត្រូវមានការតាមដានត្រួតពិនិត្យបន្តក្រោមការណែនាំរបស់គណៈកម្មាធិការរួមមួយហៅថា "គណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម" ដែលមានសមាសភាពមកពី អង្គភាពផ្តល់សេវា តំណាងសហគមន៍ និងអ្នកពាក់ព័ន្ធ។ គណៈកម្មាធិការនេះនឹងស្នើសុំការយល់ព្រមពីក្រុមប្រឹក្សាឃុំ (ឱ្យមានការឯកភាពលើសកម្មភាពដែលឃុំត្រូវអនុវត្ត) ព្រមទាំងផ្តល់ការគាំទ្រ និងត្រួតពិនិត្យលើការអនុវត្ត **ផ.ស.រ.គ** ដោយភាគីពាក់ព័ន្ធទាំងឡាយ។

**តួនាទីរបស់ក្រុមប្រឹក្សាឃុំ៖** ក្រុមប្រឹក្សាឃុំគឺជាអ្នកផ្តល់សេវា ក៏ប៉ុន្តែករណីខ្លះ ក្រុមប្រឹក្សាឃុំ គឺជាតំណាងរបស់ប្រជាពលរដ្ឋ និងមានតួនាទីជាអ្នកពិនិត្យមើល ការផ្តល់សេវា នានានៅមូលដ្ឋាន។ អាស្រ័យហេតុនេះស្ថាប័នពាក់ព័ន្ធសំខាន់ៗនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវជួយពង្រឹងតួនាទីពិនិត្យមើលរបស់តួអង្គសំខាន់ៗនៅថ្នាក់ឃុំ (ដូចជាសមាជិកក្រុមប្រឹក្សាឃុំ ស្មៀន និងមេភូមិ)។ សមាជិកក្រុមប្រឹក្សាឃុំនឹងក្លាយជាស្ពានសម្រាប់ការប្រាស្រ័យទាក់ទងរវាងប្រជាពលរដ្ឋ ជាមួយអង្គភាព ឬភ្នាក់ងារផ្តល់សេវានានាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ។

ការអនុវត្តសមាសភាគទី២នេះ ត្រូវធ្វើឡើង ដោយប្រជាពលរដ្ឋ និងសហគមន៍ រួមជាមួយការសម្របសម្រួលពីអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ដែលទទួលបានការបណ្តុះបណ្តាល ហ្វឹកហ្វឺន និងណែនាំពីអង្គការដៃគូអនុវត្ត ។

**លទ្ធផលរំពឹងទុកសំខាន់ៗនៃសមាភាគទី២នេះ មានចំនួន៤ ដូចតទៅ៖**

**៣.១.ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ**

កិច្ចដំណើរការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ នឹងធ្វើឡើងនៅតាមភូមិនីមួយៗ (ឬប្រមូលផ្តុំភូមិមួយចំនួន) ដោយមានការចូលរួមសម្របសម្រួលពីអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងប្រជាពលរដ្ឋ សមាជិកសហគមន៍នឹងធ្វើការដាក់ពិន្ទុដោយប្រើប្រាស់ទិន្នន័យព័ត៌មានក្នុងកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ ដែលបានបិទផ្សាយស្រាប់ទៅតាមវិស័យនីមួយៗ ដើម្បីជា

មូលដ្ឋានក្នុងការពិភាក្សា និងផ្ទៀងផ្ទាត់មុននឹងធ្វើការដាក់ពិន្ទុ ហើយចាត់អាទិភាពតាមវិស័យ ឬបញ្ហានានា។ រដ្ឋបាលថ្នាក់ក្រោមជាតិ (អង្គភាពផ្តល់សេវា) ក៏នឹងត្រូវចូលរួមពេញលេញក្នុងសកម្មភាពតាមដានត្រួតពិនិត្យនេះ។ អង្គការដៃគូអនុវត្តនឹងស្នើឡើងអំពីទីកន្លែងដែលត្រូវធ្វើការត្រួតពិនិត្យតាមដានស្របតាមគោលការណ៍ណែនាំ ព្រមទាំងសម្របសម្រួលចងក្រងក្រុមស្ត្រី យុវវ័យ កុមារ ជនជាតិដើម ជនពិការ ជនងាយរងគ្រោះ និងគ្រួសារក្រីក្រ ដើម្បីចូលរួមក្នុងការជួបជុំនានា។

គោលការណ៍ណែនាំសម្រាប់បំពេញប័ណ្ណដាក់ពិន្ទុ (ការវាយតម្លៃខ្លួនឯងរបស់អង្គភាពផ្តល់សេវា និងប័ណ្ណដាក់ពិន្ទុដោយប្រជាពលរដ្ឋ) លើការផ្តល់សេវារបស់វិស័យនានានឹងត្រូវរៀបចំជាសៀវភៅណែនាំស្តីពីកិច្ចប្រតិបត្តិការគណនេយ្យភាពសង្គមសម្រាប់ផ្នែកតម្រូវការដាច់ដោយឡែកមួយ។ ទន្ទឹមនឹងនេះ រាល់ឧបករណ៍ទាំងឡាយដែលបានធ្វើការអនុវត្តសាកល្បងនៅមូលដ្ឋាននឹងត្រូវធ្វើការកែសម្រួលឱ្យកាន់តែប្រសើរឡើង តាមរយៈការប្រមូលមតិយោបល់នានាពីអ្នកអនុវត្ត។ ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកនេះ ចាំបាច់ត្រូវអនុវត្តសកម្មភាពមួយចំនួនដូចជា៖

### សកម្មភាព ៣.១.១ អនុវត្តការដាក់ពិន្ទុលើសេវាតាមវិស័យនានាដោយអង្គភាពផ្តល់សេវា

ការអនុវត្តការដាក់ពិន្ទុលើសេវាតាមវិស័យទាំង៣ដោយអង្គភាពផ្តល់សេវាផ្ទាល់ គឺរៀបចំឡើងក្នុងគោលបំណងផ្តល់ឱកាសឲ្យអង្គភាពផ្តល់សេវា (រដ្ឋបាលឃុំ មណ្ឌលសុខភាព និងសាលាបឋមសិក្សា) ធ្វើការវាយតម្លៃខ្លួនឯងពីការបំពេញការងាររបស់ខ្លួន ព្រមទាំងកំណត់នូវបញ្ហា និងដំណោះស្រាយជាអាទិភាពក្នុងការកែលម្អនូវសកម្មភាពការងាររបស់ខ្លួន និងអ្នកពាក់ព័ន្ធ។ ក្នុងដំណើរការដាក់ពិន្ទុនេះដឹកនាំដោយប្រធានអង្គភាពផ្តល់សេវា និងសម្របសម្រួលដោយអង្គការដៃគូអនុវត្ត និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍។ ក្នុងដំណើរការនេះត្រូវរៀបចំអនុវត្តជារៀងរាល់ឆ្នាំ និងមានអ្នកចូលរួមយ៉ាងតិច៦នាក់(យ៉ាងច្រើន ២០នាក់) សម្រាប់១ស្ថាប័នអនុវត្ត។ លទ្ធផលនៃការដាក់ពិន្ទុវាយតម្លៃខ្លួនឯងត្រូវយកមកបង្ហាញ និងពិភាក្សាជាមួយលទ្ធផលការដាក់ពិន្ទុដោយប្រជាពលរដ្ឋក្នុងកិច្ចប្រជុំរួមគ្នា ដូចមានរៀបរាប់ក្នុងចំណុច ៣.២។

### សកម្មភាព ៣.១.២ អនុវត្តប័ណ្ណដាក់ពិន្ទុចំពោះសេវាតាមវិស័យនានាដោយប្រជាពលរដ្ឋប្រចាំឆ្នាំនៅគ្រប់ឃុំនៃស្រុកគោលដៅនីមួយៗ

ប័ណ្ណដាក់ពិន្ទុចំពោះការផ្តល់សេវាតាមវិស័យនានានៅសហគមន៍នឹងត្រូវអនុវត្តប្រចាំឆ្នាំនៅក្នុងស្រុកទាំងអស់ដែលបានកំណត់នៅក្នុងផែនការ។ នៅក្នុងស្រុកនីមួយៗមានការរំពឹងទុកថានឹងមានការចូលរួមពីប្រជាពលរដ្ឋប្រហែល៨០០នាក់ (ក្នុងនោះមានស្ត្រី៥០%) មកចូលរួមក្នុងដំណើរការអនុវត្តការដាក់ពិន្ទុរាប់បញ្ចូលទាំងសាលារៀន មណ្ឌលសុខភាព រដ្ឋបាលឃុំ ស្រុក[13] និងសេវាផ្សេងៗទៀត ព្រមទាំងបញ្ហាជាអាទិភាពនានារបស់សហគមន៍។ ក្នុងស្រុកនីមួយៗ អង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ នឹងជួយគាំទ្រ ផ្តល់ការបណ្តុះបណ្តាល និងផ្តល់យោបល់ណែនាំដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ក្នុងការដឹកនាំដំណើរការប័ណ្ណដាក់ពិន្ទុដោយប្រជាពលរដ្ឋ។

---

[13]នៅក្នុងដំណាក់កាលដំបូងប័ណ្ណដាក់ពិន្ទុយ៉ាងហោចណាស់ត្រូវផ្តោតលើ សាលាឃុំមណ្ឌលសុខភាពនិងសាលារៀន។ សហគមន៍អាចបន្ថែមអាទិភាពផ្សេងទៀត ប្រសិនបើចាំបាច់។ថ្នាក់ស្រុក រំពឹងថានឹងអាចចាប់ផ្តើមអនុវត្តបន្តិចម្តងៗអាស្រ័យទៅតាមការផ្ទេរមុខងារ និងការអនុវត្តមូលនិធិស្រុក។

ដើម្បីគាំទ្រដល់ដំណើរការរៀបចំប័ណ្ណដាក់ពិន្ទុដោយប្រជាពលរដ្ឋ ចាំបាច់ត្រូវមានការពង្រឹងសមត្ថភាព និងលើកកម្ពស់ការយល់ដឹងដែលនឹងរៀបរាប់លម្អិតបន្ថែមនៅក្នុងសមាសភាគទី៣។

**សកម្មភាព ៣.១.៣ ការតាមដានត្រួតពិនិត្យស៊ីជម្រៅដោយប្រជាពលរដ្ឋទៅលើសេវាមូលដ្ឋាន និងបញ្ហាជាក់លាក់មួយចំនួន**

នៅពេលដែលសហគមន៍បានបំពេញប័ណ្ណដាក់ពិន្ទុទៅលើការផ្តល់សេវាតាមវិស័យនានារួចមក អ្នកពាក់ព័ន្ធត្រូវបន្តគាំទ្រដល់សហគមន៍ឱ្យមានការយកចិត្តទុកដាក់កាន់តែខ្លាំង និងអាចធ្វើការវាយតម្លៃស៊ីជម្រៅទៅលើបញ្ហា និងសេវាទាំងឡាយណាដែលមាននៅក្នុងប័ណ្ណដាក់ពិន្ទុ។ ការត្រួតពិនិត្យតាមដានស៊ីជម្រៅអាចធ្វើឡើងតាមទម្រង់ផ្សេងៗអាស្រ័យទៅតាមបញ្ហា និងសមត្ថភាពរបស់អង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ និងសមត្ថភាពរបស់អ្នកសម្របសម្រួល។ ឧទាហរណ៍៖ ប័ណ្ណដាក់ពិន្ទុបានលើកឡើងអំពីបញ្ហាមួយទាក់ទងទៅនឹងគុណភាពនៃសេវាសុខភាព ជាពិសេសបុគ្គលិកមណ្ឌលសុខភាព ដែលសហគមន៍អាចស្នើឱ្យមានការត្រួតពិនិត្យដោយប្រជាពលរដ្ឋទៅលើការមិនមកធ្វើការរបស់បុគ្គលិកមណ្ឌលសុខភាពនោះ។ ប្រសិនបើបញ្ហាត្រូវបានរកឃើញទាក់ទងទៅនឹងការចាត់ចែងហិរញ្ញវត្ថុនោះ នឹងអាចមានការស្នើសុំឱ្យមានការធ្វើសវនកម្ម។ លទ្ធផលរកឃើញនឹងត្រូវយកទៅពិភាក្សានៅក្នុងកិច្ចប្រជុំរួម និងត្រូវដាក់បញ្ចូលក្នុងផ.ស.រ.គ។ លទ្ធផលរកឃើញពាក់ព័ន្ធអាចយកទៅបញ្ចូលទៅក្នុងកញ្ចប់ព័ត៌មានសម្រាប់ឆ្នាំបន្ទាប់ទៀតផងដែរ។

## ៣.២. កិច្ចប្រជុំរួមគ្នា និងផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម

នៅពេលបញ្ចប់ការអនុវត្តប័ណ្ណដាក់ពិន្ទុ ជំហានបន្ទាប់គឺត្រូវរៀបចំកិច្ចប្រជុំរួម ដើម្បីចែករំលែកលទ្ធផលរកឃើញជាមួយអ្នកពាក់ព័ន្ធនានានៅមូលដ្ឋាន (ដូចជាសមាជិកក្រុមប្រឹក្សា ប្រធានមណ្ឌលសុខភាព នាយកសាលា មេភូមិ មន្ត្រីស្រុក និងប្រជាពលរដ្ឋ) ដើម្បីឯកភាពទៅលើវិធានការនានាដែលត្រូវដោះស្រាយចំពោះបញ្ហាទាំងនោះ។ ក្នុងសៀវភៅណែនាំស្តីពីកិច្ចប្រតិបត្តការគណនេយ្យភាពសង្គមផ្នែកតម្រូវការ មានរៀបរាប់ពីដំណើរការសម្រាប់កិច្ចប្រជុំរួមនេះ ដែលរួមមានទិដ្ឋភាពសំខាន់ៗ ដូចខាងក្រោម៖

- ក្រុមប្រឹក្សា មន្ត្រីការិយាល័យអប់រំ និងការិយាល័យស្រុកប្រតិបត្តិ អ្នកផ្តល់សេវា ត្រូវជួបប្រជុំជាមួយប្រជាពលរដ្ឋ នៅទីតាំងណាមួយ ជាជាងហៅប្រជាពលរដ្ឋឱ្យមកចូលរួមប្រជុំនៅការិយាល័យរបស់រដ្ឋ
- ការបង្ហាញអំពីលទ្ធផលត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ ត្រូវបង្ហាញដោយតំណាងប្រជាពលរដ្ឋ ឬតំណាងអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ
- ស្ថាប័ន អង្គភាពផ្តល់សេវា និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវស្តាប់ និងឆ្លើយតបទៅកាន់ប្រជាពលរដ្ឋ
- ប្រជាពលរដ្ឋនឹងពិភាក្សាពីកញ្ចប់ព័ត៌មាន រួមមានព័ត៌មានលើការបំពេញការងារ និងព័ត៌មានថវិកា ក៏ដូចជាលទ្ធផលទទួលបានពីការត្រួតពិនិត្យតាមដាន របស់ប្រជាពលរដ្ឋ
- លទ្ធផលនៃការវាយតម្លៃខ្លួនឯងរបស់អង្គភាពផ្តល់សេវា និងអនុសាសន៍នានាសម្រាប់កែលម្អ
- កិច្ចប្រជុំរួមត្រូវធ្វើយ៉ាងណាដើម្បីឱ្យលទ្ធផលនៃកិច្ចប្រជុំនេះ (ផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម) អាចបញ្ចូលក្នុងកម្មវិធីវិនិយោគឃុំ និងបង្ហាញនៅក្នុងសមាហរណកម្មថ្នាក់ស្រុក។
- កិច្ចប្រជុំនេះ មានលក្ខណៈស្ថាបនា ដោយមានអ្នកជំនាញធ្វើការសម្របសម្រួល ពិភាក្សារវាង អង្គភាពផ្តល់សេវា រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋ។

**លទ្ធផលសំខាន់ៗដែលបានព្រមព្រៀងនៅក្នុងកិច្ចប្រជុំរួមនឹងបង្កើតបានផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម(ផ.ស.រ.គ)មួយ។** សមាសធាតុសំខាន់នៃ **ផ.ស.រ.គ** ដែលបានឯកភាពយល់ព្រមនៅក្នុងកិច្ចប្រជុំរួម និងត្រូវធ្វើការត្រួតពិនិត្យតាមដានបន្តដោយ**គណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម** ដែលដឹកនាំដោយមេឃុំ និងមានសមាសភាពចូលរួមផ្សេងៗទៀត ដូចជា តំណាងសហគមន៍ ឃុំ សាលារៀន និងមណ្ឌលសុខភាព រួមទាំងតំណាងមកពីរដ្ឋបាលស្រុក និងការិយាល័យជំនាញនានាផងដែរ។ គណៈកម្មាធិការនានានៅថ្នាក់មូលដ្ឋានត្រូវចូលរួមដើម្បីធានាថា សកម្មភាពដែលបានលើកឡើងនៅក្នុងផែនការ ផ.ស.រ.គ ត្រូវបានអនុវត្ត ដូចជាក្រុមទ្រទ្រង់សុខភាពភូមិ[14] គណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព គណៈកម្មាធិការទ្រទ្រង់សាលា និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ[15] ។ល។ សកម្មភាពផ្តួចផ្តើមមួយចំនួនដែលមានពីមុនៗមក ដោយមានការត្រួតពិនិត្យដោយប្រជាពលរដ្ឋ តែងត្រូវបានអនុវត្តប្រកបដោយជោគជ័យ ប៉ុន្តែការអនុវត្តផែនការដើម្បីកែលម្អគឺនៅមានកម្រិតនៅឡើយ។ ហេតុនេះ ការប្រាស្រ័យទាក់ទង និងឆ្លើយឆ្លងគ្នាទៅវិញទៅមករវាងប្រជាពលរដ្ឋដែលជាអ្នកទទួលសេវា អ្នកផ្តល់សេវា និងអាជ្ញាធរមូលដ្ឋានតាម រយៈកិច្ចប្រជុំរួម ព្រមទាំងមានការគាំទ្រត្រួតពិនិត្យតាមដានពីគណៈកម្មាធិការ **ផ.ស.រ.គ** បន្ថែមទៀត។

គណៈកម្មាធិការ **ផ.ស.រ.គ** ត្រូវធានាថាលទ្ធផលបានមកពីប័ណ្ណដាក់ពិន្ទុ ឬលទ្ធផលរបស់ **ផ.ស.រ.គ** ត្រូវបានដាក់បញ្ចូលនៅក្នុងផែនការវិនិយោគឃុំ និងត្រូវយកទៅបង្ហាញនៅក្នុងសមាហរណកម្មថ្នាក់ស្រុកនូវបញ្ហាមួយចំនួនដែលពាក់ព័ន្ធ។

**ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុកផ្នែកនេះ ចាំបាច់ត្រូវអនុវត្តសកម្មភាពមួយចំនួនដូចខាងក្រោម៖**

### សកម្មភាព ៣.២.១ ដំណើរការកិច្ចប្រជុំរួម និងរៀបចំ ផ.ស.រ.គ

បន្ទាប់ពីបញ្ចប់ដំណើរការអនុវត្តប័ណ្ណដាក់ពិន្ទុលើសេវាទាំងបី អង្គការដៃគូអនុវត្តនៅថ្នាក់ជាតិ នឹងធ្វើការងារជាមួយអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ រួមជាមួយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងស្រង់យកលទ្ធផលដែលបានមកពីប័ណ្ណដាក់ពិន្ទុ (កម្រិតភូមិ) ត្រូវមកបង្ហាញទៅតាមទម្រង់មួយដែលសាមញ្ញ ស្រួលយល់ និងងាយស្រួលប្រើប្រាស់។ ដើម្បីឱ្យដំណើរការនេះមានប្រសិទ្ធភាព គឺទាមទារឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋ និងកិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាពជាច្រើន (សូមមើលសមាសភាគទី៣)។ រាល់សកម្មភាព ដែលឆ្លើយតបនឹងបញ្ហា ត្រូវប្រកបដោយសមធម៌រវាងស្ត្រី យុវវ័យ កុមារ ជនជាតិដើម និងជនពិការនៅក្នុងនោះផងដែរ។

កិច្ចប្រជុំរួមគ្នាសម្រេចបានផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម ដែលរៀបរាប់ពីសកម្មភាពជាអាទិភាពដែលសហគមន៍ និងអ្នកពាក់ព័ន្ធនានានៅមូលដ្ឋានព្រមព្រៀងគ្នា ដែលអាចធ្វើបាន និងសកម្មភាពត្រូវធ្វើបន្ត ដើម្បីលើកកម្ពស់គុណភាព និងភាពងាយទទួលបានសេវាសាធារណៈ។ ផ. ស.រ.គ ជាលទ្ធ

[14] ការផ្សារភ្ជាប់រវាងការអនុវត្តគណនេយ្យភាពសង្គម ជាមួយនិងគោលនយោបាយរបស់ក្រសួងសុខាភិបាលស្តីពីការចូលរួមរបស់សហគមន៍ មានសារៈសំខាន់ណាស់ ព្រោះថាគោលនយោបាយនេះអាចផ្តល់ជាការណែនាំបុគ្គលិកសុខាភិបាលនិងអ្នកផ្តល់សេវានានាទាក់ទងនឹងការចែករំលែកព័ត៌មាន ការបិទផ្សាយឯកសារសំខាន់ៗនានាជាសាធារណៈការចូលរួមរបស់បុគ្គលិកសុខាភិបាលក្នុងដំណើរការប័ណ្ណដាក់ពិន្ទុ និងការចូលរួមប្រជុំ ក្នុងការអនុវត្តផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម ...។ល។

[15] គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ និងគ.ក.ស.ក ថ្នាក់ស្រុក ចូលរួមយកចិត្តទុកដាក់លើការងារយុវវ័យ។

ផល នៃការប្តេជ្ញាចិត្តរបស់ប្រជាពលរដ្ឋ និងស្ថាប័ន អង្គភាពផ្តល់សេវាក្នុងការដាក់ចេញដំណោះស្រាយជាក់លាក់ដើម្បីសម្រេចបាននូវលទ្ធផលជាវិជ្ជមាន។ អង្គភាពផ្តល់សេវា និងអ្នកពាក់ព័ន្ធត្រូវបំពេញតួនាទីក្នុងការរៀបចំ និងឆ្លើយតបចំពោះសកម្មភាពជាអាទិភាពដែលបានលើកឡើងនៅក្នុងផ.ស.រ.គ។ ទម្រង់បែបបទនៃ ផ.ស.រ.គ នឹងត្រូវសាកល្បង និងដាក់បញ្ចូលទៅក្នុងសៀវភៅណែនាំ ប៉ុន្តែផែនការនេះត្រូវមានលក្ខណៈគ្រប់ជ្រុងជ្រោយសំខាន់៤គឺ៖

១) សកម្មភាពរបស់សហគមន៍ដែលអាចអនុវត្តបានដោយខ្លួនឯង (ឧ.៖ការសម្អាតបរិវេណមណ្ឌលសុខភាព ការតាមដានចំនួនម៉ោងបំពេញការងាររបស់បុគ្គលិកមណ្ឌលសុខភាព)
២) វិធានការដែលអ្នកផ្តល់សេវានានាត្រូវប្រកាន់យកដោយមានការកែប្រែថវិកាតិចតួច (ឧ. នាយកសាលាមានវិធានការលើការបង្រៀនរបស់គ្រូ ឥរិយាបថរបស់បុគ្គលិកសុខាភិបាលប្រព្រឹត្តចំពោះអ្នកជម្ងឺដោយការគោរព និងការកែលម្អអនាម័យ)។
៣) សកម្មភាពរបស់សមាជិកក្រុមប្រឹក្សាឃុំ ដែលសកម្មភាពទាំងនេះអាចធ្វើឡើងក្នុងរូបភាព២៖
   ក) ជាអ្នកផ្តល់សេវា៖ ឃុំអាចចាត់វិធានការលើសេវាដែលខ្លួនផ្តល់ដល់ប្រជាពលរដ្ឋ (ដូចជាត្រូវធានាថា មានទម្រង់បែបបទចុះបញ្ជីអត្រានុកូលដ្ឋាន រៀបចំដំណើរការកសាងផែនការឱ្យបានទូលំទូលាយតាមគោលការណ៍ណែនាំ)
   ខ) ជាអ្នកត្រួតពិនិត្យ៖ ដោយសារតែក្រុមប្រឹក្សាឃុំត្រូវទទួលខុសត្រូវក្នុងការកាត់បន្ថយភាពក្រីក្រ និងដោះស្រាយបញ្ហាផ្សេងៗនៅមូលដ្ឋាន គេរំពឹងថា ក្រុមប្រឹក្សាឃុំអាចមានឥទ្ធិពលចំពោះការផ្តល់សេវានានា (ដូចជាសាលារៀន និងមណ្ឌលសុខភាព) ឬស្នើសុំការគាំទ្រពីការិយាល័យស្រុក។
៤) សកម្មភាពមួយចំនួនដែលត្រូវអនុវត្តដោយ**ការិយាល័យជំនាញថ្នាក់ស្រុក** មានដូចជាការស្វែងរកការគាំទ្រពីថ្នាក់លើ (ឧ.ការស្នើសុំគ្រូបន្ថែម ការស្នើសុំឱសថបន្ថែមសម្រាប់មណ្ឌលសុខភាព និងការស្នើសុំផ្តល់វ៉ាក់សាំងផ្សេងៗជាដើម)។

### សកម្មភាព ៣.២.២ ការផ្សព្វផ្សាយ និងអនុវត្តផែនការសកម្មភាពផ.ស.រ.គ

នៅពេលមានការព្រមព្រៀងគ្នា សកម្មភាពទាំងឡាយដែលមានក្នុង **ផ.ស.រ.គ** នឹងត្រូវអនុវត្តដោយប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សាលារៀន និងមណ្ឌលសុខភាព រួមទាំងមន្ត្រីជំនាញថ្នាក់ស្រុកដែលពាក់ព័ន្ធ។ ដំបូងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិនឹងធ្វើការជាមួយសហគមន៍ដើម្បីផ្តល់ព័ត៌មានដល់ពួកគេអំពីខ្លឹមសារ និងសារៈសំខាន់នៃ **ផ.ស.រ.គ** ក្នុងការចូលរួមវាយតម្លៃការអនុវត្ត។ បន្ទាប់មកត្រូវផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋឱ្យកាន់តែទូលំទូលាយអំពីដំណើរការនេះ ហើយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ រួមជាមួយក្រុមប្រឹក្សាឃុំ និងអង្គការដៃគូ ត្រូវធ្វើការបង្ហាញ **ផ.ស.រ.គ** នៅមូលដ្ឋាន រួមទាំងការផ្សព្វផ្សាយព័ត៌មាននៅថ្នាក់ស្រុក (ដូចជា ការផ្តល់ដល់សារព័ត៌មាននូវការសម្ភាសន៍ផ្សេងៗ)។

### សកម្មភាព ៣.២.៣ ការបង្កើតគណៈកម្មាធិការផែនការសកម្មភាពរួមស្ដីពីការងារគណនេយ្យភាពសង្គម

ការអនុវត្តសកម្មភាពនៅក្នុង **ផ.ស.រ.គ** នឹងត្រូវត្រួតពិនិត្យដោយ "គណៈកម្មាធិការផ.ស.រ.គ" រួមគ្នាមួយដែលរៀបចំ និងដឹកនាំកិច្ចប្រជុំដោយមេឃុំ ព្រមទាំងមានតំណាងមកពីភាគីពាក់ព័ន្ធផ្សេងៗ។ ទស្សនកិច្ចសិក្សា និងកិច្ចប្រជុំនឹងត្រូវរៀបចំតាមជាក់ស្ដែង (អាស្រ័យលើសកម្មភាពដែលបានឯកភាព សមាជិកគណៈកម្មាធិការ **ផ.ស.រ.គ** នឹងផ្ដល់ព័ត៌មានដល់ប្រជាពលរដ្ឋ និងអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិអំពីអនុសាសន៍នៃការអនុវត្តរបស់ពួកគាត់)។ សកម្មភាពទាំងឡាយណាដែលតម្រូវឱ្យមានការប្រើប្រាស់ថវិកាត្រូវមានការពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ ដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគឃុំ ឬថវិកាសាលារៀន ថវិកាមណ្ឌលសុខភាព និងក្នុងកម្មវិធីរបស់ការិយាល័យស្រុក។ **ផ.ស.រ.គ** នឹងត្រូវយកទៅបង្ហាញនៅក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុកដើម្បីស្វែងរកការគាំទ្រពីអង្គភាពពាក់ព័ន្ធ[16]។ ការរៀបចំ និងការបង្កើតគណៈកម្មាធិការផ.ស.រ.គ នឹងមានចែងលម្អិតនៅក្នុងសៀវភៅណែនាំកិច្ចប្រតិបត្តិការគណនេយ្យភាពសង្គម (Operational Guidelines)។

## ៣.៣.ការរៀបចំលិខិតបទដ្ឋាននានាដើម្បីគាំទ្រការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាឃុំ

**ក្រុមប្រឹក្សាឃុំត្រូវមានតួនាទីជាអ្នកដឹកនាំដ៏សំខាន់នៅក្នុងការអនុវត្តសកម្មភាពគណនេយ្យភាពសង្គមនៅមូលដ្ឋាន។** តាមរយៈបទពិសោធន៍នៃការអនុវត្តសកម្មភាពគណនេយ្យភាពសង្គមដែលបានអនុវត្តសាកល្បងកន្លងមក បានបង្ហាញថា សមិទ្ធផលដែលសម្រេចបានកាន់តែមានប្រសិទ្ធភាព នៅពេលសមាជិកក្រុមប្រឹក្សាឃុំមានទំនុកចិត្តក្នុងការធ្វើអន្តរាគមន៍ ដើម្បីឱ្យមានការផ្លាស់ប្ដូរ។

**ទំនាក់ទំនងរវាងគណនេយ្យភាពសង្គម និងការរៀបចំគោលនយោបាយគឺជាចំនុចសំខាន់ដែលត្រូវយកចិត្តទុកដាក់** ដោយហេតុថាក្រុមប្រឹក្សា គឺជាតំណាងប្រជាពលរដ្ឋដែលកើតឡើងដោយការបោះឆ្នោត សមាជិកក្រុមប្រឹក្សាឃុំមានតួនាទីត្រួតពិនិត្យមើលការងារក្នុងអាណត្តិរបស់ខ្លួន និងត្រួតពិនិត្យមើលរាល់បញ្ហាផ្ដល់សេវានានាដែលមានផលប៉ះពាល់ដល់សហគមន៍។ ការអនុវត្តគណនេយ្យភាពសង្គមជួយបំពេញឱ្យគ្នាទៅវិញទៅមកដើម្បីឱ្យប្រព័ន្ធទាំងមូលកាន់តែមានគណនេយ្យភាព។ ទោះបីជា សេវាផ្ដល់តាមរយៈក្រសួង ស្ថាប័នជំនាញក៏ដោយ ក៏ឃុំត្រូវដើរតួនាទីយ៉ាងសំខាន់ជាអ្នកតំណាង ទទួលខុសត្រូវក្នុងដំណើរការអភិវឌ្ឍដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ[17] ។

ដើម្បីសម្រេចបាននូវលទ្ធផលរំពឹងទុក៣.៣នេះ ចាំបាច់ត្រូវអនុវត្តសកម្មភាព ចំនួន២ ដូចជា៖

### សកម្មភាព ៣.៣.១ រៀបចំ និងដាក់ឱ្យអនុវត្ត សេចក្ដីណែនាំស្ដីពីតួនាទី ភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ

ដើម្បីឱ្យការងារគណនេយ្យភាពសង្គមមាននិរន្តរភាព ដំណើរការធម្មតាជាប្រចាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឃុំ មណ្ឌលសុខភាព និងសាលាបឋមសិក្សា ចាំបាច់ត្រូវមាន សេចក្ដីណែនាំ ដើម្បីជួយជំរុញឱ្យរដ្ឋបាលមូល

---

[16] សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុកជាវេទិកាមួយដែលអាចឲ្យសហគមន៍អាចស្វែងរកការគាំទ្រចំពោះលទ្ធផលនៃការអនុវត្តប័ណ្ណដាក់ពិន្ទុរបស់ខ្លួន។

[17] នៅថ្នាក់ស្រុក ទោះបីនីតិវិធីក្នុងការអនុវត្តមិនទាន់បង្កើតឡើងនៅឡើយ តែតួនាទីក្នុងការត្រួតពិនិត្យ និងមើលពីលើអំពីការផ្ដល់សេវារបស់រដ្ឋគឺជាតួនាទីរបស់គណៈអភិបាល។ ការិយាល័យអន្តរវិស័យទទួលខុសត្រូវក្នុងការសម្របសម្រួលរវាងក្រសួងជំនាញ និងគម្រោងអភិវឌ្ឍន៍ និងជួយដោះស្រាយបញ្ហាផ្សេងៗស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។

ដ្ឋាន និងអ្នកផ្តល់សេវានានាផ្តល់ការគាំទ្រ និងចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការអនុវត្តនេះ ព្រមទាំងទទួលបានការណែនាំផ្ទាល់ (ឬការបណ្តុះបណ្តាល) អំពីរបៀបអនុវត្តការងារនោះ។

### សកម្មភាព ៣.៣.២ ពិនិត្យកែសម្រួលលិខិតបទដ្ឋានគតិយុត្តិសម្រាប់ការត្រួតពិនិត្យរបស់ឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌ ទៅលើការផ្តល់សេវាមូលដ្ឋាននានា

លិខិតបទដ្ឋានគតិយុត្ត នឹងត្រូវរៀបចំឡើងដោយមានបញ្ជាក់អំពីមុខងារ និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាស្រុកក្នុងការត្រួតពិនិត្យការផ្តល់សេវានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន[18] ព្រមទាំងតួនាទីប្រជាពលរដ្ឋនៅក្នុងដំណើរការត្រួតពិនិត្យ[19]។ គ.ជ.អ.ប អាចជួលទីប្រឹក្សាជំនាញ ដើម្បីឱ្យជួយរៀបចំសេចក្តីព្រាងប្រកាសនោះ ដើម្បីពិភាក្សា និងអនុម័ត។

## ៣.៤. ការលើកកម្ពស់ការយល់ដឹង និងការពង្រឹងសមត្ថភាព

លទ្ធផលនេះ អង្គការដៃគូអនុវត្តនៅថ្នាក់ជាតិ ឬអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ នឹងធ្វើការបណ្តុះបណ្តាលអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍។ ការបណ្តុះបណ្តាលអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍មានវគ្គបណ្តុះបណ្តាលចំនួន៤ ដែលក្នុងមួយវគ្គៗមានចំនួន៤ថ្ងៃ [20] ដោយផ្អែកតាមឯកសារបច្ចេកទេសស្តីពីការបណ្តុះបណ្តាលអ្នកសម្របសម្រួលសហគមន៍។ វគ្គបណ្តុះបណ្តាលទាំងនោះមានបញ្ចូលទាំងការរៀនសូត្រតាមរយៈការអនុវត្តផ្ទាល់ (ដូចជា ការអនុវត្តសកម្មភាពកម្មវិធីផ្សេងៗ រួមមានការយល់ដឹងពីកញ្ចប់ព័ត៌មាន ដំណើរការប័ណ្ណដាក់ពិន្ទុចំពោះសេវាកម្មនានា ការសម្របសម្រួលកិច្ចប្រជុំរួម...។ល។)។

ដើម្បីសម្រេចបានលទ្ធផលរំពឹងទុកខាងលើ ចាំបាច់ត្រូវអនុវត្តសកម្មភាពចំនួន៣ ដូចតទៅ៖

### សកម្មភាព ៣.៤.១ អនុវត្តកម្មវិធីបណ្តុះបណ្តាល ការផ្តល់យោបល់ណែនាំ និងការរៀនសូត្រតាមរយៈការអនុវត្តផ្ទាល់ជាមួយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍

អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ត្រូវបានបណ្តុះបណ្តាលអំពីរបៀបជួយប្រជាពលរដ្ឋឱ្យទទួលបាននូវព័ត៌មានសំខាន់ៗ និងរៀនពីរបៀបសម្របសម្រួលការអនុវត្តគណនេយ្យភាពសង្គម វិធីសម្របសម្រួលការប្រាស្រ័យទាក់ទងរវាងប្រជាពលរដ្ឋ និងរដ្ឋបាលមូលដ្ឋានព្រមទាំងអ្នកផ្តល់សេវានានា។ លើសពីនេះទៀត អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ នឹងទទួលបានការផ្តល់យោបល់ណែនាំ និងការរៀនសូត្រតាមរយៈការអនុវត្តផ្ទាល់ជាប្រចាំ។ ក្នុងឃុំនីមួយៗនៃស្រុកគោលដៅ [21] អាចមានអ្នកសម្របសម្រួល

---

[18]ទោះបីជា ឃុំមានអាណត្តិការងារខ្លួន ក្នុងការកាត់បន្ថយភាពក្រីក្រនិងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់ក៏ដោយ ក៏ចាំបាច់ត្រូវមានការបញ្ជាក់ឲ្យបានច្បាស់លាស់លម្អិតបន្ថែមទៀត ដើម្បីជួយជម្រុញឲ្យឃុំចូលរួមក្នុងដំណើការគណនេយ្យភាពសង្គមបានល្អប្រសើរ។

[19]នៅពេលរៀបចំប្រកាសរួចរាល់ ត្រូវពិនិត្យនិងកែសម្រួលសៀវភៅណែនាំអនុវត្តនិងប្រព័ន្ធដែលមានស្រាប់នានា ឱ្យស្របទៅតាមប្រកាសនោះ។

[20] តាមការអនុវត្តកន្លងមក អង្គការសង្គមស៊ីវិលមួយចំនួនបានកែសម្រួលឯកសារបច្ចេកទេសស្តីពីការបណ្តុះបណ្តាលអ្នកសម្របសម្រួលសហគមន៍ និងបានបណ្តុះបណ្តាលក្នុងរយៈពេលមួយសមស្រប។

[21] តាមរយៈបទពិសោធន៍កន្លងមក ការបណ្តុះបណ្តាលរួមបញ្ចូលគ្នារវាងអង្គភាពរដ្ឋបាលនានានជាមួយនិងអង្គការមិនមែនរដ្ឋាភិបាលមានអត្ថប្រយោជន៍ច្រើនព្រោះវិធីនេះ អាចជួយឱ្យមានការយល់ដឹង និងមានទំនុកចិត្តព្រមទាំងពង្រឹងទំនាក់ទំនងការងារទៅវិញទៅមក។ ការបណ្តុះបណ្តាលនឹងផ្តោតទៅលើការពង្រឹងសម្លេងរួមគ្នា និងផ្តោតទៅលើក្រុមស្ត្រី យុវវ័យ និងក្រុមភាគតិចផ្សេងទៀត។

គណនេយ្យភាពសហគមន៍ដែលទទួលការបណ្តុះបណ្តាលជាផ្លូវការត្រឹមត្រូវចំនួនយ៉ាងតិច៤នាក់ ដែលមានសមត្ថភាពអាចផ្តល់ការគាំទ្រជាប្រចាំចំពោះសកម្មភាពការងារគណនេយ្យភាពសង្គម[22] នៅក្នុងឃុំ ទាំងនោះ។

### សកម្មភាព ៣.៤.២ ការលើកកម្ពស់ការយល់ដឹងអំពីការងារត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ និងការរៀបចំផ.ស.រ.គ សម្រាប់អង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ សហគមន៍ និងប្រជាពលរដ្ឋ

តួនាទីចម្បងរបស់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ គឺត្រូវជួយពន្យល់សមាជិកប្រជាពលរដ្ឋឱ្យចូលរួមក្នុងដំណើរការអនុវត្តគណនេយ្យភាពសង្គម។ តួនាទីនេះ រួមមានសកម្មភាពមួយចំនួន ដូចជាការលើកកម្ពស់ការយល់ដឹង និងការកសាងសមត្ថភាពដល់ប្រជាពលរដ្ឋ ហើយអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិធ្វើការណែនាំ និងសម្របសម្រួលយ៉ាងសកម្ម ដើម្បីឱ្យប្រជាពលរដ្ឋចូលរួមនៅក្នុងដំណើរការត្រួតពិនិត្យលើការងារគណនេយ្យភាពសង្គមនេះ។ សកម្មភាពទាំងនេះពាក់ព័ន្ធជាមួយនឹងការចែករំលែកព័ត៌មាននៅថ្នាក់មូលដ្ឋាន(រួមទាំងការយល់ដឹងពីសិទ្ធិ) ការពិភាក្សា ដើម្បីជួយសមាជិកសហគមន៍ឱ្យបានយល់ដឹងពីគោលការណ៍ និងការអនុវត្តគណនេយ្យភាពសង្គម ការបំពេញប័ណ្ណដាក់ពិន្ទុដោយប្រជាពលរដ្ឋ និងការគាំទ្រសម្រាប់ការប្រជុំរួមដែលត្រូវធ្វើឡើងជាប្រចាំរយៈពេលពេញមួយឆ្នាំ។

### សកម្មភាព ៣.៤.៣ ការបណ្តុះបណ្តាល អំពីការរៀបចំ ផ.ស.រ.គ ការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ និងមុខងារត្រួតពិនិត្យមើលពីលើសម្រាប់មន្ត្រីមូលដ្ឋាន និងអ្នកផ្តល់សេវា

សកម្មភាពគណនេយ្យភាពសង្គមផ្តល់ឱកាសពង្រឹងសមត្ថភាពដល់បុគ្គល និងស្ថាប័ននានានៅថ្នាក់ឃុំ និងស្រុក ដែលជាអ្នកត្រួតពិនិត្យលើការផ្តល់សេវា។ លទ្ធផលនេះ គឺការផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីថ្នាក់មូលដ្ឋាន (រួមមាន សមាជិកក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីសំខាន់ៗ) និងបុគ្គលិកដែលជាអ្នកផ្តល់សេវា។ ម្យ៉ាងទៀត វគ្គបណ្តុះបណ្តាលគណនេយ្យភាពសង្គមនៅមូលដ្ឋាន នឹងត្រូវផ្តល់ដល់ផ្នែកផ្គត់ផ្គង់ផង និងផ្នែកតម្រូវការផង ដើម្បីឱ្យមានការយល់អំពីគ្នានិងគ្នា និងពង្រឹងទំនាក់ទំនងរវាងអ្នកពាក់ព័ន្ធសំខាន់ៗទាំងឡាយ។

**ការអនុវត្តសមាសភាគទី២នេះ រំពឹងថានឹងសម្រេចបាននូវសមិទ្ធផល ដូចជា៖ ប្រជាពលរដ្ឋនឹងចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការត្រួតពិនិត្យការបំពេញការងារ និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រីឯអង្គភាពឬផ្នែកផ្តល់សេវានៅមូលដ្ឋានសហការគ្នាជាមួយអង្គភាពរដ្ឋនានា រៀបចំផែនការសកម្មភាព អនុម័ត និងអនុវត្តសកម្មភាពនានា ដែលមានក្នុងផែនការសកម្មភាព និងថវិកាទាំងនោះ។** សមាសភាគនេះនឹងប្រើប្រាស់ប័ណ្ណដាក់ពិន្ទុដោយសហគមន៍ ដើម្បីជាមធ្យោបាយត្រួតពិនិត្យធ្វើរបាយការណ៍អំពីសេវានៅមូលដ្ឋាន និងការបំពេញការងាររបស់អ្នកផ្តល់សេវា។ កិច្ចប្រជុំរួមគ្នារវាងប្រជាពលរដ្ឋ និងអ្នកផ្តល់សេវា គឺដើម្បីបង្ហាញអំពីលទ្ធផលដែលបានរកឃើញ និងដាក់ចេញជាវិធានការដោះស្រាយនានាទៅក្នុង **ផ.ស.រ.គ** រួមមាន៖ ការបណ្តុះ បណ្តាល ការប្រឹក្សាយោបល់ និងការអភិវឌ្ឍសមត្ថភាពដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ដែលធ្វើការជាមួយអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិដើម្បីលើកកម្ពស់ការយល់ដឹង និងសមត្ថភាពរបស់អ្នកពាក់ព័ន្ធនៅមូលដ្ឋាន។ មន្ត្រីរដ្ឋបាលស្រុកនឹងទទួលបានការបណ្តុះបណ្តាល ដើម្បីធ្វើការបណ្តុះបណ្តាលបន្តដល់ថ្នាក់ឃុំ ហើយមុខងាររបស់ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំត្រូវបានពង្រឹងតាមរយៈការត្រួតពិនិត្យលើការផ្តល់សេវានៅមូលដ្ឋាន។

---

[22] សមាសភាគទី៣ ក្រុមគ្រូឧទ្ទេសថ្នាក់ជាតិ នឹងផ្តល់ការបណ្តុះបណ្តាលដល់គ្រូបង្គោលដែលជាបុគ្គលិកមកពី អង្គការមិនមែនរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានដែលមានតួនាទីផ្តល់ការបណ្តុះបណ្តាលបន្ត ទៅឲ្យអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍។

## តារាងទី៣៖ សង្ខេបអំពីសមាសភាគទី២

| ផ្នែក | ការពិពណ៌នា |
|---|---|
| គោលបំណង | បង្កើតឱ្យមានការត្រួតពិនិត្យ និងរាយការណ៍ដោយប្រជាពលរដ្ឋ និងអ្នកប្រើប្រាស់សេវា ចំពោះការបំពេញមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវានានានៅមូលដ្ឋាន។ |
| សមិទ្ធផល និងសូចនាករ | **ធ្វើអោយប្រសើរឡើងនូវការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការត្រួតពិនិត្យ និងផ្តល់ព័ត៌មានត្រឡប់លើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**<br>• ការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ និងសកម្មភាពរួមអាចជាផ្នែកមួយនៃវដ្តប្រចាំឆ្នាំសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវាមូលដ្ឋាន<br>**ការឆ្លើយតបលើការវិភាជន៍ធនធានកាន់តែប្រសើរ**<br>• ការផ្លាស់ប្តូរថវិកាចំណាយដើម្បីឆ្លុះបញ្ចាំងបញ្ហាអាទិភាពនិងបង្ហាញពីសកម្មភាពក្នុង ផ.ស.រ.គ<br>**ការដាក់បញ្ចូលអោយបានច្រើន និងស្មើភាពក្នុងការវិភាជន៍ធនធាន និងផ្តល់សេវា**<br>• ផ.ស.រ.គ ថវិកាចំណាយ ឆ្លុះបញ្ចាំងពីក្រុមជនដែលគេមិនសូវគិតគូរដល់(យុវជន កុមារ គ្រួសារក្រីក្រ ស្ត្រី ជនជាតិដើម)<br>**លើកកម្ពស់ការបំពេញការងាររបស់តួអង្គនៅថ្នាក់មូលដ្ឋាន(មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវា)**<br>• ការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ ឬផ.ស.រ.គ ជាសកម្មភាពគន្លឹះ<br>➢ អ្នកផ្តល់សេវាមានការផ្លាស់ប្តូរឥរិយាបថ និងផ្តល់សេវាកាន់តែប្រសើរឡើង<br>➢ ក្រុមប្រឹក្សាមានការផ្លាស់ប្តូរខ្ពស់លើការផ្តល់សេវាក្នុងមូលដ្ឋាន<br>➢ មន្ត្រីស្រុកអនុវត្តការងារ និងត្រួតពិនិត្យកាន់តែប្រសើរឡើង<br>**លើកកម្ពស់សមត្ថភាពតួអង្គលើផ្នែកអភិបាលកិច្ចមូលដ្ឋាន និងដំណើរការអភិវឌ្ឍន៍**<br>• ក្រុមប្រឹក្សាប្រើប្រាស់តួនាទីក្នុងការជំរុញការផ្លាស់ប្តូរកាន់តែប្រសើរឡើង<br>• ប្រជាពលរដ្ឋចូលរួមកាន់តែសកម្មឡើងលើផ្នែកអភិបាលកិច្ចមូលដ្ឋាននិងដំណើរការអភិវឌ្ឍន៍។ |
| លទ្ធផលរំពឹងទុក | **៣.១.ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ**<br>សកម្មភាព ៣.១.១ អនុវត្តការដាក់ពិន្ទុលើសេវាតាមវិស័យនានាដោយអង្គភាពផ្តល់សេវា<br>សកម្មភាព ៣.១.២ អនុវត្តប័ណ្ណដាក់ពិន្ទុចំពោះសេវាតាមវិស័យនានាដោយប្រជាពលរដ្ឋប្រចាំឆ្នាំនៅគ្រប់ឃុំនៃស្រុកគោលដៅនីមួយៗ<br>សកម្មភាព ៣.១.៣ ការត្រួតពិនិត្យតាមដានស៊ីជម្រៅដោយប្រជាពលរដ្ឋទៅលើសេវាមូលដ្ឋាន និងបញ្ហាជាក់លាក់មួយចំនួន<br>**៣.២.កិច្ចប្រជុំរួម និងផែនការសកម្មភាពរួម**<br>សកម្មភាព ៣.២.១ ដំណើរការកិច្ចប្រជុំរួមគ្នា និងរៀបចំផ.ស.រ.គ<br>សកម្មភាព ៣.២.២ ការផ្សព្វផ្សាយ និងអនុវត្ត ផ.ស.រ.គ<br>សកម្មភាព ៣.២.៣ គណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម<br>**៣.៣.ការរៀបចំលិខិតបទដ្ឋាននានា ដើម្បីគាំទ្រការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ និងការពិនិត្យមើលពីលើរបស់សមាជិកក្រុមប្រឹក្សា**<br>សកម្មភាព ៣.៣.១ រៀបចំ អនុម័ត និងដាក់ឱ្យអនុវត្តនូវប្រកាស និងសេចក្តីណែនាំស្តីពីតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ និងការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ<br>សកម្មភាព ៣.៣.២ ពិនិត្យកែសម្រួល លិខិតបទដ្ឋានគតិយុត្តិសម្រាប់ការត្រួតពិនិត្យរបស់ឃុំ សង្កាត់ |

| | |
|---|---|
| | និងក្រុង ស្រុក ខណ្ឌ ទៅលើការផ្តល់សេវាមូលដ្ឋាននានា<br>**៣.៤.ការលើកកម្ពស់ការយល់ដឹង និងការពង្រឹងសមត្ថភាព**<br>**សកម្មភាព ៣.៤.១** អនុវត្តកម្មវិធីបណ្តុះបណ្តាល ការផ្តល់យោបល់ណែនាំ និងការរៀនសូត្រតាមរយៈការអនុវត្តផ្ទាល់ជាមួយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍<br>**សកម្មភាព ៣.៤.២** ការលើកកម្ពស់ការយល់ដឹងអំពីការងារតាមដានត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ និងការរៀបចំ ផ.ស.រ.គ ដោយអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ សហគមន៍ និងប្រជាពលរដ្ឋ<br>**សកម្មភាព ៣.៤.៣** ការបណ្តុះបណ្តាល អំពីការរៀបចំផ.ស.រ.គ ការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ និងមុខងារត្រួតពិនិត្យមើលពីលើសម្រាប់មន្ត្រីមូលដ្ឋាន និងអ្នកផ្តល់សេវា។ |

## ៤.សមាសភាគទី៣ ៖ ការសម្របសម្រួល និងការពង្រឹងសមត្ថភាព

**សមាសភាគនេះ មានគោលបំណងកំណត់ឱ្យបាននូវភាគីចូលរួមពាក់ព័ន្ធពីក្រសួង ស្ថាប័នរដ្ឋ និងស្ថាប័នមិនមែនរដ្ឋ ដោយកសាងជំនាញសម្របសម្រួលសម្រាប់ការចូលរួមពាក់ព័ន្ធនៃភាគីទាំងនោះ ព្រមទាំងដំណើរការអនុវត្តគណនេយ្យភាពសង្គម។** សមាសភាគនេះរៀបរាប់ពីសកម្មភាពនានាដែលបានកំណត់នៅក្នុងសមាសភាគទី ១ និងទី២ ដែលត្រូវបានគាំទ្រដោយមានការចូលរួមពីមូលដ្ឋាន ថែមទាំងទទួលបានការសម្របសម្រួលពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការដៃគូអនុវត្ត ព្រមទាំងកំណត់នូវវិធីសាស្ត្រនានាសម្រាប់ការកសាងសមត្ថភាពដូចដែលបានរំពឹងទុកនៅក្នុងដំណើរការគណនេយ្យភាពសង្គមរវាងប្រជាពលរដ្ឋ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

**គណនេយ្យភាពសង្គមទាមទារឱ្យមានការអភិវឌ្ឍសមត្ថភាព និងការតាំងចិត្តពីសំណាក់ក្រសួង ស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល និងឯកជន ដើម្បីមានទំនាក់ទំនងជាមួយគ្នាតាមរយៈភាពជាដៃគូ។** នេះជាប្រការសំខាន់ដែលអង្គភាពរបស់រដ្ឋ និងអ្នកផ្តល់សេវានានាត្រូវយល់ដឹង និងទទួលយកនូវអ្វីដែលជាតួនាទីរបស់ខ្លួនក្នុងការឆ្លើយតប និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋស្របតាមអាណត្តិការងាររបស់ខ្លួនដែលត្រូវបំពេញ។ ចំណែកប្រជាពលរដ្ឋវិញត្រូវយល់ថា ពួកគេមានសិទ្ធិដឹងឮអំពីកិច្ចការនៅមូលដ្ឋានតាមរយៈចូលរួមនៅក្នុងកិច្ចការសាធារណៈ ហើយរំពឹងថានឹងទាមទារឱ្យមានគណនេយ្យភាពពីមន្ត្រីសាធារណៈ។

**គណនេយ្យភាពសង្គម មានគោលបំណងក្នុងការពង្រឹងការយល់ដឹង ការជឿទុកចិត្ត និងការចូលរួមប្រកបដោយការស្ថាបនារវាងស្ថាប័នរដ្ឋ សង្គមស៊ីវិល និងឯកជន។** មធ្យោបាយពង្រឹងគណនេយ្យភាពសង្គមមានគោលបំណងបង្កើតឱ្យមានទំនាក់ទំនងការងារប្រកបដោយលទ្ធផលរវាងប្រជាពលរដ្ឋ និងស្ថាប័នរដ្ឋដោយផ្អែកលើគោលការណ៍នៃការគោរពគ្នាទៅវិញទៅមក។ ការសហការគ្នាពិតប្រាកដ មានន័យថា ជាការស្វែងរកកិច្ចសហការគ្នា ជាជាងការប្រឈមមុខដាក់គ្នា។ គេត្រូវទទួលស្គាល់នូវ តួនាទីស្របច្បាប់របស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល ក្នុងការចោទជាសំណួរ និងផ្តល់យោបល់ទៅលើសកម្មភាព និងការសម្រេចចិត្តរបស់មន្ត្រីសាធារណៈ និងអ្នកផ្តល់សេវានានា។ គោលបំណងសំខាន់មួយទៀត គឺត្រូវលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ដោយគិតអំពី ស្ត្រី យុវវ័យ កុមារ ជនពិការ ជនជាតិដើម និងប្រជាពលរដ្ឋក្រីក្រ ដែលជារឿយៗពុំសូវបានចូលរួមក្នុងដំណើរការសម្រេចចិត្ត និងអភិបាលកិច្ចឡើយ។

**គណនេយ្យភាពសង្គមពាក់ព័ន្ធនឹងការបង្កើតឱ្យមានមធ្យោបាយ និងយន្តការសម្របសម្រួលសម្រាប់ការចូលរួមប្រកបដោយន័យស្ថាបនារវាងស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋ** ប៉ុន្តែដើម្បីឱ្យការចូលរួមប្រកបដោយប្រសិទ្ធភាព ទីកន្លែងសម្រាប់រៀបចំកម្មវិធី និងកិច្ចប្រជុំនានា ត្រូវមានសុវត្ថិភាព និងធំទូលាយ។ អ្នកចូលរួមទាំងអស់ (ទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិល) ត្រូវទទួលបាននូវព័ត៌មានដែលពាក់ព័ន្ធព្រមទាំងមានពេលវេលាគ្រប់គ្រាន់ក្នុងការត្រៀមខ្លួនដោះស្រាយ។ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ដែលបានទទួលការបណ្តុះបណ្តាលមានតួនាទីសំខាន់ក្នុងការៈ

- ជួយរៀបចំឱ្យមានអ្នកចូលរួម សម្របសម្រួលឱ្យមានការចូលរួមពីតំណាងរបស់ក្រុមប្រជាពលរដ្ឋផ្សេងៗ (ដូចជា ស្ត្រី យុវវ័យ កុមារ ជនពិការ ជនជាតិដើម និងប្រជាពលរដ្ឋក្រីក្រ)
- លើកកម្ពស់ឱ្យមានការចូលរួម និងបញ្ចេញមតិយោបល់ ប្រកបដោយសមធម៌ និងសកម្ម (នៃតំណាងក្រុមប្រជាពលរដ្ឋផ្សេងៗ)នៅក្នុងពេលប្រជុំ
- គ្រប់គ្រង សម្របសម្រួលការខ្វែងមតិយោបល់គ្នា ឬភាពប្រទាំងប្រទើសផ្សេងៗដែលអាចកើតមាន
- ផ្តល់យោបល់ដល់ក្រុមនានាដែលចូលរួមឱ្យទទួលបាននូវលទ្ធផលល្អប្រសើរ
- ធានាឱ្យមានការតាមដានប្រកបដោយប្រសិទ្ធភាព។

សមាសភាគទី៣ មានគោលដៅពង្រឹងគណនេយ្យភាពសង្គមដោយណែនាំ និងអប់រំឱ្យមានទំលាប់ថ្មីមួយក្នុងការចូលរួមដោយស្ថាបនារវាងប្រជាពលរដ្ឋ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយត្រូវឱ្យមានការចូលរួមពីអ្នកជំនាញ និងអង្គការដែលអាចសម្របសម្រួលដំណើរការដូចបានលើកឡើងក្នុងសមាសភាគទី១ និងទី២។ ក្នុងនោះរួមមានៈ ១) ផ្តល់ការបណ្តុះបណ្តាល និងផ្តល់យោបល់ណែនាំដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ២)ការគាំទ្របន្តដោយអង្គការជាដៃគូអនុវត្ត និងត្រូវខិតខំពង្រឹងសមត្ថភាពអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ៣)ជួយដល់អ្នកនៅមូលដ្ឋានទាំងអស់ (អង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ ប្រជាពលរដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវា) ឱ្យទទួលបាននូវចំណេះដឹងជាក់ស្តែងមានសមត្ថភាព និងជំនាញចាំបាច់នានា សម្រាប់អនុវត្តគណនេយ្យភាពសង្គម និងធ្វើយ៉ាងណាឱ្យមានទំនាក់ទំនងក្នុងន័យស្ថាបនា និងប្រកបដោយប្រសិទ្ធភាព។

**ដើម្បីសម្រេចលទ្ធផលរំពឹងទុកនៃសមាសភាគនេះ ផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់ ត្រូវអនុវត្តសកម្មភាពដូចខាងក្រោមៈ**

**ផ្នែកតម្រូវការៈ** សមាសភាគនេះ បង្ហាញអំពីតម្រូវការធនធានមនុស្សដែលចាំបាច់ក្នុងការធ្វើឱ្យប្រសើរឡើងនូវការប្រាស្រ័យទាក់ទងរវាងស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល និងឯកជននៅថ្នាក់មូលដ្ឋាន។ ក្រៅពីនេះត្រូវផ្តោតលើការកសាងសមត្ថភាពជំនាញរបស់ប្រជាពលរដ្ឋ (ស្ត្រី និងបុរស) និងអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិដើម្បីចូលរួមប្រកបដោយន័យស្ថាបនាជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវានានា លើដំណើរការនៃការងារគណនេយ្យភាពសង្គមគឺ ព័ត៌មាន ថវិកា និងការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ។

**ផ្តល់ការបណ្តុះបណ្តាល និងផ្តល់ការហ្វឹកហ្វឺនដល់ក្រុមអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍** ដើម្បីគាំទ្រដល់ការអនុវត្តសកម្មភាពគណនេយ្យភាពសង្គម និងការប្រជុំរួមប្រកបដោយប្រសិទ្ធភាព។ សកម្មភាពដែលស្ថិតនៅក្នុងសមាសភាគទី៣ ត្រូវកសាងសមត្ថភាពដល់អង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិមួយចំនួន និងគាំទ្រ

សកម្មភាព ដែលទាក់ទងនឹងគណនេយ្យភាពសង្គម ដោយផ្តោតលើប្រជាពលរដ្ឋ និងសមាជិកសហគមន៍ (ផ្តោតជាសំខាន់លើស្ត្រី យុវវ័យ កុមារ ជនជាតិដើម និងជនពិការ)។

**ផ្នែកផ្តត់ផ្គង់៖** សមាសភាគនេះ បង្ហាញអំពីភាពចាំបាច់នៃការប្រាស្រ័យទាក់ទងគ្នារវាងប្រជាពលរដ្ឋ និងរដ្ឋបាលមូលដ្ឋានតាមរយៈការផ្តល់ការគាំទ្រឱ្យបានសមស្របចំពោះស្ថាប័ន និងអង្គភាពរបស់រដ្ឋ ដើម្បីអាចទ្រទ្រង់ និងផ្តល់ការគាំទ្របច្ចេកទេសដល់ការអនុវត្តការងារគណនេយ្យភាពសង្គម។ កិច្ចការសំខាន់នៃសកម្មភាពអភិវឌ្ឍន៍នានានៅមូលដ្ឋាន គឺការអភិវឌ្ឍជំនាញដែលធ្វើឱ្យមានការសន្ទនា និងការសហការប្រកបដោយប្រសិទ្ធភាពនៃតួអង្គទាំងពីរ។ មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ រំពឹងថានឹងបានអភិវឌ្ឍសមត្ថភាពប្រកបដោយប្រសិទ្ធភាពអំពីរបៀបជំរុញលើកកម្ពស់ការងារគណនេយ្យភាពសង្គមជាមួយប្រជាពលរដ្ឋ អង្គការសហគមន៍នៅមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាល។

**តាមរយៈការបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធនានានៅមូលដ្ឋានអំពីគណនេយ្យភាពសង្គម និងជំនាញសម្របសម្រួល សមាសភាគទី៣មានគោលបំណងមិនត្រឹមតែគាំទ្រការចូលរួមអនុវត្តនៅក្នុងពេលចាប់ផ្តើមប្រកបដោយន័យស្ថាបនាប៉ុណ្ណោះទេ ថែមទាំងកសាងសមត្ថភាព និងជំនាញចាំបាច់ដើម្បីឱ្យការចូលរួមនោះមាននិរន្តរភាព។** អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិនឹងទទួលបានការ បណ្តុះបណ្តាលក្នុងការផ្តួចផ្តើម និងអនុវត្តគណនេយ្យភាពសង្គម ព្រមទាំងសម្របសម្រួល សហការ និងពិភាក្សាគ្នាក្នុងចំណោមស្ថាប័នអង្គភាពរបស់រាជរដ្ឋាភិបាល និងអង្គការដៃគូអនុវត្ត។

ការរំពឹងទុកថានឹងមានអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ដែលសកម្មមកពីសហគមន៍ មូលដ្ឋាន តែខ្លះទៀតអាចជាសមាជិកនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ដែលទាំងនោះគឺជាបេក្ខភាពដ៏សមស្រប ក្នុងការបំពេញតួនាទីជាអ្នកជំរុញការងារគណនេយ្យភាពសង្គម។ ការបណ្តុះបណ្តាល និងការពង្រឹងសមត្ថភាពនៅថ្នាក់មូលដ្ឋានអាចធ្វើឡើងរួមគ្នា(ទាំងស្ថាប័ន និងអង្គភាពរបស់រដ្ឋ អង្គការដៃគូអនុវត្ត)។ បទពិសោធន៍បានបង្ហាញថា ការបណ្តុះបណ្តាលរួមគ្នានឹងធ្វើឱ្យទាំងស្ថាប័ន អង្គភាពរបស់រដ្ឋ និងអង្គការដៃគូអនុវត្តកាន់តែមានភាពស្និទ្ធស្នាលជឿជាក់គ្នាទៅវិញទៅមកនិងមានកិច្ចសហការកាន់តែខ្លាំងឡើង។ ការធ្វើបែបនេះ គឺមានសារៈសំខាន់ ដើម្បីចូលរួមក្នុងន័យស្ថាបនា និងឱ្យមាននិរន្តរភាពតទៅ និងជួយដោះស្រាយជម្លោះ និងបញ្ហាពិបាកនានាដែលអាចកើតមាន។

**ដើម្បីបង្កើតឱ្យមានការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពរវាងស្ថាប័ន និងអង្គភាពរបស់រដ្ឋាភិបាលជាមួយប្រជាពលរដ្ឋ ចាំបាច់ត្រូវមានការរៀបចំក្រុមប្រជាពលរដ្ឋឱ្យបានល្អ** ហើយការសម្របសម្រួលដោយអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិគឺជាយន្តការដ៏សំខាន់ និងជាមធ្យោបាយដ៏ល្អសម្រាប់ការជួបជុំរបស់ប្រជាពលរដ្ឋ និងការបញ្ចេញមតិ ព្រមទាំងការធ្វើសកម្មភាពរួមគ្នា។ បើទោះជាការជួបជុំបញ្ចេញមតិយោបល់របស់ប្រជាពលរដ្ឋនៅមូលដ្ឋានក្នុងប្រទេសកម្ពុជានៅមានកម្រិតក៏ដោយ ប៉ុន្តែក៏មានភាពជោគជ័យក្នុងការលើកកម្ពស់នូវសិទ្ធិអំណាចរបស់ប្រជាពលរដ្ឋនៅកន្លែងមួយចំនួន តាមរយៈការបង្កើតជាអង្គការសហគមន៍មូលដ្ឋានដែរ។ ការធ្វើបែបនេះផ្តល់នូវសារៈសំខាន់ណាស់នៅក្នុងបរិបទប្រទេសកម្ពុជា ដែលជាទូទៅបុគ្គលម្នាក់ៗមានការរួញរាក្នុងការបញ្ចេញមតិយោបល់។ ផ្អែកតាមហេតុផលទាំងនេះ កម្មវិធីនេះនឹងផ្តល់ការកសាងសមត្ថភាពរបស់អង្គការសហគមន៍មូលដ្ឋាននៅក្នុងស្រុកគោលដៅ និងគាំទ្រចំពោះអង្គការសហគមន៍ទាំងនោះឱ្យដើរតួនាទីស្នូលក្នុងការលើក

កម្ពស់គណនេយ្យភាពសង្គមនៅក្នុងសហគមន៍របស់ពួកគេ។ ការរៀបចំសម្រាប់ការអនុវត្តមានបញ្ជាក់នៅក្នុងជំពូកទី៣នៃឯកសារនេះ។

### ៤.១.ការសម្របសម្រួល

អង្គការដៃគូអនុវត្តនៅថ្នាក់ជាតិ ឬអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ នឹងដើរតួនាទីសំខាន់នៅក្នុងការសម្របសម្រួល បណ្តុះបណ្តាល ហ្វឹកហ្វឺន ណែនាំ និងធ្វើការជាមួយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ដោយត្រូវផ្តល់ចំណេះដឹង ជំនាញ និងការគាំទ្រដល់អ្នកពាក់ព័ន្ធនានានៅមូលដ្ឋាន ដើម្បីអនុវត្តសកម្មភាពគណនេយ្យភាពសង្គមឱ្យបានជោគជ័យ។ តាមរយៈកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយនឹងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ អង្គការដៃគូអនុវត្តនៅថ្នាក់ជាតិ ឬអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិនឹងចាត់តាំងអ្នកសម្របសម្រួលដែលមានជំនាញ និងអ្នកបណ្តុះបណ្តាល ដើម្បីកសាងសមត្ថភាព ឱ្យចេះសម្របសម្រួលសកម្មភាពគណនេយ្យភាពសង្គមនៅមូលដ្ឋាន។ អង្គការដៃគូអនុវត្តនៅថ្នាក់ជាតិ ឬអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ ត្រូវអនុវត្តតាមសៀវភៅណែនាំស្តីពីកិច្ចប្រតិបត្តិការគណនេយ្យភាពសង្គមផ្នែកតម្រូវការឱ្យបានត្រឹមត្រូវ និងពង្រឹងសមត្ថភាពតាមមធ្យោបាយផ្សេងៗ អាស្រ័យទៅតាមសមត្ថភាព និងបរិបទតាមទំហំការងារក្នុងស្រុកនីមួយៗ។ អង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ តម្រូវឱ្យមានបុគ្គលិកទទួលបន្ទុកជាគ្រូបង្គោល ឬអ្នកផ្តល់យោបល់ ជាអ្នកគ្រប់គ្រង និងផ្នែករដ្ឋបាល។

ដើម្បីសម្រេចលទ្ធផលរំពឹងទុកនេះ សកម្មភាពមួយចំនួននឹងត្រូវអនុវត្ត ដូចជា៖

#### សកម្មភាព ៤.១.១ ការជ្រើសរើស និងការចុះកិច្ចសន្យា ជាមួយអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ

អង្គការមិនមែនរដ្ឋាភិបាល (ជាតិ និងអន្តរជាតិ) រំពឹងថានឹងធ្វើការជ្រើសរើសអង្គការដៃគូអនុវត្តនានានៅមូលដ្ឋានតាមរយៈការទំនាក់ទំនងជាមួយដៃគូដែលមានស្រាប់ ឬតាមរយៈការវាយតម្លៃស្នាដៃអនុវត្តក្នុងស្រុកគោលដៅ។ អង្គការដៃគូអនុវត្ត ត្រូវទទួលខុសត្រូវក្នុងការផ្តល់យោបល់ គាំទ្រការអភិវឌ្ឍសមត្ថភាព និងធានាឱ្យមានប្រសិទ្ធភាពក្នុងការអនុវត្តដោយអង្គការដៃគូនៅមូលដ្ឋាន។

#### សកម្មភាព ៤.១.២ ការជ្រើសរើសអង្គការសហគមន៍មូលដ្ឋានជាយុទ្ធសាស្ត្រ (ផ្តោតលើតំណាងក្រុមស្ត្រី យុវវ័យ កុមារ ជនពិការ និងជនជាតិដើម)

ដើម្បីរៀបចំសហគមន៍ឱ្យមានប្រសិទ្ធភាពនៅថ្នាក់មូលដ្ឋានសម្រាប់ការអនុវត្តសកម្មភាពគណនេយ្យភាពសង្គម ត្រូវកំណត់អង្គការសហគមន៍មូលដ្ឋានណាដែលមានចំណាប់អារម្មណ៍ជាមួយនឹងគណនេយ្យភាពសង្គម។ អង្គការសហគមន៍មូលដ្ឋាននោះ ត្រូវបំពេញតួនាទីជាអ្នកអនុវត្តគម្រោង និងជាអ្នកទទួលផល។ អង្គការដៃគូមូលដ្ឋានគួរជ្រើសរើស និងចុះកិច្ចព្រមព្រៀងជាដៃគូជាមួយអង្គការសហគមន៍មូលដ្ឋាន នៅក្នុងស្រុកគោលដៅនីមួយៗ។ ដោយសារតែអង្គការសហគមន៍មូលដ្ឋានទាំងនោះ ត្រូវដើរតួនាទីសំខាន់ជាភ្នាក់ងារដែលបណ្តាលឱ្យមានការផ្លាស់ប្តូរ ហេតុនេះត្រូវផ្តល់អាទិភាពជ្រើសរើសអង្គការសហគមន៍មូលដ្ឋានណាដែលមានតំណាងស្ត្រី យុវវ័យ កុមារ ជនពិការ ជនជាតិដើម និងប្រជាពលរដ្ឋក្រីក្រភាគច្រើន។ ក្នុងអំឡុងពេលនៃការអនុវត្ត អង្គការសហគមន៍មូលដ្ឋានត្រូវចូលរួមក្នុងការអភិវឌ្ឍសមត្ថភាពនិងសកម្មភាពរៀនសូត្រតាម រយៈការអនុវត្តដោយផ្ទាល់។

### សកម្មភាព ៤.១.៣ ការជ្រើសរើស ការចងក្រង អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ជាក្រុម (ផ្តោតលើស្ត្រី យុវវ័យ)

ចំណុចសំខាន់របស់កម្មវិធី គឺការបង្កើតឱ្យមានក្រុមអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (ដោយស្ម័គ្រចិត្ត) ដែលទទួលការបណ្តុះបណ្តាលនៅក្នុងស្រុកគោលដៅនីមួយៗ (មានចំនួនយ៉ាងតិច៤នាក់ក្នុងមួយឃុំ)។ ត្រូវលើកទឹកចិត្តឲ្យមានអ្នកសម្របសម្រួលជាស្ត្រីចំនួន៥០% យ៉ាងតិច និងអ្នកសម្របសម្រួលដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ ។ សៀវភៅណែនាំស្តីពីកិច្ចប្រតិបត្តិការគណនេយ្យភាពសង្គមផ្នែកតម្រូវការ នឹងមានរៀបរាប់ពីមធ្យោបាយក្នុងការសម្រេចបានគោលដៅខាងលើនេះ។ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ដែលបានជ្រើសរើស នឹងជួយឱ្យអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិចូលរួមជាប្រចាំនៅក្នុងសកម្មភាពនៃកម្មវិធី ហើយជួយជំរុញដល់ការអភិវឌ្ឍសមត្ថភាព និងជួយពង្រឹងដល់អង្គការសហគមន៍មូលដ្ឋាន ផ្ទេរចំណេះដឹង និងជំនាញដល់សមាជិក សហគមន៍មូលដ្ឋានផ្សេងទៀត។

ដោយមានការគាំទ្រពីអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍នឹងអនុវត្តសកម្មភាពមួយចំនួនសម្រាប់ប្រជាពលរដ្ឋនៅមូលដ្ឋាន និងសមាជិកសហគមន៍មូលដ្ឋាន ដោយផ្តល់ជាដំណឹងដល់ប្រជាពលរដ្ឋ ជួយសម្របសម្រួល និងពង្រឹងសមត្ថភាព ដើម្បីអនុវត្តការងារគណនេយ្យភាពសង្គម និងឱ្យមានការចូលរួមក្នុងន័យស្ថាបនាជាមួយរដ្ឋបាលមូលដ្ឋាន និងអង្គភាពផ្តល់សេវា។ សកម្មភាពនៃការរៀនសូត្រតាមរយៈការអនុវត្តផ្ទាល់ ត្រូវផ្តោតជាពិសេសចំពោះការចូលរួមរបស់ស្ត្រី យុវវ័យ កុមារ ជនពិការ ជនជាតិដើម និងប្រជាពលរដ្ឋក្រីក្រដែលចាត់ទុកថាជាក្រុមគោលដៅ និងនាំឱ្យមានភាពប្រសើរឡើងនៃការផ្តល់សេវា។ ក្រុមនេះ នឹងផ្តោតទៅលើបញ្ហាដែលទាក់ទងនឹងកញ្ចប់ព័ត៌មាន (សិទ្ធិ ថវិកា ការបំពេញការងារ និងស្តង់ដារ) ភាពជាម្ចាស់ដែលសកម្មក្នុងការចូលរួមស្ថាបនារបស់ប្រជាពលរដ្ឋ ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្នុងការងារគណនេយ្យភាពសង្គម ដូចដែលបានរៀបរាប់នៅក្នុងសមាសភាគទី១ និងទី២ខាងលើ។ ការអភិវឌ្ឍសមត្ថភាពអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ដែលត្រូវធ្វើឡើង តាមការបណ្តុះបណ្តាល និងការរៀនសូត្រតាមរយៈការអនុវត្តផ្ទាល់ ដែលធ្វើឱ្យអ្នកសម្របសម្រួលគណនេយ្យសហគមន៍ អាចទទួលបានចំណេះដឹងច្បាស់លាស់ អាចអនុវត្តបាន និងបង្កើតឱ្យមានបណ្តាញជាច្រើន ទាំងអ្នកជំរុញលើកទឹកចិត្ត ទាំងអ្នកអនុវត្តដែលមានសមត្ថភាពនៅថ្នាក់មូលដ្ឋាន ទាំងខាងអង្គការសង្គមស៊ីវិល និងក្រុមប្រឹក្សាឃុំ ហើយពួកគេត្រូវបានផ្តល់សិទ្ធិអំណាចដើម្បីផ្តួចផ្តើម និងធ្វើឱ្យមាននិរន្តរភាពក្នុងការអនុវត្តការងារគណនេយ្យភាពសង្គមនៅមូលដ្ឋាន។ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ដែលបានបញ្ចប់វគ្គបណ្តុះបណ្តាល និងអនុវត្តការងារដោយជោគជ័យ នឹងទទួលបានលិខិតបញ្ជាក់ ។

### សកម្មភាព ៤.១.៤ ការបង្កើតសហគមន៍អនុវត្ត ដើម្បីផ្តល់ការគាំទ្រជាប្រចាំដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍

ផ.អ.គ.ស នឹងប្រើប្រាស់ទិន្នន័យព័ត៌មានគណនេយ្យភាពសង្គម ប្រព័ន្ធព័ត៌មានសង្គម និងទម្រង់ផ្សេងៗទៀតនៃការប្រាស្រ័យទាក់ទង ដើម្បីគាំទ្រដល់អ្នកសម្របសម្រួល និងសហគមន៍មូលដ្ឋានជាដៃគូផ្សេងៗ។ ការប្រើប្រាស់នេះរួមបញ្ចូលនូវការបង្កើតឱ្យមានទិន្នន័យថ្នាក់ជាតិមួយដែលមានព័ត៌មានទាក់ទងនឹងអ្នកសម្របសម្រួលគណនេយ្យភាពសង្គម(ដើម្បីលើកកម្ពស់បណ្តាញទំនាក់ទំនង និងជំនាញនានា) ការបង្កើតក្រុមបណ្តាញទំនាក់ទំនងសង្គមសម្រាប់អ្នកសម្របសម្រួលគណនេយ្យភាពសង្គម ដើម្បីជំរុញលើកកម្ពស់ការពិភាក្សា ការចែករំលែក

ព័ត៌មាន និងផ្សព្វផ្សាយព័ត៌មានថ្មីៗ។ សកម្មភាពនេះនឹងពឹងផ្អែកទៅលើលទ្ធភាពផ្នែកហិរញ្ញវត្ថុរបស់អង្គការដៃគូអនុវត្ត ។

### ៤.២. ការបណ្តុះបណ្តាល ការហ្វឹកហ្វឺន និងការពង្រឹងសមត្ថភាព

ក្រុមគ្រូឧទ្ទេសថ្នាក់ជាតិនឹងបង្កើតឡើងដោយប្រើគ្រូបង្គោលមកពីលេខាធិការដ្ឋានគ.ជ.អ.ប ក្រសួងស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូអនុវត្តថ្នាក់ជាតិ ដែលក្រុមនេះនឹងដើរតួនាទីជាអ្នកគាំទ្រដល់ដៃគូអនុវត្តទាំងស្ថាប័ន និងអង្គភាពរបស់រដ្ឋ និងអង្គការសង្គមស៊ីវិលលើការផ្តល់ការបណ្តុះបណ្តាល រៀបចំកម្មវិធីសម្រាប់កសាងសមត្ថភាព និងវិធីសាស្ត្ររៀនសូត្រតាមរយៈការអនុវត្តផ្ទាល់ ព្រមទាំងបណ្តុះបណ្តាលគ្រូបង្គោលរបស់ដៃគូអនុវត្តទាំងអស់ក៏ដូចជាគ្រូបង្គោលជាមន្ត្រីរាជរដ្ឋាភិបាល។ ការងារគណនេយ្យភាពសង្គមតម្រូវឱ្យមានក្រុមគ្រូឧទ្ទេសថ្នាក់ជាតិរួមគ្នាសម្រាប់ផ្តល់ការបណ្តុះបណ្តាល ទាំងអង្គភាពរបស់រាជរដ្ឋាភិបាល និងអង្គការដៃគូអនុវត្ត មានអត្ថប្រយោជន៍ច្រើនដោយសារតែមានប្រធានបទច្រើនដែលត្រួតគ្នា (ឧទាហរណ៍ដូចជា ការផ្តល់ការណែនាំទូទៅខ្លឹមសារព័ត៌មានសម្រាប់ប្រជាពលរដ្ឋ គោលការណ៍បើកចំហនៃព័ត៌មាននិងកិច្ចប្រជុំរួមគ្នាជាដើម)។ ក្នុងនោះក្រុមគ្រូឧទ្ទេសថ្នាក់ជាតិត្រូវ៖

- រៀបចំឱ្យមានកម្មវិធីបណ្តុះបណ្តាល សម្ភារៈបណ្តុះបណ្តាល និងវិធីសាស្ត្រនានា
- បណ្តុះបណ្តាលដល់គ្រូបង្គោលថ្នាក់ខេត្ត និងស្រុកទាំងអង្គភាពរបស់រដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល
- ផ្តល់ការគាំទ្រ ហ្វឹកហ្វឺន ការណែនាំជាបន្តបន្ទាប់ ព្រមទាំងជំនួយបច្ចេកទេសដែលត្រូវការ។

លទ្ធផលរំពឹងនេះ អាចសម្រេចបាន លុះត្រាតែបានអនុវត្តសកម្មភាពសំខាន់ៗមួយចំនួន ដូចជា៖

#### សកម្មភាព ៤.២.១ ការរៀបចំក្រុមគ្រូឧទ្ទេសថ្នាក់ជាតិស្តីពីគណនេយ្យភាពសង្គម

សកម្មភាពលម្អិតនេះរួមមាន៖ ១)រៀបចំល័ក្ខខ័ណ្ឌការងារសម្រាប់ក្រុមគ្រូឧទ្ទេសថ្នាក់ជាតិ ២) ជ្រើសរើសសមាសភាព (ធនធានមនុស្ស) ដែលមានសមត្ថភាព ជំនាញ បទពិសោធន៍ បណ្តុះបណ្តាលមកពីក្រសួង ស្ថាប័នអនុវត្តទាំងពីរ (ផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ) និង ៣)រៀបចំនិតិវិធី កម្មវិធី ផែនការសកម្មភាពអភិវឌ្ឍសមត្ថភាព និងថវិការួមគ្នាសម្រាប់អនុវត្តសកម្មភាពបណ្តុះបណ្តាល និងពង្រឹងសមត្ថភាព សម្រាប់ផ្នែកតម្រូវការ ក្រុមអភិវឌ្ឍសមត្ថភាពនឹងផ្តល់ការបណ្តុះបណ្តាលដល់គ្រូបង្គោល គឺត្រូវផ្តល់ចំពោះបេក្ខជនដែលបានជ្រើសរើសពីអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិដែលនឹងត្រូវបណ្តុះបណ្តាល និងណែនាំបន្តដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍។ បុគ្គលិកដែលចាត់តាំងមកពីអង្គការដៃគូអនុវត្តនៅថ្នាក់ជាតិនឹងត្រូវចូលរួមចំណែកផងដែរនៅក្នុងការបណ្តុះបណ្តាលដល់គ្រូបង្គោល។ ក្រុមគ្រូឧទ្ទេសថ្នាក់ជាតិនឹងផ្តល់ការបណ្តុះបណ្តាលរំលឹកឡើងវិញ និងការគាំទ្រជាប្រចាំព្រមទាំងធ្វើការងារជាមួយអង្គការដៃគូអនុវត្តនៅថ្នាក់ជាតិដែលជាអ្នកអនុវត្ត ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងនូវកម្មវិធីបណ្តុះបណ្តាល និងយុទ្ធសាស្ត្រក្នុងការរៀនសូត្រតាមរយៈការអនុវត្តផ្ទាល់ក្នុងកំឡុងពេល៣ឆ្នាំដំបូងនៃកម្មវិធី។ សម្រាប់ផ្នែកផ្គត់ផ្គង់ ត្រូវសម្របសម្រួលជាមួយលេខាធិការដ្ឋានគ.ជ.អ.ប និងប្រើយន្តការមណ្ឌលអភិវឌ្ឍធនធានមនុស្សថ្នាក់ខេត្ត ដើម្បីផ្តល់ការបណ្តុះបណ្តាលបន្តដល់មន្ត្រីនៅថ្នាក់ស្រុក រដ្ឋបាលឃុំ (រួមទាំងមន្ត្រីសុខាភិបាល និងអប់រំ) និងបន្តការគាំទ្រកសាងសមត្ថភាពឱ្យបានគ្រប់គ្រាន់ផងដែរ។

### សកម្មភាព ៤.២.២ ការរៀបចំកម្មវិធី សម្ភារៈ និងវិធីសាស្ត្របណ្តុះបណ្តាលសម្រាប់ផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់

ក្រុមគ្រូឧទ្ទេសថ្នាក់ជាតិត្រូវរៀបចំសម្ភារៈបណ្តុះបណ្តាលទាំងអស់ដើម្បីកសាងសមត្ថភាព និងធ្វើការបណ្តុះបណ្តាល។ កម្មវិធីបណ្តុះបណ្តាលត្រូវ៖

- ផ្អែកលើគោលការណ៍នៃការសិក្សាសម្រាប់មនុស្សពេញវ័យ និងការរៀនសូត្រតាមរយៈការអនុវត្តផ្ទាល់ និងសកម្ម (ដោយបញ្ចូលវដ្តនៃព័ត៌មាន ការឆ្លុះបញ្ចាំង និងសកម្មភាពនានា)
- ធ្វើការសាកល្បងមុននឹងដាក់ឱ្យអនុវត្ត
- បង្កើតឡើងដោយមានការចូលរួម មានលំហាត់អនុវត្ត និងមានមធ្យោបាយវាយតម្លៃវគ្គ
- កំណត់អំពីតម្រូវការផ្សេងៗរបស់ស្ត្រី យុវវ័យ កុមារ ជនពិការ ជនជាតិដើម និងក្រុមប្រជាពលរដ្ឋផ្សេងៗទៀត។

លេខាធិការដ្ឋានគ.ជ.អ.ប និងក្រុមគ្រូឧទ្ទេសថ្នាក់ជាតិ នឹងសហការគ្នា ដើម្បីរៀបចំជាកម្មវិធី និងសម្ភារៈបណ្តុះបណ្តាលឱ្យបានសមស្របសម្រាប់អង្គភាពរដ្ឋបាលថ្នាក់ក្រោមជាតិ (នៅថ្នាក់ស្រុក និងឃុំ)។ យោងតាមសកម្មភាពពាក់ព័ន្ធនិងការសិក្សារៀនសូត្រ(សមាសភាគទី៤) កម្មវិធី និងសម្ភារៈបណ្តុះបណ្តាលទាំងនោះនឹងត្រូវយកមកពិនិត្យមើល និងកែសម្រួលឡើងវិញជារៀងរាល់ឆ្នាំតាមការចាំបាច់។

### សកម្មភាព ៤.២.៣ ការពង្រឹងសមត្ថភាពដល់អង្គការដៃគូអនុវត្តនៅថ្នាក់ជាតិ និងអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ ដើម្បីឱ្យក្លាយជាគ្រូបង្គោល

សកម្មភាពនេះមានគោលបំណងកសាងសមត្ថភាពអង្គការដៃគូអនុវត្តន៍នៅថ្នាក់ជាតិ និងអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ តាមរយៈការប្រើប្រាស់វិធីសាស្ត្របណ្តុះបណ្តាលគ្រូបង្គោល។ យន្តការមួយចំនួនទៀតក៏ត្រូវបានប្រើប្រាស់ដែរ ដើម្បីឱ្យអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិមានសមត្ថភាពអាចផ្តល់ការគាំទ្រ និងមានជំនួយបច្ចេកទេសដែលពួកគេត្រូវការ ដើម្បីបំពេញតួនាទីប្រកបដោយជោគជ័យ និងមានប្រសិទ្ធភាព។ នៅក្នុងដំណាក់កាលដំបូង បុគ្គលិកពាក់ព័ន្ធនានាដែលមកពីអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិទាំងអស់ ចូលរួមក្នុងវគ្គបណ្តុះបណ្តាលគ្រូបង្គោល ដើម្បីទទួលបានចំណេះដឹងនិងជំនាញដែលត្រូវការ សម្រាប់យកទៅបណ្តុះបណ្តាលបន្តដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍។ ការបណ្តុះបណ្តាលគ្រូបង្គោលនឹងធ្វើឡើងនៅថ្នាក់ជាតិមានរយៈពេលយ៉ាងតិច៥ថ្ងៃ។ សកម្មភាពអភិវឌ្ឍសមត្ថភាព និងការអនុវត្តនានានឹងត្រូវផ្តល់ក្នុងអំឡុងពេលនៃកម្មវិធី ដោយអនុញ្ញាតឱ្យអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិអាចបន្តពង្រឹងចំណេះដឹង សមត្ថភាពជំនាញនានាបន្ថែមទៀត។

អង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិនឹងទទួលបាននូវគោលការណ៍ណែនាំទាក់ទងទៅនឹងការបណ្តុះបណ្តាលដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ (ដែលបានរៀបចំដោយក្រុមគ្រូឧទ្ទេសថ្នាក់ជាតិ) ព្រមទាំងទទួលបានព័ត៌មានដែលមានសារៈសំខាន់ និងការណែនាំអំពីវិធីសាស្ត្រដែលចាំបាច់នានា ដើម្បីឱ្យពួកគេអាចបន្តផ្តល់ការបណ្តុះបណ្តាលតាមវិធីសាស្ត្រផ្សេងៗ និងផ្តល់ការពង្រឹងសមត្ថភាពតាមបែបអនុវត្តផ្ទាល់ដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍។ ត្រូវលើកទឹកចិត្តដល់បុគ្គលិកអង្គការដៃគូអនុវត្តនៅថ្នាក់ជាតិ និងនៅមូលដ្ឋានឱ្យអាចធ្វើការសម្របសម្រួល និងកែសម្រួលសម្ភារៈបណ្តុះបណ្តាលឱ្យបានសមស្រប រួមចំណែកកែលម្អសៀវភៅបណ្តុះបណ្តាលស្តីពីកិច្ចប្រតិបត្តិការគណនេយ្យភាពសង្គមកាន់តែប្រសើរឡើង។

ក្រៅពីការបណ្តុះបណ្តាលគ្រូបង្គោល និងការផ្តល់ធនធានសម្រាប់ការបណ្តុះបណ្តាលដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ អង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិក៏ត្រូវទទួលបានការផ្តល់យោបល់ជាប្រចាំ ការគាំទ្រផ្នែកប្រតិបត្តិការ និងជំនួយផ្នែកបច្ចេកទេសពីអង្គការដៃគូអនុវត្តនៅថ្នាក់ជាតិ (ដោយមានការជួយគាំទ្រពីក្រុមគ្រូឧទ្ទេសថ្នាក់ជាតិក្នុងការបណ្តុះបណ្តាលតាមតម្រូវការ)។

**សកម្មភាព ៤.២.៤ ការបណ្តុះបណ្តាលមន្ត្រីថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក ឱ្យក្លាយជាគ្រូបង្គោល**

ក្រុមគ្រូឧទ្ទេសថ្នាក់ជាតិនឹងទទួលខុសត្រូវក្នុងការរៀបចំកម្មវិធីកសាងសមត្ថភាពជូនដល់អង្គភាពរដ្ឋបាលនានា និងធ្វើការបណ្តុះបណ្តាលគ្រូបង្គោលដល់មន្ត្រីពាក់ព័ន្ធនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក (រួមទាំងមន្ត្រី និងបុគ្គលិកសុខាភិបាល និងអប់រំ ថ្នាក់ខេត្ត ស្រុកផងដែរ)។ ការបណ្តុះបណ្តាលគ្រូបង្គោលនឹងធ្វើនៅថ្នាក់ជាតិ និងមានរយៈពេលយ៉ាងតិចចំនួន៥ថ្ងៃ។ ការបណ្តុះបណ្តាលនេះជាការបំពេញបន្ថែមលើកម្មវិធីបណ្តុះបណ្តាលនានា ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**សមាសភាគទី៣** គឺសំដៅបង្កើតឱ្យមានការប្រាស្រ័យទាក់ទង និងការចូលរួមប្រកបដោយប្រសិទ្ធភាពរវាងប្រជាពលរដ្ឋ និងសមាជិកក្រុមប្រឹក្សាឃុំ។ សមាសភាគនេះនឹងបង្កើតឱ្យមានក្រុមគ្រូឧទ្ទេសថ្នាក់ជាតិដែលមានសមត្ថភាព ជំនាញសម្របសម្រួល ព្រមទាំងបានអភិវឌ្ឍសមត្ថភាពដល់អង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការសម្របសម្រួលឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាព។ ដើម្បីសម្រេចបានកិច្ចការនេះ ត្រូវរៀបចំចងក្រងនូវសម្ភារ ការបណ្តុះបណ្តាលគ្រូបង្គោល ព្រមទាំងមានកម្មវិធីបណ្តុះបណ្តាលផ្ទាល់ និងការរៀនសូត្រតាមរយៈការអនុវត្តដោយផ្ទាល់ជាប្រចាំ។ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍នឹងទទួលបានការគាំទ្រដោយការអនុវត្តសកម្មភាពនានា។ លទ្ធផលនេះនឹងផ្តោតលើសេចក្តីត្រូវការក្នុងការចូលរួមជាលក្ខណៈប្រព័ន្ធរបស់ស្ត្រី យុវវ័យ កុមារ ជនជាតិដើម និងជនពិការក្នុងការចូលរួមដោយពេញលេញ។

## តារាងទី ៤៖ សង្ខេបអំពីសមាសភាគស្តីពីការសម្របសម្រួលនិងការពង្រឹងសមត្ថភាព

| ផ្នែក | ការរៀបរាប់ |
|---|---|
| **គោលបំណង** | បង្កើតឱ្យមានក្រុមជំនាញក្នុងការសម្របសម្រួលឱ្យមានការចូល រួមពីតួអង្គរដ្ឋ និងមិនមែនរដ្ឋនៅក្នុងដំណើរការគណនេយ្យភាពសង្គមប្រកបដោយលក្ខណៈស្ថាបនា និងទទួលបានលទ្ធផលល្អប្រសើរ។<br><br>ធ្វើការអភិវឌ្ឍសមត្ថភាពរបស់តួអង្គរដ្ឋ និងមិនមែនរដ្ឋដែលគាំទ្រសកម្មភាពនៅថ្នាក់មូលដ្ឋានដើម្បីចូលរួមនៅក្នុងដំណើរការក្របខណ្ឌគណនេយ្យភាពសង្គម។ |
| **សមិទ្ធផល និងសូចនាករ** | **ការពង្រឹងសិទ្ធិអំណាច និងសមត្ថភាពប្រជាពលរដ្ឋ**<br>• ការពង្រឹងសិទ្ធិអំណាចសហគមន៍ (ជាពិសេសស្ត្រី និងយុវវ័យ កុមារ ជនពិការ ជនជាតិដើម) ដោយមានការផ្លាស់ប្តូរ ឱ្យកាន់តែសកម្មក្នុងការចូលរួម<br>• ប្រជាពលរដ្ឋមានការយល់ដឹងច្រើនអំពីសិទ្ធិទទួលសេវា និងការបំពេញការងាររបស់អ្នកផ្តល់សេវា<br>**សមត្ថភាពតួអង្គមូលដ្ឋាន** |

| | |
|---|---|
| | • បន្តការហ្វឹកហ្វឺនដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ដើម្បីឲ្យមានសមត្ថភាព និងឆន្ទៈក្នុងការដឹកនាំការងារគណនេយ្យភាពទាំងការសម្របសម្រួល និងការផ្សព្វផ្សាយ<br>• អង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិមានលទ្ធភាពកាន់តែច្រើនក្នុងការហ្វឹកហ្វឺន និងគាំទ្រសកម្មភាពសហគមន៍<br>• តួអង្គរដ្ឋនៅថ្នាក់មូលដ្ឋានមានការយល់ដឹងជាងមុនអំពីគណនេយ្យភាពសង្គម និងការអនុវត្តសកម្មភាព |
| លទ្ធផលរំពឹងទុក | ៤.១.ការសម្របសម្រួល<br>សកម្មភាព ៤.១.១ ការជ្រើសរើស និងការចុះកិច្ចសន្យា ជាមួយអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ ដែលគាំទ្រអ្នកសម្របសម្រួលគណនេយ្យភាពនៅមូលដ្ឋាន<br>សកម្មភាព ៤.១.២ ការជ្រើសរើសអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិជាយុទ្ធសាស្ត្រ (ផ្តោតលើក្រុម ស្ត្រី យុវវ័យ កុមារ និងជនពិការ)<br>សកម្មភាព ៤.១.៣ ការជ្រើសរើស ការចងក្រង អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ជាក្រុម (ផ្តោតលើស្ត្រី យុវវ័យ កុមារ ជនពិការ)<br>សកម្មភាព ៤.១.៤ ការបង្កើតសហគមន៍អនុវត្ត ដើម្បីផ្តល់ការគាំទ្រជាប្រចាំដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍<br>៤.២.ការបណ្តុះបណ្តាល ការហ្វឹកហ្វឺន និងកសាងសមត្ថភាព[23]<br>សកម្មភាព ៤.២.១ ការរៀបចំក្រុមគ្រូឧទ្ទេសស្តីពីគណនេយ្យភាពសង្គម<br>សកម្មភាព ៤.២.២ ការរៀបចំកម្មវិធី សម្ភារៈនិងវិធីសាស្ត្របណ្តុះបណ្តាលសម្រាប់ផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់<br>សកម្មភាព ៤.២.៣ ការពង្រឹងសមត្ថភាព ដល់អង្គការដៃគូនៅថ្នាក់ជាតិ និងមូលដ្ឋាន ដើម្បីឱ្យក្លាយជាគ្រូបង្គោល<br>សកម្មភាព ៤.២.៤ ការបណ្តុះបណ្តាលមន្ត្រីថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក ឱ្យក្លាយជាគ្រូបង្គោល |

## ៥.សមាសភាគទី៤៖ ការប្រមូលមេរៀនបទពិសោធន៍ និងការត្រួតពិនិត្យតាមដាន

សមាសភាគទី៤នេះ ផ្តល់អាទិភាពលើការប្រមូលមេរៀនបទពិសោធន៍ ក្នុងការអនុវត្តកិច្ចការសំខាន់ៗនៃផែនការសកម្មភាពគណនេយ្យភាពសង្គម ដូចជាព័ត៌មានថវិកា និងការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ ការសម្របសម្រួល និងការអភិវឌ្ឍសមត្ថភាព។ ដើម្បីលើកកម្ពស់ការអនុវត្តសកម្មភាពគណនេយ្យភាពសង្គម ផ.អ.គ.ស នឹងបញ្ចូលកិច្ចការសំខាន់ គឺចងក្រងមេរៀនបទពិសោធន៍ និងបង្កើតឱ្យមានទម្លាប់នៃការសិក្សារៀនសូត្រអំពីបទ

[23]សមាសភាគទី៣ រួមបញ្ចូលការបណ្តុះបណ្តាលតាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់ស្រុក (សម្រាប់ទាំងភាគីរដ្ឋបាល និងអង្គការនានា)។ សមាសភាពទី១ និងទី២ ផ្តោតលើលទ្ធផលសំខាន់ៗមួយចំនួន ដូចជា ការលើកកម្ពស់ការយល់ដឹង និងការពង្រឹងសមត្ថភាពអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ អង្គការសហគមន៍មូលដ្ឋាន និងប្រជាពលរដ្ឋ និងការបណ្តុះបណ្តាលដល់ភ្នាក់ងារឃុំ និងអ្នកផ្តល់សេវានានា។

ពិសោធន៍របស់អ្នកពាក់ព័ន្ធនានា។ គោលបំណងចំបងនៃសមាសភាគនេះ គឺដើម្បីឱ្យមេរៀនបទពិសោធន៍ជាក់ស្តែងដែលទទួលបានបញ្ចូលទៅក្នុងការអនុវត្តកម្មវិធី។ ការសម្រេចបាននូវគោលបំណងនេះ មិនមែនជាការងាយស្រួលឡើយ មេរៀនបទពិសោធន៍ថ្មីៗបានបង្ហាញអំពីឧបសគ្គជាច្រើននៅក្នុងការរៀនសូត្រអំពីដំណើរការអភិវឌ្ឍនានា មិនមែនតែការងារគណនេយ្យភាពសង្គមប៉ុណ្ណោះទេ។ ដើម្បីដោះស្រាយឧបសគ្គនេះ ការបង្កើតទម្លាប់ក្នុងការសិក្សារៀនសូត្រ គឺជាគោលបំណងចម្បងនៃសមាសភាគនេះ។

**ការងារចម្បងរបស់ ផ.អ.គ.ស គឺត្រូវធ្វើយ៉ាងណាឱ្យមានការយល់ដឹងនៅមូលដ្ឋាន អំពីកិច្ចការណាខ្លះដែលអនុវត្តបាន ឬអនុវត្តមិនបាន ដែលត្រូវមានការចែករំលែកនូវមេរៀនបទពិសោធន៍ដែលទទួលបានឱ្យទូលំទូលាយ និងផ្តល់មតិយោបល់លើការកែសម្រួលគោលនយោបាយ។** ការផ្តោតជាចម្បងក្នុងការសិក្សារៀនសូត្រនេះ គឺសម្រាប់អ្នកពាក់ព័ន្ធនានានៅមូលដ្ឋាន រួមមាន៖ អង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវធ្វើការរួមគ្នាក្នុងការអនុវត្តដំណើរការនៃការផ្តល់ព័ត៌មាន បើកចំហថវិកា ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ។ អ្នកពាក់ព័ន្ធទាំងនេះនឹងផ្តល់ព័ត៌មាន ត្រឡប់អំពីគោលការណ៍ណែនាំ ការសាកល្បងនានា ព្រមទាំងផ្តល់យោបល់ផ្តួចផ្តើមដោយផ្តោតទៅលើគោលគំនិត ខ្លឹមសារ ដំណើរការ និងការរៀបចំរចនាសម្ព័ន្ធ និងយន្តការស្ថាប័ន ជាដើម។ សមាសភាគនេះនឹង៖

១) ផ្តួចផ្តើមសកម្មភាពនានាទៅតាមស្ថានភាពនៅមូលដ្ឋាន និងសហគមន៍ជាក់លាក់ណាមួយ ដែលអាចចែករំលែក និងយកទៅអនុវត្តបាននៅកន្លែងដទៃទៀត
២) អនុញ្ញាតឱ្យអ្នកពាក់ព័ន្ធនានាអាចបញ្ចេញមតិដោយសេរីលើកិច្ចការដែលអាចអនុវត្តបាន ឬមិនបាន
៣) ធានាថាគោលនយោបាយ និងគោលការណ៍ណែនាំនានារបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងតម្លាភាព និងគណនេយ្យភាពមានការឆ្លើយតបចំពោះបញ្ហា និងអាចអនុវត្តបានដោយជោគជ័យ។

**ដើម្បីអនុវត្តកិច្ចការនេះឱ្យបានល្អប្រសើរ និងអនុវត្តបានទាំងស្រុង ផ.អ.គ.ស ត្រូវមានការចូលរួមពីអង្គការដៃគូជំនាញផ្នែកប្រមូលចងក្រងមេរៀនបទពិសោធន៍។** អង្គការដៃគូជំនាញផ្នែកចងក្រងមេរៀនបទពិសោធន៍នឹងបង្កើតឱ្យមានវេទិកាសម្រាប់សិក្សារៀនសូត្រ និងត្រួតពិនិត្យពីថ្នាក់មូលដ្ឋានដល់ថ្នាក់ជាតិ ដូចបានរៀបរាប់នៅក្នុងលទ្ធផលខាងក្រោម។ ដៃគូជំនាញនេះនឹងបង្កើតជាវេទិការួមមួយ ដើម្បីទទួលបានមតិឆ្លុះបញ្ចាំង និងព័ត៌មានត្រឡប់ទៅលើគោលនយោបាយ និងការអនុវត្តជាក់ស្តែងទាំងស្ថាប័ន អង្គភាពរបស់ផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ។

សមាសភាគទី៤នេះ មានលទ្ធផលរំពឹងទុកចំនួនពីរ ដូចតទៅ៖

### ៥.១.ការប្រមូលមេរៀនបទពិសោធន៍ និងការផ្តល់ព័ត៌មានត្រឡប់

ដើម្បីអាចសម្រេចបានលទ្ធផលរំពឹងទុកនេះ ទាក់ទងនឹងការប្រមូលមេរៀនបទពិសោធន៍ និងការផ្តល់ព័ត៌មានត្រឡប់ ចាំបាច់ត្រូវអនុវត្តសកម្មភាពមួយចំនួន ដូច ខាងក្រោម៖

#### សកម្មភាព ៥.១.១ ការរៀបចំបង្កើតយុទ្ធសាស្រ្ត និងផែនការសកម្មភាព ពាក់ព័ន្ធការប្រមូលមេរៀនបទពិសោធន៍ដែលមានលក្ខណៈច្នៃប្រឌិត

ការបង្កើតទម្លាប់នៃការសិក្សារៀនសូត្រនឹងត្រូវបំពាក់បំប៉នបន្ថែមតាមរយៈយន្តការមួយដែលមានការច្នៃប្រឌិត និងមានរបៀបរបបជាក់លាក់។ ឧបករណ៍ និងដំណើរការនានានឹងត្រូវបង្កើតសម្រាប់ការធ្វើសេចក្តីរាយ

ការណ៍ពីមូលដ្ឋាន ចំណែកឯវេទិកាសាធារណៈនឹងត្រូវរៀបចំឡើង ដើម្បីជំរុញឱ្យមានការជជែកពិភាក្សាដេញដោលនិងសន្ទនាគ្នា តាមគោលការណ៍បើកទូលាយសម្រាប់ការសិក្សារៀនសូត្រ។ យុទ្ធសាស្ត្រ និងផែនការសកម្មភាពលម្អិតសម្រាប់សកម្មភាពសិក្សារៀនសូត្រ ការស្រាវជ្រាវ និងតាមដានត្រួតពិនិត្យ ដែលជាគោលការណ៍ណែនាំក្នុងការសិក្សារៀនសូត្រ ត្រូវរៀបចំឡើង ។ យុទ្ធសាស្ត្រនេះនឹងបញ្ចូលនូវលទ្ធផលជាច្រើនដែលត្រូវរៀបរាប់នៅផ្នែកខាងក្រោម។

### សកម្មភាព ៥.១.២ ការរៀបចំ និងផ្សព្វផ្សាយ ឧបករណ៍និងឯកសារណែនាំនានា

ដើម្បីឱ្យមានការយកចិត្តទុកដាក់កាន់តែច្រើនចំពោះ "ការសិក្សាតាមរយៈការអនុវត្តផ្ទាល់" ចាំបាច់ត្រូវមានការលើកទឹកចិត្តជាប្រចាំដល់អ្នកពាក់ព័ន្ធនានានៅមូលដ្ឋាន និងគាំទ្រឱ្យមានការចូលរួមនៅក្នុងដំណើរការនៃការឆ្លុះបញ្ចាំងនិងការអនុវត្តនានា។ គេរំពឹងថាការសិក្សារៀនសូត្រនឹងត្រូវគាំទ្រសម្របសម្រួលដោយដៃគូអនុវត្តតាមរយៈការសហការជាមួយនឹងដៃគូដទៃទៀតនៅមូលដ្ឋាន។ ការសិក្សារៀនសូត្រ គឺជាគោលបំណងសំខាន់នៅក្នុងសំណើសុំផ្តល់មូលនិធិគាំទ្រ ដែលត្រូវរៀបចំដោយដៃគូអនុវត្ត។ ការអនុវត្តនេះគឺត្រូវផ្អែកលើឯកសារណែនាំទាំងឡាយដែលបង្កើតឡើងដោយដៃគូជំនាញក្នុងការសិក្សារៀនសូត្រ។

### សកម្មភាព ៥.១.៣ ការរៀបចំវេទិកាសិក្សារៀនសូត្រ និងផ្តល់ព័ត៌មានត្រឡប់ ឱ្យបានទៀងទាត់

ការរៀបចំវេទិកាផ្លាស់ប្តូរព័ត៌មាន យោបល់ ការជជែកពិភាក្សា និងការសន្ទនាគ្នានៅថ្នាក់មូលដ្ឋាន និងនៅថ្នាក់ជាតិ មានគោលបំណងបង្កើតជាវេទិកាចូលរួមយោបល់ដោយសេរីអំពីអ្វីដែលអ្នកចូលរួម មានការយល់ដឹងនិងបានសិក្សារៀនសូត្រពីការអនុវត្តផ្ទាល់។ កិច្ចការនេះ ពាក់ព័ន្ធជាមួយការផ្តល់សិទ្ធិ និងការចូលរួមពីអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ នៅក្នុងដំណើរការឆ្លុះបញ្ចាំង និងការសម្របសម្រួលរបស់អង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ។ ដៃគូអនុវត្តនានានៅថ្នាក់ជាតិនឹងសម្របសម្រួលឱ្យមានដំណើរការ និងការផ្លាស់ប្តូរយោបល់លើប្រធានបទផ្សេងៗ ដែលជាការចែករំលែកបទពិសោធន៍គ្នា។ ដៃគូសម្របសម្រួលការសិក្សារៀនសូត្រ នឹងរៀបចំឱ្យមានវេទិកាពីរដងក្នុងមួយឆ្នាំ (រួមមានៈ ស្ថាប័ន អង្គភាពរដ្ឋ និងអង្គការសង្គមស៊ីវិលសំខាន់ៗ ក៏ដូចជាអ្នកពាក់ព័ន្ធការងារស្រាវជ្រាវនានា) ដើម្បីធ្វើការពិភាក្សា និងសម្រេចលើមេរៀនដែលទទួលបាន។

### សកម្មភាព ៥.១.៤ ការបង្កើតឱ្យមាន ការផ្តល់ព័ត៌មានត្រឡប់ និងដំណើរការពិនិត្យកែសម្រួលគោលនយោបាយ ដើម្បីលើកកម្ពស់ការអនុវត្ត ផ.អ.គ.ស

ទន្ទឹមនឹងការរំពឹងទុកថា ដៃគូអនុវត្តនៅមូលដ្ឋានអាចមានភាពបត់បែនក្នុងការប្រើប្រាស់ឧបករណ៍នានាស្របតាមបរិបទនៅក្នុងមូលដ្ឋានរបស់ខ្លួន គេក៏រំពឹងថានៅក្នុងដំណើរការនៃការអនុវត្ត នឹងទទួលបាននូវមេរៀនជាច្រើនដែលអាចជួយដល់ដៃគូទាំងអស់នៅក្នុងការអនុវត្តផ.អ.គ.ស។ មេរៀនបទពិសោធន៍ដែលទទួលបាននឹងត្រូវចងក្រងជាឯកសារទៅតាមៈ

១) មេរៀនបទពិសោធន៍ដែលអាចលើកកម្ពស់ការអនុវត្តនូវដំណើរការនានាដែលមានស្រាប់ (មេរៀនទាំងនេះនឹងត្រូវផ្សព្វផ្សាយតាមរយៈការធ្វើបច្ចុប្បន្នភាព និងកែសម្រួលឯកសារណែនាំនានា)

២) មេរៀនទាំងឡាយណាដែលប៉ះពាល់ ឬធ្វើឱ្យមានការផ្លាស់ប្តូរគោលនយោបាយ និងដំណើរការនានាដែលបង្កើតឡើងរហូតមកទល់បច្ចុប្បន្ននេះ។

មេរៀនទាំងឡាយដែលប៉ះពាល់ដល់ការផ្លាស់ប្តូរគោលនយោបាយនឹងត្រូវចងក្រង និងផ្សព្វផ្សាយ ព្រមទាំងធ្វើការកែសម្រួលនូវគោលការណ៍ ឬនីតិវិធីដែលមានស្រាប់។ ដំណើរការនៃការកែសម្រួល និងការផ្តល់ព័ត៌មានត្រឡប់នឹងជួយដល់ការអនុវត្ត ផ.អ.គ.ស ក្នុងដំណើរការសិក្សារៀនសូត្រ ក៏ដូចជា អាចសម្របទៅតាមការចាំបាច់ដើម្បីធ្វើឱ្យលទ្ធផលប្រសើរឡើងជាបន្តបន្ទាប់។

**សកម្មភាព ៥.១.៥ ដៃគូជំនាញផ្នែកសិក្សាចងក្រងបទពិសោធន៍ រៀបចំការសិក្សានានាដើម្បីគាំទ្រដល់ការអភិវឌ្ឍគោលនយោបាយ និងការអនុវត្តផ.អ.គ.ស**

***របៀបអនុវត្ត ផ.អ.គ.ស នៅតំបន់ទីប្រជុំជនៈ*** នៅក្នុងដំណាក់កាលដំបូងនៃការអនុវត្តផ.អ.គ.ស គឺបានផ្តោតតែលើការអនុវត្តនៅថ្នាក់ឃុំនៃស្រុកគោលដៅ(តំបន់ជនបទ) តែត្រូវមានការសិក្សាអំពីដំណើរការនៃការបង្កើតឱ្យមានរបៀបអនុវត្ត ផ.អ.គ.ស នៅតំបន់ទីប្រជុំជនដែលនឹងត្រូវរៀបចំដោយដៃគូជំនាញអនុវត្តការសិក្សាចងក្រងបទពិសោធន៍។ ផ្អែកតាមបទពិសោធន៍នៃការអនុវត្តផ.អ.គ.សនៅជនបទ ត្រូវរៀបចំរបៀបអនុវត្តស្រដៀងគ្នា ដើម្បីទទួលបាននូវលទ្ធផលដូចគ្នានៅតំបន់ទីប្រជុំជន ដោយសម្របទៅតាមបរិបទផ្សេងៗនៃស្ថាប័នអង្គភាព និងសហគមន៍ទីប្រជុំជន (មានន័យថា សេវាសម្រាប់តំបន់ទីប្រជុំជន និងបញ្ហាជាអាទិភាពរបស់សហគមន៍ទីប្រជុំជន តម្រូវការធនធានផ្សេងៗគ្នា ហេតុនេះ ប្រជាពលរដ្ឋទីប្រជុំជនអាចត្រូវការព័ត៌មានផ្សេងៗគ្នា ហើយដំណើរការចូលរួមក៏ ខុសៗគ្នាដែរ)។ រហូតដល់ចុងឆ្នាំ២០១៨ ឧបករណ៍ និងដំណើរការទាំងឡាយសម្រាប់តំបន់ទីប្រជុំជននឹងអាចបង្កើតឡើងក្នុងគោលបំណងពង្រីកសកម្មភាពទៅដល់សង្កាត់ និងក្រុង ក្នុងឆ្នាំ២០១៩។ នៅឆ្នាំ២០១៨ ដៃគូជំនាញផ្នែកសិក្សាចងក្រងបទពិសោធន៍ នឹងធ្វើការសិក្សារៀបចំសិក្ខាសាលា និងរៀបចំឯកសារសម្រាប់អនុវត្ត ផ.អ.គ.ស នៅទីប្រជុំជន។

***ឱកាសក្នុងការធ្វើឱ្យគណនេយ្យភាពសង្គមមានភាពប្រសើរឡើងតាមរយៈយន្តការបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍៖*** តាមរយៈបទពិសោធន៍ពីប្រទេសនានាបានបង្ហាញថា យន្តការដើម្បីឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការជំរុញការផ្តល់សេវា និងការវិភាជន៍ធនធានកាន់តែប្រសើរឡើងអាចពង្រឹងបានតាមរយៈការប្រើប្រាស់យន្តការបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគម៍។ ប៉ុន្តែមកទល់នឹងពេលនេះ ប្រទេសកម្ពុជាមិនទាន់បានប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ដើម្បីលើកកម្ពស់ការទទួលបាននូវព័ត៌មាន ការដោះស្រាយបណ្តឹងតវ៉ានានា ឬប្រព័ន្ធគណនេយ្យភាពណាមួយនៅឡើយ។ ការប្រើប្រាស់បច្ចេកវិទ្យាទូរស័ព្ទនៅក្នុងប្រទេសកម្ពុជា និងការបង្កើនតំបន់គ្របដណ្តប់សេវាច្រើនឡើងៗ នឹងផ្តល់ជាមធ្យោបាយដើម្បីសាកល្បងមើលថាតើប្រជាពលរដ្ឋកម្ពុជាប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគម៍បានកម្រិតណា។ នៅក្នុងកម្មវិធីដែលផ្តោតទៅលើការប្រមូលមេរៀនបទពិសោធន៍ នឹងធ្វើការស្រាវជ្រាវ និងសាកល្បងនូវជម្រើសក្នុងការប្រើប្រាស់នូវមធ្យោបាយបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគម៍ ព្រមទាំងកំណត់អ្នកដែលទទួលជោគជ័យទាំងស្ថាប័នរដ្ឋបាល និងអង្គការសង្គមស៊ីវិលក្នុងការធ្វើឱ្យមានការផ្លាស់ប្តូរ និងធ្វើការពិចារណាពីអាទិភាពសម្រាប់សាកល្បងនៅក្នុងបរិបទនៃការអនុវត្ត ផ.អ.គ.ស។

***និរន្តរភាពនៃការរៀបចំស្ថាប័នសម្របសម្រួលសកម្មភាពក្នុងការអនុវត្តផ.អ.គ.ស*** ការលើកកម្ពស់និរន្តរភាពនៃដំណើរការសម្របសម្រួលគណនេយ្យភាពសង្គម គឺជាចំនុចសំខាន់ក្នុងការផ្តួចផ្តើមអនុវត្តគណនេយ្យភាពសង្គមទូទាំងប្រទេស។ នៅពេលចាប់ផ្តើមដំបូងនៃកម្មវិធី យុទ្ធសាស្ត្រក្នុងការសម្របសម្រួល និងការសាកល្បង

រៀបចំសម្របសម្រួលនឹងត្រូវបានអនុវត្ត។ ការងារនេះ នឹងការបង្ហាញនូវជម្រើសនានា និងលក្ខណៈវិនិច្ឆ័យសម្រាប់ធ្វើការវាយតម្លៃ (ដែលត្រូវធ្វើឡើងដោយដៃគូជំនាញក្នុងការប្រមូលមេរៀនបទពិសោធន៍ និងការត្រួតពិនិត្យតាមដាន)។ ក្នុងចំណោមជម្រើសផ្សេងៗទៀត ការិយាល័យប្រជាពលរដ្ឋ ឬតំណាងប្រជាពលរដ្ឋ ត្រូវបានចាត់ទុកជាកន្លែងមួយដែលធ្វើការសម្របសម្រួលសកម្មភាពគណនេយ្យភាពសង្គមនៅថ្នាក់ស្រុក។

## ៥.២.ការត្រួតពិនិត្យតាមដាន និងលទ្ធផលសម្រេច

លទ្ធផលរំពឹងទុក៥.២ រំពឹងថានឹងអាចសម្រេចបាន លុះត្រាតែបានអនុវត្តសកម្មភាពដូចខាងក្រោម៖

### សកម្មភាព ៥.២.១ រៀបចំការត្រួតពិនិត្យតាមដានលើលទ្ធផល ស្របតាមក្របខ័ណ្ឌការងារដែលបានព្រមព្រៀង

សកម្មភាពនេះ និងរបាយការណ៍អនុវត្តដែលនឹងត្រូវរៀបចំដោយអង្គការមិនមែនរដ្ឋាភិបាលដែលជួយសម្របសម្រួលអនុវត្តផ្នែកតម្រូវការ និងគ.ជ.អ.ប ដែលអនុវត្តការងារលើផ្នែកផ្គត់ផ្គង់។ ដៃគូជំនាញពាក់ព័ន្ធការសិក្សាចងក្រងមេរៀនបទពិសោធន៍នឹងចងក្រងនូវព័ត៌មានទាំងនេះឱ្យបានគ្រប់ជ្រុងជ្រោយទៅក្នុងរបាយការណ៍រួមគ្នាប្រចាំត្រីមាស និងប្រចាំឆ្នាំ។ របាយការណ៍ទាំងនេះមានបញ្ចូលរបាយការណ៍ ស្តីអំពីការសិក្សាពិនិត្យមើលឡើងវិញ និងការវាយតម្លៃរបស់ដៃគូជំនាញផ្នែកសិក្សាបទពិសោធន៍ ទៅលើបញ្ហាឧបសគ្គ និងការផ្តល់នូវអនុសាសន៍នានា ហើយអាចនឹងធ្វើឡើងដោយផ្តោតលើប្រធានបទជាក់លាក់ ឬក៏ប្រើប្រាស់នូវវិធីសាស្ត្រករណីសិក្សា (ឧទាហរណ៍ ការចងក្រងសហគមន៍) ជាជាងផ្តោតលើទិដ្ឋភាពទូទៅនៃការអនុវត្ត។ របាយការណ៍ទាំងនោះនឹងត្រូវធ្វើការផ្សព្វផ្សាយ និងចែកជូនជាសាធារណៈ ដោយលើកយកមកធ្វើការពិភាក្សាក្នុងកិច្ចប្រជុំត្រីមាសដែលធ្វើឡើងដើម្បីត្រួតពិនិត្យលើការអនុវត្ត ដឹកនាំដោយដៃគូជំនាញពាក់ព័ន្ធសិក្សារៀនសូត្របទពិសោធន៍ និងមានអ្នកចូលរួមទាំងផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់។

### សកម្មភាព ៥.២.២ ធ្វើការវាយតម្លៃទៅលើផលប៉ះពាល់

ការវាយតម្លៃលើផលប៉ះពាល់ គឺត្រូវធ្វើឡើងតាមបែបប្រៀបធៀបសូចនាករនៃសមិទ្ធផលទទួលបានដោយប្រើទិន្នន័យដើមគ្រា ធៀបជាមួយទិន្នន័យចុងគ្រាតាមបណ្តាឆ្នាំក្រោយពេលអនុវត្តកម្មវិធី និងប្រៀបធៀបរវាងក្រុមដែលមិនបានអនុវត្តសកម្មភាពជាមួយក្រុមដែលបានអនុវត្តសកម្មភាព[24]។ សូចនាករមួយចំនួនទៀតក៏នឹងត្រូវយកមកធ្វើការប្រៀបធៀបដែរដូចជា៖

១) សូចនាករកញ្ចប់ព័ត៌មាន (អត្រាអ្នកចុះឈ្មោះចូលរៀន អត្រាទទួលបានវ៉ាក់សាំង ។ល។)
២) សូចនាករប័ណ្ណដាក់ពិន្ទុនៅសហគមន៍ (ដែលប្រើសម្រាប់វាស់ស្ទង់ពីការពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះសេវានានា)
៣) សូចនាករស្តីពីការយល់ដឹងរបស់ប្រជាពលរដ្ឋ ការលើកកម្ពស់សិទ្ធិអំណាច និងការវាយតម្លៃពីការឆ្លើយតបនានាដែលប្រមូលបានពីការធ្វើការអង្កេតលើប្រជាពលរដ្ឋ[25]។

---

[24] ការប្រើប្រាស់វិធីសាស្ត្រDD ដើម្បីឲ្យស្របទៅតាមបរិបទនីមួយៗ។ បច្ចុប្បន្នវិធីសាស្ត្រDD កាន់តែមានការប្រើប្រាស់ច្រើនឡើងផ្នែកសេដ្ឋកិច្ចអភិវឌ្ឍ។ ព័ត៌មានលំអិតមាននៅគេហទំព័រhttp://www.poertyactionlab.org/។ បច្ចេកទេសដែលប្រើប្រាស់ គឺសម្រាប់សិក្សាឱ្យដឹងពីភាពខុសគ្នារវាងក្រុមដែលមិនទាន់បានអនុវត្តសកម្មភាព និងក្រុមដែលបានអនុវត្តសកម្មភាព។

[25]ដើម្បីធ្វើការអង្កេតនេះចាំបាច់ត្រូវយកចិត្តដាក់លើការវាស់វែងពីចំណេះដឹងជាជាងសួរសំនួរនាំមុខដូចជា"តើអ្នកបានដឹងអំពីលុយរបស់សាលាដែរឬទេ?"។

### សកម្មភាព ៥.២.៣ ការអនុវត្តដំណើរការចងក្រងជាឯកសារ និងសវនកម្ម

ដំណើរការនានាដូចជា ការបណ្តុះបណ្តាល ការសម្របសម្រួល ការទទួលយកអនុសាសន៍របស់ប្រជាពលរដ្ឋ ការបញ្ជ្រាបយុវវ័យ កុមារ ជនពិការ ការផ្តួចផ្តើមផ្សេងៗ និងនិរន្តរភាព នឹងត្រូវវាយតម្លៃតាមរយៈសវនកម្មលើដំណើរការនៃការអនុវត្ត។ ការត្រួតពិនិត្យមើលឡើងវិញលើគោលនយោបាយក្នុងមួយឆមាសម្តង ផ្តល់ឱកាសក្នុងការពិភាក្សាអំពីមេរៀនបទពិសោធន៍ដែលទទួលបាន។ មេរៀនបទពិសោធន៍ដែលទទួលបាននឹងផ្តោតទៅលើកម្រិតនៃការផ្លាស់ប្តូរប្រែប្រួលដែលដំណើរការអនុវត្តបានធ្វើឱ្យមានផលប៉ះពាល់ដល់លទ្ធផលនានា។ ការសម្រេចចុងក្រោយនៃសវនកម្មលើដំណើរការនៃការអនុវត្តនឹងធ្វើឡើងនៅពេលដែលយុទ្ធសាស្ត្រស្តីពីការប្រមូលចងក្រងបទពិសោធន៍ និងស្រាវជ្រាវត្រូវបានបញ្ចប់។ ការធ្វើសវនកម្មលើដំណើរការរួមមាន ប្រសិទ្ធភាពនៃការបណ្តុះបណ្តាល ដំណើរការ និងវិធីសាស្ត្រផ្សេងៗក្នុងការបណ្តុះបណ្តាល ដែលមានប្រសិទ្ធភាពខ្ពស់ ដោយមានការរៀបចំផ្សេងៗក្នុងការសម្របសម្រួលវិធីសាស្ត្រប៉ះពាល់លើការអនុវត្ត អត្រាទទួលយកអនុសាសន៍របស់ប្រជាពលរដ្ឋនៅមានកម្រិតការបញ្ជ្រាបយេនឌ័រមានប្រសិទ្ធភាពកម្រិតណា បញ្ហាយេនឌ័រត្រូវបានដោះស្រាយដោយជោគជ័យកម្រិតណា ការផ្តួចផ្តើមសកម្មភាពនៅមូលដ្ឋានទទួលបានលទ្ធផលកម្រិតណា ហើយតើការសម្រេចចិត្តនានាប៉ះពាល់លើនិរន្តរភាពកម្មវិធីកម្រិតណា។ គេរំពឹងថា ភាគច្រើននៃការសិក្សាទាំងនេះនឹងត្រូវចុះកិច្ចសន្យាបន្តពីដៃគូជំនាញពាក់ព័ន្ធការសិក្សារៀនសូត្របទពិសោធន៍ទៅឱ្យទីប្រឹក្សាជំនាញ និងអ្នកស្រាវជ្រាវផ្សេងៗទៀត។

សមាសភាគទី៤ ពាក់ព័ន្ធការប្រមូលមេរៀនបទពិសោធន៍ និងការត្រួតពិនិត្យតាមដាន គឺជំរុញអ្នកពាក់ព័ន្ធនានាឲ្យមានការសិក្សា និងផ្លាស់ប្តូរបទពិសោធន៍ ក៏ដូចជាខិតខំបញ្ចូលមេរៀនបទពិសោធន៍ដែលទទួលបានជាក់ស្តែង ទៅក្នុងដំណើរការកសាងគោលនយោបាយ និងដំណើរការអនុវត្ត។ ភ្នាក់ងារអនុវត្តនានានឹងមានទំនោរក្នុងការប្រើប្រាស់វិធីសាស្ត្រផ្ទាល់ខ្លួន និងផ្តោតការយកចិត្តទុកដាក់ពិសេសតែនៅក្នុងបរិបទដែលមាននៅក្នុង ផ.អ.គ.ស (ឧទាហរណ៍៖ ផលប៉ះពាល់ទៅលើស្ត្រី ឬយុវវ័យ កុមារ ជនជាតិដើម ជនពិការ)។ សមាសភាគនេះ ក៏មានបំណងសិក្សារៀនសូត្រអំពីបទពិសោធន៍អ្វីខ្លះដែលអនុវត្តបាន និងអនុវត្តមិនបាន ហើយសិក្សាស្វែងយល់អំពី មេរៀនបទពិសោធន៍មួយចំនួននៅមូលដ្ឋាន ដើម្បីរៀបចំចងក្រង និងចែករំលែកទូទាំងប្រទេស។ សមាសភាគដែលពាក់ព័ន្ធការរៀនសូត្របទពិសោធន៍នឹងត្រូវធានាថា៖

១) ការផ្តួចផ្តើមច្នៃប្រឌិតដែលប្រើតាមស្ថានភាពនៅមូលដ្ឋាន និងតាមសហគមន៍ជាក់លាក់ ហើយអាចយកទៅអនុវត្តនៅកន្លែងផ្សេងៗទៀត

២) គោលនយោបាយ និងគោលការណ៍ណែនាំនានារបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងតម្លាភាព និងគណនេយ្យភាពមានការឆ្លើយតបចំពោះបញ្ហា និងអាចទទួលបានជោគជ័យ។

**តារាងទី ៥៖ សង្ខេបអំពីសមាសភាគនៃការត្រួតពិនិត្យតាមដាន និងការពង្រឹងសមត្ថភាព**

| ផ្នែក | ការរៀបរាប់ |
|---|---|
| គោលបំណង | បង្កើតឱ្យមានវប្បធម៌ក្នុងការសិក្សាចងក្រងបទពិសោធន៍ក្នុងចំណោមតួអង្គទាំងអស់។<br>ធានាឱ្យមានការរៀនសូត្រដោយផ្អែកលើភាពជាក់ស្តែង និងដាក់បញ្ចូលទៅក្នុងគោលនយោបាយ និងការអនុវត្ត។<br>លើកកម្ពស់ការយល់ដឹង និងវាស់ស្ទង់ពីលទ្ធផល។ |

| ផ្នែក | ការរៀបរាប់ |
|---|---|
| **សមិទ្ធផល និងសូចនាករ** | វប្បធម៌ថ្មីក្នុងការឆ្លុះបញ្ចាំង និងរៀនសូត្រ គឺជាដំណើរការសិក្សាចងក្រងបទពិសោធន៍ទាំងតួអង្គរដ្ឋ និងមិនមែនរដ្ឋ<br>• លទ្ធភាព និងការតាំងចិត្តក្នុងការចូលរួមសម្រាប់មេរៀនជាបទពិសោធន៍<br>• គុណភាពសម្រាប់ការចងក្រងឯកសារ និងការពិភាក្សាលើដំណើរការផ្លាស់ប្តូរអោយប្រសើរឡើង។<br>លើកកម្ពស់ការធ្វើអោយប្រសើរឡើងតាមការរៀនសូត្រលើគោលនយោបាយគណនេយ្យភាពសង្គម និងការអនុវត្ត<br>• ការសិក្សាចងក្រងបទពិសោធន៍ និងព័ត៌មានត្រឡប់ ដែលជំរុញអោយមានការផ្លាស់ប្តូរគោលនយោបាយ និងការអនុវត្ត<br>• អភិវឌ្ឍន៍គោលនយោបាយសម្រាប់តំបន់ទីប្រជុំជន។ |
| លទ្ធផលរំពឹងទុក | **៥.១. ការប្រមូលមេរៀនបទពិសោធន៍  និងការផ្តល់ព័ត៌មានត្រឡប់**<br>**សកម្មភាព ៥.១.១** ការរៀបចំបង្កើតយុទ្ធសាស្រ្ត និងផែនការសកម្មភាព ពាក់ព័ន្ធការប្រមូលមេរៀនបទពិសោធន៍ដែលមានលក្ខណៈច្នៃប្រឌិត<br>**សកម្មភាព ៥.១.២** ការរៀបចំផ្សព្វផ្សាយ ឧបករណ៍ និងឯកសារណែនាំនានា<br>**សកម្មភាព ៥.១.៣** ការរៀបចំវេទិកាសិក្សារៀនសូត្រ  និងផ្តល់ព័ត៌មានត្រឡប់ ឱ្យបានទៀងទាត់<br>**សកម្មភាព ៥.១.៤** ការបង្កើតឱ្យមាន ការផ្តល់ព័ត៌មានត្រឡប់  និងដំណើរការពិនិត្យកែសម្រួលគោលនយបាយ ដើម្បីលើកកម្ពស់ការអនុវត្ត ផ.អ.គ.ស<br>**សកម្មភាព ៥.១.៥** ដៃគូជំនាញផ្នែកសិក្សាចងក្រងបទពិសោធន៍  រៀបចំការសិក្សានានា ដើម្បីគាំទ្រដល់ការអភិវឌ្ឍគោលនយោបាយ  និងការអនុវត្ត ផ.អ.គ.ស<br>**៥.២. ការត្រួតពិនិត្យតាមដាន និងលទ្ធផលសម្រេចបាន**<br>**សកម្មភាព ៥.២.១** រៀបចំការត្រួតពិនិត្យតាមដានលើលទ្ធផល ស្របតាមក្របខ័ណ្ឌការងារដែលបានព្រមព្រៀង<br>**សកម្មភាព ៥.២.២** ធ្វើការវាយតម្លៃទៅលើផលប៉ះពាល់<br>**សកម្មភាព ៥.២.៣** ការអនុវត្តដំណើរការចងក្រងជាឯកសារ និងសវនកម្ម។ |

# ជំពូកទី៣

# ការរៀបចំស្ថាប័ន ការចាត់ចែងអនុវត្ត និងការផ្តល់ហិរញ្ញប្បទាន

## ១. សេចក្តីផ្តើម

ក្នុងរយៈពេលកន្លងមកនេះ ការពង្រឹងគណនេយ្យភាពក្នុងក្របខ័ណ្ឌនៃកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ បានផ្តោតសំខាន់លើ គណនេយ្យភាពផ្នែកនយោបាយ និង គណនេយ្យភាពផ្នែករដ្ឋបាល។ ដោយឡែកគណនេយ្យភាពសង្គមជាផ្នែកមួយដ៏មានសារៈសំខាន់នៃគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ឬគណនេយ្យភាពរវាងក្រុមប្រឹក្សាដែលជាប់ឆ្នោតជាមួយប្រជាពលរដ្ឋដែលបានបោះឆ្នោតឲ្យ ពុំបានកំណត់ច្បាស់លាស់សម្រាប់ការអនុវត្តនៅក្រោមកម្មវិធីជាតិនៅឡើយ។ ដើម្បីបំពេញបន្ថែមទៅនឹងការខ្វះចន្លោះនេះ គ.ជ.អ.ប បានរៀបចំផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គម ផែនការអនុវត្តបីឆ្នាំគណនេយ្យភាពសង្គមតាមបែបប្រជាធិបតេយ្យ ព្រមទាំងបានបញ្ចូលសមិទ្ធផលនៃការងារគណនេយ្យភាពសង្គមជាចំណុចដៅមួយដ៏សំខាន់ក្នុងសមិទ្ធផលរំពឹងទុកទី២ ស្តីពីគណនេយ្យភាពតាមបែបប្រជាធិបតេយ្យក្នុងឯកសារផែនការអនុវត្តបីឆ្នាំដំណាក់កាលទី២ (២០១៥-២០១៧) ដោយមានការពិគ្រោះយោបល់ជាមួយអង្គការដៃគូអនុវត្ត និងអ្នកពាក់ព័ន្ធនានា ដើម្បីកំណត់នូវ យុទ្ធសាស្ត្រចាំបាច់សកម្មភាពជាក់លាក់ និងតួនាទី ភារកិច្ចរបស់ស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការដៃគូអនុវត្ត ក្នុងការចូលរួមចំណែកអនុវត្តការងារគណនេយ្យភាពសង្គមតាមផែនការយុទ្ធសាស្ត្រច្បាស់លាស់មួយ នឹងមានការឯកភាពគ្នាក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់។

ជាមួយគ្នានេះដែរ ទោះបីជាក្នុងផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គម បានកំណត់នូវយុទ្ធសាស្ត្រទាំងប្រាំ និងមានសមាសភាគសំខាន់ៗសម្រាប់អនុវត្តយុទ្ធសាស្ត្រទាំងនោះក្តីក៏មិនទាន់គ្រប់ជ្រុងជ្រោយនៅឡើយ ចាំបាច់គឺត្រូវមានការកំណត់បន្ថែមទៀតពីការរៀបចំស្ថាប័ន ការរៀបចំចាត់ចែងអនុវត្ត គ្រោងថវិកា និងការផ្តល់ហិរញ្ញប្បទាននានា ដើម្បីអាចដំណើរការសកម្មភាព និងអាចសម្រេចកិច្ចការតាមការគ្រោងទុក។

## ២. ការរៀបចំស្ថាប័ន

### ២.១.ទិដ្ឋភាពទូទៅ

**ការរៀបចំស្ថាប័នដើម្បីអនុវត្តការងារនឹងត្រូវដំណើរការជាមួយរចនាសម្ព័ន្ធដែលមានស្រាប់ដោយសារតែ** ផ.អ.គ.ស គឺជាសកម្មភាពនៃកម្មវិធីត្រូវអនុវត្តទូទាំងប្រទេស ដើម្បីជួយគាំទ្រ និងពង្រឹងកំណែទម្រង់តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ហេតុនេះការប្រើប្រាស់ប្រព័ន្ធ និងរចនាសម្ព័ន្ធដែលមានស្រាប់គឺមានភាពសមហេតុផល។

**សកម្មភាពទាំងឡាយនឹងត្រូវអនុវត្តដោយស្ថាប័នរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ឬដោយស្ថាប័នទាំងពីររួមគ្នា។** ក្នុងការអនុវត្តជាក់ស្តែង សកម្មភាពមួយចំនួនដែលបានរៀបរាប់នៅក្នុងសមាសភាគទាំង៤របស់ផ.អ.គ.ស នឹងត្រូវអនុវត្តដោយផ្នែកផ្គត់ផ្គង់ សកម្មភាពខ្លះទៀតត្រូវអនុវត្តដោយផ្នែកតម្រូវការ ហើយសកម្មភាពខ្លះទៀតនឹងត្រូវអនុវត្តរួមគ្នាដើម្បីបង្កើនប្រសិទ្ធភាពកាន់តែប្រសើរឡើង។ សកម្មភាពមួយចំនួននៃការងារគណនេយ្យភាពសង្គមត្រូវដឹកនាំដោយស្ថាប័នរាជរដ្ឋាភិបាលដូចជា ការចេញគោលការណ៍ណែនាំនានាដើម្បីឱ្យមានការបិទផ្សាយព័ត៌មាន ចំណែកសកម្មភាពមួយចំនួនទៀត រួមមានការត្រួតពិនិត្យតាមដាន និងការវាយតម្លៃរបស់ប្រជាពលរដ្ឋ ត្រូវអនុវត្តដោយតម្លាភាព និងមានការគាំទ្រពីអង្គការដៃគូអនុវត្ត ហើយចំណេះដឹងនេះ ត្រូវប្រើប្រាស់ដើម្បីធ្វើការសម្រេចចិត្តថា អ្នកណាត្រូវធ្វើអ្វី និងត្រូវរៀបចំដោយរបៀបណា។ សកម្មភាពពីរនៅក្នុង ផ.អ.គ.ស ដែលត្រូវធ្វើរួមគ្នា នឹងត្រូវសម្របសម្រួលរវាងផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់។ ឧបសម្ព័ន្ធ៣បែងចែកនូវការទទួលខុសត្រូវ ថាតើសកម្មភាពណាខ្លះ ដែលអនុវត្តដោយរាជរដ្ឋាភិបាល សកម្មភាពណាខ្លះដែលអនុវត្តដោយអង្គការដៃគូអនុវត្ត និងសកម្មភាពណាដែលត្រូវអនុវត្តរួមគ្នា។ ជាការសំខាន់ណាស់ដែលត្រូវធ្វើការកត់សម្គាល់ថា បើទោះបីជាមានសកម្មភាពខ្លះត្រូវអនុវត្តដោយស្ថាប័នរាជរដ្ឋាភិបាលក៏ដោយ ក៏អង្គការសង្គមស៊ីវិលមានតួនាទីសំខាន់ក្នុងការសហការ និងគាំទ្រគ្នាទៅវិញទៅមកដែរ។ ដើម្បីធានាឱ្យមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព និងការកសាងទំនាក់ទំនងការងារឲ្យទទួលបានលទ្ធផលល្អប្រសើររវាងស្ថាប័នរដ្ឋ និងសង្គមស៊ីវិលនៅគ្រប់កម្រិត គឺជាកត្តាចម្បងដែលធ្វើឱ្យការអនុវត្តផ.អ.គ.ស ទទួលបានជោគជ័យ។

លេខាធិការដ្ឋានគ.ជ.អ.ប ដែលអនុវត្តសកម្មភាពផ្នែកផ្គត់ផ្គង់ គឺជួយសម្របសម្រួលរាល់សកម្មភាពទាំងអស់ស្របតាមកម្មវិធីជាតិសម្រាប់ការ កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងផែនការអនុវត្ត៣ឆ្នាំដំណាក់កាលទី២ (ផអ៣ទី២) ដែល **ផ.អ.គ.ស** ក៏ជាផ្នែកមួយនៃសមិទ្ធផលរំពឹងទុកទី២ នៃផអ៣ទី២ផងដែរ។ ជាក់ស្តែង លេខាធិការដ្ឋានគ.ជ.អ.ប បានសម្របសម្រួលដំណើរការដោយបានរៀបចំផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ [26] និងបានអនុម័តនៅក្នុងខែកក្កដាឆ្នាំ២០១៣។ លេខាធិការដ្ឋានគ.ជ.អ.ប ទទួលភារកិច្ចដឹកនាំការអនុវត្ត ហើយតួនាទី និងការទទួលខុសត្រូវ មានរៀបរាប់លម្អិតនៅផ្នែកខាងក្រោម។ **ចំពោះផ្នែកតម្រូវការវិញ ត្រូវរៀបចំ ក្រុមសម្របសម្រួលមួយ** ដែលធ្វើការជាមួយក្រុមអង្គការដៃគូអនុវត្តនៅថ្នាក់ជាតិ និងអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តសកម្មភាពផ.**អ.គ.ស** (សូមមើលរូបភាពទី២ និងការពិព៌ណនាក្នុងផ្នែក ២.៣ ការទទួលខុសត្រូវរបស់សង្គមស៊ីវិល)។

[26]គ.ជ.អ.ប បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិល និងបានអនុម័តឯកសារផែនការយុទ្ធសាស្ត្រនោះ បន្ទាប់មក ទើបរៀបចំជាផែនការអនុវត្ត៣ឆ្នាំនេះមក។

## ២.២.ការទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋ (ផ្នែកផ្គត់ផ្គង់)

រូបភាពទី 1 ការរៀបចំការអនុវត្តសម្រាប់ផ្នែកផ្គត់ផ្គង់




លេខាធិការដ្ឋានគ.ជ.អ.ប គឺជាអង្គភាពទទួលខុសត្រូវអនុវត្តផអ៣ទី២ នឹងរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានចាំបាច់នានាដើម្បីអនុវត្តផ.អ.គ.ស នៅពេលចាប់ផ្តើម ហើយដើរតួនាទីសម្របសម្រួលជាទូទៅក្នុងពេលអនុវត្តផែនការនេះរួមមាន៖

- ដឹកនាំ និងសម្របសម្រួលនៅថ្នាក់ជាតិ៖ ដើម្បីធានាឱ្យមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធសំខាន់ៗ និងតំណាងអង្គការដៃគូអនុវត្ត ។
- សម្របសម្រួលការដឹកនាំនៅថ្នាក់ក្រោមជាតិ៖ លើកកម្ពស់តួនាទីរបស់ក្រុមប្រឹក្សា ក្នុងការត្រួតពិនិត្យ និងអនុវត្តតួនាទីជាតំណាង ពាក់ព័ន្ធនឹងការផ្តល់សេវានានាបែបរិសហមជ្ឈការដែលស្ថិតក្រោមដែនសមត្ថកិច្ច និងគាំទ្រដល់សមាជិកក្រុមប្រឹក្សានៅក្នុងការត្រួតពិនិត្យតាមដានការអនុវត្តផ.អ.គ.ស និងធ្វើសេចក្តីរាយការណ៍ពីលទ្ធផលសម្រេចបាន។
- កិច្ចសហការ៖ សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃដើម្បីធានាថាលិខិតបទដ្ឋានសំខាន់ៗ បានរៀបចំឡើង និងអនុវត្តដើម្បីលើកកម្ពស់ការផ្សព្វផ្សាយជាសាធារណៈ និងការផ្តល់សេវាតាមរយៈការពង្រឹងគណនេយ្យភាព។

- ការគាំទ្រផ្នែកបច្ចេកទេសៈ ផ្តល់ការគាំទ្រតាមរយៈអង្គភាពនានាក្នុងរចនាសម្ព័ន្ធ ក្នុងការរៀបចំគោលការណ៍ណែនាំនានា ដែលទាក់ទងទៅនឹងការរៀបចំកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ ការផ្សព្វផ្សាយព័ត៌មាន និងយន្តការចាំបាច់នានាដោយលើកទឹកចិត្តក្រុមប្រឹក្សាក្នុងការផ្តល់ព័ត៌មាន និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង ដើម្បីឆ្លើយតបចំពោះការតាមដានរបស់ប្រជាពលរដ្ឋ ដូចជា កិច្ចប្រជុំរួមរៀបចំ **ផ.ស.រ.គ** និងគណៈកម្មាធិការ ផ.ស.រ.គ។

តួនាទីរបស់អង្គភាពនានានៅមូលដ្ឋានពិតជាមានសារៈសំខាន់ដូចជា ខេត្ត ឃុំ ស្រុក សាលារៀន និងមណ្ឌលសុខភាព (រួមមាន សមាជិកក្រុមប្រឹក្សា គ្រូបង្រៀន នាយកសាលា និងប្រធានមណ្ឌលសុខភាព) ដែលទាមទារឱ្យមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ។ ផ.អ.គ.សនឹងជួយឱ្យពួកគេសម្រេចបានតាមតួនាទីនេះដូចខាងក្រោមៈ

- **មណ្ឌលអភិវឌ្ឍធនធានមនុស្សៈ**

  ជាទូទៅតួនាទីរបស់មណ្ឌលអភិវឌ្ឍធនធានមនុស្សមាន២ផ្នែកគឺៈ
  - ទី១ៈផ្តោតលើការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ
  - ទី២ៈផ្តោតលើការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពដល់មន្ត្រី និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

សម្រាប់ការអនុវត្តការងារគណនេយ្យភាពសង្គម មណ្ឌលអភិវឌ្ឍធនធានមនុស្សមិនត្រឹមតែគាំទ្រសកម្មភាពអភិវឌ្ឍសមត្ថភាពជាមួយក្រុមប្រឹក្សា មន្ត្រី និងបុគ្គលិកថ្នាក់ក្រោមជាតិប៉ុណ្ណោះទេ ថែមទាំងរួមបញ្ចូលនូវស្ថាប័នពាក់ព័ន្ធ (មន្ទីរសុខាភិបាល មន្ទីរអប់រំយុវជន និងកីឡា ការិយាល័យអប់រំស្រុក ការិយាល័យស្រុកប្រតិបត្តិ ជាដើម) និងជួយគាំទ្របន្ថែមលើសកម្មភាពត្រួតពិនិត្យតាមដានការអនុវត្តការងារគណនេយ្យភាពសង្គមនៅស្រុក និងឃុំគោលដៅ ។ តួនាទីមណ្ឌលអភិវឌ្ឍធនធានមនុស្សមានដូចខាងក្រោមៈ

  - ផ្សព្វផ្សាយពីការងារគណនេយ្យភាពសង្គមដល់ថ្នាក់ដឹកនាំខេត្ត ស្រុក និងស្ថាប័នពាក់ព័ន្ធ
  - បណ្តុះបណ្តាលស្តីពីការអនុវត្តសកម្មភាពការងារគណនេយ្យភាពសង្គមដល់មន្ត្រីបច្ចេកទេសពាក់ព័ន្ធ
  - ត្រួតពិនិត្យនិងតាមដានការអនុវត្ត
  - រៀបចំឲ្យមានមន្ត្រីបង្គោលសម្រាប់ទទួលបន្ទុកការងារគណនេយ្យភាពសង្គមដើម្បីគាំទ្របច្ចេកទេសដល់ការអនុវត្តថ្នាក់ក្រោមជាតិ។

- **ក្រុមប្រឹក្សា និងរដ្ឋបាលស្រុក**មានតួនាទីក្នុងការផ្តល់ព័ត៌មាន ប្រមូលចងក្រងព័ត៌មាន និងសម្របសម្រួល រួមមានៈ
  - ធ្វើការចងក្រងព័ត៌មាន ពីសេវាទាំង៣
  - ធ្វើការយ៉ាងសកម្មជាមួយអង្គការសង្គមស៊ីវិលនៅមូលដ្ឋាន(អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ អង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ) ដើម្បីផ្តល់លទ្ធភាពឱ្យពួកគេទទួលបានព័ត៌មាននៅក្នុងកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ(I4Cs) ។
  - គាំទ្រសកម្មភាពផ្សព្វផ្សាយព័ត៌មាន និងសម្របសម្រួលនៅថ្នាក់ស្រុក (ដូចជា ការផ្សព្វផ្សាយកញ្ចប់ព័ត៌មាន លទ្ធផលនៃប័ណ្ណដាក់ពិន្ទុ និងផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាសង្គម

ព្រមទាំងបញ្ចូលផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គមទៅក្នុងសិក្ខាសាលាសមាហរណ៍កម្មថ្នាក់ស្រុក ...។ល។)

- ចូលរួមនៅក្នុងដំណើរការគណនេយ្យភាពសង្គម (ព័ត៌មានស្តង់ដា ព័ត៌មានអំពីថវិកា និងការតាមដានត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ) នៅពេលដែលមានមូលនិធិក្រុង ស្រុក។
- រៀបចំឲ្យមានមន្ត្រីបង្គោលសម្រាប់ទទួលបន្ទុកការងារគណនេយ្យភាពសង្គមដើម្បីគាំទ្របច្ចេកទេសដល់ការអនុវត្តថ្នាក់ឃុំ មណ្ឌលសុខភាព និងសាលាបឋមសិក្សា។

❖ **ក្រុមប្រឹក្សាឃុំ** មានតួនាទីសំខាន់២: ត្រូវមានគណនេយ្យភាពចំពោះអ្នកប្រើប្រាស់សេវារបស់ក្រុមប្រឹក្សាឃុំ និងក្នុងនាមជាតំណាងកើតឡើងដោយការបោះឆ្នោតត្រូវមានគណនេយ្យភាពចំពោះអ្នកដែលបោះឆ្នោតឱ្យ។ ហេតុនេះក្រុមប្រឹក្សាឃុំត្រូវ៖

- ធ្វើការជាមួយអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ដើម្បីធានាឱ្យប្រជាពលរដ្ឋទទួលបាននូវព័ត៌មានអំពីស្តង់ដារ និងព័ត៌មានថវិកា (កញ្ចប់ព័ត៌មាន) ព្រមទាំងស្តាប់ និងឆ្លើយតបចំពោះលទ្ធផលនៃការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ (កិច្ចប្រជុំរួមគ្នា)។
- ដើរតួនាទីយ៉ាងសកម្មក្នុងការបង្កើត ផ.ស.រ.គ ក្នុងនាមជាតំណាងឱ្យប្រជាពលរដ្ឋ ជាអ្នកផ្តល់សេវា និងជាអ្នកត្រួតពិនិត្យមើលការផ្តល់សេវានានានៅមូលដ្ឋាន។
- ដឹកនាំគណៈកម្មាធិការផ.ស.រ.គ ក្នុងការអនុវត្ត និងតាមដាន ផ.ស.រ.គ។
- ធានាឲ្យមានការចាត់តាំងមន្ត្រីបង្គោលទទួលបន្ទុកការងារគណនេយ្យភាពសង្គមដើម្បីសហការ និងសម្របសម្រួលបច្ចេកទេសដល់អ្នកផ្តល់សេវាទាំងបី នៅមណ្ឌលសុខភាព សាលាបឋមសិក្សា និងរដ្ឋបាលឃុំ។

❖ **អ្នកផ្តល់សេវា** [27] ដើរតួនាទីសំខាន់នៅក្នុងការធ្វើឱ្យប្រសើរឡើងនូវការទទួលបានព័ត៌មាន និងត្រូវចូលរួមក្នុងដំណើរការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ និងសម្របសម្រួលក្នុងការកែលម្អតាមរយៈ៖

- ផ្តល់ព័ត៌មាន (ទាក់ទងនឹងការងារថវិកា និងការបំពេញការងារ) តម្រូវការក្នុងដំណាក់កាលនៃការប្រមូលព័ត៌មាន
- ធ្វើការជាមួយអង្គការសង្គមស៊ីវិលនៅមូលដ្ឋាន (អង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍) ដើម្បីបង្កលទ្ធភាពទទួលបានព័ត៌មាន និងព័ត៌មានថវិកា (I4Cs) ដែលទាក់ទងនឹងសេវារបស់ខ្លួន និងចូលរួមជាមួយប្រជាពលរដ្ឋក្នុងដំណើរការត្រួតពិនិត្យតាមដាន និងចូលរួមនៅក្នុងកិច្ចប្រជុំរួមគ្នា។
- បំពេញតួនាទី ក្នុងការរៀបចំ និងឆ្លើយតបចំពោះសកម្មភាពដែលបានលើកឡើងនៅក្នុងផ.ស.រ.គ និងធានាឱ្យមានការព្រមព្រៀងចំពោះសកម្មភាពដែលត្រូវយកទៅអនុវត្ត។
- ធ្វើឱ្យការផ្តល់សេវារបស់ខ្លួនកាន់តែមានភាពប្រសើរឡើង និងមាននិរន្តរភាព។

[27] តួនាទីរបស់គណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព និងគណៈកម្មការទ្រទ្រង់សាលានឹងត្រូវរៀបចំបន្ថែមដោយមានការប្រឹក្សាយោបល់ជាមួយ ក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា។ ដើម្បីធានាឲ្យមានការទំនាក់ទំនងមួយដែលមិនមានការខ្វះចន្លោះ សំណើនឹងធ្វើឲ្យមានការទំនាក់ទំនងដោយផ្ទាល់រវាងអ្នកផ្តល់សេវានានា (ឧទាហរណ៍ រវាងគ្រូបង្រៀន និងនាយកសាលា ប្រធានមណ្ឌលសុខភាព និងបុគ្គលិក)។

❖ **ការិយាល័យអប់រំ និងការិយាល័យស្រុកប្រតិបត្តិ៖** មន្ត្រីការិយាល័យអប់រំ និងមន្ត្រីការិយាល័យស្រុកប្រតិបត្តិដើរតួនាទីសម្របសម្រួល និងត្រួតពិនិត្យលើសាលាបឋមសិក្សានិងមណ្ឌលសុខភាព។ ការអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គម នឹងធ្វើឱ្យអង្គភាពផ្តល់សេវាបំពេញការងារបានល្អប្រសើរជាងមុនតាមរយៈការផ្តល់មតិយោបល់កែលម្អបានច្បាស់លាស់ជាងមុន ដើម្បីឲ្យមន្ត្រីទាំងនោះបំពេញការងារដែលប្រគល់ឱ្យបានកាន់តែប្រសើរឡើង។ មន្ត្រីថ្នាក់ស្រុកនឹងបំពេញការងារចម្បងៗរួមមាន៖

- ផ្តល់ និងចងក្រងទិន្នន័យសម្រាប់កញ្ចប់ព័ត៌មាន។
- គាំទ្រការអនុវត្តសកម្មភាពនៅមូលដ្ឋានដែលបានកំណត់នៅក្នុងផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម។
- ដើរតួជាអ្នកពាំនាំនូវព័ត៌មាន និងផ្តល់ព័ត៌មានត្រឡប់ទៅកាន់ក្រសួង និងស្ថាប័នជំនាញដែលពាក់ព័ន្ធ។

## ២.៣.ការទទួលខុសត្រូវរបស់អង្គការដៃគូអនុវត្ត

រូបភាពទី ៣ ការរៀបចំការអនុវត្តសម្រាប់ផ្នែកតម្រូវការ




**ការសម្របសម្រួលនៅថ្នាក់ជាតិ៖** រចនាសម្ព័ន្ធសម្របសម្រួលមួយនឹងបង្កើតឡើង ដើម្បីធានាឱ្យមានការសម្របសម្រួលជាទូទៅខាងផ្នែកតម្រូវការនៅក្នុងការអនុវត្តគណនេយ្យភាពសង្គម។ តួនាទីចំបងរបស់ក្រុមសម្របសម្រួលគឺធ្វើការជាមួយក្រុមអង្គការដៃគូអនុវត្តនៅថ្នាក់ជាតិ និងអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ ព្រមទាំងទំនាក់ទំនងជាមួយលេខាធិការដ្ឋានគ.ជ.អ.ប ហើយត្រូវរាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម (គ.គ.អ.ស) និងដៃគូអភិវឌ្ឍនានា។ ការងារជាក់លាក់រួមមាន៖

➢ **បង្កើតនីតិវិធី និងគោលការណ៍ណែនាំក្នុងការគ្រប់គ្រងផ្នែកតម្រូវការ៖** ដើម្បីដំណើរការផ្នែកតម្រូវការ ក្រុមការងាររៀបចំតាក់តែងនឹងរៀបចំសៀវភៅណែនាំដើម្បីគាំទ្រដល់ អង្គការដៃគូអនុវត្តនៅថ្នាក់ក្រោម

ជាតិ និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍សម្រាប់អនុវត្តកម្មវិធី[28]។ ភាគីពាក់ព័ន្ធក្នុងការសម្របសម្រួលទូទៅត្រូវរៀបចំសម្ភារៈធនធានចាំបាច់សម្រាប់ផ្នែកតម្រូវការ។

- **ផ្តល់ការសម្របសម្រួលទូទៅក្នុងផ្នែកតម្រូវការ៖** ក្រុមសម្របសម្រួលអង្គការសង្គមស៊ីវិលនឹងទទួលខុសត្រូវគាំទ្រដល់ក្រុមអង្គការដៃគូផ្សេងៗ ក្នុងការជួយសម្របសម្រួល និងជួយប្រាស្រ័យទាក់ទងឱ្យកាន់តែមានប្រសិទ្ធភាពរវាងអង្គការទាំងនោះ។ ក្រុមសម្របសម្រួល នឹងរាយការណ៍អំពីវឌ្ឍនភាព មានការប្រជុំជាទៀងទាត់ជាមួយអង្គការដៃគូអនុវត្តនៅថ្នាក់ជាតិក្នុងការរៀបចំការងារអភិបាលកិច្ចរបស់គម្រោង និងជួយបង្កើតឱ្យមានឧបករណ៍ចាំបាច់នានា។

**ក្រុមអង្គការដៃគូអនុវត្ត៖** ផែនការសកម្មភាពក្នុង ផ.អ.គ.ស នឹងធានាថាប្រជាពលរដ្ឋទទួលបានការគាំទ្រពីបណ្តាអ្នកពាក់ព័ន្ធនានារបស់អង្គការដៃគូអនុវត្ត (ដូចជា អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ អង្គការដៃគូអនុវត្តនៅមូលដ្ឋាន និងអង្គការសហគមន៍មូលដ្ឋាន) ដើម្បីចូលរួមក្នុងដំណើរការការងារគណនេយ្យភាពសង្គម។ សកម្មភាពគណនេយ្យភាពសង្គមតាមសហគមន៍ នឹងនាំមុខដោយប្រជាពលរដ្ឋដែលមានការគាំទ្រដោយបណ្តាញអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ដែលទទួលបាននូវការបង្ហាត់បង្ហាញ និងគ្រប់គ្រងដោយអង្គការដៃគូអនុវត្តនៅមូលដ្ឋាននៅថ្នាក់ខេត្ត និងថ្នាក់ជាតិដែលមានជំនាញក្នុងការសម្របសម្រួល ជំរុញ និងគាំទ្រ ព្រមទាំងការបង្ហាត់បង្រៀន។ មុខងាររបស់អ្នកពាក់ព័ន្ធដែលបានបង្ហាញក្នុងរូបភាពទី ៣ មានរៀបរាប់ខាងក្រោម៖

- **អង្គការដៃគូអនុវត្តថ្នាក់ជាតិ៖** អាចធ្វើការជាមួយអង្គការដៃគូអនុវត្តនៅ មូលដ្ឋាន ដែលមានស្រាប់ ឬ ដោយបង្កើតភាពជាដៃគូថ្មីជាមួយអង្គការផ្សេងទៀត ឬអនុវត្តសកម្មភាពដោយផ្ទាល់(បុគ្គលិកអង្គការដៃគូអនុវត្តថ្នាក់ជាតិ)តាមការជាក់ស្តែង។ អង្គការដៃគូអនុវត្តថ្នាក់ជាតិ នឹងអនុវត្តសកម្មភាពមួយចំនួនដូចជា គ្រប់គ្រងចាត់ចែងលើការប្រើប្រាស់មូលនិធិ ផ្តល់ការគាំទ្រ ផ្តល់ការបង្ហាត់បង្ហាញ ណែនាំ ផ្តល់ការបណ្តុះបណ្តាល និងដោះស្រាយបញ្ហាផ្សេងៗ ផ្តល់ការធានាលើគុណភាពការងារ ធ្វើរបាយការណ៍ ត្រួតពិនិត្យ និងបង្កើតបរិយាកាសឱ្យមានការសិក្សាចងក្រងបទពិសោធន៍ និងចែករំលែកបទពិសោធន៍។ អង្គការ**ដៃគូអនុវត្តថ្នាក់ជាតិ** នឹងផ្តល់មូលនិធិដល់ការចំណាយលើផ្នែកបុគ្គលិករបស់អង្គការដៃគូអនុវត្តនៅមូលដ្ឋាន ចំណាយដោយផ្ទាល់លើការបណ្តុះបណ្តាល ការផ្តល់យោបល់ និងការរៀនសូត្រតាមរយៈការអនុវត្តសកម្មភាពផ្ទាល់ (ដូចជា ការធ្វើដំណើរ ប្រាក់បេសកកម្ម និងចំណាយសម្រាប់ការប្រជុំ)។ សកម្មភាពសំខាន់ៗរួមមាន៖ (១) រៀបចំលក្ខណៈវិនិច្ឆ័យ និងល័ក្ខខ័ណ្ឌការងារសម្រាប់អង្គការដៃគូនៅមូលដ្ឋាន (២)ជ្រើសរើសអង្គការដៃគូ និងចុះអនុស្សារណៈយោគយល់គ្នា ឬចុះកិច្ចសន្យាជាមួយអង្គការដៃគូអនុវត្តនៅមូលដ្ឋានទាំងនោះ និង(៣)រៀបចំកិច្ចប្រជុំជាប្រចាំ ដើម្បីត្រួតពិនិត្យលើការបំពេញការងារ និងការប្រឈមនានាក្នុងការអនុវត្តសកម្មភាពពាក់ព័ន្ធផ្នែកតម្រូវការ។
- **អង្គការដៃគូអនុវត្តនៅមូលដ្ឋាន៖** អង្គការដៃគូអនុវត្តនៅមូលដ្ឋានដែលមានទំនាក់ទំនងស្រាប់ជាមួយឃុំគោលដៅនឹងចាត់តាំងអ្នកសម្របសម្រួលដែលមានជំនាញយ៉ាងតិច៣នាក់ក្នុងស្រុកនីមួយៗ ដើម្បី

[28] តាមរយៈដំណើរការរួមគ្នាដែលផ្តល់ការគាំទ្រដោយគម្រោងអភិបាលកិច្ចល្អមូលដ្ឋាន នៅក្នុងដំណាក់កាលដំបូងនៃការរៀបចំតាក់តែង និងសាកល្បងក្រុមរៀបចំតាក់តែងផ.អ.គ.សនឹងទទួលខុសត្រូវក្នុងការរៀបចំឲ្យមានឧបករណ៍សម្រាប់ផ្នែកតម្រូវការ ដូចជា ប័ណ្ណដាក់ពិន្ទុសហគមន៍ ដំណើរការក្នុងការកំណត់ និងវាយតម្លៃសកម្មភាពត្រួតពិនិត្យស៊ីជម្រៅ គោលការណ៍ណែនាំស្តីពីការចងក្រងសហគមន៍គោលការណ៍ណែនាំយុទ្ធនាការលើកកម្ពស់ការយល់ដឹង និងការប្រើប្រាស់សារព័ត៌មាន ព្រមទាំងយុទ្ធសាស្រ្តក្នុងការរៀបចំស្ថាប័នផ្សេងៗសម្រាប់ការសម្របសម្រួល។

ណែនាំ ការអភិវឌ្ឍសមត្ថភាព និងគាំទ្រសកម្មភាពគណនេយ្យភាពសង្គម។ អ្នកសម្របសម្រួលត្រូវមានស្ត្រីយ៉ាងហោចណាស់ពាក់កណ្តាល ហើយមួយភាគបួននៃអ្នកសម្របសម្រួលត្រូវមានអាយុក្រោម៣០ឆ្នាំ។ គេរំពឹងថា អ្នកសម្របសម្រួល ជាទូទៅគឺជាអ្នកដែលធ្វើការជាបុគ្គលិករបស់អង្គការដៃគូអនុវត្តនៅមូលដ្ឋាន ឬស្ថិតនៅក្នុងបណ្តាញរបស់អង្គការដែលមានជំនាញក្នុងការសម្របសម្រួល ការបញ្ចុះបញ្ចូល ជំរុញឱ្យមានការសន្ទនាគ្នាក្នុងន័យស្ថាបនា និងយកចិត្តទុកដាក់បំពេញតួនាទី។ អ្នកសម្របសម្រួលរបស់អង្គការដៃគូអនុវត្តនៅមូលដ្ឋាន នឹងបង្កើត ពង្រឹង ព្រមទាំងផ្តល់យោបល់ដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ។ តួនាទីសម្របសម្រួលរបស់អង្គការដៃគូអនុវត្តនៅមូលដ្ឋានរួមមានៈ

- សម្របសម្រួលបង្កើតក្រុមអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ អភិវឌ្ឍសមត្ថភាពរបស់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (ដោយផ្តោតលើស្ត្រី ជនជាតិដើម យុវវ័យ កុមារ និងជនពិការ)
- គាំទ្រអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ក្នុងការសម្របសម្រួលសកម្មភាពផ្សព្វផ្សាយកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ ដោយជំរុញឱ្យប្រជាពលរដ្ឋចង់ចេះ ចង់ដឹង និងស្វែងយល់អំពីព័ត៌មានថវិកា។
- គាំទ្រអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ដើម្បីធ្វើការសម្របសម្រួល អនុវត្តការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ (ដូចជា សម្របសម្រួលការប្រជុំរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដើម្បីត្រួតពិនិត្យឡើងវិញ ប្រមូលយកលទ្ធផលនានា និងធ្វើការបង្ហាញលទ្ធផលទាំងនេះនៅក្នុងកិច្ចប្រជុំរួម តាមទម្រង់មួយងាយយល់)។
- គាំទ្រអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ដើម្បីឱ្យធ្វើការសម្របសម្រួលនៅក្នុងកិច្ចប្រជុំរួម រវាងប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ អ្នកផ្តល់សេវានានា (ដូចជា គ្រូបង្រៀន និងបុគ្គលិកសុខាភិបាល) និងមន្ត្រីថ្នាក់ស្រុក។
- ធ្វើការជាមួយអ្នកពាក់ព័ន្ធនានាដើម្បីជួយរៀបចំ ផ.ស.រ.គ និងបន្តគាំទ្រ ការអនុវត្ត ផ.ស.រ.គ (ដូចជា កិច្ចប្រជុំគណៈកម្មាធិការផ.ស.រ.គជាដើម)។។
- ជួយគាំទ្រក្នុងការរៀបចំ និងបង្ហាញពីលទ្ធផលផ.ស.រ.គ នៅក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក និងសម្រាប់ប្រព័ន្ធព័ត៌មាននៅថ្នាក់ស្រុក។
- ត្រួតពិនិត្យមើលលើការផ្តល់កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ

➢ **អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ៈ ផ.អ.គ.ស** នឹងផ្តល់ឱកាសឲ្យមានការចូលរួម និងប្រាស្រ័យទាក់ទងរវាងប្រជាពលរដ្ឋ និងអង្គភាពផ្តល់សេវាក្នុងបរិយាកាសស្និទ្ធស្នាល និងធ្វើការបញ្ចេញមតិដោយគ្មានការភ័យខ្លាច[29]។ សមាជិកសហគមន៍យ៉ាងតិច៤នាក់នឹងត្រូវជ្រើសរើស (ក្នុងនោះយ៉ាងហោចមាន២នាក់ជាស្ត្រី) មកពីឃុំនីមួយៗ ដើម្បីទទួលការបណ្តុះបណ្តាលជាអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ដោយធ្វើឱ្យពួកគេអាចអភិវឌ្ឍចំណេះដឹង និងជំនាញចាំបាច់ក្នុងការធ្វើការសម្របសម្រួល និងបង្រៀនដល់ប្រជាពលរដ្ឋ ជួយប្រជាពលរដ្ឋឱ្យទទួលបាននូវព័ត៌មាន សម្របសម្រួលការអនុវត្តគណនេយ្យភាពសង្គម ព្រមទាំងបង្កើតឱ្យមានទំនាក់ទំនងការងារប្រកបដោយការស្ថាបនារវាងប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន ឬអ្នកផ្តល់សេវានានា។ តួនាទីរបស់អ្នកសម្របសម្រួល

[29] នៅមូលដ្ឋានមានការបង្កើតជាក្រុមៗជាច្រើន ប៉ុន្តែជួនកាលមិនបានដំណើរការប្រកបដោយប្រសិទ្ធភាពទេ។

គណនេយ្យភាពសហគមន៍ស្ម័គ្រចិត្តទាំងនេះមានសារៈសំខាន់ណាស់ក្នុងការពង្រឹងសមត្ថភាពនៅក្នុងសហគមន៍ដើម្បីធ្វើឱ្យការអនុវត្តគណនេយ្យភាពសង្គមមាននិរន្តរភាពនៅពេលដែលកម្មវិធីនេះត្រូវបានបញ្ចប់ ឬនៅពេលដែលអង្គការមិនមែនរដ្ឋាភិបាលធ្វើការកាត់បន្ថយការងារនៅតាមសហគមន៍។ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ នឹងត្រូវបានជ្រើសរើសដោយផ្អែកលើការប្រកួតប្រជែង។ នៅចុងបញ្ចប់នៃកម្មវិធី គឺត្រូវឱ្យមានអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ឱ្យបានច្រើន (ចំនួនប្រហែល៤០ នាក់) ក្នុងស្រុកគោលដៅនីមួយៗ ដែលអាចផ្តល់ការគាំទ្រជាប្រចាំក្នុងការអនុវត្តគណនេយ្យភាពសង្គម។ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍នឹងត្រូវៈ

- ចូលរួមកម្មវិធីបណ្តុះបណ្តាល និងចូលរួមកម្មវិធីសិក្សារៀនសូត្រ ចងក្រងបទពិសោធន៍តាមរយៈការអនុវត្តបណ្តើររៀនបណ្តើរ។
- អនុវត្តសកម្មភាពការលើកកម្ពស់ការយល់ដឹងនៅតាមភូមិដើម្បីឱ្យប្រជាពលរដ្ឋមានចំណាប់អារម្មណ៍នៅក្នុងការងារគណនេយ្យភាពសង្គម
- រៀបចំ និងសម្របសម្រួលឱ្យមានព្រឹត្តិការណ៍ផ្សព្វផ្សាយកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ និងការយល់ដឹងពីថវិកា
- រៀបចំ និងសម្របសម្រួលការបំពេញប័ណ្ណដាក់ពិន្ទុតាមវិស័យនានាចូលរួមចំណែកដល់ការអនុវត្តសកម្មភាពត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ រៀបចំ និងសម្របសម្រួលកិច្ចប្រជុំរួមគ្នា
- រៀបចំការផ្សព្វផ្សាយស្តីពីលទ្ធផលផ.ស.រ.គ
- គាំទ្រដល់ការអនុវត្ត និងត្រួតពិនិត្យលើផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម។

នៅពេលបញ្ចប់ការបណ្តុះបណ្តាល សិក្ខាកាមទាំងអស់ដែលបានបញ្ចប់វគ្គសិក្សាដោយជោគជ័យ នឹងទទួលបានលិខិតបញ្ជាក់ការសិក្សា ដែលបញ្ជាក់ថាពួកគេទទួលបានការបណ្តុះបណ្តាល ដើម្បីក្លាយជាអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍។ អ្នកដែលបញ្ចប់វគ្គសិក្សាប្រកបដោយជោគជ័យ ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងក្រុមអនុវត្ត និងទទួលបានការគាំទ្រក្នុងការផ្សព្វផ្សាយពីជំនាញរបស់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍។ ថ្វីត្បិតអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍មិនបានទទួលប្រាក់កម្រៃក្នុងការអនុវត្តកម្មវិធី តែជំនាញដែលពួកគេបានរៀនសូត្រ មុខងារនៅក្នុងសហគមន៍ និងលិខិតបញ្ជាក់ការសិក្សា គឺជាការលើកទឹកចិត្តដ៏សំខាន់។

សមាសភាគទី៣ និងទី៤ ស្ថាប័នដៃគូដែលមានជំនាញ រំពឹងថានឹងត្រូវបាន ជ្រើសរើសឱ្យមកចូលរួមក្នុងដំណើរការគាំទ្រការបណ្តុះបណ្តាល និងការសិក្សាចងក្រងបទពិសោធន៍៖

- **ក្រុមគ្រូឧទ្ទេសថ្នាក់ជាតិ៖** ជាក្រុមគ្រូដែលផ្តល់ការបណ្តុះបណ្តាលសម្រាប់ ផ.អ.គ.ស តាមវិធីសាស្ត្របណ្តុះបណ្តាលគ្រូបង្គោល(ToT)។ ក្រុមនេះ នឹងត្រូវជ្រើសរើសឡើង ដើម្បីឱ្យជួយរៀបចំកម្មវិធីសិក្សាសម្ភារសម្រាប់បណ្តុះបណ្តាល និងរៀបចំការបណ្តុះបណ្តាល ទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ។ <u>**សម្រាប់ផ្នែកតម្រូវការ**</u> ការបណ្តុះបណ្តាលរួមមាន៖ ការបណ្តុះបណ្តាលអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (ការបណ្តុះបណ្តាលជនបង្គោលរបស់អង្គការនៅមូលដ្ឋាន និងអ្នកផ្តល់យោបល់) ដូចបានរៀបរាប់នៅក្នុងសមាសភាគទី៣ ចំនុច ៤.២ ការបណ្តុះបណ្តាល ការហ្វឹកហ្វឺន និងការពង្រឹងសមត្ថភាព។ <u>**សម្រាប់ផ្នែកផ្គត់ផ្គង់**</u> ការបណ្តុះបណ្តាលរួមមានការបណ្តុះបណ្តាល ដល់មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ

(មន្ត្រីរដ្ឋបាលស្រុក ក្រុមប្រឹក្សាស្រុក មន្ត្រីបង្គោលថ្នាក់ស្រុក មន្ត្រីការិយាល័យស្រុកប្រតិបត្តិ ការិយាល័យអប់រំស្រុក និងអ្នកពាក់ព័ន្ធមួយចំនួនទៀត )។

- **អង្គការដៃគូជំនាញផ្នែកប្រមូលមេរៀនបទពិសោធន៍ និងការត្រួតពិនិត្យតាមដាន៖** អង្គការដៃគូនេះនឹងជ្រើសរើសមក ដើម្បីគ្រប់គ្រងចាត់ចែងលើការរៀបចំវេទិកាសម្រាប់ការប្រមូលមេរៀនបទពិសោធន៍ និងចូលរួមអនុវត្តសមាសភាគប្រមូលមេរៀនបទពិសោធន៍ និងការត្រួតពិនិត្យតាមដាន ។ ដោយផ្តោតការយកចិត្តទុកដាក់លើការផ្តល់ព័ត៌មានត្រឡប់ជាប្រចាំ និងរៀនសូត្រពីបទពិសោធន៍ និងការកែសម្រួលកាតព្វកិច្ចដៃគូជំនាញនេះរួមមាន៖ ប្រមូល និងចងក្រងមេរៀនបទពិសោធន៍ពីមូលដ្ឋាន ព្រមទាំងបញ្ចូលបទពិសោធន៍ដែលបានរៀនសូត្រទាំងនេះ ទៅក្នុងដំណើរការនៃការកែសម្រួលលើគោលនយោបាយ និងការអនុវត្ត។ អង្គការដៃគូនៅថ្នាក់ជាតិ នឹងទទួលបានការគាំទ្រនូវវិធីសាស្ត្រនៃការប្រមូលមេរៀន និងបទពិសោធន៍ ដោយសហការជាមួយអង្គការដៃគូនៅមូលដ្ឋាន ដើម្បីធ្វើការចងក្រង និងឆ្លុះបញ្ចាំងពីការងារនេះថា បានដំណើរការដូចម្តេចខ្លះ ដូចជា ភាពជោគជ័យ បរាជ័យ ភាពរាំងស្ទះ និងឱកាសក្នុងការផ្តួចផ្តើមនានាឱ្យមានវេទិការួមសម្រាប់ធ្វើការឆ្លុះបញ្ចាំង និងផ្តល់យោបល់ត្រឡប់លើដំណើរការ (ការធ្វើសវនកម្មលើដំណើរ) និងលទ្ធផលនានា ដែលបង្កើតឱ្យមានការត្រួតពិនិត្យមើលឡើងវិញ និងការវាយតម្លៃ ការផ្សព្វផ្សាយព័ត៌មាន ឧបករណ៍នានា ករណីសិក្សា និងលើកកម្ពស់ការយល់ដឹងពាក់ព័ន្ធនឹងគណនេយ្យភាពសង្គមក្នុងចំណោមស្ថាប័ន អង្គភាពរបស់រដ្ឋ និងមិនមែនរដ្ឋនៅប្រទេសកម្ពុជាដូចបានរៀបរាប់នៅក្នុងសមាសភាគទី៤ ចំនុច ៥.១ ការប្រមូលមេរៀនបទពិសោធន៍ និងការផ្តល់ព័ត៌មានត្រឡប់។
- **ការរៀបចំយន្តការសម្របសម្រួល៖** ផ.អ.គ.ស ពាក់ព័ន្ធទាំងសកម្មភាពផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់ដែលត្រូវមានការសម្របសម្រួល និងតម្រូវឱ្យមានការរៀបចំយន្តការអភិបាលកិច្ចកម្រិតខ្ពស់សម្រាប់ការសម្រេចចិត្តជាយុទ្ធសាស្ត្រ ការត្រួតពិនិត្យមើលពីលើ និងការសម្របសម្រួលនានា។ ដូចនេះ **គណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម(គ.គ.អ.ស)** ឬហៅថា Implementation Social Accountability Framework Partnership Steering Committee (I-SAF PSC) បានបង្កើតឡើងក្នុងគោលបំណង ដើម្បីផ្តល់វេទិកាសម្រាប់កិច្ចពិភាក្សា និងធ្វើសេចក្តីសម្រេចចិត្តលើការរៀបចំគោលនយោបាយ ផែនការសកម្មភាពនិងថវិកា ការកំណត់តំបន់គោលដៅ និងនីតិវិធីគាំទ្រការអនុវត្តការងារគណនេយ្យភាពសង្គមនៅថ្នាក់ក្រោមជាតិ។ **គ.គ.អ.ស** មានសមាសភាពមកពី តំណាងក្រសួងស្ថាប័នរាជរដ្ឋាភិបាល តំណាងអង្គការសង្គមស៊ីវិល និងតំណាងដៃគូអភិវឌ្ឍន៍ដែលផ្តល់ហិរញ្ញប្បទានសម្រាប់ការអនុវត្តកម្មវិធីគណនេយ្យភាពសង្គម។ "**គ.គ.អ.ស**" **នឹង**ត្រូវជួបប្រជុំយ៉ាងតិចបួនដងក្នុងមួយឆ្នាំ និងរាល់ការធ្វើសេចក្តីសម្រេចចិត្ត នឹងត្រូវធ្វើឡើង ដោយមានការព្រមព្រៀងគ្នា។ ចំពោះតួនាទីភារកិច្ច និងរបៀបរបបការងាររបស់គណៈកម្មាធិការមានរៀបរាប់លំអិតក្នុងល័ក្ខខ័ណ្ឌការងាររបស់គណៈកម្មាធិការ។

## ៣.ការចាត់ចែងអនុវត្ត

### ៣.១. ការចាប់ផ្តើមអនុវត្ត

លេខាធិការដ្ឋានគ.ជ.អ.ប នឹងធ្វើការយ៉ាងជិតស្និទ្ធិជាមួយអង្គការសង្គមស៊ីវិល និងស្ថាប័នមួយចំនួន ដោយរៀបចំចងក្រងឯកសារឱ្យទៅជាកម្មវិធីដើម្បីអនុវត្ត។ រៀបចំបង្កើតឧបករណ៍ និងដំណើរការនានា រៀបចំផែនការអនុវត្តគណនេយ្យភាពសង្គម កែសម្រួលឧបករណ៍តាមបទពិសោធន៍ដែលមានស្រាប់ ក៏ដូចជាពិនិត្យឡើងវិញទៅលើការអនុវត្តកន្លងមកដើម្បីចៀសវាងការធ្វើសកម្មភាពដដែលៗ។ ការពិភាក្សា និងការសាកល្បងឧបករណ៍សំខាន់ៗ និងការរៀបចំឯកសារនានា ធ្វើឡើងដូចបានរៀបរាប់ក្នុងសមាសភាគទី១ ទី២និងទី៣ខាងលើ។ ឧទាហរណ៍ តើធ្វើយ៉ាងណាទើបការយល់ដឹងពីព័ត៌មាននិងការងារថវិកា វិធីសាស្ត្របំណ្ណដាក់ពិន្ទុ និងការរៀបចំ ផ.ស.រ.គ កាន់តែមានភាពល្អប្រសើរឡើង ហើយការសាកល្បងរៀបចំយន្តការសម្របសម្រួល(យកបទពិសោធន៍ពីលក្ខណៈផ្សេងៗគ្នារបស់ស្ថាប័ននីមួយៗ)។

### ៣.២. ក្របខ័ណ្ឌពេលវេលាសម្រាប់ការអនុវត្ត

ដោយសារការរៀបចំអនុវត្តគណនេយ្យភាពសង្គមនេះត្រូវការពេលវេលាច្រើន ដូចជារៀបចំសៀវភៅណែនាំយន្តការផ្តល់ហិរញ្ញប្បទាន និងការសម្របសម្រួលនានា ហេតុនេះផែនការអនុវត្តគណនេយ្យភាពសង្គមនឹងត្រូវអនុវត្ត ជាបីដំណាក់កាលសំខាន់ៗដោយធ្វើយ៉ាងណាអាចពង្រីកសកម្មភាពឱ្យបានគ្របដណ្តប់ស្រុកចំនួន១២០ នៅឆ្នាំទី៣៖

- ២០១៤៖សាកល្បងឧបករណ៍ និងដំណើរការនានាចំនួន ២២ ស្រុក
- ២០១៥៖ អនុវត្តសាកល្បងចំនួន ២៧ ស្រុក
- ២០១៦៖ អនុវត្តលើស្រុកគោលដៅចំនួន ៥៤ ស្រុក
- ២០១៧៖ ចំនួន ៤៦ស្រុកបន្ថែមទៀត (៥៤(ឆ្នាំទី១) + ៤៦(ឆ្នាំទី២))
- ២០១៨៖ ចំនួន ២០ ស្រុកបន្ថែមទៀត (៥៤(ឆ្នាំទី១) + ៤៦ (ឆ្នាំទី២) + ២០(ឆ្នាំទី៣))
- ២០១៩៖ ចាប់ផ្តើមអនុវត្តផែនការអនុវត្តសង្កាត់ ខណ្ឌ និងក្រុង
- តំបន់គ្របដណ្តប់ គឺអាស្រ័យលើធនធានដែលមានសម្រាប់ការអនុវត្តរបស់អង្គការសង្គមស៊ីវិល និង"ការសម្រេចចិត្តចូលរួម" របស់អង្គការសង្គមស៊ីវិលទាំងនោះ។

## ៤. ការផ្តល់ហិរញ្ញប្បទាន

### ៤.១. ការចំណាយថវិកា

ក្នុងរយៈពេល៣ឆ្នាំ ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៨ ថវិកាគម្រោងចំណាយក្នុងការអនុវត្ត ផ.អ.គ.ស មានចំនួន១២.៩លានដុល្លារអាមេរិក ក្នុងនោះ៨លានដុល្លារ សម្រាប់អនុវត្តសកម្មភាពផ្នែកតម្រូវការ រីឯជាង២,១លានដុល្លារសម្រាប់សកម្មភាពផ្នែកផ្គត់ផ្គង់ហើយ និងថវិកាចំនួន២.៧លានដុល្លារទៀត សម្រាប់អនុវត្តសកម្មភាពក្នុងសមាសភាគទី៣ និងទី៤ ដោយថវិកានេះត្រូវផ្តល់ដល់ស្ថាប័នឬអ្នកជំនាញការឯករាជ្យ។

ផ្អែកលើការវាស់វែង ដែលបានកំណត់ក្នុងសមាសភាគទី១ និងទី២ ដែលមានគ្រប់សកម្មភាពនៅមូលដ្ឋានទាំងអស់ដូចជា ការពង្រឹងសមត្ថភាពនៅថ្នាក់ឃុំ ភូមិ និងសហគមន៍ ការចំណាយប្រចាំឆ្នាំសម្រាប់ការអនុវត្តក្នុងមួយស្រុក គឺជាមធ្យមប្រហែល៤០.០០០ដុល្លារក្នុងរយៈពេល៣ឆ្នាំ សម្រាប់ទាំងការចំណាយផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការនៅថ្នាក់មូលដ្ឋាន។

**តារាងទី ៦៖** ការប៉ាន់ស្មានថវិកាតាមសមាសភាគ (សម្រាប់រយៈពេលចាប់ពីឆ្នាំ២០១៦ដល់២០១៨)

| សមាសភាគ | 2016 | 2017 | 2018 | សរុប | % |
|---|---|---|---|---|---|
| **ផ្នែកផ្គត់ផ្គង់**(សមាសភាគទី១ភាពងាយទទួលបានព័ត៌មានស្តីពីស្តង់ដារ ថវិកា និងការបំពេញមុខងារ) | $520,063 | $758,392 | $912,293 | $2,190,748 | 17 |
| **ផ្នែកតម្រូវការ** (សមាសភាគទី២ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ) | $2,394,949 | $2,932,041 | $2,729,889 | $8,056,879 | 62 |
| **ស្ថាប័នដៃគូជំនាញ បណ្តុះបណ្តាល** (សមាសភាគទី៣ ការសម្របសម្រួល និងការពង្រឹងសមត្ថភាព) | $538,750 | $742,000 | $674,250 | $1,955,000 | 15 |
| **ស្ថាប័នដៃគូប្រមូលមេរៀន និងបទពិសោធន៍** (សមាសភាគទី៤ ការប្រមូលមេរៀនបទពិសោធន៍ និងការត្រួតពិនិត្យតាមដាន) | $200,000 | $200,000 | $350,000 | $750,000 | 6 |
| **សរុប** | $3,653,762 | $4,632,433 | $4,666,432 | $12,952,627 | 100% |
| គិតជាភាគរយ | 28% | 36 % | 36 % | 100 % | |

តារាងទី៧៖ ការចំណាយគ្រោងចាប់ពីឆ្នាំ២០១៦-២០១៨ សម្រាប់ផ្នែកតម្រូវការនិងផ្នែកផ្គត់ផ្គង់

| | សរុប | |
|---|---|---|
| ថវិកាសម្រាប់សកម្មភាពអង្គការដៃគូអនុវត្ត (ផ្នែកតម្រូវការ) | $8,007,474 | **79%** |
| ថវិកាសម្រាប់សកម្មភាពរាជរដ្ឋាភិបាល(ផ្នែកផ្គត់ផ្គង់) (រួមទាំងសិក្សារៀនសូត្រ និងការបណ្តុះបណ្តាល) | $2,190,748 | **21%** |
| **សរុប** | **$10,198,222** | |

## ៤.២. ការផ្តល់ហិរញ្ញប្បទាន

**គោលការណ៍៖** ការផ្តល់ហិរញ្ញប្បទានសម្រាប់អនុវត្តផ.អ.គ.ស មានភាពស៊ាំញ៉ាំដោយសារតែការផ្តល់ថវិកាត្រូវធ្វើឱ្យបានសមស្របចំពោះរាជរដ្ឋាភិបាល និងអង្គការដៃគូអនុវត្ត ដើម្បីអាចអនុវត្តសកម្មភាពទាំងនោះបានត្រូវមានការប្តេជ្ញាចិត្តពីភាគីទាំងពីរ។ គោលការណ៍ផ្តល់ហិរញ្ញវត្ថុខាងក្រោមនេះ ត្រូវអនុវត្តទៅតាមលទ្ធភាព ៖

- ថវិកាសម្រាប់លេខាធិការដ្ឋានគ.ជ.អ.ប ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ មានចែងនៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គ.ជ.អ.ប រីឯថវិកាសម្រាប់អង្គការដៃគូអនុវត្ត នឹងដាក់ដោយឡែក នៅក្នុងផ.ស.ថ រៀងៗខ្លួនទៅតាមប្រភពអ្នកផ្តល់ជំនួយ ដែលនឹងត្រូវគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ដោយអង្គការដៃគូអនុវត្តខ្លួនឯងផ្ទាល់។
- ថវិកាសម្រាប់ផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់ ត្រូវរក្សាឱ្យមានតុល្យភាពតាមលទ្ធភាពដែលធ្វើបានដើម្បីបង្ហាញនូវការប្តេជ្ញាចិត្ត និងភាពជាម្ចាស់។

- ការផ្តល់ថវិកាសម្រាប់សមាសភាគទី៤"ការសិក្សាប្រមូលមេរៀនបទពិសោធន៍ និងការត្រួតពិនិត្យតាមដាន" គួរកំណត់ជាក់លាក់យ៉ាងហោចណាស់សម្រាប់រយៈពេល២ឆ្នាំ។
- ការផ្តល់ថវិកាពីប្រភពផ្សេងៗ (រួមមានទាំងការផ្តល់ថវិកាតាមវិស័យ) នឹងត្រូវបានសម្របសម្រួល និងលើកទឹកចិត្តបន្ថែមទៀតសម្រាប់ការចំណាយស្របទៅតាមផែនការអនុវត្ត។
- ក្របខ័ណ្ឌហិរញ្ញប្បទានប្រកបដោយនិរន្តរភាពសម្រាប់សកម្មភាពនានា គួរត្រូវបានបង្កើតឡើងតាមរយៈការអនុវត្តផ្ទាល់។

**ទំហំការងារត្រូវផ្សារភ្ជាប់នឹងការផ្តល់ហិរញ្ញវត្ថុ៖** ផ.អ.គ.ស ជួយបង្កើតនូវអភិក្រមប្រកបដោយនិរន្តរភាព និងកំណត់គោលដៅដែលអាចសម្រេចបានសម្រាប់សកម្មភាពចំបងចំនួន៣រួមមាន៖ ព័ត៌មាននានា ព័ត៌មានថវិកា និងការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ (រួមទាំងការរៀបចំផែនការសកម្មភាពរួមគ្នា)។ ផ.អ.គ.ស បំពេញបន្ថែមការខ្វះចន្លោះនៃដំណើរការនានាដែលមានស្រាប់តាមរយៈការអនុវត្តសកម្មភាពរួមមួយចំនួន ហេតុនេះបើទំហំការងារកាន់តែធំ នោះតម្រូវការថវិកានឹងកាន់តែច្រើនឡើងដែរ។ ចំនួនស្រុកដែលចូលរួមអនុវត្តនឹងត្រូវបានកំណត់ផ្អែកលើថវិកាដែលមានសម្រាប់រយៈពេល៣ឆ្នាំ។ ទិដ្ឋភាពសំខាន់មួយនៃផ.អ.គ.ស ដែលជាកម្មវិធីត្រូវអនុវត្តនៅទូទាំងប្រទេស គឺការណែនាំជារបៀបអនុវត្តប្រកបដោយនិរន្តរភាព និងដែលអាចអនុវត្តបាននៅគ្រប់ស្រុកទាំងអស់នៅទូទាំងប្រទេស ។

**ការផ្តល់ហិរញ្ញប្បទាន ក្នុងដំណាក់កាលរៀបចំដំបូងនៃផ.អ.គ.ស (មុនឆ្នាំ២០១៦)៖** ក្នុងដំណាក់កាលដំបូងគឺផ្តោតលើ ការងាររៀបចំឯកសារ សាកល្បងឧបករណ៍ និងដំណើរការ ដែលបានទទួលថវិកាគាំទ្រមួយចំនួនពីគម្រោងអភិបាលកិច្ចល្អមូលដ្ឋាន (គម្រោងការិយាល័យច្រកចេញចូលតែមួយដែលចាត់ចែងដោយគ.ជ.អ.ប រួមទាំងសមាសភាគសម្រាប់បង្កើនការយល់ដឹងសម្រាប់ប្រជាពលរដ្ឋ) និងសមាសភាគទី២(សមាសភាគសម្រាប់តួអង្គមិនមែនរដ្ឋ) មានថវិកាប្រហែល៤៣៥.០០០ដុល្លារ ដែលបានវិភាជន៍សម្រាប់សកម្មភាពដូចខាងក្រោម៖

- សម្រាប់ការរៀបចំកញ្ចប់ព័ត៌មាន (ឧបករណ៍ និងទម្រង់ព័ត៌មានរបស់ផ្នែកផ្គត់ផ្គង់សម្រាប់ព័ត៌មាន និងថវិកា ព្រមទាំងការណែនាំចាំបាច់នានាសម្រាប់សកម្មភាពផ្សេងៗនៅក្នុងស្រុកគោលដៅក្នុងឆ្នាំ២០១៤ ចំនួន១៣៥.០០០ដុល្លារ (គ្រប់គ្រងចាត់ចែងដោយ គ.ជ.អ.ប)
- សម្រាប់សកម្មភាពផ្នែកតម្រូវការ (រួមទាំងការរៀបចំយន្តការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ ហើយសកម្មភាពផ្នែកតម្រូវការដែលពាក់ព័ន្ធជាមួយព័ត៌មាន និងថវិកា) ចំនួន២៥០.០០០ដុល្លារ (ចាត់ចែងដោយមូលនិធិអាស៊ី)
- ធនាគារពិភពលោកនឹងគាំទ្រសម្រាប់ការសិក្សានានា និងជំនួយបច្ចេកទេស។

**ការផ្តល់ហិរញ្ញវត្ថុសម្រាប់សកម្មភាពនៃផែនការអនុវត្តគណនេយ្យភាពសង្គម ដែលអនុវត្តដោយលេខាធិការដ្ឋានគ.ជ.អ.ប ស្ថាប័នជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ (ក្នុងសមាសភាគទី១ និងទី២)** ហៅថាកាត់ថាផ្នែកផ្គត់ផ្គង់ និងត្រូវបញ្ចូលទៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនៃផអ៣ទី២របស់គ.ជ.អ.ប ជារៀងរាល់ឆ្នាំ តាមរយៈយន្តការរបស់គ.ជ.អ.ប។ នាពេលខាងមុខ ធនាគារពិភពលោក អាចនឹងបញ្ចូលសមាសភាគតម្លាភាព និងគណនេយ្យភាពនៃគម្រោងអភិវឌ្ឍន៍ និងអភិបាលកិច្ចមូលដ្ឋាន (LGDP) ទៅក្នុងផ.ស.ថប្រចាំនៃគ.ជ.អ.ប ដើម្បីជួយគាំទ្រសកម្មភាពចាំបាច់នានាសម្រាប់ផ្នែកផ្គត់ផ្គង់។

**ការផ្តល់ហិរញ្ញប្បទាន សម្រាប់អនុវត្តសកម្មភាពនៃ ផ.អ.គ.ស ដែលអនុវត្តដោយអង្គការដៃគូអនុវត្ត (សមាសភាគទី១ ទី២ និងទី៣)** ហាក់មានលក្ខណៈស្មុគស្មាញ ហើយទាមទារនូវ ការសម្របសម្រួលជាមួយដៃគូមួយចំនួន។ យុទ្ធសាស្រ្តសំខាន់២ រួមមាន៖

- **ជំរុញការចូលរួម៖** លើកទឹកចិត្តអង្គការដៃគូអនុវត្ត ឱ្យចូលរួមគាំទ្រការអនុវត្តផ**.អ.គ.ស**។ អង្គការដៃគូអនុវត្តនានានឹងប្តេជ្ញាចិត្តក្នុងការអនុវត្តនូវសកម្មភាពសំខាន់ៗនៅស្រុកគោលដៅដែលបានកំណត់ និងសកម្មភាពមានស្រាប់នៅទីនោះ។ រីឯ គ.ជ.អ.ប ក៏នឹងអនុវត្តសកម្មភាពផ្នែកផ្គត់ផ្គង់នៅស្រុកគោលដៅនោះផងដែរ។ ការចូលរួម ត្រូវស្តែងចេញតាមរយៈអនុស្សរណៈនៃការយោគយល់គ្នា។
- **ការបង្កើនថវិកា៖** ផ.អ.គ.ស មិនមានការផ្តល់ថវិកាតាមរយៈគម្រោងដាច់ដោយឡែក ដូចដែលធ្លាប់បានអនុវត្តនៅក្នុងប្រទេសកម្ពុជាកន្លងមកនោះទេ។ ផ្ទុយទៅវិញ អង្គការដៃគូអនុវត្ត ដែលកំពុងអនុវត្តសកម្មភាពរបស់ខ្លួននៅក្នុងឃុំ ស្រុកទាំងនោះ ត្រូវបន្ថែមថវិកាលើថវិការបស់ខ្លួនដែលមានស្រាប់ ដើម្បីអនុវត្តសកម្មភាពសំខាន់ៗ។ ការបន្ថែមថវិកានេះ អាចមានចំនួនពី ៨០០០-១២០០០ដុល្លារ សម្រាប់១ស្រុកក្នុង១ឆ្នាំ (ប្រហែល១០០០ដុល្លារសម្រាប់១ឃុំក្នុង១ឆ្នាំ)។ របៀបអនុវត្តបែបនេះ គឺដើម្បីធានាប្រសិទ្ធភាព និងនិរន្តរភាព ដូច្នេះដើម្បីឱ្យអង្គការដៃគូអនុវត្ត ទាំងនោះ បញ្ចូលការងារគណនេយ្យភាពសង្គមទៅក្នុងកម្មវិធី ដែលមានស្រាប់នៅតាមតំបន់ដែលអង្គការទាំងនោះមានទំនាក់ទំនង និងសកម្មភាពការងារនៅទីនោះ។ ការអនុវត្តបែបនេះ អាចជួយជំរុញឱ្យមានមធ្យោបាយថ្មី ក្នុងការអនុវត្តកិច្ចការអ្វីមួយ ជៀសវាងធ្វើគម្រោងតូចៗ និងមានលក្ខណៈដាច់ដោយឡែក។
- **ការផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍៖** ដៃគូអភិវឌ្ឍន៍ណាក៏ដោយ អាចចូលរួមក្នុងការផ្តល់ថវិកាសម្រាប់ការអនុវត្តផ.អ.គ.ស។ ដៃគូអភិវឌ្ឍន៍នីមួយៗដែលមានតម្រូវការផ្សេងៗគ្នាសម្រាប់ការផ្តល់ថវិកាគាំទ្រដល់អង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានលើកទឹកចិត្តដើម្បីពិភាក្សាជាមួយដៃគូផ្តល់ជំនួយនានា (បន្ទាប់ពីពិភាក្សាបានសម្រេចដោយចូលរួម)។ យល់ឃើញថាការចាប់ផ្តើមគឺអាស្រ័យលើការរៀបចំ សៀវភៅណែនាំស្តីពីកិច្ចប្រតិបត្តិការ គណនេយ្យភាពសង្គម ដែលបង្ហាញពីឧបករណ៍ និងដំណើរការនានាសម្រាប់អនុវត្ត។ ដៃគូអភិវឌ្ឍន៍នានា កំពុងរៀបចំសំណើសុំថវិកាសម្រាប់រយៈពេល៣ឆ្នាំដំបូងមានដូចខាងក្រោម៖
    - **ធនាគារពិភពលោកនឹងចាត់ចែងមូលនិធិ Trust Fund៖** ក្រុមធនាគារពិភពលោក បានសំណើផ្តល់ហិរញ្ញប្បទាន **Trust Fund** សម្រាប់សកម្មភាពអង្គការដៃគូអនុវត្ត ។ ធនាគារពិភពលោក នឹងពង្រឹងគោលការណ៍ដែលបានកំណត់ខាងលើ ពិសេសយន្តការមួយដោយពង្រឹងបន្ថែមលើកម្មវិធីដែលមានស្រាប់ដោយប្រើប្រាស់នូវ រចនាសម្ព័ន្ធកំពុងដំណើរការ និងភាពជាដៃគូជាមួយអង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិដែលកំពុងធ្វើសកម្មភាព។
    - **សហភាពអឺរ៉ុប៖** មូលនិធិសម្រាប់សង្គមស៊ីវិលរបស់សហភាពអឺរ៉ុបនឹងផ្តល់ឱកាសសម្រាប់អង្គការសង្គមស៊ីវិល ស្នើសុំឥណទានយកទៅអនុវត្តសកម្មភាពនានានៅក្នុងប្រទេសកម្ពុជា។ ការអនុវត្ត ផ.អ.គ.ស គឺស្របជាមួយលក្ខណៈវិនិច្ឆ័យសម្រាប់ការផ្តល់ហិរញ្ញវត្ថុនេះ ហើយសហភាពអឺរ៉ុបអាចប្រកាសឱ្យមានការដាក់សំណើ ដើម្បីអនុវត្តផ.អ.គ.ស។ សហភាពអឺរ៉ុបបានបើកឱកាសគាំទ្រដល់សង្គមស៊ីវិល ដែលប្រការនេះស្របទៅនឹងការគាំទ្ររបស់ខ្លួនលើការងារកំណែទម្រង់ការអភិវឌ្ឍតាម

បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ហើយការងារនេះក៏គាំទ្រដល់ការចូលរួមរបស់ប្រជាពលរដ្ឋ ដូចបានបរិយាយក្នុងឯកសារផែនការយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គម។

- យូនីសេហ្វUNICEF៖ ក្នុងការអនុវត្តសាកល្បងលើស្រុកគោលដៅទាំង២២ ក្នុងឆ្នាំ២០១៤ លេខាធិការដ្ឋាន គ.ជ.អ.ប បានទទួលថវិកាគាំទ្រពីអង្គការ UNICEF ចំនួន ៨៦.០០០ដុល្លារ ដើម្បីអនុវត្តការផ្សព្វផ្សាយការងារគណនេយ្យភាពសង្គមដែលថវិកាចំនួន ៤០.០០០ដុល្លារ សម្រាប់ផ្នែកផ្គត់ផ្គង់ និងថវិកាចំនួន ៤៦.០០០ដុល្លារ សម្រាប់ផ្នែកតម្រូវការ។ សម្រាប់ឆ្នាំ២០១៥ អង្គការយូនីសេហ្វបានបន្តគាំទ្រលើការរៀបចំប្រព័ន្ធទិន្នន័យដើម្បីតាមដានត្រួតពិនិត្យការអនុវត្តការងារគណនេយ្យភាពសង្គម ។ យោងតាមផែនការគម្រោងអភិបាលកិច្ចមូលដ្ឋាន ដើម្បីសិទ្ធិកុមាររបស់អង្គការយូនីសេហ្វសម្រាប់ឆ្នាំ២០១៦ដល់ ២០១៨ អង្គការនឹងបន្តជួយគាំទ្រដល់ការអនុវត្តការងារគណនេយ្យភាពសង្គមលើការរៀបចំប្រព័ន្ធទិន្នន័យនៅឆ្នាំ២០១៦បន្តទៀត។ អង្គការយូនីសេហ្វមានបំណងធ្វើការជាដៃគូអភិវឌ្ឍន៍ ដើម្បីផ្តល់ជាជំនួយបច្ចេកទេសទៅលេខាធិការដ្ឋានគ.ជ.អ.ប ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលប្រព័ន្ធទិន្នន័យត្រួតពិនិត្យនេះសម្រាប់ការអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រគណនេយ្យភាពសង្គម និងការចងក្រងឯកសារ មេរៀន និងបទពិសោធន៍សម្រាប់ការពិភាក្សា និងរៀបចំគោលនយោបាយ។
- **គម្រោងភាពជាដៃគូសកលសម្រាប់គណនេយ្យភាពសង្គម(GPSA)៖** ធនាគារពិភពលោកនឹងគ្រប់គ្រង ចាត់ចែង(នៅទីស្នាក់ការកណ្តាលរបស់ខ្លួន) មូលនិធិដែលផ្តោតជាពិសេសលើសកម្មភាពគណនេយ្យភាពសង្គម។ ដើម្បីឱ្យអង្គការមិនមែនរដ្ឋាភិបាលអាចទទួលបានមូលនិធិនេះ ត្រូវមានការចុះហត្ថលេខាជាមួយគម្រោងក្នុងភាពជាដៃគូសកលសម្រាប់ការងារគណនេយ្យភាពសង្គម។ តំណាងអង្គការសង្គមស៊ីវិល ត្រូវពិភាក្សាជាមួយគ.ជ.អ.ប ដើម្បីរៀបចំកិច្ចព្រមព្រៀង ដោយអ្នកទទួលថវិកា ទទួលបានផលប្រយោជន៍ពីក្រុមអ្នកពាក់ព័ន្ធជាសកលផ្សេងៗទៀត ដើម្បីសិក្សារៀនសូត្រពីគ្នាទៅវិញទៅមក នេះជាយន្តការមួយដែលមានលក្ខណៈស្ថាបនា និងគាំទ្រគ្នាទៅវិញទៅមក។ ដោយមានការគាំទ្រពីការិយាល័យប្រចាំប្រទេសរបស់ធនាគារពិភពលោក អង្គការមិនមែនរដ្ឋាភិបាលនឹងស្វែងរកឱ្យមានការព្រមព្រៀងគ្នាជាមួយរាជរដ្ឋាភិបាលកម្ពុជាដើម្បីក្លាយជាសមាជិកនៃក្រុមដៃគូសកលសម្រាប់ការងារគណនេយ្យភាពសង្គម។ មូលនិធិសម្រាប់ក្រុមដៃគូសកលសម្រាប់ការងារគណនេយ្យភាពសង្គមត្រូវបានបង្កើតឡើងនាពេលថ្មីៗនេះ នៅក្នុងធនាគារពិភពលោក ប្រទេសនានាអាចចូលរួមសម្រាប់ការងារគណនេយ្យភាពសង្គម ដើម្បីក្លាយជាប្រទេសសមាជិក និងដើម្បីអាចឱ្យអង្គការសង្គមស៊ីវិលស្វែងរកមូលនិធិសម្រាប់អនុវត្តសកម្មភាពគណនេយ្យភាពសង្គម។ ក្រៅពីដំណើរការនេះ ប្រទេសកម្ពុជានឹងព្រមព្រៀងទៅលើយុទ្ធសាស្ត្រសម្រាប់ការផ្តល់មូលនិធិ ដែលគេរំពឹងថាយុទ្ធសាស្ត្រនេះ នឹងផ្តោតទៅលើសកម្មភាពគណនេយ្យភាពសង្គម។ ការផ្តល់មូលនិធិតាមរយៈយន្តការនេះ មិនមានចំនួនច្រើនទេ (ប្រហែល៥០០.០០០ដុល្លារ សម្រាប់រយៈពេល៣ឆ្នាំ)។
- **ធនាគារពិភពលោកបានរៀបចំនូវឯកសារទស្សនទានសម្រាប់ទទួលបានឥណទានពីមូលនិធិអភិវឌ្ឍន៍សង្គមរបស់ប្រទេសជប៉ុន (JSDF) សម្រាប់គាំទ្រសកម្មភាពផ្នែកតម្រូវការ៖** មានការរៀបចំនូវសំណើសុំចំនួន២ ដែលមានថវិកាប្រហែល៥លានដុល្លារអាមេរិច ដើម្បីគាំទ្រសកម្មភាពផ្នែកតម្រូវការរយៈពេលនៃផ.អ.គ.ស។ គេរំពឹងថាអ្នកទទួលបានឥណទាននេះ គឺជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ

ដែលមានសមត្ថភាពគ្រប់គ្រង និងចាត់ចែងហិរញ្ញវត្ថុស្របតាមការទទួលខុសត្រូវផ្នែកសុចរិតភាពរបស់ធនាគារពិភពលោក។

- **ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់ប្រទេសស៊ុយអែត (Sida)** បានប្រកាសរួចហើយអំពីគម្រោងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលមានឈ្មោះកាត់ថា **PROCEED**។ គម្រោងនេះ បានត្រូវអនុវត្តនៅក្នុងស្រុកចំនួន៨ ក្នុងការសាកល្បងទៅលើដំណើរការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងដំណើរការនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិតាមរយៈដៃគូជាអង្គការសង្គមស៊ីវិលក្នុងស្រុក។ Sida បានបញ្ជាក់ថា អង្គការសង្គមស៊ីវិលដែលទទួលបានថវិកាតាមរយៈគម្រោងនេះអាចសម្រេចចូលរួម ដើម្បីអនុវត្តសកម្មភាពក្របខ័ណ្ឌការងារគណនេយ្យភាពសង្គម។ យើងនៅមិនទាន់ដឹងនៅឡើយទេថា តើអង្គការដៃគូអនុវត្តចំនួន៥ ត្រូវបន្តតាមរបៀបដែលអនុវត្តកន្លងមក ឬបង្វែរមកអនុវត្តតាមយុទ្ធសាស្ត្រគណនេយ្យភាពសង្គមវិញ។
- **ទីភ្នាក់ងារ USAID** នឹងផ្តល់មូលនិធិសម្រាប់គម្រោង២ ក្នុងវិស័យសុខាភិបាលរយៈពេល៥ឆ្នាំ(ខែតុលា ឆ្នាំ២០១៤-ខែកញ្ញា ឆ្នាំ២០១៩)៖ ការលើកកម្ពស់សិទ្ធិអំណាចសហគមន៍ដើម្បីសុខភាព និងព័ត៌មានពាក់ព័ន្ធសុខភាព គោលនយោបាយ និងការតស៊ូមតិ ដើម្បីជួយពង្រឹងការអនុវត្តសកម្មភាព ផ.អ.គ.សដែលពាក់ព័ន្ធនឹងសកម្មភាពសំដៅដល់ការលើកកម្ពស់សុខភាពដោយមានការពិភាក្សាពីរបៀបដើម្បីបញ្ចូលគម្រោងនេះទៅក្នុងផ.អ.គ.ស។

ការផ្តល់ហិរញ្ញវត្ថុសម្រាប់អ្នកផ្តល់ការបណ្តុះបណ្តាលស្តីពីផ.អ.គ.ស (នៅក្នុងសមាសភាគទី៣ ចំនុច ៤.២ ការបណ្តុះបណ្តាល ការហ្វឹកហ្វឺន និងការពង្រឹងសមត្ថភាព) នឹងត្រូវពិភាក្សាបន្តទៀត។ អង្គការមិនមែនរដ្ឋាភិបាលដែលអនុវត្តការងារទាំងនេះ នឹងទទួលការបណ្តុះបណ្តាលគ្រូបង្គោល និងសម្ភារៈបណ្តុះបណ្តាល ព្រមទាំងបន្តការបណ្តុះបណ្តាលនៅក្នុងអង្គការរបស់ខ្លួនបន្តទៀត។

**ការផ្តល់ហិរញ្ញវត្ថុសម្រាប់ការសិក្សាស្វែងយល់ និងអ្នកតាមដានត្រួតពិនិត្យផែនការអនុវត្តគណនេយ្យភាពសង្គម (សមាសភាគទី៤)** គួរធ្វើដាច់ដោយឡែក ដើម្បីធានាថាការសិក្សាស្វែងយល់ និងការតាមដានត្រួតពិនិត្យត្រូវបានអនុវត្តដោយប្រុងប្រយ័ត្ន និងមាននិរន្តរភាព។

**អង្គការមិនមែនរដ្ឋាភិបាលនឹងប្រជុំជាមួយដៃគូអភិវឌ្ឍន៍នានា៖** ដៃគូអភិវឌ្ឍន៍នានាអាចផ្តល់មូលនិធិដល់អង្គការមិនមែនរដ្ឋាភិបាលដើម្បីអនុវត្ត ផ.អ.គ.ស ដោយអនុវត្តតាមគោលការណ៍ណែនាំ និងល័ក្ខខ័ណ្ឌកំណត់នានា។ ដៃគូអភិវឌ្ឍន៍ទាំងអស់ ប្រហែលមិនរួមគ្នាផ្តល់មូលនិធិដល់សង្គមស៊ីវិលទេ ប៉ុន្តែដៃគូអភិវឌ្ឍន៍អាចចូលរួមក្នុងផែនការសម្របសម្រួល ដើម្បីការអនុវត្តសកម្មភាពពាក់ព័ន្ធនានានៅមូលដ្ឋានឱ្យមានប្រសិទ្ធភាព។

# ឧបសម្ព័ន្ធទី១ ÷ ការគ្រប់គ្រងហានិភ័យ

ផែនការអនុវត្តគណនេយ្យភាពសង្គម គឺជាកម្មវិធីដែលមានមហិច្ឆិតា ហើយក៏មានហានិភ័យផងដែរ។ មានវិធានការមួយចំនួនអាចកាត់បន្ថយបាននូវហានិភ័យចម្បងៗដូចបានបង្ហាញខាងក្រោមនេះ

**១.ហានិភ័យ និងវិធានការកាត់បន្ថយ**

| ហានិភ័យ | កម្រិត | វិធានការកាត់បន្ថយ |
|---|---|---|
| ១. សមត្ថភាព (ភ្នាក់ងារអនុវត្ត) | មធ្យម | • ហានិភ័យទាក់ទងនឹងសមត្ថភាពកើតមានឡើងនៅក្នុងការផ្តល់ហិរញ្ញប្បទានបន្តទៅឱ្យអង្គការមិនមែនរដ្ឋាភិបាលនៅមូលដ្ឋាន អាចនឹងកាន់តែធ្ងន់ធ្ងរឡើងនៅពេលដែលអង្គការមិនមានថវិកាគ្រប់គ្រាន់សម្រាប់ ការអនុវត្តការងារ ការគ្រប់គ្រងហិរញ្ញវត្ថុ ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ។ ហានិភ័យនេះអាចកាត់បន្ថយបានតាមរយៈការជ្រើសរើសអង្គការដៃគូណា ដែលធ្លាប់មានប្រវត្តិការងារល្អក្នុងការកសាងសមត្ថភាព និងមានប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរឹងមាំ។ |
| ២.នយោបាយ | មធ្យម | • សកម្មភាពរបស់អង្គការសង្គមស៊ីវិលក្នុងការជំរុញឲ្យមានការបើកចំហរព័ត៌មាននានា ព័ត៌មានថវិកា និងការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋអាចត្រូវបានមជ្ឈដ្ឋានទូទៅយល់ច្រលំថាជាសកម្មភាពរបស់គណបក្សនយោបាយ។<br>• ការផ្តល់ព័ត៌មាននៅមូលដ្ឋាន និងការចូលរួមរបស់ប្រជាពលរដ្ឋ គឺមានចែងនៅក្នុងលិខិតបទដ្ឋានគតិយុត្តផ្សេងៗសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ គណនេយ្យភាពសង្គមអាចជាមធ្យោបាយមួយ ដើម្បីអនុវត្តនូវគោលការណ៍នានាដែលមានចែង។ |
| ៣.ការសម្របសម្រួលកម្មវិធី | បង្គួរ | • សកម្មភាពនានា ត្រូវអនុវត្តដោយក្រសួង ស្ថាប័ន (ផ្នែកផ្គត់ផ្គង់) និងអង្គការសង្គមស៊ីវិល (ផ្នែកតម្រូវការ) ដែលសកម្មភាពទាំងនោះ ត្រូវអនុវត្តស្របគ្នាជាមួយវដ្តនៃការងារគណនេយ្យភាពសង្គម ដើម្បីរួមចំណែកដល់ដំណើរការរួម ក្នុងការសម្រេចបានលទ្ធផល និងគោលបំណងនានា។ គណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម (រួមមានក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍) បានបង្កើតឡើង។<br>• ការអនុវត្តផ្នែកតម្រូវការដោយអង្គការសង្គមស៊ីវិលត្រូវប្រើវិធីសាស្ត្ររួមរបស់គណនេយ្យភាពសង្គម |
| ៤.ភាពជាម្ចាស់របស់រាជរដ្ឋាភិបាល | មធ្យម | • ដំណើរការរៀបចំផែនការសកម្មភាព និងថវិកា និងការចូលរួមផ្សេងៗ នៃផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលអាចធ្វើឲ្យការអនុវត្ត ផ.អ.គ.ស នៅមូលដ្ឋានមានភាពការយឺតយ៉ាវ ដូចនេះត្រូវមានការណែនាំពីថ្នាក់ជាតិ។ |
| ៥.ការផ្តល់សេវា ការត្រួតពិនិត្យ និងនិរន្តរភាព | បង្គួរ | • ការអនុវត្តសកម្មភាពគណនេយ្យភាពសង្គមគឺមានការលំបាកខ្លាំងដោយសារតែអ្នកចូលរួមមិនសូវយល់ពីទស្សនទានដែលតម្រូវឱ្យមានការអភិវឌ្ឍទាំងជំនាញ និងការផ្លាស់ប្តូរឥរិយាបថ។ ដោយសារដំណើរការនេះពាក់ព័ន្ធការបណ្តុះបណ្តាលគ្រូបង្គោល និងយន្តការបណ្តុះបណ្តាលពីលើដល់ក្រោមតាមប្រព័ន្ធរដ្ឋបាលបច្ចុប្បន្ន ដូច្នេះហានិភ័យក្នុងការផ្តល់សេវា គឺមានកម្រិតបង្គួរ។ ជំនួយបច្ចេកទេសនឹងត្រូវផ្តល់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ |

| | | |
|---|---|---|
| | | ក្នុងអំឡុងពេលអនុវត្តកម្មវិធីនេះ ដោយសារទស្សនទាននេះអាចជារឿងថ្មី ដែលទាមទារនូវការពង្រឹងការយល់ដឹងបន្ថែមទៀត ។<br>• ការងារជាអាទិភាព គឺបង្កើតយន្តការជាក់លាក់មួយ ដើម្បីធានានូវការត្រួតពិនិត្យ និងការសិក្សាស្វែងយល់ប្រកបដោយប្រសិទ្ធភាព។<br>• ហានិភ័យនៃនិរន្តរភាព គឺមានកម្រិតមធ្យមសម្រាប់សកម្មភាពផ្នែកផ្គត់ផ្គង់ ដោយសារការងារនេះត្រូវបានបញ្ចូលក្នុងការងាររបស់រាជរដ្ឋាភិបាល ប៉ុន្តែមានកម្រិតបង្គួរសម្រាប់សកម្មភាពរបស់ផ្នែកតម្រូវការ ដោយសារសកម្មភាពទាំងនោះតម្រូវឱ្យមានការផ្តល់មូលនិធិតាមយន្តការឯករាជ្យ ឬតាមយន្តការរបស់រាជរដ្ឋាភិបាល (ដូចជាយន្តការមូលនិធិឃុំ សង្កាត់) ដែលងាយក្នុងការជាប់គាំង។ |
| **៦.ថវិកាមិនគ្រប់គ្រាន់ និងវិសាលភាពមានទំហំតូច** | ទាប-មធ្យម | • ផែនការអនុវត្តគណនេយ្យភាពសង្គមបានរៀបចំឡើងដោយមានលក្ខណៈងាយស្រួលក្នុងការពង្រីកសកម្មភាព ប្រសិនបើមានការផ្តល់ហិរញ្ញវត្ថុបន្ថែម។<br>• ថវិកាដែលមានស្រាប់មានចំនួនគ្រប់គ្រាន់ក្នុងការអនុវត្តសកម្មភាពសំខាន់ៗនៃការងារគណនេយ្យភាពសង្គម និងមានការកត់ត្រាត្រឹមត្រូវដែលនឹងទាក់ទាញការចាប់អារម្មណ៍របស់ដៃគូអភិវឌ្ឍន៍ក្នុងការផ្តល់ថវិកាគាំទ្រ។ |
| **៧.ការសម្របសម្រួលជាមួយអង្គការសង្គមស៊ីវិល** | ទាប | • លេខាធិការដ្ឋានគ.ជ.អ.ប និងអង្គការសង្គមស៊ីវិលបានសហការគ្នាសម្រេចបានសមិទ្ធផលជាច្រើនពាក់ព័ន្ធនឹងការរៀបចំផែនការអនុវត្តការងារគណនេយ្យភាពសង្គម ការបណ្តុះបណ្តាល និងការរៀបចំឧបករណ៍ផ្តល់ព័ត៌មាននានា។ល។<br>• កិច្ចប្រជុំសម្របសម្រួលត្រូវបានរៀបចំ ដើម្បីប្រមូលព័ត៌មាន និងពិភាក្សាលើបញ្ហានានាពាក់ព័ន្ធនឹងការងារគណនេយ្យភាពសង្គម<br>• បន្ទុកការងារមួយចំនួនរបស់លេខាធិការដ្ឋាន គ.ជ.អ.បនឹងត្រូវកាត់បន្ថយ ប្រសិនបើមានអ្នកអនុវត្តជាភាគីទី៣ទទួលបន្ទុកលើការងារ ការងារបណ្តុះបណ្តាល និងការប្រមូល ចងក្រង មេរៀនបទពិសោធន៍<br>• លេខាធិការដ្ឋានគ.ជ.អ.ប ត្រូវមានទីប្រឹក្សាបច្ចេកទេស និងបុគ្គលិកគ្រប់គ្រាន់ ដើម្បីជួយទទួលបន្ទុកការងារគណនេយ្យភាពសង្គម។ |

## ឧបសម្ព័ន្ធទី២៖ សមិទ្ធផលរំពឹងទុកទទួលបានពីការអនុវត្ត

សមិទ្ធផលរំពឹងទុកពីការអនុវត្តសកម្មភាពគណនេយ្យភាពសង្គមមានដូចខាងក្រោម៖

- ដោយសារតែមានការបង្កើតឱ្យមានយន្តការនៃការចូលរួមពីប្រជាពលរដ្ឋ ការទំនាក់ទំនងគ្នាទៅវិញទៅមក និងឬ / តំណាងប្រជាពលរដ្ឋ ដូចនេះការឆ្លើយតបរបស់រាជរដ្ឋាភិបាល)ភ្នាក់ងារផ្តល់សេវា(នឹងមានការផ្លាស់ប្តូរ។
- សមត្ថភាពប្រជាពលរដ្ឋ ស្ត្រី) និងបុរស (និង តំណាងប្រជាពលរដ្ឋមានការកើនឡើងដែលអាចបន្តការទំនាក់ទំនងជាមួយរាជរដ្ឋាភិបាលក្នុងការពង្រឹងគោលដៅគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ។

ផែនការអនុវត្តគណនេយ្យភាពសង្គមរួមចំណែកដល់៖

- **ការផ្តល់សេវា និងការវិភាជន៍ធនធានកាន់តែមានប្រសិទ្ធិភាព សមធម៌ និងកាន់តែមានគណនេយ្យភាព។** ការចូលរួមរបស់ស្ថាប័ន អង្គភាពផ្តល់សេវាសាធារណៈ គួរត្រូវបានគ្រប់គ្រងឱ្យកាន់តែប្រសើរ កាន់តែមានការឆ្លើយតបប្រកបដោយគណនេយ្យភាព និងតម្លាភាព។ សកម្មភាពរបស់ស្ថាប័ន ឬអង្គភាពផ្តល់សេវាទាំងនោះ គួរឆ្លើយតបឱ្យកាន់តែប្រសើរតាមតម្រូវការអាទិភាពរបស់ប្រជាពលរដ្ឋ ហើយត្រូវខិតខំការពារ និងបម្រើផលប្រយោជន៍របស់ក្រុមជនងាយរងគ្រោះ។
- **ការផ្តល់សិទ្ធិអំណាចកាន់តែប្រសើរ៖** សហគមន៍ និងប្រជាពលរដ្ឋ ពិសេសស្ត្រី យុវវ័យ កុមារ ជនជាតិដើម និងជនពិការដែលបានចាត់ទុកថាជាភ្នាក់ងារធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងសំខាន់ គួរត្រូវបានផ្តល់សិទ្ធិអំណាចដើម្បីអាចយល់ដឹងអំពីសិទ្ធិ និងការទទួលខុសត្រូវ ក្នុងការបង្កើនទំនាក់ទំនងជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។
- **មូលធនសង្គមកាន់តែប្រសើរ៖** ការកសាងមូលធនសង្គម និងការកើនឡើងនូវទំនុកចិត្ត រវាងសមាជិកសហគមន៍ និងរវាងប្រជាពលរដ្ឋជាមួយអង្គភាពរបស់រដ្ឋ គឺមានសារៈសំខាន់ណាស់សម្រាប់ទាំងការអភិវឌ្ឍសង្គម និងការរីកចំរើនផ្នែកសេដ្ឋកិច្ច។
- **ការរួបរួម និងឯកភាពគ្នាក្នុងសង្គមកាន់តែប្រសើរ៖** ការពង្រឹងលើមូលធនសង្គ នឹងនាំដល់ការឯកភាព និងទំនុកចិត្តក្នុងសង្គមកាន់តែរឹងមាំដែលជាសមាសធាតុដ៏ចាំបាច់ក្នុងការអភិវឌ្ឍមូលដ្ឋាន។
- **សមធម៌សង្គម និងការអភិវឌ្ឍកាន់តែមានការចូលរួម៖** មានការចូលរួមជាមតិយោបល់ប្រកបដោយសមធម៌ និងគ្រប់ជ្រុងជ្រោយរបស់ស្ត្រី យុវវ័យ កុមារ ជនពិការ ជនជាតិដើម និងក្រុមជនងាយរងគ្រោះនៅក្នុង៖ (ក) ដំណើរការនយោបាយនៅមូលដ្ឋាន និង(ខ) ការរៀបចំសម្រាប់ការផ្តល់សេវា និងការកែលម្អស្ថានភាពរូបវ័ន្តដែលមានឥទ្ធិពលដល់ក្រុមប្រជាពលរដ្ឋក្រីក្រ។

## ១. គោលបំណងរួម និងសូចនាករួម

**តើនឹងមានការផ្លាស់ប្ដូរអ្វីខ្លះដែល នឹងទទួលបានពីការអនុវត្តផ.អ.គ.ស?**

**គោលបំណងរួម៖** គោលបំណងនៃ ផ.អ.គ.ស គឺដើម្បីធ្វើឱ្យប្រសើរនូវគណនេយ្យភាព និងការឆ្លើយតបរបស់អ្នកផ្ដល់សេវា និងរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការផ្ដល់សេវា និងការវិភាជន៍ធនធានឱ្យកាន់តែប្រសើរ (ពិសេសសម្រាប់ស្ត្រី យុវវ័យ កុមារ ជនពិការ ជនជាតិដើម និងក្រុមជនងាយរងគ្រោះ)។

**សូចនាករនៃគោលបំណងខាងលើ អាចវាស់វែងបានតាមរយៈការផ្លាស់ប្តូរលើ៤ទិដ្ឋភាព៖**

- ភាពឆ្លើយតប៖ សេវាត្រូវបានផ្តល់ប្រកបដោយសមធម៌
- គណនេយ្យភាព៖ កម្រិតនៃការបើកទូលាយ និងការឆ្លើយតបទៅនឹងការផ្តល់ព័ត៌មានត្រឡប់របស់សហគមន៍
- សម្លេង និងការផ្តល់សិទ្ធិអំណាច
- បរិយាកាសអំណោយផល ។

## ២.គោលបំណងនៃសមាសភាគ និងសូចនាករ

គោលបំណង និងសូចនាកររបស់សមាសភាគនីមួយៗនឹងវាស់វែងអំពីកម្រិតនៃការផ្លាស់ប្តូរនៃលទ្ធផលដែល សម្រេចបាន។ គោលបំណង និងសូចនាករភាគច្រើនមានទំនាក់ទំនងគ្នាដែលបញ្ជាក់អំពីការផ្លាស់ប្តូរមួយចំនួន។

- **សមាសភាគទី១៖ ធ្វើឱ្យមានភាពងាយស្រួលក្នុងការទទួលបានព័ត៌មាននានា និងព័ត៌មានពាក់ព័ន្ធថវិកានៅមូលដ្ឋាន ដើម្បីឱ្យសមត្ថភាព និងចំណេះដឹងរបស់អ្នកពាក់ព័ន្ធកាន់តែប្រសើរ។** ការផ្លាស់ប្តូរ នឹងត្រូវវាស់វែងតាមរយៈលំហូរព័ត៌មាន ការបើកទូលាយព័ត៌មានថវិកានៅមូលដ្ឋាន និងការប្រើប្រាស់ព័ត៌មាននានា និងព័ត៌មានថវិកា។
- **សមាសភាគទី២៖ ធ្វើឱ្យប្រសើរឡើងនូវការផ្តល់ព័ត៌មានត្រឡប់របស់ប្រជាពលរដ្ឋ ការត្រួតពិនិត្យតាមដានលើការផ្តល់សេវានានា និងការវិភាជន៍ធនធាន។** សមិទ្ធផលនេះ នឹងត្រូវវាស់វែងតាមរយៈកម្រិតនៃការកៀរគរការចូលរួមពីអ្នកទទួលផលឬតាមដានត្រួតពិនិត្យ និងការផ្តល់ព័ត៌មានត្រឡប់របស់ប្រជាពលរដ្ឋ បរិយាប័ន្ន ឬសមធម៌ ការវិភាជន៍ធនធាន និងឥរិយាបថ ឬទង្វើផ្សេងៗ។
- **សមាសភាគទី៣៖ បង្កើនសម្លេងរបស់ប្រជាពលរដ្ឋ ផ្តល់សិទ្ធិអំណាច និងសមត្ថភាព សម្រាប់ដំណើរការគណនេយ្យភាពសង្គម។** ការសម្រេចផ្នែកនេះ នឹងត្រូវវាស់វែងទៅលើកម្រិតនៃការប្រែប្រួលនៃការទទួលបានសិទ្ធិអំណាច សមត្ថភាពរបស់សហគមន៍ និងសមត្ថភាពរបស់តួអង្គផ្សេងទៀតនៅមូលដ្ឋាន។
- **សមាសភាគទី៤៖ បង្កើនសមត្ថភាពដល់អ្នកពាក់ព័ន្ធនានាឱ្យមានការយល់ដឹងនិងការចូលរួមក្នុងដំណើរការផ្លាស់ប្តូរប្រែប្រួល។ សមាសភាគនេះ** ត្រូវវាស់វែងទៅលើកម្រិតនៃការចូលរួមរបស់អ្នកពាក់ព័ន្ធនានានៅក្នុងដំណើរការដែលនឹងជំរុញឱ្យមានការផ្លាស់ប្តូររបៀបរៀបចំគោលនយោបាយ និងការអនុវត្តផ្សេងៗផងដែរ។

## តារាងទី ៨៖ លទ្ធផលសំខាន់ៗ និងការវាស់វែង

| តើការផ្លាស់ប្តូរអ្វីខ្លះ នឹងទទួលបានពីផ.អ.គ.ស | តើលទ្ធផលអ្វីខ្លះនឹងទទួលបានក្នុងរយៈពេល៣ឆ្នាំ? | តើអ្វីជាខ្នាតវាស់វែង? | តើការវាស់វែងត្រូវធ្វើដូចម្តេច? |
|---|---|---|---|
| សូចនាកររួម | | | |
| **ការឆ្លើយតបៈមានការប្រែប្រួលក្នុងការផ្តល់សេវាប្រកបដោយសមធម៌ក្នុងការផ្តល់សេវា** | ប្រជាពលរដ្ឋទទួលបានសេវាកាន់តែប្រសើរ និងទទួលបាននូវសេវាផ្សេងៗទៀតនៅមូលដ្ឋាន។ | ភាគរយប្រជាពលរដ្ឋដែលពេញចិត្តចំពោះសេវាដែលបានផ្តល់ដោយ អ្នកផ្តល់សេវា មានការកើនឡើង។ | លទ្ធផលប័ណ្ណដាក់ពិន្ទុប្រចាំឆ្នាំដែលបានចងក្រងនឹងធ្វើការប្រៀបធៀបជាមួយក្រុមដែលមិនទាន់បានអនុវត្តសកម្មភាព |
| | មានការផ្លាស់ប្តូរប្រែប្រួលជារួមទាំងស្ត្រី យុវវ័យ កុមារ ជនពិការ ជនជាតិដើម និងប្រជាពលរដ្ឋក្រីក្រក្នុងការទទួលបានផលប្រយោជន៍ពីការផ្តល់សេវា | ភាគរយស្ត្រី យុវវ័យ កុមារ ជនពិការ ជនជាតិដើម និងក្រុមប្រជាពលរដ្ឋងាយរងគ្រោះដែលរាយការណ៍ថាពេញចិត្តចំពោះសេវាដែលបានផ្តល់ដោយអ្នកផ្តល់សេវា | លទ្ធផលប័ណ្ណដាក់ពិន្ទុប្រចាំឆ្នាំដែលបានចងក្រងនឹងធ្វើការប្រៀបធៀបជាមួយក្រុមដែលមិនទាន់បានអនុវត្តសកម្មភាព |
| **គណនេយ្យភាព**ៈមានការប្រែប្រួលលើកម្រិតនៃការបើកទូលាយ និងការឆ្លើយតបចំពោះការផ្តល់ព័ត៌មានត្រឡប់របស់សហគមន៍ | រដ្ឋបាលឃុំទាំងអស់ក្នុងស្រុកចំនួន១២០បានបិទផ្សាយព័ត៌មានដល់សាធារណជន គាំទ្រដល់ការចូលរួមត្រួតពិនិត្យ និងវាយតម្លៃរបស់ប្រជាពលរដ្ឋ និងរៀបចំផែនការសកម្មភាពរួមគ្នាស្តីពីការងារគណនេយ្យភាពសង្គម ដើម្បីធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវា | - រដ្ឋបាលឃុំ មណ្ឌលសុខភាព និងសាលាបឋមសិក្សាទាំងអស់ក្នុងស្រុកចំនួន១២០ បានបិទផ្សាយព័ត៌មានដល់សាធារណជន។<br>- រដ្ឋបាលឃុំក្នុងរដ្ឋបាលស្រុកទាំង ១២០ បានរៀបចំផែនការសកម្មភាពរួមគ្នាស្តីពីការងារគណនេយ្យភាពសង្គម។ | - លទ្ធផលទិន្នន័យតាមស្រុកដែលបានប្រមូល ចងក្រង និង បិទផ្សាយ។<br>- លទ្ធផលទិន្នន័យតាមស្រុកស្តីពីផែនការសកម្មភាពរួមគ្នាដែលបានប្រមូល ចងក្រង និងបិទផ្សាយ |
| | រដ្ឋបាលឃុំនៃស្រុកចំនួន ១២០ រួមចំណែកថវិកា ៥០០.០០០ដុល្លារ(ពីឆ្នាំ ២០១៥ ដល់ឆ្នាំ២០១៧) ដើម្បីដោះស្រាយបញ្ហានានាដែលបានលើកឡើងដោយប្រជាពលរដ្ឋតាមរយៈសកម្មភាពគណនេយ្យភាពសង្គម(ជាមធ្យមចំនួនប្រមាណ | - រដ្ឋបាលឃុំនៃស្រុកចំនួន១២០ បានបែងចែកថវិកាជាមធ្យម ១៧០ដុល្លារ ក្នុងខ្ទង់ថវិការបស់ខ្លួន ក្នុងការអនុវត្ត និងតាមដានការអនុវត្តផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម | -លិខិតណែនាំរួមស្តីអំពីការបែងចែកថវិកាឃុំសម្រាប់អនុវត្តការងារគណនេយ្យភាពសង្គម។<br>-ថវិកាឃុំ ១៧០ដុល្លាត្រូវបានប្រើប្រាស់ចំទិសដៅសម្រាប់អនុវត្តការងារគណនេយ្យភាពសង្គម |

| តើការផ្លាស់ប្តូរអ្វីខ្លះ នឹងទទួលបានពីផ.អ.គ.ស | តើលទ្ធផលអ្វីខ្លះនឹងទទួលបានក្នុងរយៈពេល៣ឆ្នាំ? | តើអ្វីជាខ្នាតវាស់វែង? | តើការវាស់វែងត្រូវធ្វើដូចម្តេច? |
|---|---|---|---|
| | ១៧០ដុល្លារក្នុង១ឃុំក្នុង១ឆ្នាំ)។ | | |
| **មានការប្រែប្រួល លើការបញ្ចេញសម្លេង និងសិទ្ធិអំណាច** | ដំណើរការផ្លាស់ប្តូរនឹងផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋក្នុងការលើកយកកង្វល់របស់ខ្លួន និងទាមទារឱ្យមានគណនេយ្យភាពពីអ្នកផ្តល់សេវា និងមន្ត្រីរាជរដ្ឋាភិបាល | ភាគរយស្រុកដែលមានប្រជាពលរដ្ឋ អាចបញ្ចេញសម្លេងរបស់គាត់ ក្រៅពីស្រុកគោលដៅផ.អ.គ.ស | ការវាយតម្លៃអំពីការផ្តល់សិទ្ធិអំណាច និងសមត្ថភាព (បែងចែកតាមស្រ្តី និងយុវវ័យកុមារ ជនជាតិដើម និងជនពិការ) |
| **មានការប្រែប្រួល លើបរិយាកាស អំណោយផល(អភិបាលកិច្ចមូលដ្ឋាន)** | ស្ថានភាព យន្តការអនុវត្តច្បាប់អាចឱ្យសង្គមស៊ីវិលចូលរួមក្នុងការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ លើការបំពេញការងាររបស់អង្គភាពផ្តល់សេវា។<br><br>ថវិកាត្រូវបានវិភាជន៍សម្រាប់ការអនុវត្ត។<br><br>ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងផ្តល់ឱកាសសម្រាប់ការចូលរួមរបស់ប្រជាពលរដ្ឋ | **(ការផ្លាស់ប្តូរគោលយោបាយ)** ភាគរយនៃសកម្មភាពធ្វើឱ្យមានការផ្លាស់ប្តូរផ្អែកតាមរបាយការណ៍របស់អង្គការសង្គមស៊ីវិល។<br><br>**(ថវិកាអនុវត្តគោលនយោបាយ)** ភាគរយស្រុកដែលមានថវិកាគាំទ្រសកម្មភាពដើម្បី លើកកម្ពស់ការទទួលបានព័ត៌មាននានា ថវិកា និងការត្រួតពិនិត្យតាមដាន របស់ប្រជាពលរដ្ឋ។<br>**(ការអនុវត្តគោលនយោបាយ)** ភាគរយស្រុកគោលដៅដែលអនុវត្តគោលនយោបាយស្របតាមលិខិតបទដ្ឋាននានា។<br><br>**(និរន្តរភាព)** គ.ជ.អ.ប បន្តផ្តល់អាទិភាពលើការងារគណនេយ្យភាពសង្គមក្នុងផែនការរបស់ខ្លួន។ | ការកត់ត្រារបាយការណ៍ពីការរីកចម្រើនលើការរៀបចំគោលនយោបាយ។<br><br>របាយការណ៍ប្រចាំត្រីមាសពីNGOsនៅមូលដ្ឋាន<br><br>របាយការណ៍របស់គ.ជ.អ.ប (ការធ្វើសវនកម្មលើព័ត៌មាន)<br><br>ការវាយតម្លៃលើការផ្តល់សិទ្ធិអំណាចនិងសមត្ថភាព។ |
| **សូចនាករតាមសមាសភាគនីមួយៗ** | | | |
| **សមាសភាគទី១៖** ភាពងាយទទួលបានព័ត៌មាននានានិងព័ត៌មានថវិកា | | | |
| **ការប្រែប្រួលអំពីតម្លាភាព និងភាពបើកទូលាយ** | កញ្ចប់ព័ត៌មាន (I4Cs) ត្រូវបានចងក្រងស្របតាម | ភាគរយស្រុកដែលជារដ្ឋបាលថ្នាក់ក្រោមជាតិ ឬអ្នកផ្តល់សេវា | អង្គការដៃគូសង្គមស៊ីវិលធ្វើរបាយការណ៍ ប្រចាំត្រីមាស |

| តើការផ្លាស់ប្តូរអ្វីខ្លះ នឹងទទួលបានពីផ.អ.គ.ស | តើលទ្ធផលអ្វីខ្លះនឹងទទួលបានក្នុងរយៈពេល៣ឆ្នាំ? | តើអ្វីជាខ្នាតវាស់វែង? | តើការវាស់វែងត្រូវធ្វើដូចម្តេច? |
|---|---|---|---|
| | សេចក្តីណែនាំ | មូលដ្ឋាន ច្រើនជាង៧០%បានប្រមូល និងចងក្រងកញ្ចប់ពត៌មាន(I4Cs)ស្របតាមសេចក្តីណែនាំ | របាយការណ៍អធិការកិច្ចប្រចាំឆ្នាំនិងព័ត៌មានសវនកម្ម |
| | ថវិកាត្រូវបានបិទផ្សាយជាសាធារណៈស្របតាមទម្រង់គំរូ | **(ការវាស់វែងអំពីព័ត៌មានដែលមាន)**<br>- ភាគរយស្រុកដែលជារដ្ឋបាលថ្នាក់ក្រោមជាតិ ឬអ្នកផ្តល់សេវាមូលដ្ឋានច្រើនជាង៧០% បានបង្ហាញថវិកាស្របតាមទម្រង់គំរូដែលផ្តល់ឱ្យ។<br>- ភាគរយស្រុកដែលមានមន្ត្រីមានសមត្ថភាពយល់ដឹងពីថវិកា និងតម្លាភាពថវិកា កើនឡើង | អង្គការដៃគូសង្គមស៊ីវិលធ្វើរបាយការណ៍ប្រចាំត្រីមាស |
| | ការអនុវត្តលិខិតបទដ្ឋាននានាត្រូវបានពង្រឹង | **(ការវាស់វែងការអនុវត្តតាម)**<br>ភាគរយស្រុកអនុវត្តតាមគោលការណ៍ និងលិខិតបទដ្ឋាននានា | របាយការណ៍អនុវត្តរបស់ស្រុកអាចធ្វើប្រចាំឆ្នាំ និងរបាយការណ៍អធិការកិច្ច |
| **ការប្រែប្រួលលើភាពងាយស្រួលទទួលបានព័ត៌មាន និង ការយល់ដឹងអំពីថវិកា** | ប្រជាពលរដ្ឋអាចយល់ដឹងពីខ្លឹមសារ និងអាចប្រើប្រាស់ព័ត៌មាន (I4Cs) បាន | **(ការវាស់វែងពីការយល់ដឹង)**<br>ភាគរយប្រជាពលរដ្ឋយល់ដឹងថាមានព័ត៌មាន និងយល់អំពីខ្លឹមសាររបស់កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ។<br><br>**(ការវាស់វែងការប្រើប្រាស់)**<br>ភាគរយកិច្ចប្រជុំដែលបានយកកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋធៀបជាមួយស្តង់ដារបំពេញការងារ និងគោលនយោបាយ ក្នុងដំណើរការត្រួតពិនិត្យតាមដាន។ | កំណត់ហេតុនៃកិច្ច ប្រជុំស្តីពីប័ណ្ណដាក់ពិន្ទុ។ អង្គការដៃគូសង្គមស៊ីវិលធ្វើរបាយការណ៍ប្រចាំត្រីមាស ដាក់ជូន គ.គ.អ.ស។ |
| | ប្រជាពលរដ្ឋមានការយល់ដឹងអំពីថវិកា និងចេះប្រើប្រាស់ព័ត៌មានទាំងនោះ | - ភាគរយស្រុកដែលមានប្រជាពលរដ្ឋពិភាក្សាពីបញ្ហាថវិកា និងការចំណាយ ក្នុងការកិច្ចប្រជុំតាមដានត្រួតពិនិត្យ។<br>- ភាគរយស្រុក ដែលបញ្ហាថវិកាត្រូវបានលើកឡើងក្នុងវេទិកា | កំណត់ហេតុនៃកិច្ចប្រជុំសម្រាប់កត់ត្រានូវប្រធានបទពិភាក្សា។ របាយការណ៍អនុវត្តប្រចាំត្រីមាសរបស់អង្គការដៃគូសង្គមស៊ីវិលធ្វើដើម្បីដាក់ជូន គ.គ.អ.ស។ |

| តើការផ្លាស់ប្តូរអ្វីខ្លះ នឹងទទួលបានពីផ.អ.គ.ស | តើលទ្ធផលអ្វីខ្លះនឹងទទួលបានក្នុងរយៈពេល៣ឆ្នាំ? | តើអ្វីជាខ្នាតវាស់វែង? | តើការវាស់វែងត្រូវធ្វើដូចម្តេច? |
|---|---|---|---|
| | | ធំៗនានា។ | |
| **សមាសភាគទី២៖ ការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ** | | | |
| **មានការប្រែប្រួល លើការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការត្រួតពិនិត្យការបំពេញការងារ និងផ្តល់ព័ត៌មានត្រឡប់ (គណនេយ្យភាព)** | ការត្រួតពិនិត្យតាមដានដោយសហគមន៍ប្រជាពលរដ្ឋដោយមានផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម (ផ.ស.រ.គ) ក្លាយជាផ្នែកនៃការអនុវត្តប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពផ្តល់សេវា។ | - ភាគរយស្រុកដែលបានបញ្ចប់ការធ្វើប័ណ្ណដាក់ពិន្ទុប្រចាំឆ្នាំ។<br>- ភាគរយនៃផ.ស.រ.គ ដែលបានបញ្ចប់ស្របតាមសេចក្តីណែនាំធ្វើប្រចាំឆ្នាំ (ជាឧទាហរណ៍ មានសកម្មភាពចំនួន៤៖សហគមន៍ ក្រុមប្រឹក្សាឃុំ ស្រុកអ្នកផ្តល់សេវា និងសកម្មភាពរបស់មន្ត្រីស្រុក)។<br>- ភាគរយនៃផ.ស.រ.គ ដែលត្រូវបានអនុវត្ត (ឧទាហរណ៍ជាង ៧០%នៃសកម្មភាពត្រូវបានអនុវត្ត)។<br>- ភាគរយនៃផ.ស.រ.គ ដែលបានស្នើសុំក្រុមប្រឹក្សាឃុំ បញ្ចូលទៅជាអាទិភាពប្រចាំឆ្នាំ។ | របាយការណ៍អនុវត្ត ប្រចាំត្រីមាសរបស់អង្គការដៃគូសង្គមស៊ីវិល។ |
| **មានការផ្លាស់ប្តូរនៃដំណើរការនៃការដាក់បញ្ចូលគ្នា (បរិយាប័ន្ន និងការឆ្លើយតប)** | ផ.ស.រ.គ បានឆ្លុះបញ្ចាំងអំពីការព្រួយបារម្ភរបស់ប្រជាពលរដ្ឋ និងក្រុមជនងាយរងគ្រោះ | - ភាគរយរដ្ឋបាលឃុំ ស្រុក ដែលការចំណាយរបស់ឃុំ សាលារៀន និងមណ្ឌលសុខភាព បានឆ្លើយតបទៅនឹងសកម្មភាពអាទិភាពនៅក្នុងផ.ស.រ.គ។<br>- ភាគរយនៃផ.ស.រ.គ ដែលបានដោះស្រាយប្រចាំឆ្នាំនូវចំនួនសកម្មភាពអាទិភាពរបស់ ស្ត្រី យុវវ័យ កុមារ ជនជាតិដើម ជនពិការ | របាយការណ៍អនុវត្ត ប្រចាំត្រីមាសរបស់ អង្គការដៃគូសង្គមស៊ីវិល |
| **ការប្រែប្រួល ចំពោះការវិភាជន៍ធនធាន (ភាពឆ្លើយតប)** | ឯកសារថវិកា និងការចំណាយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវាមានការប្រែប្រួលដែលឆ្លុះបញ្ចាំងពីបញ្ហា និងសកម្មភាពជាអាទិភាពដែលបានកំណត់ ក្នុងដំណើរការ | - ភាគរយឃុំ ស្រុក ដែលមានថវិកាចំណាយរបស់ឃុំ សាលារៀន និងមណ្ឌលសុខភាពឆ្លើយតបតាមអាទិភាព ដែលលើកឡើងក្នុងផ.ស.រ.គ។ | របាយការណ៍អំពីការអនុវត្តប្រចាំត្រីមាសរបស់ អង្គការដៃគូសង្គមស៊ីវិល |

| តើការផ្លាស់ប្តូរអ្វីខ្លះ នឹងទទួលបានពីផ.អ.គ.ស | តើលទ្ធផលអ្វីខ្លះនឹងទទួលបានក្នុងរយៈពេល៣ឆ្នាំ? | តើអ្វីជាខ្នាតវាស់វែង? | តើការវាស់វែងត្រូវធ្វើដូចម្តេច? |
|---|---|---|---|
| | ប័ណ្ណដាក់ពិន្ទុ | | |
| **ការប្រែប្រួលលើឥរិយាបថ និង ការបំពេញការងារ (ភាពឆ្លើយតប)** | ការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋ និងសកម្មភាពជំរុញផ.ស.រ.គ ជាមួយអ្នកពាក់ព័ន្ធកំណត់នូវ៖<br>➢ អ្នកផ្តល់សេវាដើម្បីកែលម្អឥរិយាបថ និងទង្វើនានា<br>➢ សមាជិកក្រុមប្រឹក្សាប្រើប្រាស់កាន់តែ ប្រសើរនូវតួនាទីរបស់ខ្លួនក្នុងការជំរុញឱ្យមានការផ្លាស់ ប្តូរប្រែប្រួល<br>➢ មន្ត្រីស្រុកកែលម្អនូវរបៀបរបបអនុវត្ត<br>➢ សហគមន៍ចូលរួមចំណែកយ៉ាងសកម្មក្នុងការអនុវត្តសកម្មភាព<br>➢ រដ្ឋបាលស្រុក ធ្វើជាស្ថាប័ននីយកម្ម គ្រប់ដំណើរការនានា | **(ការបំពេញការងារ)**<br>- ភាគរយ សាលាឃុំ សាលារៀន មណ្ឌលសុខភាព មានការ កែលម្អឥរិយាបថបន្ទាប់ពីការអនុវត្ត ផ.ស.រ.គ (ដូចជាពេលម៉ោងបំពេញ ការងារអត្តចរិកចំពោះអ្នកជំងឺ លទ្ធភាពចុះបញ្ជីកំណើត បញ្ជីមរណភាព)<br><br>**(សិទ្ធិអំណាច និងទង្វើរបស់សមាជិកក្រុមប្រឹក្សា)**<br>- ភាគរយឃុំ ស្រុក ដែលសមាជិកក្រុមប្រឹក្សា មានសិទ្ធិអំណាចក្នុងការលើកកម្ពស់ការបំពេញការងាររបស់អ្នកផ្តល់សេវានៅមូលដ្ឋាន។<br><br>**(ការអនុវត្តតាមអធិការកិច្ច)**<br>- ភាគរយស្រុកដែលមន្ត្រី មន្ទីរសុខាភិបាល និងមន្ទីរអប់រំ បានកែលម្អការអនុវត្តតាម ឬអធិការកិច្ចរបស់សាលារៀន និងមណ្ឌលសុខភាព។<br><br>**(មូលធនសង្គមភាពជាដៃគូ)**<br>- ភាគរយនៃ ផ.ស.រ.គ ដែលបានអនុវត្ត និងរួមបញ្ចូលកម្មភាពសហគមន៍ | របាយការណ៍អនុវត្តផ.ស.រ.គ របស់អង្គការដៃគូសង្គមស៊ីវិល<br><br>ការប្រៀបធៀបប័ណ្ណដាក់ពិន្ទុជាមួយក្រុមដែលមិនទាន់បានអនុវត្តសកម្មភាព<br><br>ការសិក្សាពីការផ្តល់សិទ្ធិអំណាច<br><br>របាយការណ៍អនុវត្ត ផ.ស.រ.គ របស់អង្គការសង្គមស៊ីវិល<br><br>របាយការណ៍អនុវត្តផ.ស.រ.គ របស់អង្គការសង្គមស៊ីវិល |
| សមាសភាគទី៣ ៖ ការសម្របសម្រួល និងការពង្រឹងសមត្ថភាព | | | |
| **ការប្រែប្រួលលើសិទ្ធិអំណាច និងសមត្ថភាពរបស់ប្រជាពលរដ្ឋ** | ការចូលរួមរបស់សហគមន៍ (ពិសេសស្ត្រី និងយុវវ័យ កុមារ ជនពិការ ជនជាតិដើម) ត្រូវបានផ្លាស់ប្តូរពីភាពអសកម្មទៅជាការចូលរួមយ៉ាងសកម្ម | - ភាគរយនៃការប្រែប្រួលតាមរយៈឯកសារនៃកិច្ចប្រជុំ និងអ្នកចូលរួម<br>- ភាគរយកិច្ចប្រជុំរបស់សហគមន៍ដែលពិភាក្សាពីគម្លាតរវាងបទដ្ឋានស្តង់ដារជាមួយការបំពេញការងារជាក់ស្តែង | របាយការណ៍អនុវត្ត ផ.ស.រ.គ របស់អង្គការសង្គមស៊ីវិល។ |

| តើការផ្លាស់ប្តូរអ្វីខ្លះ នឹងទទួលបានពីផ.អ.គ.ស | តើលទ្ធផលអ្វីខ្លះនឹងទទួលបានក្នុងរយៈពេល៣ឆ្នាំ? | តើអ្វីជាខ្នាតវាស់វែង? | តើការវាស់វែងត្រូវធ្វើដូចម្តេច? |
|---|---|---|---|
| | ប្រជាពលរដ្ឋកាន់តែមានការយល់ដឹងអំពីសិទ្ធិទទួលបានសេវា និងការបំពេញនូវការផ្តល់សេវា | - ភាគរយឃុំ ដែលបានធ្វើការវិភាគអំពីកង្វះខាតនានា ដើម្បីបញ្ចូលជាសកម្មភាព ទៅក្នុងផ.ស.រ.គ។ | ការអង្កេតសិក្សាអំពីសិទ្ធិអំណាច និងសមត្ថភាព |
| **ការប្រែប្រួលផ្នែកសមត្ថភាពរបស់អ្នកពាក់ព័ន្ធនានានៅមូលដ្ឋាន** | អ្នកសម្របសម្រួលសហគមន៍កាន់តែមានឆន្ទៈ និងសមត្ថភាពលើដំណើរការសម្របសម្រួលនិងបញ្ជ្រាប ការងារគណនេយ្យភាពបានដល់គ្រប់កន្លែង។<br><br>អង្គការដៃគូអនុវត្តនៅមូលដ្ឋានកាន់តែមានលទ្ធភាពហ៊ឹកហ៊ឺននិងគាំទ្រដល់សកម្មភាពសហគមន៍។<br><br>អង្គភាពនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែបានយល់ច្បាស់នូវគណនេយ្យភាពរបស់ខ្លួនហើយមានលទ្ធភាពក្នុងការធ្វើសកម្មភាព។ | - ភាគរយនៃប័ណ្ណដាក់ពិន្ទុ ដែលបានប្រែក្លាយជាផែនការសកម្មភាពជាក់ស្តែង។<br><br>- ចំនួនប័ណ្ណដាក់ពិន្ទុ និងដំណើរការនៃផ.ស.រ.គបានពង្រីក ។<br><br>- ការវាយតម្លៃចំណេះដឹង និងលទ្ធភាពប្រើប្រាស់យន្តការគណនេយ្យភាពសង្គម | ការអង្កេតសិក្សាអំពីសិទ្ធិអំណាច និងសមត្ថភាព |
| **សមាសភាគទី ៤៖ ការប្រមូលមេរៀនបទពិសោធន៍ និងការត្រួតពិនិត្យតាមដាន** | | | |
| **ការផ្លាស់ប្តូរទម្លាប់នានាចំពោះការសិក្សាស្វែងយល់ និងការដកស្រង់បទពិសោធន៍**<br>(សមត្ថភាព) | សមត្ថភាព និងឆន្ទៈ ចូលរួមក្នុងការរៀនសូត្រ ដកស្រង់បទពិសោធន៍<br><br>គុណភាពនៃការទុកដាក់ឯកសារ និងការពិគ្រោះយោបល់ស្តីពីដំណើរការផ្លាស់ប្តូរត្រូវបានធ្វើឱ្យប្រសើរឡើង។ | - ការវាយតម្លៃមេរៀននានាពីដំណើរការអនុវត្តដែលត្រូវបានចងក្រងជាឯកសារ និងអាចរកបាន។<br><br>- ការវាយតម្លៃចំណងទាក់ទងនានាត្រូវបានធ្វើឡើង មេរៀន នានាត្រូវបានចងក្រង និងអនុវត្តតាម។<br><br>- ការវាយតម្លៃការបណ្តុះបណ្តាល និងកម្មវិធីពង្រឹងសមត្ថភាពនានាដែលប្រើប្រាស់មេរៀនទាំងនោះ។ | របាយការណ៍ប្រចាំ ត្រីមាសរបស់អង្គការ សង្គមស៊ីវិល។<br><br>របាយការណ៍ប្រចាំត្រីមាស ឬប្រចាំឆ្នាំ ស្តីពីដំណើរ ការនៃការរៀនសូត្រពីបទពិសោធន៍។<br><br>មានការសិក្សាអំពីសិទ្ធិអំណាច និងសមត្ថភាព |
| **ការផ្លាស់ប្តូរលើរបៀប នៃ** | មេរៀន និងយោបល់ | ចំនួនមេរៀនដែលជំរុញឱ្យមាន | របាយការណ៍ប្រចាំត្រីមាស |

| តើការផ្លាស់ប្តូរអ្វីខ្លះ នឹងទទួលបានពីផ.អ.គ.ស | តើលទ្ធផលអ្វីខ្លះនឹងទទួលបានក្នុងរយៈពេល៣ឆ្នាំ? | តើអ្វីជាខ្នាតវាស់វែង? | តើការវាស់វែងត្រូវធ្វើដូចម្តេច? |
|---|---|---|---|
| **រៀបចំបង្កើតគោលនយោបាយ** | ត្រឡប់នានាជំរុញឱ្យមានការផ្លាស់ប្តូរគោលនយោបាយ និងការអនុវត្ត | ការផ្លាស់ប្តូរនានា នៅក្នុងគោលនយោបាយ និងការអនុវត្ត | ឬប្រចាំឆ្នាំស្តីពីដំណើរ ការនៃការរៀនសូត្រពីបទពិសោធន៍។ |

## ឧបសម្ព័ន្ធទី៣ ÷ ការបែងចែកការទទួលខុសត្រូវទៅតាមលទ្ធផលរំពឹងទុក និងសកម្មភាព

| សមាសភាគ | លទ្ធផលរំពឹងទុក និងសកម្មភាព | អ្នកទទួលខុសត្រូវ* |
|---|---|---|
| សមាសភាគទី១ ភាពងាយទទួលបានព័ត៌មាននានា និងព័ត៌មានថវិកា | ២.១ ព័ត៌មានអំពីការបំពេញការងារ | |
| | សកម្មភាព ២.១.១.ការប្រមូលទិន្នន័យ និងពិនិត្យផ្ទៀងផ្ទាត់ ដើម្បីចងក្រងជាកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ | ផ្នែកផ្គត់ផ្គង់ |
| | សកម្មភាព ២.១.២.ការបោះពុម្ព និងផ្សព្វផ្សាយ កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ | ផ្នែកផ្គត់ផ្គង់ |
| | ២.២ ការបើកចំហព័ត៌មានថវិកា | |
| | សកម្មភាព ២.២.១.ប្រមូល ពិនិត្យឡើងវិញ និងចងក្រង ព័ត៌មានអំពីថវិកា | ផ្នែកផ្គត់ផ្គង់ |
| | សកម្មភាព ២.២.២.ការបង្ហាញនិងបិទផ្សាយព័ត៌មានថវិកា ដែលមានលក្ខណៈសាមញ្ញ | ផ្នែកផ្គត់ផ្គង់ |
| | ២.៣ ការរៀបចំប្រព័ន្ធ លិខិតបទដ្ឋាននិងការអនុវត្តតាមគោលការណ៍ណែនាំ | |
| | សកម្មភាព ២.៣.១.ការរៀបចំបង្កើតនិងដាក់ឱ្យអនុវត្ត វិធីសាស្ត្រគ្រប់គ្រងទិន្នន័យនៅថ្នាក់ស្រុក | ផ្នែកផ្គត់ផ្គង់ |
| | សកម្មភាព ២.៣.២. ការរៀបចំបង្កើតនិងដាក់ឱ្យអនុវត្ត លិខិតបទដ្ឋាន និងសេចក្ដីណែនាំនានាសម្រាប់ការបើកចំហព័ត៌មានថវិកា និងព័ត៌មាននានានៅមូលដ្ឋាន | ផ្នែកផ្គត់ផ្គង់ |
| | សកម្មភាព ២.៣.៣. ការបង្កើត និងដាក់ឱ្យអនុវត្ត នូវប្រព័ន្ធត្រួតពិនិត្យ និងការអនុវត្តតាមគោលការណ៍ណែនាំ សម្រាប់ការបើកចំហព័ត៌មានថវិកានៅមូលដ្ឋាន | ផ្នែកផ្គត់ផ្គង់ |
| | សកម្មភាព ២.៣.៤. រៀបចំបង្កើត និងដាក់ឱ្យអនុវត្ត នូវដំណើរការត្រួតពិនិត្យរបស់អង្គការសង្គមស៊ីវិលចំពោះការបើកចំហព័ត៌មានថវិកានៅមូលដ្ឋាន | ផ្នែកតម្រូវការ |
| | ២.៤ ការលើកកម្ពស់ការយល់ដឹង និងការពង្រឹងសមត្ថភាព | |
| | សកម្មភាព ២.៤.១.ការបណ្ដុះបណ្ដាលសមត្ថភាពអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ អំពីគណនេយ្យភាពសង្គម ព័ត៌មាននានា និងព័ត៌មានថវិកា | ផ្នែកតម្រូវការ |
| | សកម្មភាព ២.៤.២.ការបណ្ដុះបណ្ដាល សមាជិកក្រុមប្រឹក្សា មន្ត្រីមូលដ្ឋាន និងអ្នកផ្ដល់សេវានៅមូលដ្ឋានអំពីព័ត៌មាននានា និងព័ត៌មានថវិកា | ផ្នែកផ្គត់ផ្គង់ |
| | សកម្មភាព ២.៤.៣.ការលើកកម្ពស់ការយល់ដឹងរបស់អង្គការសហគមន៍មូលដ្ឋាន សហគមន៍នានា និងប្រជាពលរដ្ឋទាក់ទងនឹងព័ត៌មាននានានិងព័ត៌មានថវិកា | ផ្នែកតម្រូវការ |
| | | |
| | | |

| សមាសភាគ | លទ្ធផលរំពឹងទុក និងសកម្មភាព | អ្នកទទួលខុសត្រូវ* |
|---|---|---|
| សមាសភាគទី២ ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ | **៣.១ ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ** | |
| | **សកម្មភាព ៣.១.១.** ការ អនុវត្តការដាក់ពិន្ទុលើសេវាតាមវិស័យនានាដោយអង្គភាពផ្តល់សេវា | ផ្នែកតម្រូវការ |
| | **សកម្មភាព ៣.១.២.** ការអនុវត្តការដាក់ពិន្ទុចំពោះសេវាតាមវិស័យនានាដោយសហគមន៍ប្រចាំឆ្នាំនៅក្នុងស្រុកគោលដៅនីមួយៗ | ផ្នែកតម្រូវការ |
| | **សកម្មភាព ៣.១.៣.**ការត្រួតពិនិត្យតាមដានស៊ីជម្រៅដោយប្រជាពលរដ្ឋទៅលើសេវាមូលដ្ឋាន និងបញ្ហាជាក់លាក់មួយចំនួន | ផ្នែកតម្រូវការ |
| | **៣.២ កិច្ចប្រជុំរួមគ្នា និងផែនការសកម្មភាពរួមគ្នា** | |
| | **សកម្មភាព ៣.២.១.**ដំណើរការកិច្ចប្រជុំរួម និងការរៀបចំផ.ស.រ.គ | រួម** |
| | **សកម្មភាព ៣.២.២.**ការផ្សព្វផ្សាយ និងអនុវត្តផែនការសកម្មភាពផ.ស.រ.គ | រួម** |
| | **សកម្មភាព ៣.២.៣.**ការបង្កើតគណៈកម្មាធិការ ផ.ស.រ.គ | រួម** |
| | **៣.៣ ការរៀបចំលិខិតបទដ្ឋាននានាដើម្បីគាំទ្រការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ និងការពិនិត្យមើលពីលើរបស់សមាជិកក្រុមប្រឹក្សា** | |
| | **សកម្មភាព ៣.៣.១.**រៀបចំ អនុម័ត និងដាក់ឱ្យអនុវត្ត នូវប្រកាស និងសេចក្តីណែនាំស្តីពីតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ពាក់ព័ន្ធនិងការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ | ផ្នែកផ្គត់ផ្គង់ |
| | **សកម្មភាព ៣.៣.២.**ពិនិត្យកែសម្រួលលិខិតបទដ្ឋានគតិយុត្តិសម្រាប់ការត្រួតពិនិត្យរបស់ឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌ ទៅលើការផ្តល់សេវាមូលដ្ឋាននានា | ផ្នែកផ្គត់ផ្គង់ |
| | **៣.៤ ការលើកកម្ពស់ការយល់ដឹង និងការពង្រឹងសមត្ថភាព** | |
| | **សកម្មភាព ៣.៤.១.**អនុវត្តកម្មវិធីបណ្តុះបណ្តាល ការផ្តល់យោបល់ណែនាំ និងការរៀនសូត្រតាមរយៈការអនុវត្តផ្ទាល់ជាមួយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍។ | ផ្នែកតម្រូវការ |
| | **សកម្មភាព ៣.៤.២.**ការលើកកម្ពស់ការយល់ដឹងអំពីការងារត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ និងការរៀបចំផ.ស.រ.គ ដោយអង្គការសហគមន៍មូលដ្ឋានសហគមន៍ និងប្រជាពលរដ្ឋ | ផ្នែកតម្រូវការ |
| | **សកម្មភាព ៣.៤.៣.**ការបណ្តុះបណ្តាល អំពីការរៀបចំផ.ស.រ.គ ការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ និងមុខងារត្រួតពិនិត្យមើលពីលើ សម្រាប់មន្ត្រីមូលដ្ឋាន និងអ្នកផ្តល់សេវា | ផ្នែកផ្គត់ផ្គង់ |
| **សមាសភាគ** | **លទ្ធផលរំពឹងទុក និងសកម្មភាព** | **ដឹកនាំដោយ*** |
| សមាសភាគទី៣ ការសម្រប | **៤.១ ការសម្របសម្រួល** | |
| | **សកម្មភាព ៤.១.១.**ការជ្រើសរើស និងការចុះកិច្ចសន្យាជាមួយអង្គការជាដៃគូនៅមូលដ្ឋាន ដែលគាំទ្រអ្នកសម្របសម្រួលគណនេយ្យភាពនៅមូលដ្ឋាន | ផ្នែកតម្រូវការ |

| | | |
|---|---|---|
| សម្រួល និងការពង្រឹងសមត្ថភាព | សកម្មភាព ៤.១.២.ការជ្រើសរើសអង្គការសហគមន៍មូលដ្ឋានជាយុទ្ធសាស្ត្រ (ផ្តោតលើ ក្រុម ស្ត្រី យុវវ័យ កុមារ និងជនពិការ) | ផ្អែកតម្រូវការ |
| | សកម្មភាព ៤.១.៣.ការជ្រើសរើស ការចងក្រងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ជាក្រុម (ផ្តោតលើស្ត្រី យុវវ័យ កុមារ ជនពិការ) | ផ្អែកតម្រូវការ |
| | សកម្មភាព ៤.១.៤.ការបង្កើតសហគមន៍អនុវត្ត ដើម្បីផ្តល់ការគាំទ្រជាប្រចាំដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ | ផ្អែកតម្រូវការ |
| | **៤.២ ការបណ្តុះបណ្តាល ការហ្វឹកហ្វឺន និងកសាងសមត្ថភាព** | |
| | សកម្មភាព ៤.២.១.ការជ្រើសរើសដៃគូជំនាញបណ្តុះបណ្តាលស្តីពីគណនេយ្យភាពសង្គម | រួម |
| | សកម្មភាព ៤.២.២.ការរៀបចំកម្មវិធី សម្ភារៈនិងវិធីសាស្ត្របណ្តុះបណ្តាលសម្រាប់ផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់ | រួម |
| | សកម្មភាព ៤.២.៣.ការពង្រឹងសមត្ថភាព ដល់អង្គការដៃគូនៅថ្នាក់ជាតិ និងមូលដ្ឋាន ដើម្បីឱ្យក្លាយជាគ្រូបង្គោល | រួម |
| | សកម្មភាព ៤.២.៤.ការបណ្តុះបណ្តាលមន្ត្រីថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក ឱ្យក្លាយជាគ្រូបង្គោល | រួម |
| សមាសភាគទី៥ ការប្រមូលមេរៀន បទពិសោធន៍ និងការត្រួតពិនិត្យតាមដាន | **៥.១ការប្រមូលមេរៀនបទពិសោធន៍ និងការផ្តល់យោបល់ត្រលប់** | |
| | សកម្មភាព ៥.១.១. ការរៀបចំបង្កើតយុទ្ធសាស្ត្រ និងផែនការសកម្មភាព ពាក់ព័ន្ធការប្រមូលមេរៀនបទពិសោធន៍ដែលមានលក្ខណៈច្នៃប្រឌិត | ភាគីទី៣**** |
| | សកម្មភាព ៥.១.២. ការរៀបចំនិងផ្សព្វផ្សាយ ឧបករណ៍និងឯកសារណែនាំនានា | ភាគីទី៣ |
| | សកម្មភាព ៥.១.៣.ការរៀបចំវេទិកាសិក្សារៀនសូត្រ និងផ្តល់ព័ត៌មានត្រឡប់ ឱ្យបានទៀងទាត់ | ភាគីទី៣ |
| | សកម្មភាព ៥.១.៤.ការបង្កើតឱ្យមាន ការផ្តល់ព័ត៌មានត្រឡប់ និងដំណើរការពិនិត្យកែសម្រួលគោលនយោបាយ ដើម្បីលើកកម្ពស់ការអនុវត្ត ផ.អ.គ.ស | ភាគីទី៣ |
| | សកម្មភាព ៥.១.៥.ដៃគូជំនាញផ្នែកសិក្សាចងក្រងបទពិសោធន៍ រៀបចំការសិក្សានានា ដើម្បីគាំទ្រដល់ការអភិវឌ្ឍគោលនយោបាយ និងការអនុវត្តផ.អ.គ.ស | ភាគីទី៣ |
| | **៥.២ ការត្រួតពិនិត្យតាមដាន និងលទ្ធផលសម្រេចបាន** | |
| | សកម្មភាព ៥.២.១. រៀបចំការត្រួតពិនិត្យតាមដានលើលទ្ធផល ស្របតាមក្របខ័ណ្ឌការងារដែលបានព្រមព្រៀង | ភាគីទី៣ |
| | សកម្មភាព ៥.២.២.ធ្វើការវាយតម្លៃទៅលើផលប៉ះពាល់ | ភាគីទី៣ |
| | សកម្មភាព ៥.២.៣.ការអនុវត្តដំណើរការចងក្រងជាឯកសារ និងសវនកម្ម | ភាគីទី៣ |

<u>សំគាល់៖</u>

*លទ្ធផល និងសកម្មភាពដែលតម្រូវឱ្យមានការចូលរួម និងទំនាក់ទំនងជាប្រចាំទាំងរាជរដ្ឋាភិបាល និងសង្គមស៊ីវិល ហើយ នេះគ្រាន់តែបង្ហាញថាអ្នកណាជាអ្នកដឹកនាំ។

** ទោះបីផែនសកម្មភាពផ.ស.រ.គ ជាការទទួលខុសត្រូវរួមរវាងរាជរដ្ឋាភិបាល និងសង្គមស៊ីវិលការអនុវត្តផ.ស.រ.គ គឺអាស្រ័យលើមេឃុំ និងក្រុមប្រឹក្សាឃុំ សម្រាប់អនុវត្តសកម្មភាពក្នុងឃុំ។

*** ការបណ្តុះបណ្តាលមន្ត្រីរាជរដ្ឋាភិបាលនឹងត្រូវអនុវត្តដោយរាជរដ្ឋាភិបាល ក៏ដូចជាការធ្វើរួមគ្នាជាមួយដៃគូសង្គមស៊ីវិល។

**** ទោះបី ក្រុមសិក្សានេះ រាជរដ្ឋាភិបាលជាអ្នកទាក់ទងក៏ដោយ ផ្នែកនេះគួរអនុវត្តដោយឯករាជ្យ។

## ឧបសម្ព័ន្ធទី៤ ÷ ពាក្យសំខាន់ៗ និងនិយមន័យ

(វាក្យស័ព្ទទាំងអស់គឺសម្រាប់ប្រើប្រាស់ក្នុងបរិបទនៃក្របខ័ណ្ឌគណនេយ្យភាពសង្គម)

| | |
|---|---|
| **គណនេយ្យភាព** | កាតព្វកិច្ចរបស់អ្នកដែលទទួលបាននូវការទទួលខុសត្រូវ និងសិទ្ធិអំណាចដើម្បីឆ្លើយបំភ្លឺ និងទទួលខុសត្រូវចំពោះទង្វើនានារបស់ខ្លួន រួមទាំងផលវិបាកដែលកើតឡើងពីទង្វើទាំងនោះ ។ *(ដកស្រង់ពីសៀវភៅកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩ ទំព័រ១៦២)* |
| **លទ្ធផលរំពឹងទុក** | ផលិតផល ឧបករណ៍ សម្ភារ និងសេវាទាំងឡាយដែលទទួលបានពីអន្តរាគមន៍អភិវឌ្ឍន៍មួយ ហើយវាក៏អាចរួមបញ្ចូលទាំងការផ្លាស់ប្តូរនានាផ្តើមចេញពីអន្តរាគមន៍ដែលពាក់ព័ន្ធនឹងការសម្រេចនូវសមិទ្ធផលរំពឹងទុកនានា។ ស្ថាប័ននានាត្រូវមានគណនេយ្យភាពក្នុងការសម្រេចលទ្ធផលរំពឹងទុកឱ្យបានទាន់ពេលវេលា មានគុណភាព និងបរិមាណសមស្រប។ |
| **តម្លាភាព** | ការផ្តល់នូវព័ត៌មានទាន់ពេលវេលា និងអាចជឿទុកចិត្តបានហើយព័ត៌មាននេះអាចទទួល បានការប្រើប្រាស់ដោយអ្នកពាក់ព័ន្ធទាំងអស់។ |
| **សកម្មភាព** | ទង្វើដែលប្រកាន់យក ឬកិច្ចការដែលបានបំពេញដោយប្រើប្រាស់នូវធាតុចូលនានាដូចជា មូលនិធិ ជំនួយបច្ចេកទេស និងធនធានផ្សេងទៀតដែលបានកៀរគរ ដើម្បីបង្កើតចេញជាលទ្ធផលរំពឹងទុកជាក់លាក់នានា។ |
| **ការអភិវឌ្ឍសមត្ថភាព** | ជាដំណើរការមួយដែលនាំមកនូវការលើកកម្ពស់ជំនាញ (ទាំងជំនាញទូទៅ និងជំនាញជាក់លាក់) ដែលធ្វើឱ្យប្រសើរឡើងនូវនីតិវិធី និងការពង្រឹងស្ថាប័ន។ ការកសាងសមត្ថភាពសំដៅលើការវិនិយោគលើមនុស្ស ស្ថាប័ន និងបែបផែននៃការអនុវត្តនានា។ |
| **ការចូលរួមរបស់អង្គការសង្គមស៊ីវិល** | ជាដំណើរការនៅក្នុងសហគមន៍ដែលប្រជាពលរដ្ឋប្រមូលផ្តុំគ្នាបង្កើតឡើងដើម្បីសម្រេចគោលដៅរួមនានារបស់ខ្លួននៅមូលដ្ឋាន និងធ្វើការងារជាបុគ្គល ឬរួមគ្នាតាមរយៈអង្គការសហគមន៍មិនមែនរដ្ឋាភិបាលដើម្បីមានឥទ្ធិពលទៅលើដំណើរការធ្វើសេចក្តីសម្រេចចិត្ត។ |
| **អង្គការសង្គមស៊ីវិល** | ជាអង្គការមិនមែនរដ្ឋាភិបាល និងមិនរកប្រាក់ចំណេញដែលមានវត្តមានក្នុងសង្គមដែលតំណាងឱ្យផលប្រយោជន៍ និងគុណតម្លៃរបស់សមាជិកខ្លួន ឬអ្នកដទៃ ដោយផ្អែកលើការយកចិត្តទុកដាក់នានាដែលមានលក្ខណៈជាក្រមសីលធម៌ វប្បធម៌ នយោបាយ វិទ្យាសាស្ត្រ សាសនា ឬសប្បុរសធម៌។ |
| **បរិយាប័ន្ន** | ជាការលើកកម្ពស់ស្ថានភាពរបស់បុគ្គល និងក្រុមនានាក្នុងការចូលរួម និងទទួលផលពីសកម្មភាពនានារបស់សង្គមដោយមិនរើសអើង។ គោលបំណងនៃបរិយាប័ន្ន គឺការផ្តល់នូវសិទ្ធិដល់ក្រុមផ្សេងៗគ្នា ជាពិសេសប្រជាពលរដ្ឋក្រីក្រ ក្រុមជនងាយរងគ្រោះឲ្យទទួលបាននូវឱកាសសមស្រប |

| | |
|---|---|
| | ព្រមទាំងធានាមតិយោបល់ និងការយល់ឃើញនានារបស់ក្រុមទាំងនោះត្រូវបានយកមកពិចារណា សម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត ដែលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគេ ក៏ដូចជាដើម្បីធានាឲ្យពួកគេទទួលបាន និងប្រើប្រាស់ដោយស្មើភាពនូវផលប្រយោជន៍ពីការផ្តល់សេវា ការអភិវឌ្ឍមូលដ្ឋាន និងលក្ខខណ្ឌនានាផ្នែកសង្គម នយោបាយ និងរូបវន្ត។ |
| **សូចនាករ** | កត្តា ឬអញ្ញតជាបរិមាណ ឬជាគុណភាពដែលផ្តល់ជាមួយ មានលក្ខណៈសាមញ្ញ និងអាចជឿទុកចិត្តបានសម្រាប់វាស់វែងសមិទ្ធផល ឬឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនានាដែលកើតចេញពីអន្តរាគមន៍ណាមួយ ឬក៏ជួយក្នុងការវាយតម្លៃពីការបំពេញការងាររបស់តួអង្គអភិវឌ្ឍន៍ណាមួយ។ |
| **ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ** | គឺជាព័ត៌មានដែលរៀបចំឡើងសម្រាប់លើកកម្ពស់គណនេយ្យភាព។ ព័ត៌មានសម្រាប់ប្រជាពលរដ្ឋនឹងមានជាសម្ភារៈសម្រាប់បង្ហាញសាធារណជន (កញ្ចប់ព័ត៌មាន) និងខិតប័ណ្ណផ្សព្វផ្សាយ ដែលផ្តល់ឲ្យប្រជាពលរដ្ឋនូវព័ត៌មានសំខាន់ៗអំពីសេវាសាធារណៈនៅមូលដ្ឋាន។ កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋមានព័ត៌មានអំពីមណ្ឌលសុខភាព សាលាបឋមសិក្សា និងសេវារបស់សាលាឃុំ ព្រមទាំងព័ត៌មានអំពីសិទ្ធិរបស់អ្នកប្រើប្រាស់ អំពីស្តង់ដារសេវា ការបំពេញការងាររបស់បុគ្គលិក ព័ត៌មានអំពីថវិកា និងការចំណាយ។ កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ ត្រូវបានរៀបចំតាក់តែងឡើងដើម្បីជួយដល់អ្នកប្រើប្រាស់ និងងាយទទួលបានព័ត៌មានទោះបីប្រជាពលរដ្ឋដែលចេះអក្សរតិចតួចក៏ដោយ។ |
| **កិច្ចប្រជុំរួម** | បង្កើតឡើងដើម្បីជាការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ។ កិច្ចប្រជុំរួម ត្រូវបានសម្របសម្រួលឲ្យមានឡើងតាមកន្លែងដែលអ្នកប្រើប្រាស់សេវា និងប្រជាពលរដ្ឋបានជួបគ្នាជាមួយអ្នកផ្តល់សេវា (ដូចជាមន្ត្រីថ្នាក់ស្រុក និងរដ្ឋបាលឃុំ មណ្ឌលសុខភាព និងសាលាបឋមសិក្សា) ដើម្បីចែករំលែកនូវមតិយោបល់ផ្សេងៗអំពីគុណភាពសេវា និងដើម្បីរៀបចំនូវផែនការសកម្មភាពរួមសម្រាប់កែលម្អផ្សេងៗ។ |
| **ប័ណ្ណដាក់ពិន្ទុដោយសហគមន៍** | គឺជាឧបករណ៍សម្រាប់ត្រួតពិនិត្យតាមដានគណនេយ្យភាពសង្គម ដែលអាចឱ្យប្រជាពលរដ្ឋ និងអ្នកប្រើប្រាស់សេវា វាយតម្លៃគុណភាពសេវានៅមូលដ្ឋាន និងដើម្បីពង្រឹងសហប្រតិបត្តិការជាមួយមន្ត្រី និងអ្នកផ្តល់សេវាក្នុងការរៀបចំ និងអនុវត្តសកម្មភាពនានាសម្រាប់ ធ្វើឱ្យមានការផ្លាស់ប្តូរ។ |
| **ផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម** | គឺជាផែនការសកម្មភាពចម្បងនៃដំណើរការត្រួតពិនិត្យតាមដាន តាមរយៈប័ណ្ណដាក់ពិន្ទុដោយសហគមន៍។ ផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គមនេះ គឺជាបញ្ជីសកម្មភាពដែលប្រជាពលរដ្ឋ អ្នកផ្តល់សេវា និងមន្ត្រីឃុំ ស្រុក បានឯកភាពជាមួយគ្នាដើម្បីអនុវត្តក្នុងការកែលម្អគុណភាពសេវា និងការបំពេញការងាររបស់សាលាឃុំ សាលាបឋមសិក្សា និងមណ្ឌលសុខភាព។ ផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គមនេះ ត្រូវបានពិភាក្សា និងព្រមព្រៀងគ្នានៅរាល់គ្រប់កិច្ចប្រជុំរួម។ |

| | |
|---|---|
| ផ្នែកផ្គត់ផ្គង់ | សំដៅលើតួនាទីរបស់តួអង្គជាស្ថាប័នរដ្ឋ នៅក្នុងដំណើរការអនុវត្តគណនេយ្យភាពសង្គម។ រាជរដ្ឋាភិបាលមានតួនាទីក្នុងការគាំទ្រគណនេយ្យភាពសង្គមតាមរយៈការបង្កើតនូវដំណើរការគោលការណ៍ ស្តង់ដារ និងលិខិតបទដ្ឋាននានា។ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពផ្តល់សេវា ត្រូវទទួលខុសត្រូវក្នុងការ ចែករំលែកព័ត៌មាន និងការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ និងតំណាងរបស់ពួកគាត់នៅថ្នាក់មូលដ្ឋាន។ |
| ផ្នែកតម្រូវការ | សំដៅលើតួនាទីរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិលក្នុងដំណើរការគណនេយ្យភាពសង្គម។ តួអង្គទាំងអស់នេះ មានការទទួលខុសត្រូវដើម្បីធ្វើឱ្យមានការយល់ដឹងអំពីសិទ្ធិ និងភារកិច្ចរបស់ខ្លួន ដើម្បីស្វែងយល់ពីគោលនយោបាយ និងសេវានានារបស់រាជរដ្ឋាភិបាល ព្រមទាំងដើម្បីធ្វើការប្រាស្រ័យទាក់ទង និងការចូលរួមប្រកបដោយភាពស្ថាបនាជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័នផ្តល់សេវានានាដើម្បីលើកម្ពស់ការបំពេញមុខងាររបស់ស្ថាប័នទាំងនេះ។ |
| ស្តង់ដារសេវា | សំដៅលើកម្រិត និងគុណភាពសេវាដែលរាជរដ្ឋាភិបាលបានកំណត់តាមរយៈគោលនយោបាយ និងលិខិតបទដ្ឋាននានា ហើយប្រជាពលរដ្ឋអាចរំពឹងទទួលបានពេលស្នើសុំ ឬត្រូវការ។ |
| តួអង្គរដ្ឋ | សំដៅលើស្ថាប័ន អង្គភាព មន្ទីរ ការិយាល័យជំនាញ មន្ត្រីរបស់រាជរដ្ឋាភិបាល ដូចជាមន្ទីរជំនាញថ្នាក់ខេត្ត និងថ្នាក់ស្រុក មន្ត្រីផ្តល់សេវានៅមូលដ្ឋាន សាលាបឋមសិក្សា មណ្ឌលសុខភាព ក្រុមប្រឹក្សាឃុំ ជាដើម។ |
| តួអង្គមិនមែនរដ្ឋ | សំដៅលើប្រជាពលរដ្ឋ អង្គការសហគមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិលដែល អង្គការមិនមែនរដ្ឋាភិបាលនានា។ ក្រៅពីនេះ តួអង្គមិនមែនរដ្ឋ ក៏សំដៅលើស្ថាប័នសារព័ត៌មាន និងស្ថាប័នបណ្តុះបណ្តាលផ្សេងៗ។ |
| វដ្តនៃគណនេយ្យភាពសង្គម | សំដៅលើដំណើរការអនុវត្តសកម្មភាពនានាពាក់ព័ន្ធក្របខណ្ឌការងារគណនេយ្យភាព សង្គមប្រចាំឆ្នាំ។ វដ្តនៃការអនុវត្តរួមមាន៖ ១).ការចងក្រង និងកែសម្រួលកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ ២).រៀបចំសកម្មភាពបង្កើនការយល់ដឹងរបស់សាធារណជនអំពីថវិកា ៣).ការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋលើការផ្តល់សេវាសាធារណៈនៅមូលដ្ឋាន ៤).ការផ្សព្វផ្សាយ និងអនុវត្តផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម ៥).តាមដានត្រួតពិនិត្យការរីកចម្រើន និងការចងក្រងជាឯកសារ អំពីមេរៀនបទពិសោធន៍នានា។ |
| អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ | ជាអ្នកស្ម័គ្រចិត្តនៅតាមសហគមន៍ដែលត្រូវបានជ្រើសរើស និងបណ្តុះបណ្តាលដោយអង្គការមិនមែនរដ្ឋាភិបាលដើម្បីជួយសហគមន៍ឱ្យបានចូលរួមអនុវត្តសកម្មភាពគណនេយ្យភាពសង្គមនៅថ្នាក់មូលដ្ឋាន ព្រមទាំងប្រមូលផ្តុំ និងលើកកម្ពស់ឱ្យមានការចូលរួមរបស់សហគមន៍នៅក្នុងដំណើរការគណនេយ្យភាពសង្គម។ |

| | |
|---|---|
| **អង្គភាពផ្តល់សេវា** | ជាតួអង្គនានា ដែលទទួលខុសត្រូវផ្ទាល់សម្រាប់ការផ្តល់សេវាសាធារណៈ។ អង្គភាពផ្តល់សេវា រួមមាន រដ្ឋបាលឃុំ សាលាបឋមសិក្សា មណ្ឌលសុខភាព។ល។ |
| **អ្នកប្រើប្រាស់សេវា** | សំដៅលើរូបវន្តបុគ្គល និងឬនីតិបុគ្គលប្រជាពលរដ្ឋដែលប្រើប្រាស់សេវាសាធារណៈនៅមូលដ្ឋាន ដូចជាសេវានានា ដែលផ្តល់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ សាលារៀនបឋមសិក្សា និងមណ្ឌលសុខភាព ។ល។ |
| **អង្គការដៃគូអនុវត្តនៅថ្នាក់ជាតិ** | សំដៅលើអង្គការមិនមែនរដ្ឋាភិបាល (ជាតិ ឬអន្តរជាតិ) ដែលបានចុះអនុសារណៈយោគយល់គ្នាជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងការអនុវត្ត ផ.អ.គ.ស |
| **អង្គការដៃគូអនុវត្តនៅថ្នាក់ក្រោមជាតិ** | សំដៅលើអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះអនុសារណៈយោគយល់គ្នា ឬកិច្ចព្រមព្រៀងជាមួយអង្គការដៃគូអនុវត្តនៅថ្នាក់ជាតិ ដើម្បីអនុវត្ត ផ.អ.គ.ស នៅថ្នាក់ក្រោមជាតិ |
| **សំណុំសកម្មភាពអប្បរមា** | គឺសំដៅលើកញ្ចប់សេវាសុខភាព និងសកម្មភាពសំខាន់ៗមួយចំនួនដែលត្រូវផ្តល់ដោយមណ្ឌលសុខភាព រាប់បញ្ចូលទាំងសេវាដែលផ្តល់អោយនៅនឹងកន្លែងមណ្ឌលសុខភាព និងសេវាចំបងៗដែលត្រូវផ្តល់អោយនៅថ្នាក់សហគមន៍។ |
| **មូលធនសង្គម** | គឺសំដៅលើទំនាក់ទំនងល្អរបស់មនុស្សនៅក្នុងសង្គមដែលមានគុណតម្លៃ ទំនៀមទំលាប់ និងជឿជាក់គ្នាទៅវិញទៅមក។ ការជឿជាក់គ្នាទៅវិញទៅមករវាងប្រជាពលរដ្ឋ ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាកត្តាជំរុញឲ្យមានការផ្សារភ្ជាប់គ្នាក្នុងសង្គម ការអភិវឌ្ឍ និងកំណើនសេដ្ឋកិច្ចមូលដ្ឋាន។ |

## ឧបសម្ព័ន្ធទី ៥÷ បញ្ជីអក្សរកាត់

| | |
|---|---|
| ផ.ស.គ.ស | ផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| **ផអ៣ទី២** | ផែនការអនុវត្តបីឆ្នាំដំណាក់កាលទីពីរ(២០១៥-២០១៧)នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ |
| ផ.ស.រ.គ (JAAP) | ផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម (Joint Accountability Action Plan) |
| គ.ជ.អ.ប | គណកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| DPT | ថ្នាំបង្ការបីមុខការពារជំងឺខាន់ស្លាក់ ក្អក និងតេតាណូស |
| NGO | អង្គការមិនមែនរដ្ឋាភិបាល (Non-Government Organization) |
| CSO | អង្គការសង្គមស៊ីវិល ( Civil Society Organizaton) |
| I4Cs | កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (Informatin for Citizens) |
| CAF | អ្នកសម្របសម្រួលគណនេយ្យភាពសង្គមសហគមន៍ (Community Accountability Facilitator) |
| ផ.អ.គ.ស<br>I-SAF | ផែនការអនុវត្តគណនេយ្យភាពសង្គម<br>(Implementation of Social Accountabiltiy Framework) |
| PID | ទិន្នន័យព័ត៌មានគម្រោង (Project Information Database) |
| CDB | ទិន្នន័យមូលដ្ឋានឃុំ (Commune Database ) |
| LGDP | គម្រោងអភិវឌ្ឍន៍ និងអភិបាលកិច្ចមូលដ្ឋាន(Local Governance and Development Project) |
| គ.គ.អ.ស<br>(I-SAF-PSC) | គណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម<br>(I-SAF Partnership Steering Committee) |
| Post-On | ទិន្នន័យលទ្ធផលការងារ |